



# ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់

## កម្ពុជា

២៤ ឧសភា ២០២២

Save the Children | Norad – Norwegian Agency for Development Cooperation | All Children Reading: A Grand Challenge for Development | GPE Transforming Education | Foreign, Commonwealth & Development Office | UNESCO – United Nations Educational, Scientific and Cultural Organization

code | World Vision | USAID – From the American People | The World Bank | ADEA – Association for the Development of Education in Africa | unicef

# សិទ្ធិ និងការអនុញ្ញាត

Supply Chain Analysis: Cambodia (ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់ ៖ កម្ពុជា) ទទួលបានអាជ្ញាប័ណ្ណ Creative CommonsAttribution-NonCommercial-NoDerivatives 4.0 International License (CC BY-NC-ND 4.0) ដូច្នេះរាល់សិទ្ធិ និងការអនុញ្ញាតទាំងពួងត្រូវអនុលោមតាមអាជ្ញាប័ណ្ណខាងលើ។ ដើម្បីជ្រាបបន្ថែមពីច្បាប់ចម្លងរបស់អាជ្ញាប័ណ្ណនេះសូមចូលទៅកាន់គេហទំព័រខាងក្រោម ៖ https://creativecommons.org/licenses/by-nc-nd/4.0/legalcode។

ក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-NonCommercial-NoDerivatives ឯកសារទាំងឡាយអាចចែករម្លែកបានដោយសេរី តាមមធ្យោបាយ ឬទម្រង់ណាមួយក៏ដោយ ឱ្យតែការចែករម្លែកនោះធ្វើឡើងដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

- ការទទួលស្គាល់សិទ្ធិអ្នកនិពន្ធ–ផ្តល់ប្រភពនិងដាក់ឈ្មោះអ្នកនិពន្ធ ផ្តល់ព័ត៌មានដោយផ្ញើតំណភ្ជាប់ទៅកាន់អាជ្ញាប័ណ្ណ និងបញ្ជាក់ប្រាប់ប្រសិនបើមានការផ្លាស់ប្តូរ ឬកែឃ្លាត្រង់កន្លែងណាមួយ។ ទង្វើបែបនេះអាចចាត់ទុកថាមានលក្ខណ:សមស្របហើយ ក៏ប៉ុន្តែពុំវាមានន័យថាអ្នកទទួលបានអាជ្ញាប័ណ្ណទទួលឯកភាព ឬទទួលស្គាល់ការប្រើប្រាស់របស់លោកអ្នកឡើយ។
- មិនមែនប្រើប្រាស់សម្រាប់ធ្វើអាជីវកម្ម–លោកអ្នកមិនគួរគប្បីប្រើប្រាស់ឯកសារនេះក្នុងគោលបំណងធ្វើអាជីវកម្មឡើយ។
- មិនត្រូវកម្លាយ–ប្រសិនបើមានការកាត់ខ្លឹមសារបញ្ចូលគ្នា បំប្លែង ឬកែច្នៃលើឯកសារនេះ នោះលោកអ្នកមិនអាចចែកចាយឯកសារបានមកពីការកែប្រែនេះឡើយ។

*រូបភាពលើក្រប © Jean-Claude Redonnet*

**EDC**

43 Foundry Avenue Waltham, MA 02453

ទូរស័ព្ទលេខ ៖ 617-969-7100

បុស្តុន | ឈីកាហ្គោ |ញូវយ៉ក | វ៉ាស៊ីនតោនឌីស៊ី

មជ្ឈមណ្ឌលអភិវឌ្ឍន៍ការអប់រំ (EDC) ជាអង្គការមិនរកប្រាក់កម្រៃសកលសម្រាប់ជំរុញដំណោះស្រាយប្រកបដោយចីរភាពដើម្បីកែលម្អការអប់រំ លើកកម្ពស់សុខភាព និងពង្រីកឱកាសសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៥៨មក យើងក្លាយខ្លួនជាអ្នកដឹកនាំក្នុងការរចនា ការអនុវត្ត និងការវាយតម្លៃនិងច្នៃប្រឌិតកម្មវិធីសំខាន់ៗនៅក្នុងប្រទេសជាង៨០ជុំវិញពិភពលោក។

# មាតិកា


បញ្ជីអក្សរកាត់ ..... v

សេចក្តីថ្លែងអំណរគុណ ..... vii

ខ្លឹមសារសង្ខេប និងអនុសាសន៍កម្រិតខ្ពស់ ..... 1

អនុសាសន៍កម្រិតខ្ពស់ ..... 4

សេចក្តីសង្ខេបនៃអនុសាសន៍តាមដំណាក់កាលខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ..... 6

អនុសាសន៍របស់ GBA ៖ ការធ្វើផែនការនិងការព្យាករណ៍ ..... 6

អនុសាសន៍របស់ GBA ៖ ការអភិវឌ្ឍចំណងជើង ..... 6

អនុសាសន៍របស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព ..... 7

អនុសាសន៍របស់ GBA ៖ ការបញ្ជាទិញ ..... 8

អនុសាសន៍របស់ GBA ៖ ការគ្រប់គ្រងការចែកចាយ ..... 8

អនុសាសន៍របស់GBA ៖ ការប្រើប្រាស់សកម្ម ..... 9

សេចក្តីផ្តើម ..... 10

វិធីសាស្ត្រ ..... 11

កត្តាប្រឈមនៃសម្ភារៈឧបទ្ទេសបង្រៀន និងរៀន ..... 12

កម្រិតបញ្ហាប្រឈមនៃសម្ភារៈឧបទ្ទេសបង្រៀន និងរៀន ..... 12

កត្តាបញ្ហាប្រឈម ..... 13

ប្រជាជន ភូមិសាស្ត្រ អាកាសធាតុ ..... 13

ប្រព័ន្ធអប់រំ ..... 14

សេដ្ឋកិច្ច ..... 18

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ..... 22

អគ្គិសនី ..... 22

តំណភ្ជាប់បណ្តាញទំនាក់ទំនង ..... 23

ការវិភាគលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ.....24
ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់ ៖ ដំណាក់កាលយុទ្ធសាស្ត្រប្រាំមួយ.....24
ដំណាក់កាលទី១របស់ SCA ៖ ការធ្វើផែនការ និងការព្យាករណ៍.....24
ការប៉ាន់ប្រមាណតម្រូវការ.....25
ការព្យាករណ៍.....27
ការរកឃើញរបស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍/ ចំណុចខ្លាំង.....28
ការរកឃើញរបស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍/ ចំណុចខ្សោយ.....29
អនុសាសន៍របស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍.....29
ដំណាក់កាលទី២របស់ SCA ៖ ការអភិវឌ្ឍចំណងជើង.....30
ការតាក់តែងឧបទ្ទេសអំណានចាំបាច់.....30
ការរកឃើញរបស់ GBA ៖ ការអភិវឌ្ឍចំណងជើង និងចំណុចខ្លាំង.....40
ការរកឃើញរបស់ GBA ៖ ការអភិវឌ្ឍចំណងជើង និងចំណុចខ្វះខាត.....40
អនុសាសន៍របស់ GBA ៖ ការអភិវឌ្ឍចំណងជើង.....41
ដំណាក់កាលទី៣របស់ SCA ៖ ការចងក្រង និងការបោះពុម្ព.....41
ការបោះពុម្ពសៀវភៅសិក្សា.....42
ការបោះពុម្ព.....45
ការរកឃើញរបស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព / ចំណុចខ្លាំង.....47
ការរកឃើញរបស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព / ចំណុចខ្សោយ.....48
អនុសាសន៍របស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព.....48
ដំណាក់កាលទី៤របស់ SCA ៖ លទ្ធកម្ម និងការទិញ.....49
ដំណើរការលទ្ធកម្មរបស់រដ្ឋាភិបាលសម្រាប់ការបោះពុម្ព និងចែកផ្សាយ.....50
ការរកឃើញរបស់ GBA ៖ ការទិញ / ចំណុចខ្លាំង.....52
ការរកឃើញរបស់ GBA ៖ ការទិញ / ចំណុចខ្សោយ.....52
អនុសាសន៍របស់ GBA ៖ ការទិញ.....52

ដំណាក់កាលទី៥របស់ SCA ៖ ការគ្រប់គ្រងការចែកចាយ ....53

ការចែកចាយសៀវភៅនៅកម្ពុជា ....53

តាមដាននិង ត្រួតពិនិត្យ ....56

ការរកឃើញរបស់ GBA ៖ ការគ្រប់គ្រងការចែកចាយ / ចំណុចខ្លាំង ....58

ការរកឃើញរបស់ GBA ៖ ការគ្រប់គ្រងការចែកចាយ / ចំណុចខ្សោយ ....59

អនុសាសន៍របស់ GBA ៖ ការគ្រប់គ្រងការចែកចាយ ....59

ដំណាក់កាលទី៦របស់ SCA ៖ ការប្រើប្រាស់សកម្ម ....60

បណ្ណាល័យរបស់សាលា និងការផ្សព្វផ្សាយសៀវភៅ ....60

ការប្រើប្រាស់សកម្មនៅក្នុងសហគមន៍ ....62

ការរកឃើញរបស់ GBA ៖ ការប្រើប្រាស់សកម្ម / ចំណុចខ្លាំង ....64

ការរកឃើញរបស់ GBA ៖ ការប្រើប្រាស់សកម្ម / ចំណុចខ្សោយ ....64

អនុសាសន៍របស់ GBA ៖ ការប្រើប្រាស់សកម្ម ....65

សន្និដ្ឋាន ....66

ឧបសម្ព័ន្ធ១ ៖ គោលបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរ ....68

ឧបសម្ព័ន្ធ២ ៖ ឧបករណ៍ដែលយកមកប្រើប្រាស់ និងវិធីសាស្ត្រស្រាវជ្រាវ ....70

ឧបសម្ព័ន្ធ៣ ៖ អំណាននៅកម្ពុជា និងគម្រោងនានាពាក់ព័ន្ធនឹងសៀវភៅ ....74

ឧបសម្ព័ន្ធ៤ ៖ បញ្ជីរាយនាមអ្នកសម្ភាសន៍តាមលំដាប់លំដោយ ....89

ឧបសម្ព័ន្ធ៥ ៖ កិច្ចប្រជុំរវាង GBA, រោងពុម្ព និងគ្រឹះស្ថានបោះពុម្ពផ្សាយ ....96

ឧបសម្ព័ន្ធ៦ ៖ រចនាសម្ព័ន្ធរបស់ ក្រសួងអប់រំ យុវជន និងកីឡា ....104

ឧបសម្ព័ន្ធ៧ ៖ សាវតាររបស់គម្រោង ....105

ឧបសម្ព័ន្ធ៨ ៖ ឯកសារពិគ្រោះ ....107

# បញ្ជីអក្សរកាត់

| | |
|---|---|
| ACR | គម្រោងAll Children Reading-Cambodia |
| ADB | ធនាគារអភិវឌ្ឍអាស៊ី |
| AFD | ទីភ្នាក់ងារអភិវឌ្ឍបារាំង |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BETP | គម្រោងសៀវភៅអប់រំមូលដ្ឋាន |
| BFC | សៀវភៅសម្រាប់កម្ពុជា (NGO) |
| BSDP | ផែនការអភិវឌ្ឍន៍វិស័យសៀវភៅ |
| CC | ការផ្តល់អាជ្ញាប័ណ្ណ Creative Commons |
| CCOSC | សមាគមកម្ពុជាសម្រាប់សិស្សានុសិស្សក្រៅសាលារៀន |
| CDMP | ផែនការមេសម្រាប់អភិវឌ្ឍសមត្ថភាព |
| CDPF | មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាព |
| CWD | កុមារពិការ |
| DCD | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| DEMIS | នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ |
| DIT | នាយកដ្ឋានព័ត៌មានវិទ្យា |
| DOE | ការិយាល័យអប់រំស្រុក |
| ECE | អប់រំកុមារតូច |
| EGR | អំណានកុមារតូច |
| EGRA | សកម្មភាព/ការប៉ាន់ប្រមាណអំណានកុមារតូច |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| ERMs | សម្ភារៈឧបទ្ទេសអំណានចាំបាច់ |
| ESDG | ក្រុមអ្នកផ្តល់ជំនួយលើវិស័យអប់រំ |
| EU | សហភាពអឺរ៉ុប |
| GBA | អង្គការសម្ព័ន្ធសៀវភៅសកល |
| GBAIA | សកម្មភាពអង្គការសម្ព័ន្ធសៀវភៅសកល |
| GDL | បណ្ណាល័យឌីជីថលសកល |
| GPE | អង្គការភាពជាដៃគូសកលសម្រាប់វិស័យអប់រំ |
| IEC | ព័ត៌មាន អប់រំ និងទំនាក់ទំនង |
| KAPE | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |

| | |
|---|---|
| KIND | វិទ្យាស្ថានខ្មែរសម្រាប់ការអភិវឌ្ឍជាតិ |
| JBDWG | ក្រុមការងារអភិវឌ្ឍសៀវភៅរួម |
| MENAP | ផែនការសកម្មភាពជាតិអប់រំភាសាចម្រុះ |
| MoEYS | ក្រសួងអប់រំយុវជន និងកីឡា |
| MLE | ការអប់រំភាសាចម្រុះ |
| NEP | ភាពជាដៃគូអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NGS | សាលាជំនាន់ថ្មី |
| OI | វិទ្យាស្ថានបើកទូលាយ |
| OPTD | ការិយាល័យផែនការ និងចែកចាយសៀវភៅសិក្សា |
| PDH | គ្រឹស្ថានបោះពុម្ព និងចែកផ្សាយ |
| PED | នាយកដ្ឋានបឋមសិក្សា |
| POE | មន្ទីរអប់រំយុវជន និងកីឡា |
| PPE | ចំណាយលើសិស្សានុសិស្សម្នាក់ៗ |
| PTR | សមាមាត្រសិស្ស-គ្រូ |
| RBF | ការផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល |
| RFP | ស្នើសុំឱ្យដាក់សំណើ |
| RFQ | ស្នើសុំដាក់ឱ្យដាក់តម្លៃ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RtR | អង្គការរូមធូរីដ |
| SCA | ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់ |
| Sida | ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិស៊ុយអែដ |
| SRMs | សម្ភារៈអំណានបន្ថែម |
| SSBs | សៀវភៅសិស្សបន្ថែម |
| SSC | គណៈកម្មាការទ្រទ្រង់សាលារៀន |
| STEPCam | ការពង្រឹងកម្មវិធីអប់រំគ្រូបង្រៀននៅកម្ពុជា |
| TLMs | សម្ភារៈឧបទ្ទេស |
| TTO | ធនធានអប់រំ |
| UN | អង្គការសហប្រជាជាតិ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| VAT | អាករលើតម្លៃបន្ថែម |

សម្គាល់ ៖ ដើម្បីឱ្យខ្លី និងជៀសវាងភាពច្រំដែល ពាក្យ«សៀវភៅពុម្ព»ក្នុងរបាយការណ៍នេះក៏រួមបញ្ចូលទាំងសៀវភៅណែនាំរបស់គ្រូផងដែរ។

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកចងក្រងរបាយការណ៍នេះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកដែលបានចូលរួមចំណែកក្នុងការងារនេះ មានជាអាទិ៍អ្នកបោះពុម្ពផ្សាយ សហគ្រាសរោងពុម្ព អ្នកចែកចាយសៀវភៅ លោកគ្រូ-អ្នកគ្រូនិងនាយកសាលា បណ្ណារក្ស បុគ្គលិកនៃក្រសួងអប់រំយុវជននិងកីឡា ព្រមទាំងតំណាងមកពីក្រុមស្ថាប័នអ្នកផ្តល់ជំនួយនិងដៃគូប្រតិបត្តិរបស់ខ្លួន ដែលបានចែករំលែកយោបល់ និងផ្តល់អនុសាសន៍ទាក់ទងនឹងវិស័យសៀវភៅនៅកម្ពុជា។ បញ្ជីឈ្មោះអ្នកដែលបានចូលរួមមានភ្ជាប់ក្នុងឯកសារឧបសម្ព័ន្ធលេខ៤។

ការសិក្សាស្រាវជ្រាវនេះជាកម្មវិធី «គម្រោងសកម្មភាពអង្គការសម្ព័ន្ធសៀវភៅសកល (GBAIA)» របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលគាំទ្រការងាររបស់អង្គការសម្ព័ន្ធសៀវភៅសកល (GBA) ហើយត្រូវបានអនុវត្តដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍ការអប់រំ (EDC) ដែលស្ថិតក្រោមការដឹកនាំរបស់លោកបណ្ឌិត Simon James, ប្រធានអង្គភាពស្រាវជ្រាវ/និពន្ធ លោក Julian Watson, អ្នកស្រី Julianna Nielsen, លោក Roel de Haas, អ្នកស្រី ម៉ុង គីមណា, និងអ្នកស្រី Margaret Marcotte។ ក្រុមការងាររបស់ EDC ក៏រាប់បញ្ចូលលោក Ricardo Perez-Pineda, អ្នកស្រី Caitlin Flynn, និង អ្នកស្រី Brianna Reed ដែរ។ ការប្រែសម្រួលជាភាសាខ្មែរ ព្រមទាំងការរៀបចំទំព័រត្រូវធ្វើឡើងដោយ អ្នកស្រី ហួត សុជាតា។ យើងខ្ញុំកោតសរសើរក្រៃលែងចំពោះការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមការងារទាំងអស់។

ក្រុមអ្នកនិពន្ធ និងរៀបរៀង សូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសមាជិកនៃគណកម្មការសាកល្បងគម្រោងនៃអង្គការ GBA ដែលបានផ្តល់យោបល់ដ៏មានតម្លៃលើសំណៅទីមួយនៃរបាយការណ៍នេះ ជាពិសេសលើជំពូកទាក់ទងនឹង«ការរកឃើញទាំងឡាយ»។ យើងខ្ញុំមានសេចក្តីត្រេកអរជាពន្លឹកដែលបានទទួលការគាំទ្រ ការណែនាំផ្នែកបច្ចេកទេស និងមតិកែលម្អពីឯកឧត្តម សុខ ឫទ្ធី ប្រធានអគ្គនាយកគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, លោក រស់ សិរីសត្យា និង លោក Marc Bonnenfant មកពីការិយាល័យអប់រំនៃ USAID។ យើងខ្ញុំក៏សូមគោរពដឹងគុណដល់លោកស្រី Rebeca Martinez អ្នកជំនាញផ្នែកអប់រំនៃ USAID សម្រាប់ចំណេះដឹងនាំមុខផ្នែកបច្ចេកទេស ជំនាញ និងបទពិសោធន៍របស់លោកស្រី ទាក់ទងនឹងដំណើរការនៃការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ការសរសេរចងក្រងនិងការបិទបញ្ចប់ការងារនេះ។

យើងខ្ញុំសូមឧទ្ទិសរបាយការណ៍នេះជូនដល់វិញ្ញាណក្ខន្ធរបស់លោក Julian Watson ដែលធ្លាប់រស់នៅ និងធ្វើការនៅប្រទេសកម្ពុជា។ លោកមានចំណេះដឹងយ៉ាងទូលំទូលាយទាក់ទងនឹងវិស័យបោះពុម្ពនៅកម្ពុជា។ ចំណេះដឹងទាំងនេះបូករួមនឹងអត្តចរិតស្លូតបូត រួសរាយរាក់ទាក់ ជួយផ្តល់កម្លាំងចិត្តឱ្យក្រុមការងារយើងបន្តកិច្ចការស្រាវជ្រាវ និងផលិតជារបាយការណ៍នេះឡើង។ សហជីវិនរបស់លោកនៅតែចងចាំលោកទុកក្នុងចិត្តជានិច្ច។

របាយការណ៍នេះផលិតឡើង ដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) សម្រាប់ទុកជាឯកសារប្រើប្រាស់។ វាត្រូវបានរៀបចំចងក្រងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ការអប់រំ (EDC) ក្នុងក្របខណ្ឌការងាររបស់គម្រោងសកម្មភាពអង្គការសម្ព័ន្ធសៀវភៅសកល (GBAIA)។

# ខ្លឹមសារសង្ខេប និងអនុសាសន៍កម្រិតខ្ពស់

ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ (SCA) សម្រាប់ប្រទេសកម្ពុជានេះត្រូវបានចងក្រងឡើងដោយគម្រោងសកម្មភាពអង្គការសម្ព័ន្ធសៀវភៅសកល (GBAIA) របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ជំនួសមុខឱ្យអង្គការសម្ព័ន្ធសៀវភៅសកល (GBA)។ ការវិភាគខ្សែសង្វាក់ ផ្គត់ផ្គង់សៀវភៅរៀបចំឡើងដើម្បីផ្តល់ជាព័ត៌មានសម្រាប់ការងាររបស់ GBA ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា (MoEYS), ទីភ្នាក់ងារសហរដ្ឋអាមេរិសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិប្រចាំនៅកម្ពុជា (USAID/Cambodia), និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតនៅកម្ពុជាដែរ។ ដើម្បីវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅបាន យើងកំណត់ជាប្រាំមួយដំណាក់កាល ៖

**១- ការធ្វើផែនការ និងការព្យាករណ៍**

**២- ការអភិវឌ្ឍចំណងជើង**

**៣- ការបោះពុម្ព**

**៤- លទ្ធកម្ម និងការទិញ**

**៥- ការគ្រប់គ្រងការចែកចាយ**

**៦- ការប្រើប្រាស់សកម្ម**

រូបភាព ១ ៖ ប្រាំមួយដំណាក់កាលនៃខ្សែសង្វាក់សៀវភៅ



មានការកំណត់និយមន័យផ្សេងៗគ្នាទៅលើពាក្យ «សម្ភារៈឧបទ្ទេសអំណានចាំបាច់» ហើយអ្វីដែលជាសារសំខាន់របស់វាក្នុងដំណាក់កាលរៀនសូត្រមួយ អាចនឹងមិនសូវមានសារសំខាន់នៅដំណាក់កាលមួយផ្សេងទៀត។ សម្រាប់របាយការណ៍នេះយើងប្រើប្រាស់ពាក្យពេចន៍ និងនិយមន័យតាមការណែនាំរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID)៖

សៀវភៅ**អានសម្រាប់ប្រកប** សៀវភៅ**អានតាមកម្រិតថ្នាក់** និងឯកសារ**អំណានបន្ថែម** (ចាត់ទុកថាជា**អំណានចាំបាច់**) សុទ្ធតែជាធាតុផ្សំចាំបាច់សម្រាប់អំណាន ទោះបីយ៉ាងដូច្នោះក្តី ឯកសារទាំងនោះដើរតួនាទីផ្សេងៗគ្នាតាមដំណាក់កាលរៀងៗខ្លួន។

- **សៀវភៅអានសម្រាប់ប្រកប** ជាឯកសារអំណានដែលពាក្យពេចន៍ទាំងអស់មានតួអក្សរប្រកបតាមសូរសៀងរបស់វាដែលគ្រូបានបង្រៀនរួចហើយ។ សម្ភារៈទាំងនេះត្រូវបានគេរៀបចំតាមលំដាប់លំដោយអក្ខរក្រមតាមកម្មវិធីសិក្សា ហើយការរៀនប្រកបនេះនឹងចាប់ផ្តើមពីងាយទៅលំបាកបន្តិចម្តងៗ។
- **សៀវភៅអានតាមកម្រិតថ្នាក់** ជាឈុតសៀវភៅដែលគេរៀបចំតាមកម្រិតនៃភាពលំបាកដោយផ្អែកលើភាពស្មុគស្មាញនៃពាក្យ ប្រយោគ ខ្លឹមសារ និងកត្តាដទៃទៀត។
- **ឯកសារអំណានបន្ថែម** ជាអំណានសម្រាប់អនុវត្ត។ ឯកសារទាំងនេះមិនមែនសម្រាប់រៀនប្រកប ឬសម្រាប់តាមកម្រិតថ្នាក់នានាទេ ហើយក៏មិនពាក់ព័ន្ធផ្ទាល់ជាមួយកម្មវិធីសិក្សាដែរ។[១]

ម្យ៉ាងវិញទៀត យើងក៏បានបញ្ចូលសៀវភៅប្រភេទនេះទៅក្នុង**សៀវភៅអំណានបន្ថែមសម្រាប់សិស្ស** ដែលអភិវឌ្ឍដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងគម្រោង All Children Reading-Cambodia។ កម្មវិធីនេះគាំទ្រការប្រើប្រាស់សៀវភៅគោលតាមវិធីសាស្ត្រគរុកោសល្យទំនើប និងសាមញ្ញ ដោយសង្កត់ធ្ងន់លើសភាពស្មុគស្មាញនៃអត្ថបទដែលជួយពង្រឹងការអាន និងការសរសេរ។

១ *និយមន័យយកមកពី* USAID, *2020 Compendium of Standard PIRS for Education Programming*.

ការវិភាគសង្វាក់ផ្គត់ផ្គង់សៀវភៅសម្រាប់ប្រទេសកម្ពុជាអនុវត្តដោយក្រុមអ្នកសិក្សាស្រាវជ្រាវក្នុងគម្រោង USAID's GBAIA ក្នុងអំឡុងខែមករា និងខែកុម្ភៈឆ្នាំ២០២០។ ការវិភាគធ្វើឡើងដោយរួមបញ្ចូលគ្នារវាងទិន្នន័យមានស្រាប់ និងទិន្នន័យបានមកពីការចុះប្រមូលតាមមូលដ្ឋាន។ ក្រុមអ្នកសិក្សាស្រាវជ្រាវបានសម្ភាសន៍ និងប្រមូលព័ត៌មានពីភាគីពាក់ព័ន្ធនានារួមមានមន្ត្រីរបស់រាជរដ្ឋាភិបាល បុគ្គលិកអង្គការដែលជាម្ចាស់ជំនួយនិងដៃគូអនុវត្តគម្រោង អ្នកបោះពុម្ពអ្នកនិពន្ធ អ្នករចនារូបភាព រោងពុម្ព អ្នកចែកចាយ និងគ្រូបង្រៀននៅតាមសាលាបឋមសិក្សាជាច្រើននាក់។

ដោយសារតែក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នឯទៀត ផ្តោតស្ទើរតែទាំងស្រុងលើសៀវភៅសិក្សាគោលនៅក្នុងប្រទេស ទើបមានការខ្វះខាតនូវទិន្នន័យទាក់ទងនឹងសម្ភារៈអំណានចាំបាច់នានា។ លើសពីនេះ សៀវភៅអានសម្រាប់ប្រកប និងសៀវភៅអានតាមកម្រិតថ្នាក់ពុំត្រូវបានលើកឡើងទេ ដូច្នេះយើងឃើញថាចំណុចនេះលើកយកមកបង្ហាញក្នុងរបាយការណ៍តិចតួចតែប៉ុណ្ណោះ។ របាយការណ៍ SCA នេះពិនិត្យមើលលើស្ថានភាពទូទៅនៃសៀវភៅពុម្ពនិងERMs ប៉ុន្តែបានផ្តោតលើភាពចាំបាច់ជាចម្បងលើដំណើរការចែកចាយសៀវភៅនោះ។ នៅពេលយើងលើកឡើងពី ERMs ក្នុងរបាយការណ៍នេះ យើងនិយាយសំដៅទៅលើ *ឯកសារអំណានបន្ថែម*។

បញ្ហាប្រឈមទាក់ទិននឹងការផ្តល់សៀវភៅក្នុងប្រទេសកម្ពុជា គឺកើតឡើងតាមដំណាក់កាលនានានៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ចាប់តាំងពីការធ្វើផែនការនិងការព្យាករណ៍ រហូតដល់ការប្រើប្រាស់និងគ្រប់គ្រងសៀវភៅនៅក្នុងសាលារៀន ដោយសារតែកង្វះខាតនូវកិច្ចសម្របសម្រួលល្អក្នុងការអនុវត្ត។

ទោះបីជាឆ្នាំ២០១៦ ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់មុខវិជ្ជា ត្រូវបានអនុម័ត ក៏ដូចជាកម្មវិធីសិក្សាលម្អិតក្នុងឆ្នាំ២០១៨ក៏ដោយ ក៏នៅអំឡុងពេលសរសេររបាយការណ៍នេះ យើងពុំទាន់ឃើញមានការបោះពុម្ពសៀវភៅសិក្សាថ្មីនៅឡើយ ដោយសារតែថវិកាមានកំណត់។ ដើម្បីដាក់ឱ្យដំណើរការកម្មវិធីសិក្សាថ្មី សៀវភៅគោលចំនួន៥២មុខនឹងត្រូវកែលម្អឡើងវិញ ធ្វើយ៉ាងណាឱ្យកម្មវិធី និងសៀវភៅគោលទាំងនេះដើរទន្ទឹមគ្នាកាន់តែល្អប្រសើរបំផុត។

គេមិនទាន់ឃើញមានមូលនិធិកណ្តាលរបស់រដ្ឋាភិបាលបែងចែកសម្រាប់ ERMs ទេ។ រាល់ការទិញ ERMs ត្រូវប្រើប្រាស់កញ្ចប់ថវិកាប្រតិបត្តិរបស់សាលានីមួយៗដែលត្រូវបែងចែកសម្រាប់ចំណាយនានារបស់ សាលាជាច្រើនទៀតដូច្នេះហើយវាមិនអាចធានានិរន្តរភាពក្នុងការផ្គត់ផ្គង់សៀវភៅឱ្យបានគ្រប់គ្រាន់ទេ។ ជាងនេះទៅទៀតមាតាបិតាសិស្សពុំទាន់មានការយល់ដឹងគ្រប់គ្រាន់ស្តីពីសារៈសំខាន់របស់ ERMs ក្នុងអំណានឡើយ នេះជាហេតុធ្វើឱ្យតម្រូវការសៀវភៅអានលើទីផ្សារមានការធ្លាក់ចុះ។ ក្នុងប្រទេសកម្ពុជា វិស័យបោះពុម្ពផ្សាយជាលក្ខណៈឯកជននៅមានកម្រិតនៅឡើយ ដូច្នេះហើយការផ្គត់ផ្គង់ERMsក៏មានកម្រិតតាមហ្នឹងផងដែរ។ គម្លាតនៃការបោះពុម្ពនេះហើយនាំឱ្យមានការពឹងផ្អែកខ្លាំងទៅលើអង្គការមិនមែនរដ្ឋាភិបាល(NGOs) ដើម្បីបំពេញបន្ថែមលើទីផ្សារ ERM។ គម្រោងនានាដែលទទួលថវិកាពីម្ចាស់ជំនួយមិនអាចផ្គត់ផ្គង់ឯកសារអំណាននេះដល់ទូទាំងប្រទេសបានឡើយ ជាលទ្ធផលគម្រោងទាំងនោះផ្តោតការយកចិត្តទុកដាក់ខ្លួនតែលើតំបន់កំណត់ជាក់លាក់របស់ខ្លួន ធ្វើឱ្យសិស្សានុសិស្សដែលស្ថិតនៅក្រៅរង្វង់ប្រតិបត្តិរបស់ខ្លួនពុំទទួលបានសម្ភារៈទាំងនោះមកប្រើប្រាស់ទេ។ មានបញ្ហាស្មុគស្មាញមួយទៀតដោយសារតែវប្បធម៌របស់ខ្មែរគឺថាខ្មែរមានទម្លាប់និយាយផ្ទាល់មាត់ជាជាងកត់ត្រាទុក និងអាន ដូច្នេះហើយអំណានមិនត្រូវបានគេចាត់ទុកជាសកម្មភាពកម្សាន្តនោះទេតែផ្ទុយទៅវិញគេចាត់ទុកជាសកម្មភាពហ្វឹកហាត់ជាក់ស្តែងទៅវិញ។[២]

ដំណោះស្រាយលើកង្វះខាតទូទៅលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ (ជាពិសេសការដាក់បញ្ចូល ERMs ជាផ្នែកនៃគោល

២ *Jarvis, et al. ក្រលេកមើលការបោះពុម្ពផ្សាយនៅប្រទេសកម្ពុជា។*

នយោបាយលទ្ធកម្មរបស់រាជរដ្ឋាភិបាល) នឹងតម្រូវឱ្យមានការគ្រប់គ្រងត្រួតពិនិត្យ តាមរយៈនាយកដ្ឋានដែលមានសមត្ថកិច្ចរបស់MoEYS។ ថ្វីត្បិតតែគោលនយោបាយរបស់ក្រសួងពាក់ព័ន្ធនឹងកម្មវិធីសិក្សា មានលក្ខណៈបើកចំហសម្រាប់គ្រឹះស្ថានបោះពុម្ពឯកជនអភិវឌ្ឍសៀវភៅគោលក៏ដោយ ជាក់ស្តែងការអភិវឌ្ឍសៀវភៅសិក្សាទាំងឡាយធ្វើឡើងដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរបស់រដ្ឋ (PDH) តែប៉ុណ្ណោះ។ ការបើកដំណើរការលទ្ធកម្មឆ្ពោះទៅរកការប្រកួតប្រជែងកាន់តែផុលផុស ព្រមទាំងមានការបណ្តុះបណ្តាលអ្នកបោះពុម្ពផ្សាយឯកជន មិនត្រឹមតែអាចជំរុញសកម្មភាពក្នុងវិស័យនេះឱ្យពេញលេញប៉ុណ្ណោះទេ វាថែមទាំងអាចពង្រីកលទ្ធភាពទទួលបានសៀវភៅកាន់តែទូលំទូលាយ និងអនុញ្ញាតឱ្យមានធនធានថវិកាសម្រាប់ផលិត ERMs តាមរយៈការកាត់បន្ថយថ្លៃដើមដែលបានមកពីប្រសិទ្ធភាពនៃវិស័យឯកជននេះទៀតផង។

គេឃើញមានវិធានការវិជ្ជមានមួយចំនួនបានអនុវត្តកន្លងមក ដែលនឹងញុំាងឱ្យមានការកែលម្អលទ្ធភាពទទួលបានឯកសារអំណានរឹតតែប្រសើរឡើង។ ឧទាហរណ៍ជាក់ស្តែងមួយ គឺវឌ្ឍនភាពដ៏សំខាន់តាមរយៈការអនុវត្តនាពេលថ្មីៗនេះរបស់ MoEYS នៃប្រព័ន្ធត្រួតពិនិត្យនិងតាមដាន (TnT- ប្រព័ន្ធគ្រប់គ្រងការចែកចាយសៀវភៅសិក្សាគោល) ស្វ័យប្រវត្តិ។ ដើមឡើយប្រព័ន្ធនេះទទួលមូលនិធិពីធនាគារពិភពលោក តាមរយៈគម្រោងលើកកម្ពស់ការចែកចាយសៀវភៅនៅកម្ពុជា[៣] សម្រាប់ធ្វើផែនការ និងព្យាករណ៍កាន់តែមានប្រសិទ្ធភាព និងទាន់ពេលវេលា តាមរយៈការបោះពុម្ព និងការចែកចាយ។ ប្រព័ន្ធត្រួតពិនិត្យនិងតាមដាននេះនឹងមានឥទ្ធិពលយ៉ាងខ្លាំង ចំពោះដំណាក់កាលដ៏សំខាន់នៃខ្សែសង្វាក់ផ្គត់ផ្គង់។[៤]

ម្ចាស់ជំនួយបានចូលរួមយ៉ាងសកម្មក្នុងការផលិតនូវប្រភេទឯកសារប្រកបដោយភាពច្នៃប្រឌិតជាភាសាខ្មែរដើម្បីបង្រៀនអំណាន គណិតវិទ្យា និងកម្មវិធីនានាដើម្បីឱ្យសិស្សានុសិស្សទទួលឯកសារទាំងនោះបានទូលំទូលាយ។ គម្រោងAll Children Reading-Cambodia (ACR) បង្កើតកម្មវិធី និងធនធានក្នុងបំណងផ្តល់លទ្ធភាពប្រើប្រាស់ឯកសារប្រកបដោយអត្ថន័យដល់សិស្សានុសិស្សទាំងអស់ ហើយអង្គការក៏បានណែនាំសៀវភៅសិស្សបន្ថែម (SSBs) ដែលរៀបរៀងសម្រាប់រៀនប្រកបអក្សរជាមួយនឹងរចនាសម្ព័ន្ធជាក់លាក់សម្រាប់ឈានទៅដល់សៀវភៅសិក្សាគោលដោយផ្សារភ្ជាប់ជាមួយឯកសារអំណានបន្ថែម (SRMs) និងមានការណែនាំសម្រាប់សកម្មភាពបង្រៀនទៀតផង។ ថ្វីត្បិតតែសៀវភៅអានសម្រាប់ប្រកប និងសៀវភៅតាមកម្រិតថ្នាក់នៅមានតិចតួចក៏ដោយ អង្គការរូមធូរីដ (Room to Read) និងអង្គការ ខេប (KAPE) ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកទឹកចិត្តឱ្យបង្កើតឯកសារអំណានតាមកម្រិតថ្នាក់នានា។ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) បានបង្កើតកម្មវិធីមួយប្រកបដោយសក្តានុពលសម្រាប់

*៣ ធនាគារពិភពលោក, «ប្រព័ន្ធត្រួតពិនិត្យ និងតាមដាននៅកម្ពុជា»។*

*៤ សម្រាប់ព័ត៌មានស្តីពីប្រព័ន្ធត្រួតពិនិត្យ និងតាមដាន សូមអាន SCAដំណាក់កាលទី១ ៖ ការធ្វើផែនការ និងការព្យាករណ៍។*

បង្កើតអត្ថបទដែលចាត់តាមកម្រិតដោយប្រើប្រាស់ការវិភាគជាក់ស្តែង។

កិច្ចខិតខំប្រឹងប្រែងដទៃទៀតរួមមានការវិនិយោគសំខាន់ៗក្នុងការធ្វើទំនើបកម្មបណ្ណាល័យញ៉ាំងឱ្យសិស្សានុសិស្ស អាចរកសៀវភៅ និងកម្មវិធីអប់រំនានាទាំងក្នុងបណ្ណាល័យចល័ត និងបណ្ណាល័យនានា ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពក្នុងការបោះពុម្ពឯកសារអំណានផ្សេងៗទៀត។

# អនុសាសន៍កម្រិតខ្ពស់

1. MoEYS ម្ចាស់ជំនួយផ្នែកអប់រំ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យសៀវភៅ (រួមមានរោងពុម្ព អ្នកបោះពុម្ពផ្សាយ តួអង្គកម្រិតសាលារៀន និងសង្គមស៊ីវិល) គួរតែបង្កើតផែនការអភិវឌ្ឍវិស័យសៀវភៅរយៈពេលវែង (BSDP) ឬឯកសារផែនការប្រហាក់ប្រហែលគ្នា។ ផែនការនេះអាចដាក់បញ្ចូលក្នុងក្រុមការងារសម្របសម្រួលជាមួយម្ចាស់ជំនួយដែលមានស្រាប់ តាមរយៈការបង្កើតក្រុមការងារអភិវឌ្ឍសៀវភៅរួម (JBDWG) ឬរចនាសម្ព័ន្ធសម្របសម្រួលណាមួយដែលប្រើប្រាស់យន្តការដែលមានស្រាប់ បន្ទាប់ពីនោះត្រូវផ្សព្វផ្សាយឱ្យអ្នកបោះពុម្ពផ្សាយ និងតួអង្គសំខាន់នានាក្នុងវិស័យអភិវឌ្ឍសៀវភៅ ឱ្យបានដឹងនិងយល់ឱ្យបានទូលំទូលាយ។ គោលដៅរបស់ BSDP គឺចូលរួមជាមួយវិស័យឯកជន ដើម្បីរួមចំណែកធ្វើឱ្យមាននិរន្តរភាព ក្នុងការផ្គត់ផ្គង់សៀវភៅក្នុងរយៈពេល២០ឆ្នាំខាងមុខ ក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលទាំងស្រុង និងជួយឱ្យម្ចាស់ជំនួយបង្កើតផែនការយុទ្ធសាស្ត្របិទបញ្ចប់កិច្ចការរបស់ខ្លួន។
2. BSDP គួរតែរួមបញ្ចូលការវិភាគអំពីគំរូផ្សេងៗនៃតួនាទីរបស់វិស័យសាធារណៈ និងវិស័យឯកជន ដើម្បីឆ្លើយតបនឹងគម្លាតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅបឋម និងតម្រូវការកសាងសមត្ថភាពពាក់ព័ន្ធនានា មកពិភាក្សា និងផ្តល់ជាអនុសាសន៍ទៅដល់ក្រុមម្ចាស់ជំនួយក្នុងវិស័យអប់រំ (ESDG) ដល់ MoEYS និងដល់ភាគីពាក់ព័ន្ធឯទៀតក្នុងវិស័យសៀវភៅ។ អនុវត្តការត្រួតពិនិត្យយ៉ាងទូលំទូលាយលើទំនួលខុសត្រូវរបស់ស្ថាប័ននីមួយៗដែលពាក់ព័ន្ធនឹងដំណើរការបោះពុម្ពផ្សាយសៀវភៅសិក្សាដើម្បីធ្វើឱ្យវិស័យនេះមានលក្ខណៈបើកចំហរមានប្រសិទ្ធភាព និងមានតម្លាភាពហើយវាក៏ជាការលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងដើម្បីភាពសម្បូរបែបក្នុងនោះរាប់បញ្ចូលទាំងទំនួលខុសត្រូវរបស់ក្រសួងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងសិទ្ធិនៃការនិពន្ធសៀវភៅសិក្សាផង។
3. សហគមន៍ម្ចាស់ជំនួយ តាមរយៈ JBDWG គួរតែសម្របសម្រួលលើតម្រូវការពង្រឹងសមត្ថភាពដល់ភាគីពាក់ព័ន្ធតាមការចង្អុលបង្ហាញពី BSDP និងពីក្នុងរបាយការណ៍នេះ។

# សេចក្តីសង្ខេបនៃអនុសាសន៍តាមដំណាក់កាលខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ

## អនុសាសន៍របស់GBA ៖ ការធ្វើផែនការនិងការព្យាករណ៍

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- គប្បីយកសម្មតិកម្មដែលថាការចុះឈ្មោះចូលរៀនរបស់សិស្សានុសិស្សនាពេលអនាគតនឹងកើនឡើង ដើម្បីធ្វើការព្យាករណ៍លើបរិមាណសៀវភៅសិក្សា ជាជាងការពឹងផ្អែកលើទិន្នន័យដែលមានក្នុងពេលបច្ចុប្បន្ន។
- លោកគ្រូ អ្នកគ្រូ និងនាយកសាលាគួរតែរាយការណ៍ឱ្យបានត្រឹមត្រូវពីចំនួនសៀវភៅបាត់បង់ ដោយមិនត្រូវភ័យ ខ្លាចពីផលវិបាកឡើយព្រោះថាវាជារឿងធម្មតាទេហើយវារមែងតែកើតមានឡើងចំពោះការចែកចាយសៀវភៅដល់សិស្សនោះ។
- ការធ្វើផែនការ និងការគ្រោងថវិកាត្រូវគិតរួមបញ្ចូលទាំង ERMs ផង មិនមែនគិតត្រឹមតែសៀវភៅសិក្សាគោលប៉ុណ្ណោះទេ។
- ប្រព័ន្ធប្រមូលទិន្នន័យ ត្រួតពិនិត្យ និងតាមដានគួរប្រើប្រាស់ឱ្យបានទូលំទូលាយក្នុងកិច្ចការរបស់ភាគីពាក់ព័ន្ធ។ ដំបូងឡើយគម្រោងនេះទទួលមូលនិធិពីធនាគារពិភពលោកជួយសម្រួល នឹងត្រួតពិនិត្យតម្រូវការថវិកាការធ្វើលទ្ធកម្ម និងការបញ្ចេញថវិកាពី MoEYS។ MoEYS បាននិងកំពុងដោះស្រាយរាល់ការចំណាយទាក់ទិននឹងដំណើរការប្រព័ន្ធនេះ ហើយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរបស់រដ្ឋ (PDH) បានអនុម័តផ្តល់ហិរញ្ញប្បទានដល់ការបន្តដំណើរការប្រព័ន្ធនេះ ឱ្យបានទៅដល់គ្រប់ខេត្តនាឆ្នាំ២០២២។
- ម្ចាស់ជំនួយទាំងឡាយគួរផ្តល់ការគាំទ្រដល់ MoEYS តាមតម្រូវការ និងសម្របសម្រួលក្នុងការផ្តល់ហិរញ្ញប្បទានជាមួយ PDH ក្នុងការពង្រីកប្រព័ន្ធត្រួតពិនិត្យ និងតាមដាន។ កិច្ចការនេះរួមមានការវាយតម្លៃភ្លាមៗនូវតម្រូវការទាក់ទងនឹងការបណ្តុះបណ្តាលលើមន្ត្រីធ្វើការលើប្រព័ន្ធត្រួតពិនិត្យ និងការព្រាងផែនការសកម្មភាពដោយផ្អែកតាមរបកគំហើញនេះ។

## អនុសាសន៍របស់GBA ៖ ការអភិវឌ្ឍចំណងជើង

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- គួររៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្កើត ERMs សម្រាប់ NGOs និងអ្នកបោះពុម្ពផ្សាយឯកជន។
- គួរបង្កើតស្តង់ដារបណ្ណាល័យ និងសៀវភៅតាមកម្រិតថ្នាក់ ឱ្យបានសមស្របជាមួយកម្រិតថ្នាក់ទាំងប្រាំមួយនៃបឋមសិក្សា ហើយភាគីទាំងអស់ឯកភាពគ្នាអនុវត្តស្តង់ដារសម្រាប់ការអភិវឌ្ឍឯកសារអំណានចាំបាច់នេះ។

- រាល់ឯកសារអំណានចាំបាច់ដែលកើតឡើងពីមូលនិធិរបស់ម្ចាស់ជំនួយត្រូវទទួលបានការរក្សាសិទ្ធិ «CC BY»[៥] (ឬអាជ្ញាប័ណ្ណទូទៅដែលមានភាពស្រដៀងគ្នា) ហើយត្រូវបំប្លែងវាទៅជាឯកសារអេឡិចត្រូនិកសម្រាប់ការផលិតឡើងវិញតាមបែបវិមជ្ឈការ។
- ក្នុងការសិក្សាតម្លៃប្រៀបធៀប គួរវិភាគលើចំណាយផលិតកម្ម ដើម្បីកំណត់ពីភាពខុសគ្នានៃតម្លៃដែលអង្គការទាំងឡាយចំណាយ ប្រៀបធៀបនឹងចំណាយរបស់MoEYS ដើម្បីជួយកំណត់រកសក្តានុពលសម្រាប់សន្សំសំចៃចំណាយលើថ្លៃដើម។
- គួរវិភាគលើទីផ្សារឱ្យបានហ្មត់ចត់ ដើម្បីដឹងពីតម្រូវការអានរបស់សិស្សានុសិស្ស ថាតើគេចង់អានអ្វីក្នុងសៀវភៅ ព្រមទាំងតម្លៃសៀវភៅដែលមាតាបិតាសិស្សមានលទ្ធភាពទិញ។ ការវាយតម្លៃបែបនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើតយុទ្ធសាស្ត្រដើម្បីលើកកម្ពស់វប្បធម៌អំណាន។
- MoEYS គួរទទួលបានការគាំទ្រក្នុងការបង្កើតស្តង់ដារថ្នាក់ជាតិដែលកំណត់ទាំងអំណានតាមកម្រិត និងថ្នាក់អក្ខរកម្ម ដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD) កំណត់ស្តង់ដារទាំងនេះដើម្បីជាមូលដ្ឋានសម្រាប់បង្កើតឯកសារចាំបាច់សម្រាប់អាន។

## អនុសាសន៍របស់GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- ជាផ្នែកមួយនៃអនុសាសន៍កម្រិតខ្ពស់ក្នុងការវិភាគគំរូនានានៃតួនាទីរបស់វិស័យសាធារណៈ និងឯកជន នៅក្នុងប្រព័ន្ធផ្គត់ផ្គង់សៀវភៅសិក្សា ការពិនិត្យឡើងវិញឱ្យបានទូលំទូលាយអំពីការទទួលខុសត្រូវរបស់អង្គភាពនីមួយៗពាក់ព័ន្ធនឹងដំណើរការបោះពុម្ពផ្សាយសៀវភៅសិក្សាគួរតែ ធ្វើឡើងដើម្បីជំរុញឱ្យមានការបើកចំហក្នុងវិស័យនេះ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ជាកិច្ចបង្កើតឱ្យមានការប្រកួតប្រជែងដែលនាំទៅរកភាពរីកចម្រើន – រួមជាមួយនឹងទំនួលខុសត្រូវរបស់ក្រសួងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងសិទ្ធិក្នុងការនិពន្ធសៀវភៅសិក្សាគោល។
- ជាផ្នែកមួយនៃការវិភាគនេះ MoEYS គួរពិចារណាបង្វែរទិសដៅរបស់Hពីការបោះពុម្ពផ្សាយសៀវភៅសិក្សាគោលឱ្យផ្តោតទៅលើការបោះពុម្ព និងចែកចាយសៀវភៅ ក្នុងនោះក៏មានERMsផងដែរ។ DCD គួរកំណត់កម្មវិធីសិក្សា និងស្តង់ដារហើយអ្នកបោះពុម្ពផ្សាយឯកជនគួរតែប្រកួតប្រជែងដេញថ្លៃបោះពុម្ពសៀវភៅសិក្សាគោល និង ERMs នានាផង។
- ជាផ្នែកមួយនៃការវិភាគ MoEYS ក៏គួរពិចារណាផ្តល់សិទ្ធិក្នុងការបោះពុម្ពសៀវភៅសិក្សារបស់ខ្លួន ដោយ

---

៥ *ដូចដែលកំណត់លើគេហទំព័ររបស់ Creative Commons ៖ "អាជ្ញាប័ណ្ណអនុញ្ញាតឱ្យមានការចែកចាយ កាត់ខ្ទឹមសារបញ្ចូលគ្នា យកទៅផលិតឡើងវិញនូវស្នាដៃរបស់លោកអ្នក (រហូតដល់ការយកទៅធ្វើជាពាណិជ្ជកម្ម) លុះត្រាតែមានការដាក់ឈ្មោះម្ចាស់ស្នាដៃដើម។ នេះជាអ្វីដែលអាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើបាន ដើម្បីជំរុញឱ្យមានការផ្សព្វផ្សាយនិងប្រើប្រាស់សម្ភារៈមានអាជ្ញាប័ណ្ណរឹតតែទូលំទូលាយ។" https://creativecommons.org/licenses/ (ប្រើប្រាស់ដោយទទួលបានការអនុញ្ញាតពី Creative Commons Attribution 4.0 International license.)*

បើកចំហ និងដោយប្រកួតប្រជែង។ ចំណែកឯគុណភាព និងខ្លឹមសារត្រូវប្រគល់ឱ្យ DCD ទទួលភារៈត្រួតពិនិត្យការបោះពុម្ពនោះ។

- ប្រសិនបើ MoEYS អនុញ្ញាតប្រគល់សិទ្ធិបរិយាយខាងលើហើយនោះ PDH គប្បីរៀបចំឡើងវិញហើយចាត់វិធានការខាងក្រោមដើម្បីរក្សាបាននិរន្តរភាព ៖
  - » វិនិយោគក្នុងការធ្វើទំនើបកម្មដើម្បីបានតម្លៃប្រកួតប្រជែង ជាមួយនឹងដើមទុនកើនឡើងដោយសារ (១) ឯកជនភាវូបនីយកម្ម, (២) ការរួមចំណែកក្នុងទីផ្សារមូលបត្រកម្ពុជា និង (៣) ការលក់ទីតាំងដ៏មានតម្លៃរបស់ខ្លួននៅកណ្តាលរាជធានីភ្នំពេញ រួចប្តូរទៅបោះទីតាំងនៅតំបន់ឧស្សាហកម្មតាមខេត្តណាមួយ វិនិយោគក្នុងការធ្វើទំនើបកម្មដើម្បីបានតម្លៃប្រកួតប្រជែង ជាមួយនឹងដើមទុនកើនឡើងដោយសារ (១) ឯកជនភាវូបនីយកម្ម, (២) ការរួមចំណែកក្នុងទីផ្សារមូលបត្រកម្ពុជា និង (៣) ការលក់ទីតាំងដ៏មានតម្លៃរបស់ខ្លួននៅកណ្តាលរាជធានីភ្នំពេញ រួចប្តូរទៅបោះទីតាំងនៅតំបន់ឧស្សាហកម្មតាមខេត្តណាមួយ។
- ពិចារណាលុបចោលនូវអាករបន្ថែម (VAT) ១០%[៦] និងពន្ធ៧,៧% សម្រាប់នាំចូលវត្ថុធាតុដើម(ក្រដាស)។
- គួរតែបង្កើត និងចងក្រងបណ្តាញអ្នកនិពន្ធ និងបណ្តុះបណ្តាលពួកគេគ្រប់មុខវិជ្ជា។
- MoEYS ចាត់តាំងគណៈកម្មការធ្វើរបាយការណ៍វិភាគលើចំណាយសរុបលើគម្រោងអភិវឌ្ឍកម្មវិធីសិក្សាថ្មីតាមមុខវិជ្ជានីមួយៗសម្រាប់បឋមសិក្សាពីថ្នាក់ទី១ដល់ថ្នាក់ទី៦។

## អនុសាសន៍របស់GBA ៖ ការបញ្ជាទិញ

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- រដ្ឋាភិបាលគួរកែសម្រួលនិតិវិធីនៃការធ្វើលទ្ធកម្ម ហើយពិនិត្យលើលទ្ធភាពនៃការដាក់បញ្ចូលការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិលើកិច្ចសន្យាទាំងឡាយណាដែលមានទឹកប្រាក់លើសពី១០០,០០០ដុល្លារដើម្បីធានាបាននូវប្រសិទ្ធភាពនៃតម្លៃ។
- ឧស្សាហកម្មបោះពុម្ពគួរបញ្ចុះបញ្ចូលអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDEC) កម្ពុជា ឱ្យមានយន្តការលើកលែងពន្ធដារលើក្រដាសដែលយកមកប្រើប្រាស់ដើម្បីផលិតសម្ភារៈអប់រំ។

## អនុសាសន៍របស់GBA ៖ ការគ្រប់គ្រងការចែកចាយ

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- ការចែកចាយគួរធ្វើឡើយដោយចំហដល់ផ្នែកចែកចាយឯកជនឯករាជ្យ តាមរយៈការដាក់ដេញថ្លៃប្រកួតប្រជែងថ្នាក់ជាតិដើម្បីបានតម្លៃល្អបំផុត។
- លេខនិយាមកា (GPS) គួរតែភ្ជាប់ទៅតាមសាលារៀនទាំងអស់ក្នុងប្រព័ន្ធ EMIS ហើយគ្រប់កញ្ចប់សម្ភារៈទាំងអស់ត្រូវមានស្លាកបារកូដដើម្បីសម្រួលក្នុងការតាមដាន។

---

៦ *VAT មានន័យថាជាអាករបន្ថែម។*

- បើកវគ្គបណ្តុះបណ្តាលសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធតាមដាននិងត្រួតពិនិត្យគ្រប់កម្រិតទាំងអស់ ជាមួយការគាំទ្រចាំបាច់ទាំងឡាយ។

# អនុសាសន៍របស់GBA ៖ ការប្រើប្រាស់សកម្ម

**GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖**

- បណ្តុះបណ្តាល និងផ្សព្វផ្សាយលើបណ្តាញសង្គមដើម្បីលើកកម្ពស់ការប្រើប្រាស់ ERMs នៅតាមថ្នាក់បឋមសិក្សា និងសម្រាប់សិស្សពិការ។ ម្ល៉ោះហើយ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់គណកម្មការទ្រទ្រង់សាលា គួរតែបូកបន្ថែមសកម្មភាព និងការតស៊ូមតិលើកកម្ពស់អក្ខរកម្ម និងការអប់រំបរិយាបន្នក្នុងគោលនយោបាយនៃវិស័យអប់រំនៅកម្ពុជា។
- បង្រៀនសិស្សានុសិស្សនៅក្នុងថ្នាក់រៀនឱ្យចេះថែរក្សាទាំងក្រប និងសាច់ក្នុងសៀវភៅ។
- សាលារៀនគប្បីធានាបណ្ណាល័យទុកដាក់ និងត្រួតពិនិត្យសៀវភៅបានល្អ ហើយសៀវភៅទាំងនោះអាចឱ្យសិស្សខ្ចីយកទៅផ្ទះបាន។
- ណែនាំលោកគ្រូ-អ្នកគ្រូ និងអាណាព្យាបាលតាមរយៈសកម្មភាពតស៊ូមតិផ្នែកអក្ខរកម្មដូចជាសារតាមវិទ្យុ និងសិក្ខាសាលាស្តីពីការប្រើប្រាស់ ERMs (សម្រាប់ទាំងក្នុងថ្នាក់រៀន និងនៅតាមផ្ទះ) និងអង្គការនានាដែលធ្វើការផ្នែកបណ្ណាល័យនៅតាមមូលដ្ឋាន។

# សេចក្តីផ្តើម

អត្ថបទល្អៗ និងភាពសម្បូរបែបនៃសម្ភារៈអំណាន ជាគន្លឹះជំរុញដើម្បីទទួលបានបំណិនផ្នែកអំណានសម្រាប់សិស្សានុសិស្សទាំងឡាយ។[៧] សិស្សគ្រប់រូបត្រូវអានមិនត្រឹមតែសៀវភៅសិក្សារបស់ខ្លួនប៉ុណ្ណោះទេ គឺគេគប្បីអានអត្ថបទពីសម្ភារៈនានា (ERMs) ជាភាសាខ្លួនផងដែរ។ តាមរយៈសេចក្តីណែនាំពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)[៨] បញ្ជាក់ថា អត្ថបទចម្លងសម្រាប់រៀនប្រកប ឬអត្ថបទចងក្រងជាសៀវភៅរៀនមួយក្បាល ឬជាកម្រងអត្ថបទអំណានគួរតែប្រគល់ឱ្យសិស្សថ្នាក់ទី១មួយម្នាក់ៗ ហើយសម្ភារៈទាំងនោះត្រូវមានបម្រុងទុកសម្រាប់ថ្នាក់ទី២ផងដែរ។ សម្រាប់សិស្សានុសិស្សថ្នាក់ធំ សៀវភៅរៀនប្រកបគ្រាន់តែជាសៀវភៅបម្រុង ពេលដែលមានទិន្នន័យតាមរយៈការវាយតម្លៃបង្ហាញថា កម្រិតអានរបស់កុមារទាំងនេះនៅទាបខ្លាំង ពួកគេនៅតែត្រូវការសម្ភារៈបែបនេះនៅឡើយ។ ចំណែកឯអត្ថបទសម្រាប់អានតាមកម្រិតថ្នាក់វិញ សិស្សម្នាក់ៗគួរទទួលបានសំណៅកថាខណ្ឌ ឬរឿងក្រោយពេលគេចងក្រងវាជាសៀវភៅរួច។ ក្នុងករណីសម្ភារៈអំណានជាឈុតវិញនោះ ត្រូវចែកឱ្យសិស្សានុសិស្សមិនលើសពីបីនាក់ក្នុងមួយឈុតៗឡើយ។ សម្ភារៈអំណានតាមកម្រិតមួយឈុតគួរដាក់បញ្ចូលយ៉ាងហោចណាស់មួយក្បាលសម្រាប់មួយសប្តាហ៍នៅក្នុងឆ្នាំសិក្សាទាំងមូល។ ចំណែកឯឯកសារសម្រាប់អានបន្ថែមវិញ អាចផ្តល់ឱ្យទៅតាមកម្រិតថ្នាក់យ៉ាងហោចណាស់មួយក្បាលមួយសប្តាហ៍ក្នុងឆ្នាំសិក្សាទាំងមូល។

មិនខុសគ្នាពីប្រទេសដទៃទេ ទិន្នន័យដែលមានស្តីពីការបង្រៀន និងសម្ភារៈឧបទ្ទេសសម្រាប់រៀននៅបឋមសិក្សានៅកម្ពុជាផ្តោតសំខាន់លើតែសៀវភៅសិក្សាតែមួយមុខ រីឯទិន្នន័យពាក់ព័ន្ធនឹង ERMs នៅមានកម្រិតនៅឡើយ។ ការរកឃើញនេះស្របគ្នាទៅនឹងធនធានទូទៅមានកម្រិត និងកង្វះខាតការយល់ដឹងពីសំណាក់រដ្ឋាភិបាល អាណាព្យាបាល និងលោកគ្រូ-អ្នកគ្រូអំពីតួនាទីដ៏សំខាន់របស់ ERMs ចំពោះការរៀនអក្សររបស់កុមារ។

របាយការណ៍នេះលើកពីចំណុចខ្លាំង និងចំណុចខ្វះខាតនៃទំនាក់ទំនងគ្នាក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ហើយផ្តល់ជាអនុសាសន៍ដើម្បីធានាថាសិស្សានុសិស្សទទួលបានសម្ភារៈអំណានសមស្រប និងមានគុណភាពល្អ ក្នុងគោលបំណងធ្វើឱ្យមានការកែលម្អក្នុងវិស័យអំណាននៅកម្ពុជា។

---

*៧ លទ្ធផលសម្រាប់វិទ្យាស្ថានអភិវឌ្ឍន៍ និងដៃគូអន្តរជាតិ ការសិក្សាលទ្ធភាពរបស់មូលនិធិសៀវភៅសកល។*

*៨ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ សេចក្តីណែនាំអំពីរបាយការណ៍អប់រំ ឆ្នាំ២០១៩។*

# វិធីសាស្ត្រ

ដើម្បីវិភាគលើសង្វាក់ការផ្គត់ផ្គង់នៅកម្ពុជានេះ ក្រុមការងារ (GBAIA) ចំណាយរយៈពេល២០ថ្ងៃដើម្បីសម្ភាសន៍ និងស្រង់មតិពីអ្នកពាក់ព័ន្ធសំខាន់ៗ និងប្រមូលយកទិន្នន័យដែលមានស្រាប់ និងប្រកបដោយគុណភាព។ ក្រុមអ្នកស្រាវជ្រាវ GBA ក៏បានសិក្សាស្វែងយល់ពីឯកសារនានាមុន និងអំឡុងពេលប្រមូលទិន្ន័យនៅក្នុងប្រទេសកម្ពុជាផងដែរ។ ឧបករណ៍ប្រើប្រាស់ក្នុងការស្រាវជ្រាវនេះឆ្លងកាត់ការសាកល្បង និងកែសម្រួលតាមរយៈការវិភាគជាបន្តបន្ទាប់។

មានការជួបប្រជុំជាមួយអ្នកធ្វើការងារពាក់ព័ន្ធសំខាន់ៗក្នុងវិស័យនេះចំនួន៥៧លើក ក្នុងនោះមានមន្ត្រីតំណាងក្រសួង ម្ចាស់ជំនួយ ភាគីប្រតិបត្តិ អ្នកបោះពុម្ពផ្សាយ អ្នកនិពន្ធ អ្នកគំនូរ រោងពុម្ព និងអ្នកចែកចាយ (សូមអានឧបសម្ព័ន្ធ៤)។ មានការធ្វើទស្សនកិច្ចទៅកាន់សាលារៀនចំនួនពីរដង ក្នុងនោះយើងក៏បានសម្ភាសជាមួយលោកគ្រូ-អ្នកគ្រូផងដែរ។ ពិធីសារពិស្តារមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ២ ៖ «ឧបករណ៍ សម្រាប់ប្រើប្រាស់ និងវិធីសាស្ត្រស្រាវជ្រាវ»។

# កត្តាប្រឈមនៃសម្ភារៈឧបទ្ទេសបង្រៀន និងរៀន

## កម្រិតបញ្ហាប្រឈមនៃសម្ភារៈឧបទ្ទេសបង្រៀន និងរៀន

ក្នុងឆ្នាំ២០១៨ ការប៉ាន់ប្រមាណអំណានកុមារតូច (EGRA) រកឃើញថា អត្រាកុមារចេះអានអក្សរនៅមានកម្រិតទាបខ្លាំងណាស់ ជាអាទិ៍សិស្សថ្នាក់ទី១អាចស្គាល់អក្សរបានត្រឹមតែ៩-១០តួប៉ុណ្ណោះក្នុងរយៈពេល១នាទី[៩]។ សៀវភៅសិក្សាជាទូទៅមិនស៊ីសង្វាក់គ្នានឹងកម្មវិធីសិក្សាដែលបានកែសម្រួលក្នុងឆ្នាំ២០១៦នោះទេ។

ចំនួន ERMs នៅក្នុងថ្នាក់រៀនមានការពិបាកដើម្បីកំណត់ដោយហេតុថារាល់ការទិញ ERMs ត្រូវធ្វើឡើងដោយវិមជ្ឈការទៅតាមសាលារៀន និង/ឬតាមបណ្ណាល័យរៀងៗខ្លួនពីអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់របស់ខ្លួន។ ការទិញនេះបានមកពីគម្រោងថវិកាប្រតិបត្តិរបស់សាលាដែលថវិកានោះយកមកប្រើប្រាស់ស្ទើរតែគ្រប់មុខតាំងពីសម្រាប់ការថែទាំសាលារៀន ការផ្គត់ផ្គង់នានា ទឹកនិងភ្លើង និងសម្ភារៈឧបទ្ទេសនានាទៀតផង។ គម្រោងនោះមានថវិកាប្រមាណ១៣០០ ដុល្លារ ក្នុងមួយសាលា និង៤ដុល្លារសម្រាប់សិស្សម្នាក់ក្នុងកម្រិតបឋមសិក្សា និង១៥០០ដុល្លារសម្រាប់សាលាមធ្យម ព្រមទាំងថវិកាបន្ថែម៧ដុល្លារក្នុងសិស្សម្នាក់ក្នុងកម្រិតមធ្យមសិក្សា។ សាលាមួយចំនួននៅស្ទាក់ស្ទើរមិនហ៊ានចាយវាយទៅលើសម្ភារៈអំណានទេ។ សៀវភៅដែលបោះពុម្ពដោយអង្គការក្រៅរដ្ឋាភិបាលជារឿយៗគេឃើញវត្តមាននៅតាមសាលារៀន និងបណ្ណាល័យតាមសហគមន៍ តែទោះជាយ៉ាងនេះក្តីក៏សៀវភៅទាំងនោះពុំទាន់ត្រូវបានរៀបចំជាប្រព័ន្ធសម្រាប់ប្រើប្រាស់នៅឡើយ។

ERMs មានស្ទើរគ្រប់ភាសាដែលគេនិយមនិយាយទាំងប្រាំ[១០] តាមកម្រិតផ្សេងៗគ្នាដែលផ្គត់ផ្គង់ដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា។ ការកែលម្អភាពស៊ីសង្វាក់គ្នាទៅនឹងសៀវភៅទាំងនេះ គឺជាតម្រូវការបន្ទាន់មួយសម្រាប់ផ្តល់ឱកាសសិក្សាជាបន្តបន្ទាប់ និងការធានាបាននូវមុខងារអក្ខរកម្ម។[១១]

---

៩ *De Stefano, Pressley, and King, គម្រោង All Children Reading-Cambodia –របាយការណ៍ចាប់ផ្តើម ២០១៨។*

១០ *ភាសាទាំងនេះរួមមានភាសាខ្មែរដែលជាភាសាជាតិ ភាសាបារាំងជាសហភាសាផ្លូវការ ភាសាវៀតណាម ភាសាចិន និងភាសាចាមដែលគេប្រើប្រាស់ជាក្នុងសហគមន៍គេ។*

១១ *សមាគមសម្រាប់អភិវឌ្ឍន៍វិស័យអប់រំអាព្រិច សហភាពអាព្រិច អង្គការសម្ព័ន្ធភាពសៀវភៅសកល និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ Continental Framework។*

# កត្តាបញ្ហាប្រឈម

## ប្រជាជន ភូមិសាស្ត្រ អាកាសធាតុ

ក្នុងឆ្នាំ២០១៩ កម្ពុជាមានប្រជាជនសរុបប្រមាណ១៦,៥លាននាក់[១២] ដោយកំណើនប្រជាជនមានការធ្លាក់ចុះពី ២,២៥% ក្នុងឆ្នាំ២០០០ មកនៅតែ១,៥%ក្នុងឆ្នាំ២០១៨[១៣]។ ទន្ទឹមគ្នានោះដែរ កម្ពុជាបានកែលម្អលើវិស័យសុខាភិបាលសម្រាប់ពលរដ្ឋខ្លួនគួរឱ្យកត់សម្គាល់ ជាអាទិ៍អត្រាមរណៈរបស់កុមារដែលមានអាយុក្រោមប្រាំឆ្នាំ បានធ្លាក់ចុះពី ១០៦នាក់ក្នុងចំណោមកុមារ១០០០នាក់នៅឆ្នាំ២០០០ មកត្រឹមតែ២៦,៦នាក់ក្នុងចំណោមកុមារ ១០០០នាក់ក្នុងឆ្នាំ ២០១៩[១៤]។ កំណើនចំនួនសិស្សចូលរៀននាពេលអនាគត គួរតែពិចារណាក្នុង ការព្យាករណ៍ របស់រាជរដ្ឋាភិបាលលើចំណាយសម្រាប់វិស័យសង្គមកិច្ចដោយផ្អែកលើវិធីសាស្ត្រនៃកិច្ចសម្របសម្រួល ពីបណ្តាវិស័យនានាដើម្បីសម្រេចឱ្យបាននូវការផ្គត់ផ្គង់សៀវភៅគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពជាជាងប្រើប្រាស់តែទិន្នន័យសិស្សានុសិស្សកំពុងរៀននាពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ។

កម្ពុជាជាប្រទេសជាប់មាត់សមុទ្រមួយក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយមានព្រំប្រទល់ភូមិសាស្ត្រដែនគោកជាប់ជាមួយនឹងប្រទេសថៃនៅភាគពាយ័ព្យ ប្រទេសឡាវនៅភាគខាងជើង ប្រទេសវៀតណាមនៅប៉ែកខាងកើត និងជាប់នឹងឈូងសមុទ្រថៃនៅប៉ែកនិរតី។ ប្រជាជនប្រមូលផ្តុំរស់នៅកកកុញនៅប៉ែកខាងត្បូង និងខាងកើតប្រទេស ជាពិសេសតំបន់ជុំវិញរាជធានីភ្នំពេញ តំបន់ទន្លេសាប និងតំបន់ទន្លេមេគង្គ។ ប្រមាណមួយភាគបួននៃប្រជាជនរស់នៅទីក្រុង ហើយបីភាគទៀតរស់នៅតំបន់ជនបទ[១៥] ដែលជាឧបសគ្គសម្រាប់ការទទួលបានការសិក្សាប្រកបដោយគុណភាព និងលទ្ធភាពបន្តការសិក្សាដល់ថ្នាក់ខ្ពស់សម្រាប់សិស្សទូទៅ ព្រមទាំងការចែកចាយសៀវភៅប្រកបដោយប្រសិទ្ធភាព។[១៦] កម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកដោយមានរដូវធំៗចំនួនពីរ។ យ៉ាងនេះក្តីក៏នៅមានប្រែប្រួលអាកាសធាតុតាមរដូវមិនទៀងទាត់ បើយោងតាមកំណត់ត្រារលកកំដៅក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៩ ធ្វើឱ្យសាលាកាត់បន្ថយម៉ោងសិក្សារបស់ខ្លួនរហូតដល់ទៅមួយម៉ោងឯណោះ ក្នុងបំណងបង្ការទប់ស្កាត់មិនឱ្យលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សធ្លាក់ខ្លួនឈឺដោយសារកំដៅខ្លាំងនេះ[១៧]។ ការបន្ថយម៉ោងសិក្សានេះ ធ្វើឱ្យសិស្សមិននៅជាមួយសៀវភៅក្នុងរយៈពេលយូរដែរ។

---

*១២ ធនាគារពិភពលោក «ចំនួនប្រជាជនសរុប - កម្ពុជា»។*

*១៣ Google. «ទិន្នន័យសាធារណៈ: សូចនាករអភិវឌ្ឍន៍ពិភពលោក»។*

*១៤ UNICEF, «កម្ពុជា៖ សូចនាករប្រជាសាស្ត្រសំខាន់ៗ»។*

*១៥ Overton, «កម្ពុជា»។*

*១៦ សម្រាប់ព័ត៌មានបន្ថែមស្តីពីវិបាយមិនស្មើគ្នារវាងសាលារៀននៅទីក្រុង និងសាលារៀននៅជនបទ សូមយោងទៅកាន់ផ្នែក ដំណាក់កាល៤ ៖ ការប្រើប្រាស់សកម្ម។*

*១៧ Associated Press. «សាលាកម្ពុជាបន្ថយម៉ោង»។*

ពីដើមខែវិច្ឆិការហូតដល់ពាក់កណ្តាលខែមីនា កម្ពុជាទទួលរងឥទ្ធិពលខ្យល់មូសុងបក់មកពីទិសឦសាន។ វាជារដូវប្រាំង ហើយក្នុងពេលនេះមិនមានភ្លៀងធ្លាក់ទេ ដូច្នេះសំណើមក្នុងបរិយាកាសក៏ទាបដែរ[១៨] ។ ផ្ទុយទៅវិញ ចាប់ពីខែឧសភារហូតដល់ពាក់កណ្តាលខែតុលា កម្ពុជាទទួលរងឥទ្ធិពលខ្យល់មូសុងវស្សាដែលបក់ពីទិសនិរតី ដោយនាំមកនូវទឹកភ្លៀង និងសំណើមបរិយាកាសខ្លាំងមកជាមួយផង។ ភ្លៀងច្រើនពេកបង្កឱ្យមានការពន្យាពេលបវេសនកាលថ្មី [១៩] ហើយវាក៏បណ្តាលឱ្យប៉ះពាល់ដល់ការដឹកជញ្ជូននៅក្នុងប្រទេសដោយសារតែទឹកជំនន់បំផ្លិចបំផ្លាញផ្លូវអស់[២០]។ ទឹកជំនន់ឆាប់រហ័សញឹកញាប់ពេកក៏បណ្តាលឱ្យខូចខាតដល់អគារ បរិក្ខា និងប្រព័ន្ធអេឡិចត្រូនិកផ្សេងៗ ហើយសាលាបង្ខំចិត្តលុបចោលសកម្មភាពនានាទៅវិញ។ លោកគ្រូ-អ្នកគ្រូក៏បានលើកផងដែរពីបញ្ហាថ្នាក់រៀនដែលមិនមានការការពារពីអាកាសធាតុ ហើយដែលបង្កធ្វើឱ្យមានការខូចខាតសៀវភៅ និងសម្ភារៈឯទៀតនៅក្នុងសាលារៀន។[២១] ដោយសារតែសាលារៀនចាប់ផ្តើមបវេសនកាលក្នុងខែតុលា ការដឹកជញ្ជូនសៀវភៅឱ្យដល់មុនពេលវេលានោះគឺមានការលំបាកខ្លាំង។

## ប្រព័ន្ធអប់រំ

អប់រំបឋមនៅកម្ពុជាចាប់ផ្តើមពីអាយុប្រាំមួយឆ្នាំហើយមានរយៈពេលប្រាំមួយឆ្នាំដែរ។ សូចនាករសំខាន់ថ្មីៗផ្តល់បរិបទសម្រាប់សភាពទូទៅនៃវិស័យអប់រំនៅកម្ពុជាក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះអាចរកបានជាសាធារណៈ។ អត្រាចុះឈ្មោះចូលរៀនសរុប និងកំណើនចំនួនសាលារៀនបង្ហាញពីការយកចិត្តទុកដាក់ទៅលើវិស័យអប់រំជាសសរស្តម្ភសេដ្ឋកិច្ចពីសំណាក់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយសម្រាប់សិស្សានុសិស្សម្នាក់ៗ (PPE) ក្នុងកម្រិតបឋមសិក្សាស្មើ៥%នៃផលិតផលក្នុងស្រុកសរុប (GDP) ដែលមើលទៅហាក់ដូចជាទាបជាង PPE ជាមធ្យមសម្រាប់ប្រទេសដែលមានចំណូលទាបគឺដល់ទៅ៩%ឯណោះ។[២២] នេះបង្ហាញពីការចំណាយជាមធ្យមរបស់រាជរដ្ឋាភិបាលប្រៀបទៅនឹងប្រាក់ចំណូលរបស់ប្រជាជនកម្ពុជា។[២៣] សមាមាត្រសិស្ស-គ្រូ (PTR) ក្នុងកម្រិតអប់រំបឋមសិក្សាគឺ៤៤,៥ក្នុងឆ្នាំ ២០១៨–២០១៩ ខ្ពស់ជាងបណ្តាប្រទេសដែលមានចំណូលទាបបំផុតគឺ៤០។[២៤]

---

១៨ Overton *«បរិយាកាសនៃកម្ពុជា»។*

១៩ Barron and Kunthear, *«ការបើកបវេសនកាលត្រូវពន្យា»។*

២០ Overton, *«គមនាគមន៍ និងទូរគមនាគមន៍»។*

២១ Benveniste, Marshall, and Araujo, *ការបង្រៀននៅក្នុងប្រទេសកម្ពុជា។*

២២ OFhi360 *និងគោលនយោបាយអប់រំ និងមជ្ឈមណ្ឌលទិន្នន័យ, កម្ពុជា ៖ ប្រវត្តិអប់រំជាតិ។*

២៣ OUNESCO. *«ចំណាយរបស់រដ្ឋាភិបាលសម្រាប់សិស្សម្នាក់ៗជា% នៃផលិតផលក្នុងស្រុកសរុប»* n.d. http://uis.unesco.org/en/glossary-term/government-expenditure-student-gdp-capita។

២៤ Fhi360 *និងគោលនយោបាយអប់រំ និងមជ្ឈមណ្ឌលទិន្នន័យ, កម្ពុជា ៖ ប្រវត្តិអប់រំជាតិ។*

តារាង១ ៖ សូចនាករអប់រំសំខាន់ៗ និងសូចនាករគុណភាពអប់រំបឋមសិក្សា[២៥]

| សូចនាករសំខាន់ៗ | 2016-2017 | 2017-2018 | 2018-2019 |
|---|---|---|---|
| ចំនួនប្រជាជនសរុប[២៦] | 16,009,409 | 16,249,792 | 16,500,000 |
| ចំនួនសិស្សចុះឈ្មោះចូលរៀន | 2,020,061 | 2,028,694 | 2,040,257 |
| កុមារា | 1,045,830 | 1,053,131 | 1,061,457 |
| កុមារី | 974,231 | 975,563 | 978,800 |
| ចំនួនសាលាបឋមសិក្សា | 7,576 | 7,762 | 7,716 |
| រដ្ឋ | 7,144 | 7,189 | 7,228 |
| ឯកជន | 432 | 432 | 488 |
| ចំនួនថ្នាក់រៀន | 61,255 | 61,635 | 62,208[27] |
| អត្រាសិស្សចុះឈ្មោះចូលរៀនសរុប – បឋមសិក្សា | 108.9 | 107.8 | 107 |
| កុមារា | 109.7 | 108.7 | 108.1 |
| កុមារី | 108 | 106.9 | 105.9 |
| អត្រាចុះឈ្មោះប្រាកដ – បឋមសិក្សា | 93.5 | 92.6 | 92.4 |
| កុមារា | 93.2 | 92.4 | 92 |
| កុមារី | 93.9 | 92.9 | 84.6 |
| **សូចនាករគុណភាព** | | | |
| សមាមាត្រសិស្ស-គ្រូ – បឋមសិក្សា | 43.8 | 44 | 44.5[28] |
| សមាមាត្រសិស្ស-ថ្នាក់រៀនអចិន្ត្រៃយ៍ – បឋមសិក្សា | 47.3 | 46.6 | 46 |
| អត្រាសិស្សបញ្ចប់បឋមសិក្សា | 79.87 | 79.06 | 82.14 |

*២៥ ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ, ស្ថិតិ និងសូចនាករអប់រំសាធារណៈ។*

*២៦ Macrotrends. អត្រាកំណើនប្រជាជនកម្ពុជា ឆ្នាំ១៩៥០-២០២១។ https://www.macrotrends.net/countries/KHM/cambodia/population-growth-rate. n.d.*

*២៧ ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ, ស្ថិតិ និងសូចនាករអប់រំសាធារណៈ។*

*២៨ ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំ, ស្ថិតិ និងសូចនាករអប់រំសាធារណៈ។*

| សូចនាករសំខាន់ៗ | 2016-2017 | 2017-2018 | 2018-2019 |
|---|---|---|---|
| កុមារា | 76.71 | 75.68 | 78.46 |
| កុមារី | 83.22 | 82.65 | 86.06 |
| សន្ទស្សន៍សមភាពយេនឌ័រ (GPI)សម្រាប់ការចុះឈ្មោះបឋម | .98 gross<br>1.01 net | .98 gross<br>1.01 net | .98 gross<br>1.01 net |

តារាង២: សូចនាករលទ្ធផល និងគោលដៅនៃអនុវិស័យអប់រំបឋមសិក្សា[២៩]

| សូចនាករ | Baseline 2018 | Target 2023 |
|---|---|---|
| សាលាបឋមសិក្សាមានអគ្គីសនីប្រើប្រាស់ | 49.6% | 65.0% |
| ចំនួនសាលាបឋមសិក្សាដែលមានបំពាក់កុំព្យូទ័រមួយគ្រឿងតាមថ្នាក់រៀននីមួយៗសម្រាប់សិស្សានុសិស្សប្រើប្រាស់ (ប្រមាណ1%–2%) | 20 | 500 |
| ចំនួនសាលាបឋមសិក្សាមានបណ្ណាល័យ | 1,500 | 2,500 |

ប្រព័ន្ធអប់រំទទួលរងនូវឥទ្ធិពលយ៉ាងខ្លាំងពីជំងឺកូវីដ-១៩។ ការបិទសាលារៀនបានពន្យាពេលក្នុងការបណ្តុះបណ្តាលគ្រូ ការអភិវឌ្ឍសម្ភារ:ឧបទ្ទេស និងការបំពេញកិច្ចការនានាខាងក្រៅទៀត។ ជំងឺរាតត្បាតដ៏សាហាវនេះបានបន្ទុចបង្អាក់ការបង្រៀន និងរៀននៅតាមសាលា ជាហេតុបណ្តាលឱ្យមានការពន្យាពេលសិក្សា និងទាមទារឱ្យមានការរៀនសងដើម្បីទូទាត់ការខាតបង់ពេលវេលាកន្លងមក។ ការបន្តបិទសាលារៀនក្នុងរយ:ពេលយូរនោះក៏បង្វែរការឆ្ពោះទៅរៀនអនឡាញតាមផ្ទះ ការរៀនតាមវិធីសាស្ត្របញ្ចូលគ្នា និងការរៀនពីចម្ងាយ។ ដើម្បីឱ្យបានជោគជ័យក្នុងការរៀនសូត្រតាមវិធីខាងលើនេះ សិស្សានុសិស្សត្រូវការសៀវភៅជាចាំបាច់ ប៉ុន្តែវាមិនប្រាកដថា តើគ្រួសារទាំងអស់ទទួលបានសៀវភៅទាំងនោះដោយរបៀបណាប្រសិនបើពុំមានការកែលម្អសង្វាក់ផ្គត់ផ្គង់ទេនោះ។

*២៩ ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣។*

## ផែនការយុទ្ធសាស្ត្រអប់រំ និងការទទួលមូលនិធិ

កម្លាំងចលករសំខាន់សម្រាប់អភិវឌ្ឍន៍ជាតិកម្ពុជា គឺ*យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព* (យុទ្ធសាស្ត្រចតុកោណ) ជាយុទ្ធសាស្ត្រសេដ្ឋកិច្ចបួនផ្នែកដែលបានអនុវត្តក្នុងឆ្នាំ ១៩៩៨ រហូតមកដល់បច្ចុប្បន្ន[៣០]។ ដំណាក់កាលបច្ចុប្បន្ន និងជាដំណាក់កាលចុងក្រោយរំលេចពីការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទីមួយ ហើយផ្អែកលើការកែលម្អគុណភាពនៃការអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែទាំសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ទន្ទឹមនឹងការពង្រឹងសមភាពយេនឌ័រ និងកិច្ចការពារសង្គមផងដែរ។

ដូច្នេះហើយ *ផែនការយុទ្ធសាស្ត្រអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០១៩-២០២៣* (ផែនការយុទ្ធសាស្ត្រ) បានបង្កើតឡើងក្នុងចំណោមគោលការណ៍នានាដើម្បីកែលម្អគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយកំណត់អាទិភាពកំណែទម្រង់[៣១] ដោយផ្អែកលើគោលការណ៍អប់រំប្រកបដោយសមធម៌ និងគុណភាព ការលើកកម្ពស់ឱកាសពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងធានាបាននូវភាពជាអ្នកដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដល់មន្ត្រីអប់រំគ្រប់កម្រិតទាំងអស់។ នៅក្នុងប្រទេសកម្ពុជា សៀវភៅសិក្សាទាំងអស់ជាការតែងនិពន្ធ បោះពុម្ព និងចែកចាយដោយគ្រឹះស្ថានរដ្ឋ (PDH)។ *ផែនការយុទ្ធសាស្ត្រ* បានកំណត់គោលដៅឱ្យសិស្សានុសិស្សនៃសាលាបឋមសិក្សាទទួលបានសៀវភៅសិក្សាគ្រប់មុខវិជ្ជាឱ្យបាន១០០%នៅឆ្នាំ ២០២៣។

ការចំណាយរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំបានកើនឡើងពី ១,៩% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ ២០១៤ ដល់២,៩% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០១៩ ហើយប្រទេសនេះមានការរីកចម្រើន គួរឱ្យកត់សម្គាល់ក្នុងវិស័យជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[៣២]។ វិធានការកែលម្អគុណភាព និងការឆ្លើយតប សំខាន់ៗចំពោះសេវាអប់រំបានធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡាបន្តផ្តល់អាទិភាពដល់កម្មវិធីកែទម្រង់បន្ថែមទៀត។ ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ដែលបច្ចុប្បន្នមានសិស្សចំនួន២,០៤ លាននាក់ បានកើនឡើងបន្តិចគឺប្រមាណ១,៥%

---

៣០ *រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, យុទ្ធសាស្ត្រចតុកោណ។*

៣១ *ផែនការយុទ្ធសាស្ត្រ (2019– 2023 )ក្រសួងអប់រំ យុវជន និងកីឡា ៖ កំណែទម្រង់អាទិភាពចំនួនប្រាំពីររួមមាន (១) គ្រូបង្រៀន (២) ការពង្រីកសាលារៀននៅគ្រប់កម្រិត (៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយនៃការគ្រប់គ្រងសាលារៀន (៤) ការលើកកម្ពស់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ (៥) ការអប់រំជំនាញឆ្លើយតបតម្រូវការទីផ្សារការងារ (៦) ការអភិវឌ្ឍន៍កម្មវិធីសិក្សា និងសៀវភៅសិក្សាដ៏ទូលំទូលាយ និង (៧) ការរៀបចំសម្រាប់ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ឆ្នាំ ២០២៣។ https://www.globalpartnership.org/sites/default/files/document/file/2019-10-education_sector_plan-cambodia.pdf*

៣២ *ក្រសួងអប់រំ យុវជន និងកីឡា «ជំពូកV ៖ ផែនការហិរញ្ញប្បទាន»។*

ថេរ បើប្រៀបនឹងកំណើនចាប់តាំងពីឆ្នាំ ២០១៥មក[៣៣]។ ក្នុងឆ្នាំ២០១៧ ចំនួនសាលាបឋមសិក្សាទាំងសាលារដ្ឋ និងសាលាឯកជនបានកើនឡើងនៅទូទាំងប្រទេសចំនួន ៣,៦% ស្មើនឹង៧៧១៧ ហើយសាលាបឋមសិក្សាចំនួន៩៦ បានសាងសង់ឡើងដើម្បីបំពេញតម្រូវការប្រើប្រាស់របស់សិស្សពិការ។

ថ្វីបើមានការកើនឡើងទាំងនេះក៏ដោយ កម្រិតអក្ខរកម្មរបស់កុមារកម្ពុជានៅទាបនៅឡើយ។ ថ្មីៗនេះ សកម្មភាព/ការប៉ាន់ប្រមាណអំណានកុមារតូច (EGRA) ធ្វើការវាស់ស្ទង់សិស្សថ្នាក់ទី១។ ការវាយតម្លៃបានរកឃើញថា បំណិនផ្នែកអំណានរបស់សិស្សក្នុងការអានពាក្យដែលធ្លាប់ស្គាល់តែឯង ឬអានអត្ថបទខ្លីៗតាមកម្រិតថ្នាក់របស់ខ្លួន គឺពិតជាមិនមានទេ (ដោយសិស្ស ៧១% និង៩១% ទទួលបានពិន្ទុសូន្យ) ហើយសិស្សថ្នាក់ទី១អាចស្គាល់អក្សរ ៩-១០ តួតែប៉ុណ្ណោះក្នុងមួយនាទី [៣៤]។ កម្រិតទាបនេះបណ្តាលមកពីកត្តាមួយចំនួន។ កង្វះខាតសម្ភារៈឧបទ្ទេសអំណានធ្វើឱ្យសិស្សានុសិស្សទទួលបានពិន្ទុទាប ស្របពេលដែលពួកគេពុំបានអនុវត្តអំណានឱ្យទៀងទាត់និងសមស្រប។ ក្រៅពីនេះ ការបែងចែកធនធានទំនងជាពាក់ព័ន្ធនឹងទម្រង់សេដ្ឋកិច្ចសង្គមរបស់សាលារៀន។ សាលាតាមទីក្រុង សាលាឯកជន និងសាលាដែលមានឈ្មោះល្បីៗមិនត្រឹមតែ «មាន» មូលនិធិច្រើនជាងប៉ុណ្ណោះទេ ប៉ុន្តែសាលាគេមានគ្រូបង្រៀនប្រកបដោយបទពិសោធន៍ និងចំណេះដឹងខ្ពង់ខ្ពស់ថែមទៀតផង។ នេះសឱ្យឃើញថាកម្ពុជាទទួលទណ្ឌកម្មទ្វេរដង ព្រោះថាសាលារៀនជាច្រើនក្រីក្រហើយ ថែមទាំងពុំមានឱកាសទទួលបានធនធាន រួមទាំងថវិកាសម្រាប់ទិញសៀវភៅ និងសម្ភារៈសិក្សាដើម្បីគាំទ្រការបង្រៀនឱ្យមានគុណភាពខ្ពស់ទៀត។ របាយការណ៍ PISA *(កម្មវិធីសម្រាប់ការវាយតម្លៃអន្តរជាតិ)* ឆ្នាំ២០១៨បានលើកឡើង «ការស្រាវជ្រាវបានបង្ហាញថា ការបង្កើនធនធានអប់រំបន្ថែមទៅដល់សិស្សានុសិស្ស និងសាលាដែលជួបការលំបាកប្រាកដជាជះលទ្ធផលយ៉ាងល្អរបស់សិស្ស និងដោះស្រាយវិសមភាពក្នុង វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ វាក៏ត្រូវបានបង្ហាញផងដែរថានៅក្នុងប្រព័ន្ធអប់រំប្រសើរ ធនធានទាំងឡាយទំនងត្រូវបានគេបែងចែកប្រកបដោយសមធម៌រវាងសាលារៀនដែលមានលក្ខណសម្បត្តិល្អប្រសើរ និងសាលាដែលជួបប្រទះការលំបាក (OECD, ២០១៦)» [៣៥]។

## សេដ្ឋកិច្ច

ក្នុងរយៈពេល១២ឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ដែលធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសមួយលូតលាស់ផ្នែកសេដ្ឋកិច្ចលឿននៅក្នុងលោក។ នៅឆ្នាំ ២០១៥ កម្ពុជាបានផ្លាស់ប្តូរមុខមាត់ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ហើយចន្លោះឆ្នាំ ១៩៩៨ និងឆ្នាំ ២០១៨ កម្ពុជាសម្រេចបាន នូវអត្រា

---

*៣៣ ការចុះឈ្មោះចូលរៀននៅប្រទេសកម្ពុជាគឺទាបជាងឆ្នាំ២០០៣ដែលមានចំនួនសិស្សរហូតដល់ ២,៧ លាននាក់ នេះបណ្តាលមកពីការធ្លាក់ចុះនៃអត្រាកំណើតរបស់ទារក។*

*៣៤ DeStefano, Pressley, និង King, គម្រោង All Children Reading-Cambodia។*

*៣៥ ក្រសួងអប់រំ យុវជន និងកីឡា ៖ វិស័យអប់រំនៅកម្ពុជា។*

កំណើនដល់ទៅ ៨%។ [៣៦]

កំណើនសេដ្ឋកិច្ចខ្ពស់ខ្លាញ់នេះបានមកពីការនាំចេញផ្នែកវាយនភ័ណ្ឌ និងវិស័យទេសចរណ៍ ប៉ុន្តែនៅឆ្នាំ ២០១៩ កំណើននេះមានការធ្លាក់ចុះបន្តិចបន្តួចមកនៅត្រឹម ៧,១% យ៉ាងនេះក្តីក៏វានៅតែមានភាពរឹងមាំនៅឡើយ។ [៣៧]

ភាពក្រីក្របានធ្លាក់ចុះយ៉ាងខ្លាំងពីប្រមាណ ៥០% នៃចំនួនប្រជាជនក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ១៣,៥% ក្នុងឆ្នាំ ២០១៤ ជាពិសេសជាមួយនឹងការថយចុះខ្លាំងបំផុត ដែលកើតឡើងនៅតំបន់ជនបទ[៣៨]។ ទោះជាយ៉ាងនេះក្តី អ្នកក្រីក្រជាង៩០%នៅតែរស់នៅក្នុងទីជនបទ ហើយប្រជាជនប្រហែល ៤,៥ លាននាក់ ស្ថិតនៅតែជិតបន្ទាត់ក្រីក្រ ម៉្លោះហើយពួកគេងាយនឹងធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញនៅពេលដែលជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ច និងផលប៉ះពាល់ទាំងឡាយមកពីខាងក្រៅ។[៣៩]

ដូច្នេះហើយប្រជាជនទាំងនោះមានធនធានស្តួចស្តើង ឬពុំមានលទ្ធភាពសម្រាប់ចំណាយលើសម្ភារៈអំណានពីផ្សារបានទេ។ គេសង្កេតឃើញផងដែរថា មានកុមារមួយចំនួនមានរបស់លេងដែរទិញពីក្នុងហាងមក (២៣,៣% ទៅ៧៨,៨%) ដែលមានច្រើនជាងឆ្ងាយពីចំនួននៃសៀវភៅអាន (០,២% ទៅ ១១%) នៅក្នុងគ្រួសារ។[៤០]

## កំណើនសារពើពន្ធ

ក្នុងឆ្នាំ ២០១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទទួលបានចំណូលពន្ធគយ និងអាករចំនួន ៦,០ ពាន់លានដុល្លារ ដែលលើសពីគោលដៅរបស់ខ្លួនចំនួន ៤,៥៦ ពាន់លានដុល្លារ។ សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា ការកើនឡើងនៃប្រាក់ចំណូលសារពើពន្ធគឺជាលទ្ធផលនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ហើយនេះសបញ្ជាក់ថា កម្ពុជាកំពុងក្លាយជាប្រទេសមួយដែលមានវប្បធម៌បង់ពន្ធ។[៤១] ការកើនឡើងនៃប្រាក់ចំណូលជាតិ ក៏ធ្វើឱ្យមានកំណើនលើចំណាយសម្រាប់សម្ភារៈអប់រំ ៖ ជាអាទិ៍ចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការផ្គត់ផ្គង់សៀវភៅសិក្សាដល់សាលារៀនបានកើនឡើងក្នុងរយៈពេលមួយទស្សវត្សរ៍ចុងក្រោយពី ៤,៨ លានដុល្លារក្នុងឆ្នាំ ២០១១ ដល់ ៦,៤ លានដុល្លារក្នុងឆ្នាំ ២០២០។

---

៣៦ *រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។*

៣៧ *ធនាគារពិភពលោក, «ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា ៖ ទិដ្ឋភាពទូទៅ»។*

៣៨ *រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។*

៣៩ *ធនាគារពិភពលោក, «ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា ៖ ទិដ្ឋភាពទូទៅ»។*

៤០ *វិទ្យាស្ថានជាតិស្ថិតិ, អគ្គនាយកដ្ឋានសុខភាព និងកម្មវិធី DHS ប្រទេសកម្ពុជា ៖ ការស្ទង់មតិប្រជាសាស្រ្ត និងសុខភាពឆ្នាំ ២០១៤។*

៤១ *Xinhua. «អាស៊ីប៉ាស៊ីហ្វិក ៖ ចំណូលប្រទេសកម្ពុជា»។*

កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តលើសេចក្តីព្រាងច្បាប់ថវិកាចំណាយសម្រាប់ឆ្នាំ ២០២០ មានចំនួន ៧,១៧ ពាន់លានដុល្លារអាមេរិក ដោយបែងចែក ១,៩៤ ពាន់លានដុល្លារអាមេរិកសម្រាប់ការចំណាយលើវិស័យសង្គម។ ថវិកាទាំងនេះបានកើនឡើងពី២២,៧% និង ៨,៦%លើសឆ្នាំមុន ផ្អែកលើប្រាក់ចំណូលសរុបដែលបានព្យាករណ៍ទុកប្រមាណ ៦,៥ ពាន់លានដុល្លារអាមេរិកសម្រាប់ឆ្នាំ ២០២០។

មុនពេលជំងឺរាតត្បាតកូវីដ-១៩ សេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ៦,៥% ក្នុងឆ្នាំ ២០២០ ដែលបង្កើនផលិតផលក្នុងស្រុកសរុបរបស់ខ្លួនដល់ ២៩,៤ ពាន់លានដុល្លារ ដោយផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់រំពឹងថានឹងកើនឡើងដល់ ១,៨១៦ ដុល្លារ [៤២]។

## តារាង៣: គម្រោងថវិកាជាតិ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា[៤៣]

| ពិពណ៌នា | ឯកត្តា (ពាន់លាន)[៤៤] | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|
| ចំណូលរដ្ឋាភិបាលទូទៅ | រូបិយប័ណ្ណជាតិ | 19,386.75 | 23,538.27 | 25,632.29 | 27,350.79 |
| ចំណូលរដ្ឋាភិបាលទូទៅ | ភាគរយ នៃផ.ស.ស | 21.6 | 23.80 | 23.65 | 23.02 |
| ចំណាយសរុបរបស់រដ្ឋាភិបាលទូទៅ | រូបិយប័ណ្ណជាតិ | 20,082.43 | 24,358.02 | 27,054.92 | 29,344.58 |
| ចំណាយសរុបរបស់រដ្ឋាភិបាលទូទៅ | ភាគរយ នៃផ.ស.ស | 22.38 | 24.62 | 24.96 | 24.70 |
| ប្រាក់ឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធរបស់រដ្ឋាភិបាលទូទៅ | រូបិយប័ណ្ណជាតិ | -695.678 | -819.754 | -1,422.63 | -1,993.80 |
| ប្រាក់ឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធរបស់រដ្ឋាភិបាលទូទៅ | ភាគរយ នៃផ.ស.ស | -0.78 | -0.83 | -1.31 | -1.68 |

*៤២ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា, គម្រោងថវិកាជាតិ។*

*៤៣ មូលនិធិរូបិយវត្ថុអន្តរជាតិ. មូលដ្ឋានទិន្នន័យទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ២០១៩។ ទិន្នន័យជាក់ស្តែងសម្រាប់ឆ្នាំ ២០១៧-២០១៨; ការប៉ាន់ស្មានសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត។ សម្គាល់៖ ប្រាក់ឱ្យខ្ចី (+)/ប្រាក់កម្ចី (–)សុទ្ធរបស់រដ្ឋាភិបាលទូទៅ (រូបិយប័ណ្ណជាតិ) ត្រូវបានគណនាដោយយកចំណូលសរុប ដកចំណាយសរុប។ នេះជាសមតុល្យស្ថិតិហិរញ្ញវត្ថុស្នូលរបស់រដ្ឋាភិបាល (GFS)ដែលវាស់វែងពីវិសាលភាពដែលរដ្ឋាភិបាលបម្រុងធនធានហិរញ្ញវត្ថុសម្រាប់វិស័យនានាពាក់ព័ន្ធ និងមិនពាក់ព័ន្ធសេដ្ឋកិច្ច(ប្រាក់ឱ្យខ្ចីសុទ្ធ ឬការប្រើប្រាស់ធនធានហិរញ្ញវត្ថុបង្កើតឡើងដោយវិស័យផ្សេងទៀត (ប្រាក់កម្ចីសុទ្ធ)។*

*៤៤ អត្រាប្តូរប្រាក់ប្រហាក់ប្រហែល ១ដុល្លារស.រ.អា = ៤,០៩៦ រៀល។*

| ពិពណ៌នា | ឯកត្តា (ពាន់លាន)[៤៤] | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|
| ប្រាក់ឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធបឋមរបស់រដ្ឋាភិបាលទូទៅ | រូបិយប័ណ្ណជាតិ | -407.355 | -477.433 | -1,047.51 | -1,582.68 |
| ប្រាក់ឱ្យខ្ចី/ប្រាក់កម្ចីសុទ្ធបឋមរបស់រដ្ឋាភិបាលទូទៅ | ភាគរយ នៃផ.ស.ស | -0.45 | -0.48 | -0.97 | -1.33 |

## ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ក្នុងរបៀបវារៈសម្រាប់កំណើនរបស់ខ្លួន RGC មានចេតនារបស់ក្នុងការខ្ចីពីដៃគូអភិវឌ្ឍន៍សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលនឹងកែលម្អបណ្តាញដឹកជញ្ជូន នេះក៏ធ្វើឱ្យប្រសើរឡើងថែមទៀតនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។ ការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនញ៉ាំងឱ្យមានការចែកចាយសៀវភៅកាន់តែងាយស្រួល។

## អគ្គិសនី

ប៉ុន្មានឆ្នាំចុងក្រោយនេះកម្ពុជាបានផលិតអគ្គិសនីដោយខ្លួនឯងកាន់តែច្រើនជាងមុនតាមរយៈការពង្រីកបណ្តាញអគ្គិសនី និងតាមរយៈថាមពលកកើតឡើងវិញ។ នៅដើមឆ្នាំ២០១៨ ផ្ទះចំនួន៩៧,៦% មានថាមពលអគ្គិសនីប្រើប្រាស់ក្នុងនោះ៧៨% គឺបណ្តាញអគ្គិសនី និង ១៩,៨% ជាថាមពលប្រព័ន្ធ [ព្រះអាទិត្យ] សូឡា និងអាគុយ។ ទោះជាយ៉ាងណាក៏ដោយ គេមិនទាន់ទុកចិត្តលើបណ្តាញនេះបាននៅឡើយទេ ដោយសារតែចរន្តអគ្គិសនីដាច់ជារឿយៗ និងម៉្យាងវិញទៀតការប្រែប្រួលនៃវ៉ុលអគ្គិសនីបង្កឱ្យខូចខាតឧបករណ៍ប្រើប្រាស់តាមផ្ទះ។ តាមការប្រមាណមានប្រហែល ផ្ទះ១៣% ប៉ុណ្ណោះមានអគ្គិសនីប្រើប្រាស់ប្រកបដោយសុវត្ថិភាពរហូតដល់២៣ម៉ោងក្នុងមួយថ្ងៃៗ។ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ សាលាបឋមសិក្សាប្រហែល៤៩,៦% មានអគ្គិសនីប្រើប្រាស់។ នេះបញ្ជាក់យ៉ាងច្បាស់ក្រឡែតថាវាមានទំនាក់ទំនងជាមួយនឹងសមត្ថភាពអានរបស់កុមារដោយហេតុថា មានករណីដាច់ភ្លើងតាមសាលារៀននៅពេលថ្ងៃ ចំម៉ោងសិក្សា។

តារាង៤ ៖ ប្រភពអគ្គិសនីតាមផ្ទះ (ក្រុង និងជនបទ), ឆ្នាំ ២០១៧[៤៥]

| ប្រភពអគ្គិសនី | ប្រទេសកម្ពុជា | ក្រុង | ជនបទ |
|---|---|---|---|
| ចរន្តអគ្គិសនីសាធារណៈ/ភ្លើងរដ្ឋ | 78% | 97.7% | 72.8% |
| អាគុយ | 11.9% | 1.3% | 14.7% |
| ថាមពលព្រះអាទិត្យ | 7.9% | 0.4% | 9.9% |
| ផ្សេងៗ | 2.2.% | 0.6% | 2.6% |

៤៥ *វិទ្យាស្ថានជាតិស្ថិតិ* ការស្ទង់មតិសេដ្ឋកិច្ចសង្គមកម្ពុជាឆ្នាំ ២០១៧។

## តំណភ្ជាប់បណ្តាញទំនាក់ទំនង

ទូរស័ព្ទចល័ត និងបណ្តាញអិនធឺណិតមានការតភ្ជាប់យ៉ាងច្រើននៅកម្ពុជា។ ស៊ីមកាតដាក់លក់ពេញទីផ្សារ និងបានបើកដំណើរការយ៉ាងសម្បូរបែប។ តាមពិតទៅវាមានចំនួនលើសពីចំនួនប្រជាជនទៅទៀត ហើយប្រជាជនកម្ពុជាជាង ៥០% មានទូរស័ព្ទយ៉ាងហោចណាស់មួយគ្រឿង។ តួលេខនៃការជាវទូរស័ព្ទចល័តសរុបត្រូវគេប៉ាន់ប្រមាណថាមានចំនួនប្រហែល ២០,៨ លានគ្រឿង។ ក្នុងឆ្នាំ ២០១៩ និយតករទូរគមនាគមន៍កម្ពុជាបានប៉ាន់ប្រមាណថា ចំនួនអ្នកប្រើប្រាស់អិនធឺណិតជាលក្ខណៈបុគ្គលសរុប ទាំងកុំព្យូទ័រ និងទូរស័ព្ទចល័តបានកើនឡើងដល់ ១៥,៨ លានដែលស្មើនឹង ៩៨,៥% នៃចំនួនប្រជាជន[៤៦]។ អ្នកប្រើប្រាស់ភាគច្រើននៅតែប្រើប្រាស់អិនធឺណិតតាមទូរស័ព្ទរបស់ពួកគេ ហើយចំនួនអ្នករស់នៅតាមជនបទដែលប្រើប្រាស់អិនធឺណិតទាបជាងតំបន់ទីក្រុង (៣១% ធៀបនឹង ៤៨% ក្នុងឆ្នាំ ២០១៦)[៤៧]។មានក្រុមហ៊ុនទូរគមនាគមន៍ចំនួនប្រាំមួយនៅក្នុងប្រទេសកម្ពុជា ៖ Cellcard, Smart, Metfone, Axiata, Seatel, និង Cootel ក្រុមហ៊ុនបីដំបូងស្រូបយកអ្នកប្រើប្រាស់បានប្រមាណ៩០%។ មានកញ្ចប់ទិន្នន័យជាច្រើនដែលអតិថិជនអាចរកបានពីអ្នកផ្តល់សេវានីមួយៗ ដូច្នេះការប្រើប្រាស់គឺមានតម្លៃសមរម្យ។

ទោះបីជាមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានបំពាក់ជាមូលដ្ឋានក៏ដោយ ក៏គេគប្បីជំឡើងល្បឿន គុណភាព និងសមត្ថភាពរបស់វាដើម្បីបំពេញតម្រូវការនៃសេដ្ឋកិច្ចឌីជីថល។[៤៨]

ទុកជាយ៉ាងនេះក្តី មានសាលាបឋមសិក្សាចំនួនតែ២០ប៉ុណ្ណោះ ដែលមានបំពាក់បន្ទប់កុំព្យូទ័រសម្រាប់ឱ្យសិស្សានុសិស្សប្រើប្រាស់ (២០១៧-២០១៨) ហើយសាលាបឋមសិក្សាមិនដល់ ៥០% ផង មានអគ្គិសនីប្រើប្រាស់[៤៩] ។ ដូច្នេះហើយសាលារៀនភាគច្រើនមិនអាចទាញយកអត្ថប្រយោជន៍ពីអត្ថបទឌីជីថល ទន្ទឹមគ្នានឹងសម្ភារៈឧបទ្ទេសបោះពុម្ពនៅក្នុងថ្នាក់រៀននៅមានកម្រិតនៅឡើយនោះ។ MoEYS មានគោលដៅបំពាក់បន្ទប់កុំព្យូទ័រ ឱ្យសាលារៀនចំនួន ៥២០ត្រឹមឆ្នាំ ២០២៣។ ការផ្តល់នេះមានន័យថា បានត្រឹមតែមួយភាគតូចទេ ហើយសាលាត្រូវភ្ជាប់អគ្គិសនី ភ្ជាប់កុំព្យូទ័រ និងចូលប្រើប្រាស់អត្ថបទទាំងនោះ។

---

*៤៦ Vannak. «អ្នកប្រើប្រាស់អិនធឺណិតជិត១៦លាន»។*

*៤៧ Phong, Kimchhoy, Kihol Srou, and Javier Solá. ការសិក្សាស្រាវជ្រាវ៖ ទូរស័ព្ទដៃ និងការប្រើប្រាស់អិនធឺណិតនៅប្រទេសកម្ពុជា ឆ្នាំ ២០១៦ https://asiafoundation.org/wp-content/uploads/2016/12/Mobile-Phones-and-Internet-Use-in-Cambodia-2016.pdf។*

*៤៨ IM Vutha, H. E. តំណភ្ជាប់ប្រព័ន្ធឌីជីថលនៅប្រទេសកម្ពុជា https://www.itu.int/en/ITU-D/Regional-Presence/AsiaPacific/SiteAssets/Pages/Events/2019/RRITP2019/ASP/Digital%20Connectivity%20in%20Cambodia.pdf. n.d។*

*៤៩ ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣។*

# ការវិភាគលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ

## ទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់ ៖ ដំណាក់កាលយុទ្ធសាស្ត្រប្រាំមួយ

ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅកម្ពុជាពិនិត្យមើលតំណភ្ជាប់ជាយុទ្ធសាស្ត្រទាំងប្រាំមួយនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។ ខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅដែលមានប្រសិទ្ធភាពទាមទារឱ្យមានការព្យាករណ៍ និងមានផែនការត្រឹមត្រូវ, ការអភិវឌ្ឍន៍ចំណងជើងល្អៗទាំងផ្នែកភាសា និងទាំងទម្រង់ដែលកុមារអាចយល់និងប្រើប្រាស់បាន, អ្នកបោះពុម្ពផ្សាយ និងអ្នកនៅរោងពុម្ពអាចរកចំណងជើងទាំងនោះបាន, ប្រព័ន្ធចែកចាយសៀវភៅមានដំណើរការល្អ និងការផ្តល់ចំណេះដឹង និងការគាំទ្រសមស្របដើម្បីធានាការប្រើប្រាស់ និងទាក់ទាញឱ្យពលរដ្ឋក្លាយខ្លួនជាអ្នកអានយ៉ាងផុលផុស។ ដំណាក់កាលនីមួយៗមានបញ្ចូល *សេចក្តីសង្ខេប* *ការរកឃើញ* និង*អនុសាសន៍*។ សូមមើលឧបសម្ព័ន្ធទី៤។

## ដំណាក់កាលទី១របស់ SCA ៖ ការធ្វើផែនការ និងការព្យាករណ៍

រូបភាព ២ ៖ ដំណាក់កាលនីមួយៗ, តួអង្គ និងសកម្មភាព, និងការដាច់នៃខ្សែសង្វាក់សៀវភៅនៅកម្ពុជា



ការធ្វើផែនការ និងការព្យាករណ៍គឺវដ្តមួយកើតឡើងដដែលៗដោយរដ្ឋាភិបាល និងអ្នកបោះពុម្ពផ្សាយ ដើម្បីវាយតម្លៃពីភាពចាំបាច់ និងតម្រូវការសៀវភៅ និងរៀបចំធនធានហិរញ្ញវត្ថុ និងសម្ភារៈដើម្បីបំពេញតម្រូវការនោះ។ ដើម្បីធ្វើទៅរួច ក្រសួងអប់រំកម្ពុជាត្រូវការព័ត៌មានទាន់ពេល ហើយមិនត្រឹមតែលើចំនួនសិស្សចុះឈ្មោះចូលរៀនប៉ុណ្ណោះទេ គឺត្រូវការការប៉ាន់ប្រមាណលើការចុះឈ្មោះ និងការប៉ាន់ប្រមាណជាក់ស្តែងនៃការខូចខាតរបស់សៀវភៅទៅតាមពេលវេលាផងដែរ។ អ្នកបោះពុម្ពផ្សាយត្រូវតែរៀបចំផែនការ និងត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការពីក្រសួង និងសាលារៀននានា ក៏ដូចជាពីសំណាក់មាតាបិតាសិស្សដែលអាចទិញសៀវភៅឱ្យកូនអាន។ សម្រាប់ RGC ការប្រមូលការគ្រប់គ្រង ការវិភាគ និងការប្រើប្រាស់ទិន្នន័យទាក់ទងនឹងភាពចាំបាច់នៃសៀវភៅ តម្រូវការ និងការផ្តល់គឺជាផ្នែកសំខាន់មួយនៃការរៀបចំផែនការអប់រំ។ សម្រាប់អ្នកបោះពុម្ពផ្សាយគឺការស្រាវជ្រាវទីផ្សារ។ ទាំងរដ្ឋាភិបាល និងអ្នកបោះពុម្ពផ្សាយ ការប្រមូលទិន្នន័យត្រឹមត្រូវ និងទាន់ពេលវេលាមានសារៈសំខាន់សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅឱ្យមានដំណើរការឥតអាក់។

នៅប្រទេសកម្ពុជា ការកំណត់តម្រូវការនៃការផ្គត់ផ្គង់សៀវភៅត្រូវអនុវត្តដោយ PDH (ពិពណ៌នាលម្អិតក្នុងដំណាក់កាលទី២ ៖ ការអភិវឌ្ឍន៍ចំណងជើង) ហើយស្ថានប័ននេះរាយការណ៍ទិន្នន័យ ទៅនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD) របស់ក្រសួងអប់រំ យុវជន និងកីឡា ហើយបន្ទាប់មកការិយាល័យផែនការ និងចែកផ្សាយ សៀវភៅសិក្សា (OPTD) គណនាការចំណាយ រួមទាំងរាល់ចំណាយសម្រាប់ការផ្គត់ផ្គង់សៀវភៅ យោងទៅតាមថវិកាដែលកំណត់ស្រាប់។ ប្រព័ន្ធពណ៌នាខាងក្រោមបច្ចុប្បន្នផ្តោតទាំងស្រុងលើសៀវភៅសិក្សា ហើយមិនដោះស្រាយ ERMs ទេ។

## ការប៉ាន់ប្រមាណតម្រូវការ

### គោលការណ៍សៀវភៅ

ក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយសៀវភៅអប់រំកុមារតូចសម្រាប់ទាំងកុមារតូច និងកុមារនៅបឋមសិក្សា នេះជាឱកាសត្រួតពិនិត្យឡើងវិញនូវសម្ភារៈឧបទ្ទេស (ឧទាហរណ៍ សៀវភៅលំហាត់សម្រាប់បង្រៀនពីរបៀបសរសេរភាសាខ្មែរ និងលេខ និងអភិវឌ្ឍជំនាញចលករនានា) សម្រាប់មត្តេយ្យសិក្សាតាមសហគមន៍ត្រូវអនុវត្តឱ្យស្របតាមស្តង់ដារកម្មវិធីសិក្សា។ ចាប់តាំងពីពេលនោះមក ការបែងចែកថវិកាសម្រាប់ការផ្គត់ផ្គង់សៀវភៅសិក្សាបានកើនឡើង ៣៣% ពី៤,៨ លានដុល្លារក្នុងឆ្នាំ ២០១១ ដល់៦,៤ លានដុល្លារក្នុងឆ្នាំ ២០២០។

ដោយយល់ពីអត្ថប្រយោជន៍របស់សៀវភៅដើរតួសំខាន់សម្រាប់អក្ខរកម្មកុមារតូច នាយកដ្ឋានបឋមសិក្សា (PED) ថ្មីៗនេះបានស្វែងរក «គំរូកែលម្អការផ្គត់ផ្គង់ និងការប្រើប្រាស់សៀវភៅគោល និងសម្ភារៈឧបទ្ទេសផ្សេងទៀត» ទៅក្នុង

យុទ្ធសាស្ត្រអប់រំបច្ចុប្បន្នរបស់ខ្លួន។ ផែនការមានដូចខាងក្រោម ៖[៥០]

- ប្រមូលទិន្នន័យអំពីការប្រើប្រាស់សៀវភៅសិក្សាគោលតាមមុខវិជ្ជានីមួយៗ។
- អនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសៀវភៅសិក្សាគោល។
- ប្រមូលផ្តុំម្ចាស់ជំនួយដើម្បីផ្គត់ផ្គង់សៀវភៅសិក្សា និងសៀវភៅអានបន្ថែម។
- បែងចែកថវិកាសម្រាប់ទិញសៀវភៅអាន និងសម្ភារៈនានាក្នុងសាលារៀន។
- អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអភិវឌ្ឍន៍ និងផ្គត់ផ្គង់សៀវភៅ។
- រៀបចំកន្លែងអានសៀវភៅ ឬបណ្ណាល័យនៅក្នុងសាលារៀនដែលលើកទឹកចិត្តឱ្យមានការរីករាយក្នុងការអាន។
- ផ្តល់សម្ភារៈបង្រៀន និងសិក្សាឱ្យបាន គ្រប់គ្រាន់ដល់គ្រូ និងសិស្សទាំងអស់ រួមទាំងឧបករណ៍ជំនួយដល់សិស្សដែលមានតម្រូវការពិសេស។
- បង្កើតសម្ភារៈអានបន្ថែម (SRMs) និងលើកទឹកចិត្តលោកគ្រូ-អ្នកគ្រូឱ្យប្រើប្រាស់។
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយស្តីពីកម្មវិធីសិក្សាស្នូលនៅក្នុងសៀវភៅសិស្ស និងសៀវភៅគ្រូនៅឆ្នាំ ២០១៩។

នៅកម្ពុជា សៀវភៅសិក្សាទាំងអស់ត្រូវបានបង្កើតឡើងដោយPDH។ សៀវភៅប្រមាណ ៥,៥លានក្បាលត្រូវបានបោះពុម្ពជារៀងរាល់ឆ្នាំ ដើម្បីជំនួសសៀវភៅដែលខូច ឬបាត់បង់ និងដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃចំនួនសិស្សចុះឈ្មោះចូលរៀន។ សៀវភៅ២លានក្បាលទៀតត្រូវបោះពុម្ពឡើងសម្រាប់ចែកចាយលើទីផ្សារឯកជន (អាណាព្យាបាលសិស្ស ។ល។)។

បច្ចុប្បន្នមានសៀវភៅសិក្សាចំនួន២៧ មុខតម្រូវសម្រាប់សាលារដ្ឋ និងឯកជនក្នុងការបង្រៀនកម្មវិធីសិក្សាបច្ចុប្បន្ន គឺថា៣មុខសម្រាប់ថ្នាក់ទី១-ថ្នាក់ទី៣ និង៥មុខ សម្រាប់ថ្នាក់ទី៤-ទី៦។ សៀវភៅត្រូវបានដឹកជញ្ជូនទៅកាន់សាលារដ្ឋដោយឥតគិតថ្លៃ។

## តារាង៥ ៖ ចំនួនសៀវភៅ ចំណងជើងតាមថ្នាក់ពីទី១-ទី៦ [៥១]

| ចំណងជើង | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| ភាសាខ្មែរ | ✔ | ✔ | ✔ | ✔ | ✔ | ✔ |

*៥០ ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣,៣០។*

*៥១ ព័ត៌មានផ្តល់ដោយ PDH។*

| ចំណងជើង | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| គណិតវិទ្យា | ✔ | ✔ | ✔ | ✔ | ✔ | ✔ |
| វិទ្យាសាស្ត្រ | ✔ | ✔ | ✔ | ✔ | ✔ | ✔ |
| សិក្សាសង្គម | ចូលគ្នា | ចូលគ្នា | ចូលគ្នា | ✔ | ✔ | ✔ |
| ភាសាអង់គ្លេស | ✖ | ✖ | ✖ | ✔ | ✔ | ✔ |
| ចំណងជើង តាមថ្នាក់ | 3 | 3 | 3 | 5 | 5 | 5 |

ការប្រមូលទិន្នន័យនៅលើសៀវភៅសិក្សាគឺស្ថិតនៅលើ DCD និង PHD ដែលមិនធ្វើផ្ទាល់ជាមួយអង្គភាពប្រមូលទិន្នន័យផ្សេងទៀតទេ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តនៃប្រព័ន្ធឌីជីថលដើម្បីតាមដាន និងត្រួតពិនិត្យ (TnT) (ដែលជាប្រព័ន្ធគ្រប់គ្រងការចែកចាយសៀវភៅសិក្សា) នាពេលថ្មីៗនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការប្រមូលទិន្នន័យសម្រាប់ការចែកចាយសៀវភៅសិក្សា។ (ប្រព័ន្ធ TnT នឹងពណ៌នាបន្ថែមទៀតនៅក្នុងដំណាក់កាល ៥ ៖ ការគ្រប់គ្រងការចែកចាយ។ )

នាយកសាលាបញ្ជូនរបាយការណ៍ស្តីពីតម្រូវការរបស់ខ្លួនទៅការិយាល័យអប់រំស្រុក (DOE)។ តម្រូវការទាំងនេះគឺផ្អែកលើការព្យាករណ៍ទុកមុនរយៈពេល២ ឆ្នាំ និងកម្រិតសារពើភ័ណ្ឌមិនជាក់លាក់ដោយសារលោកគ្រូ-អ្នកគ្រូមួយចំនួនមិនហ៊ានរាយការណ៍ពីការបាត់បង់សៀវភៅដែលជាទ្រព្យសម្បត្តិរបស់រដ្ឋនោះឡើយ។ របាយការណ៍ជាលាយលក្ខអក្សរនេះនឹងត្រូវបញ្ជូនទៅការិយាល័យអប់រំខេត្តជាបន្តទៀត។

សាលារៀននីមួយៗមានទំនួលខុសត្រូវក្នុងការផ្គត់ផ្គង់សៀវភៅដល់សិស្សានុសិស្សគ្រប់រូប។ ដូច្នេះ គេត្រូវផ្តល់ទិន្នន័យសមស្របទៅអង្គភាពផែនការ និងចែកចាយរបស់ DCD ។

មិនមានប្រព័ន្ធសម្រាប់ស្នើ ERMs ទេ។ សាលារៀនទទួលបានមូលនិធិសម្រាប់ប្រើប្រាស់តាមតម្រូវការជាក់ស្តែង។ ថវិកាទាំងនេះនឹងត្រូវប្រើប្រាស់សម្រាប់កុមារមិនថាតូចឬធំទេផងដែរ ដោយហេតុថាថវិកានេះមិនបានកំហិតដោយឡែកពីគ្នារវាងសិស្សថ្នាក់ទី១-៦ ទេ។

## ការព្យាករណ៍

ដូចនៅក្នុងការធ្វើផែនការ ការព្យាករណ៍ថវិកាគឺផ្អែកលើតែសៀវភៅសិក្សាក្នុងថ្នាក់ ហើយមិនរួមបញ្ចូល ERMs ទេ។ នៅក្នុងប្រទេសកម្ពុជា ក៏ដូចនៅប្រទេសដទៃទៀតដែរ សំណើថវិការបស់ក្រសួងពាក់ព័ន្ធគឺកម្រនឹងបានដូចនឹងការ

ស្នើសុំណាស់។ ដូច្នេះ MoEYS ត្រូវតែពិចារណាលើសមាមាត្រសៀវភៅសិក្សា និងសិស្សដែលអាចទទួលយកបានសម្រាប់មុខវិជ្ជា និងក្នុងថ្នាក់នីមួយៗ ហើយពិនិត្យឡើងវិញនូវសមាមាត្រនេះបើយោងតាមការបែងចែកថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF)។ តាមលទ្ធភាពដែលអាចធ្វើបាន គេណែនាំថាសមាមាត្រ ១ : ១ សម្រាប់សៀវភៅសិក្សាគ្រប់មុខវិជ្ជាត្រូវបែងចែកទៅឱ្យសិស្សគ្រប់ថ្នាក់។ ការស្រាវជ្រាវនៅទូទាំងប្រទេសបានបង្ហាញថា «ធនធានគរុកោសល្យ ជាពិសេសសៀវភៅសិក្សាមុខវិជ្ជាស្នូលសម្រាប់អំណាន និងគណិតវិទ្យា មានប្រសិទ្ធភាពក្នុងការកែលម្អការរៀនសូត្រជាខ្លាំង។ ការផ្តល់សៀវភៅសិក្សាមួយក្បាលដល់សិស្សម្នាក់ៗក្នុងថ្នាក់រៀនបានបង្កើនអក្ខរភាពពី ៥–២០%»[៥២]។ ក្នុងករណីអវត្តមានសៀវភៅសិស្សនោះ ERMs នៅក្នុងថ្នាក់រៀនអាចជួយពង្រឹងសមត្ថភាពអានរបស់សិស្សានុសិស្សផងដែរ។

ការចំណាយរបស់ក្រសួងអប់រំ យុវជន និងកីឡា លើការផ្គត់ផ្គង់សៀវភៅសិក្សា ដល់សាលារៀន បានកើនឡើង៣៣% ពី ៤,៨ លានដុល្លារក្នុងឆ្នាំ ២០១១ ដល់ ៦,៤ លានដុល្លារនៅឆ្នាំ ២០២០ ក្នុងចំណោមថវិកាអប់រំប៉ាន់ស្មានសរុបប្រមាណ ៨៧៩,២ លានដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០២០ បង្ហាញថាការប៉ាន់ប្រមាណនេះមានកម្រិតទាបគឺ ១,៦៥ ដុល្លារអាមេរិកសម្រាប់សិស្សម្នាក់ៗក្នុងមួយឆ្នាំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា [៥៣] ។ ជាមួយនឹងការថយចុះនៃការចុះឈ្មោះចំនួន៧៣១ ៨៥៦នាក់ (ដោយសារតែការថយចុះប្រជាសាស្ត្រជាជាងការបោះបង់ការសិក្សា) ការកើនឡើងនៃសមាមាត្រសិស្សទៅសៀវភៅទំនងជាបានមកពីការបង្កើនទំហំថវិកា។ គួរតែមានការស្រាវជ្រាវបន្ថែមដើម្បីស្វែងយល់ថាតើនេះយល់ឃើញនេះត្រឹមត្រូវឬយ៉ាងណានោះ។

## ការរកឃើញរបស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍/ ចំណុចខ្លាំង

- គោលដៅសមាមាត្រសៀវភៅ-សិស្ស១:១ សម្រេចបានចំពោះមុខវិជ្ជាមួយចំនួន ហើយស្ទើរតែ១:១សម្រាប់មុខវិជ្ជាដទៃទៀត។ (ក្រសួងអប់រំ យុវជន និងកីឡា មានគោលបំណងផ្តល់សៀវភៅគ្រប់មុខវិជ្ជាដល់សិស្សបឋមសិក្សាឱ្យបាន១០០% ត្រឹមឆ្នាំ ២០២៣។) [៥៤]
- ប្រព័ន្ធតាមដាន និងត្រួតពិនិត្យមានអត្ថប្រយោជន៍ក្នុងការកែលម្អការព្យាករណ៍តម្រូវការ ហើយអាចមានប្រយោជន៍ក្នុងការធ្វើផែនការថវិកានាពេលអនាគត។
- គណ:កម្មាធិការគាំទ្រសាលា (SSCs) មានសារសំខាន់ក្នុងការបញ្ជាក់សៀវភៅនៅក្នុងថ្នាក់រៀន។
- នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ (DEMIS) របស់ក្រសួងអប់រំ យុវជន និងកីឡាទទួលបានសេចក្តីសង្ខេបស្ថិតិ និងសូចនាករអប់រំសាធារណ:រហូតដល់ឆ្នាំ ២០១៩បោះពុម្ពផ្សាយដោយប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS)។

---

*៥២ Fehrler et al., 2009*

*៥៣ ព័ត៌មានផ្តល់ដោយ PDH។*

*៥៤ ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣។*

## ការរកឃើញរបស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍/ ចំណុចខ្សោយ

- ការធ្វើផែនការ និងការព្យាករណ៍គឺផ្តោតតែលើសៀវភៅសិក្សាប៉ុណ្ណោះ ដោយមិនបានរួមបញ្ចូល ERMs ទេ។
- បរិមាណសៀវភៅគឺផ្អែកលើទិន្នន័យចុះឈ្មោះមិនត្រឹមត្រូវ ដែលមិនបានគ្រោងទុកសម្រាប់ករណីកើនឡើងនៃការចុះឈ្មោះឡើយ។
- ទំនួលខុសត្រូវក្នុងការប្រមូលព័ត៌មានអំពីការផ្គត់ផ្គង់សៀវភៅសិក្សាគឺស្ថិតនៅជាមួយនឹង DCD និង PDH ដែលមិនធ្វើការដោយផ្ទាល់ជាមួយអង្គការប្រមូលទិន្នន័យផ្សេងទៀត។ PDH ប្រមូលទិន្នន័យអំពីតម្រូវការបំពេញបន្ថែមក្នុងថ្នាក់នីមួយៗ ហើយបញ្ជូនទៅ MoEYS ដែលជាធម្មតាកាត់បន្ថយចំនួនសៀវភៅដើម្បីតម្រូវនឹងថវិការបស់ខ្លួន (ករណីបែបនេះ លោកគ្រូ-អ្នកគ្រូបន្តប្រើប្រាស់សៀវភៅចាស់ ខណៈពេលដែលអាណាព្យាបាលទិញសៀវភៅថ្មីៗពីទីផ្សារសម្រាប់កូនរៀន)។

## អនុសាសន៍របស់ GBA ៖ ការធ្វើផែនការ និងការព្យាករណ៍

អនុសាសន៍របស់ GBA ៖

- គួរពិនិត្យឡើងវិញនូវអាយុកាលនៃសៀវភៅសិក្សា ដោយហេតុថាការប៉ាន់ស្មានរបស់រដ្ឋាភិបាលពុំទាន់ស្របគ្នានឹងបទពិសោធន៍ជាលក្ខណៈអន្តរជាតិដែលបង្ហាញថាអាយុកាលនៃសៀវភៅសិក្សាក្នុងចន្លោះបីទៅបួនឆ្នាំនោះវាសមរម្យណាស់ទៅហើយ។ ការព្យាករណ៍គួរតែផ្អែកលើអាយុកាលនេះ ជាជាងការប៉ាន់ប្រមាណរហូតដល់ទៅប្រាំឆ្នាំ ដូចពេលបច្ចុប្បន្ន។
- លោកគ្រូ-អ្នកគ្រូ និងនាយកសាលាគួរតែរាយការណ៍ឱ្យបានត្រឹមត្រូវពីចំនួនសៀវភៅបាត់បង់ ដោយមិនត្រូវភ័យខ្លាចពីផលវិបាកឡើយព្រោះថាវាជារឿងធម្មតាទេហើយវារមែងតែកើតមានឡើងចំពោះការចែកចាយសៀវភៅដល់សិស្សនោះ។
- ការធ្វើផែនការ និងការគ្រោងថវិកាត្រូវគិតរួមបញ្ចូលទាំងERMsផង មិនមែនគិតត្រឹមតែសៀវភៅសិក្សាគោលប៉ុណ្ណោះទេ។
- ប្រព័ន្ធប្រមូលទិន្នន័យ ត្រួតពិនិត្យ និងតាមដានគួរប្រើប្រាស់ឱ្យបានទូលំទូលាយក្នុងកិច្ចការរបស់ភាគីពាក់ព័ន្ធ។ ដំបូងឡើយ គម្រោងនេះទទួលបានមូលនិធិពីធនាគារពិភពលោក ដើម្បីជួយសម្រួល និងត្រួតពិនិត្យតម្រូវការថវិកា ការធ្វើលទ្ធកម្ម និងការបញ្ចេញថវិកាពីMoEYS។ MoEYS បាននិងកំពុងដោះស្រាយរាល់ការចំណាយទាក់ទិននឹងដំណើរការប្រព័ន្ធនេះ ហើយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរបស់រដ្ឋ (PDH) បានអនុម័តផ្តល់ហិរញ្ញប្បទានដល់ការបន្តដំណើរការប្រព័ន្ធនេះទៅគ្រប់ខេត្តក្រុង។
- ម្ចាស់ជំនួយទាំងឡាយគួរផ្តល់ការគាំទ្រដល់MoEYS តាមតម្រូវការ និងសម្របសម្រួលក្នុងការផ្តល់ហិរញ្ញប្បទានជាមួយPDHលើការពង្រីកប្រព័ន្ធត្រួតពិនិត្យ និងតាមដាន។ កិច្ចការនេះរួមមានការវាយតម្លៃភ្លាមៗនូវតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីសម្រាប់អនុវត្តន៍ប្រព័ន្ធ និងការព្រាងផែនការសកម្មភាពដោយផ្អែកតាមរបកគំហើញនេះ។

## ដំណាក់កាលទី២របស់ SCA ៖ ការអភិវឌ្ឍចំណងជើង

ការអភិវឌ្ឍចំណងជើង សំដៅលើការបង្កើតអត្ថបទ និងសៀវភៅដែលមានគោលបំណងគាំទ្រដល់ការទទួលបានជំនាញអំណានភាសាដែលកុមារប្រើប្រាស់ និងយល់បាន។ ដំណើរការនៃការអភិវឌ្ឍចំណងជើងចាប់ផ្តើមតាំងពីពេលជ្រើសរើសអ្នកនិពន្ធ (ឬក្នុងករណីខ្លះ តាំងពីពេលជ្រើសរើសសំណៅអត្ថបទពេញលេញដើម្បីបោះពុម្ព) ហើយបន្តរហូតដល់ឯកសារជា PDF ចុងក្រោយនៃសៀវភៅត្រូវបានផ្ញើទៅកាន់រោងពុម្ព។ វាគឺជាដំណើរការដែលទាមទារឱ្យមានអ្នកជំនាញផ្នែកគរុកោសល្យ អ្នកនិពន្ធ អ្នកកែសម្រួល អ្នករចនាទំព័រ វិចិត្រករ អ្នកកែអត្ថបទ អ្នកឯកទេសគុណភាពរូបភាពនិងប្លង់ទំព័រ និងអ្នកជំនាញដទៃទៀត។ មុខងារនៃការអភិវឌ្ឍចំណងជើងសម្រាប់ ERMs អាចត្រូវបានអនុវត្តដោយអ្នកបោះពុម្ពផ្សាយ មិនថារដ្ឋ ឬឯកជន ហើយជារឿយៗ ក្នុងករណីប្រទេសកំពុងអភិវឌ្ឍន៍ ក៏មានការចូលរួមពីម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលយកចិត្តទុកដាក់ផ្តល់សម្ភារៈឧបទ្ទេសទាំងនេះដោយសារសាលាមានភាពខ្វះខាត។

នៅកម្ពុជា ERMs ជាទូទៅបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងមានការចូលរួមពីសំណាក់វិស័យឯកជនផងដែរ ប៉ុន្តែមាននៅក្នុងកម្រិតតិចតួចបំផុត។

## ការតាក់តែងឧបទ្ទេសអំណានចាំបាច់

ក្រោយពីបានជ័យជម្នះពីរបបសាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧៥ ពួកខ្មែរក្រហមចាប់ផ្តើមប្រព្រឹត្តអំពើយង់ឃ្នងដោយដុតបំផ្លាញសៀវភៅចោលទាំងអស់។ លុះពេលដែលវៀតណាម និងរុស្ស៊ីចូលមកក្រោយសង្គ្រាមរលត់ទៅ ទើបអត្ថបទចាប់ផ្តើមវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយឯកសារទាំងនោះសោតទៀតត្រឹមតែជាសំណៅថតចម្លងប៉ុណ្ណោះ។ មហាវិនាសកម្មនៃឧស្សាហកម្មសៀវភៅបន្តអូសបន្លាយរហូតដល់សព្វថ្ងៃនេះ ហើយរដ្ឋាភិបាលប្រឹងជម្នះដោយលំបាក។

នៅក្នុងប្រទេសកម្ពុជា ស្ទើរតែពុំមានក្រុមសៀវភៅអានតាមកម្រិត ឬសៀវភៅរៀនប្រកបឡើយ។ រដ្ឋមិនទាន់ដាក់បញ្ចូលការផ្គត់ផ្គង់ ERMs ជាផ្នែកមួយនៃគោលនយោបាយផ្គត់ផ្គង់សៀវភៅដល់សាលារៀនដោយឥតគិតថ្លៃនៅឡើយ ហើយរដ្ឋក៏មិនកំណត់ថវិកាសម្រាប់ការទិញវាដែរ។ ដូច្នេះទំនួលខុសត្រូវគឺស្ថិតនៅលើអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយក្នុងការផ្តល់សម្ភារៈផ្សេងៗសម្រាប់កុមារនៅកម្រិតបឋមសិក្សា ក្នុងនោះមានទាំងភាសាខ្មែរ ក៏ដូចជាភាសាជនជាតិភាគតិចផងដែរ។ សម្ភារៈជាភាសាអង់គ្លេសក៏មានដែរដោយហេតុថាភាសានេះមានអ្នកចេះអានច្រើន។

បញ្ហាទូទៅពីរក្នុងចំណោមអ្នកផ្គត់ផ្គង់ ERMs គឺកង្វះការសម្របសម្រួលក្នុងចំណោមពួកគេ និងការផ្គត់ផ្គង់មិនទាន់អាចបំពេញតម្រូវការ។ ដូចដែលបានរៀបរាប់ខាងលើរួចមកហើយថា អង្គការមិនមែនរដ្ឋាភិបាលនីមួយៗបំពេញការងារនៅក្នុងមូលដ្ឋានក្នុងតំបន់រៀងៗខ្លួន។ រីឯអាណាព្យាបាលសិស្សជារឿយៗមិនដឹងថាតើមានខ្លះលក់នៅលើទីផ្សារសម្រាប់ពួកគេដែរ។

MoEYS ទទួលស្គាល់សារៈសំខាន់នៃ ERMs ក្នុងការលើកកម្ពស់អក្ខរកម្ម និងគាំទ្រឱ្យមានការផ្សព្វផ្សាយ ប៉ុន្តែគោល

នយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល គឺទុកឱ្យលោកនាយក-នាយិកាសម្រេចចិត្តលើការចំណាយថវិកាប្រតិបត្តិការរបស់សាលា ដែលពួកគេមិនសូវហ៊ានផ្តល់អាទិភាពក្នុងការទិញ ERMs ទេព្រោះថាថវិការបស់ខ្លួនមានកំណត់។

នាយកដ្ឋានអប់រំពិសេស ដែលទទួលបន្ទុកលើវិស័យអប់រំកុមារពិការ (CWD) កំពុងអនុវត្ត *ផែនការសកម្មភាពអប់រំពហុភាសា*ដែលបានកែសម្រួល ដោយផ្អែកលើផែនការសកម្មភាពជាតិអប់រំពហុភាសា (MENAP) របស់ រាជរដ្ឋាភិបាល ដែលត្រូវបានអនុវត្តក្នុងឆ្នាំ ២០១៥ ដោយ MoEYS សហការជាមួយ អង្គការUNICEF Cambodia, អង្គការCARE និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ គោលបំណងសំខាន់គឺដើម្បីធ្វើឱ្យសិស្សានុសិស្សជនជាតិដើមភាគតិចទទួលបានកម្រិតស្មើគ្នា ដោយការបង្រៀនភាសាជនជាតិដើមភាគតិចនៅក្នុងមត្តេយ្យសិក្សា និងបឋមសិក្សាបីឆ្នាំដំបូង ហើយបន្ទាប់មកនឹងមានការផ្លាស់ប្តូរសន្សឹមៗទៅជាភាសាខ្មែរ និងកម្មវិធីសិក្សាជាតិពេលគេចូលថ្នាក់ទី៤ ។

នៅឆ្នាំ២០២០ នាយកដ្ឋានអប់រំពិសេស កៀរគររកជំនួយបច្ចេកទេសដើម្បីពិនិត្យឡើងវិញនូវសៀវភៅសិស្ស សៀវភៅគ្រូបង្រៀន TLMs លើ MLE នៅកម្រិតមត្តេយ្យ និងបឋមសិក្សាក្នុងប្រាំភាសាដែលមានស្រាប់ [៥៥]។ សៀវភៅសិក្សា និង TLMs ជាភាសាចារ៉ាយក៏នឹងត្រូវបង្កើតផងដែរ។

## អ្នកបោះពុម្ពផ្សាយវិស័យឯកជន

មានគ្រឹះស្ថានបោះពុម្ពឯកជនតូចៗនៅកម្ពុជាដែលបោះពុម្ពផ្សាយសៀវភៅកុមារទូទៅ។ ក្នុងចំណោមនោះមានដូចជា ៖

- រីឌីងប៊ុក (Reading Book)
- សង្កប្ប (Saing ka pak)
- ក្រោមដំបូលតែមួយ (Under the Roof)
- បន្ទាយស្រី (Bantay Srey)
- កូមីក អាត (Comic Arts)
- នគរអាន (Nokar an edition)
- ដំរីស (Domrey sor)
- Mango Tree
- ប៊ុកវើល (Book World)
- កូនមាន់ (Koan Moan)
- ហាដឃីត (Heart Kids)

*៥៥ ភាសាទាំងនេះរួមមានភាសាខ្មែរ ភាសាជាតិ និងភាសាផ្លូវការភាសាបារាំង (សហផ្លូវការ) ភាសាវៀតណាម ភាសាចិន និងភាសាចាម (ភាសាជនជាតិភាគតិចដែលមានអ្នកនិយាយច្រើនជាងគេ)។*

ស្ថាប័នបោះពុម្ពផ្សាយនីមួយៗមាចំណងជើងនៅក្នុងបញ្ជីរបស់ខ្លួនរវាងពី ៥ ទៅ៣០។ ចំនួនតិចតួច នៅឡើយក៏ពិតមែនប៉ុន្តែវារីកចម្រើន នេះសឱ្យឃើញថាវិស័យបោះពុម្ពឯកជនដែលត្រូវរងការបំផ្លិចបំផ្លាញចោលគ្មានសល់នោះកំពុងដំណើរការបន្តិចម្តងៗវិញហើយ។ យ៉ាងនេះក្តី សៀវភៅភាគច្រើននៅកម្ពុជានៅតែផលិតដោយអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់ជំនួយ។

## ការអភិវឌ្ឍន៍សៀវភៅដោយអង្គការក្រៅរដ្ឋាភិបាល

ខាងក្រោមនេះជាឈ្មោះអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយជាមួយនឹងសកម្មភាពផ្គត់ផ្គង់ ERM ទៅដល់សាលារៀន និងបណ្ណាល័យ ៖

- គម្រោង All Children Reading-Cambodia (ACR)
- អង្គការរូមធូរីដ
- មូលនិធិអាស៊ី
- កម្មវិធី តោះអាន
- អង្គការស៊ីប៉ា
- វិទ្យាស្ថានបើកទូលាយ
- ប្រភពប្រាជ្ញា (Fount of Wisdom)

### *អង្គការស៊ីប៉ា*

អង្គការស៊ីប៉ាជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលទទួលមូលនិធិពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ(AFD)។ អង្គការនេះមានការិយាល័យតូចមួយនៅក្រុងវែរសៃយ៍ ប្រទេសបារាំង ហើយក៏មានការិយាល័យធំមួយនៅភ្នំពេញ។ អង្គការនេះជាអង្គការមិនមែនរដ្ឋាភិបាលដំបូងគេដែលចាប់ដៃគូជាផ្លូវការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដទៃទៀត។ អង្គការស៊ីប៉ាបោះពុម្ពសៀវភៅកុមារជាភាសាខ្មែរ (និងបកប្រែអក្សរសិល្ប៍បរទេសទៅជាភាសាខ្មែរ) និងគេអាចរកសៀវភៅទាំងនេះមកអាននៅតាមបណ្ណាល័យចល័ត និងបណ្ណាល័យសាលារៀន អង្គការមិនមែនរដ្ឋាភិបាល និងនៅបណ្ណាគារនានា។ គោលដៅរបស់ស៊ីប៉ាគឺដើម្បីបង្កើតគម្រោងប្រកបដោយនិរន្តរភាព ហើយផ្ទេរគម្រោងទាំងនោះឱ្យទៅស្ថាប័នរដ្ឋ និងឯកជន ផ្តល់មូលនិធិ និងគ្រប់គ្រងបន្ត។ ជាអាទិ៍ មានបណ្ណាល័យតាមសាលារៀនចំនួន៣០០ ដែលអង្គការនេះបានបង្កើតឡើង ហើយបន្ទាប់មកត្រូវបានប្រគល់ជូនទៅក្រសួងអប់រំ។ បណ្ណាល័យទាំងនេះត្រូវបានបញ្ចូលជាសម្បត្តិរបស់ក្រសួងអប់រំ ៨០%នៃបណ្ណាល័យទាំងនោះទទួលបានការថែទាំពីសាលារៀនចាប់តាំងពីការផ្ទេរមកម្ល៉េះ។ ស៊ីប៉ានៅតែជាដៃគូមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរួមចំណែកក្នុងយុទ្ធសាស្ត្រជាតិ និងការបណ្តុះបណ្តាលទាក់ទងនឹងការអភិវឌ្ឍបណ្ណាល័យ និងលើក

កម្ពស់សមត្ថភាពដល់បណ្ណារក្ស។

ស៊ីប៉ាផ្តល់ការអប់រំក្រៅប្រព័ន្ធតាមរយៈបណ្ណាល័យចល័តតាមសហគមន៍ ក៏ដូចជាបណ្ណាល័យនៅក្នុង ពន្ធនាគារ ដែលការអប់រំអក្ខរកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិត។ ដោយធ្វើការជាមួយសហគ្រាសឯកជន អង្គការនេះក៏បានពង្រីកបណ្ណាល័យទៅក្នុងរោងចក្រកាត់ដេរតាមបណ្តាខេត្តមួយចំនួនផងដែរ។

ក្នុងនាមជាអ្នកបោះពុម្ពផ្សាយ ស៊ីប៉ាជ្រើសរើសអ្នកនិពន្ធ អ្នកត្រួតពិនិត្យ អ្នកបកប្រែ អ្នករចនារូបភាព និងក្រុមទីផ្សារផ្ទាល់ខ្លួនដែលសុទ្ធសឹងតែជាជនជាតិខ្មែរ។ ប្រាក់ចំណូលដែលបានមកពីការលក់សៀវភៅឱ្យទៅបណ្ណាគារ បានរួមចំណែកបន្ថែមធនធានដល់អង្គការ ពីលើជំនួយខាងក្រៅ។ ស៊ីប៉ាបានបោះពុម្ពសៀវភៅជាង ២០០ចំណងជើង និងលក់បាន ២,៥លានច្បាប់ចាប់តាំងពីឆ្នាំ ២០០០មក។ ជាង៥០%នៃសៀវភៅខ្លួន គឺសម្រាប់កុមារកម្រិតបឋមសិក្សា។ នៅឆ្នាំ២០២០ ស៊ីប៉ាបានបោះពុម្ពសៀវភៅថ្មី១៥ចំណងជើង និងបោះពុម្ពឡើងវិញចំនួន៩១មុខ។ ក្នុងការសរសេរអត្ថបទរឿងសម្រាប់កុមារបឋមសិក្សា អ្នកនិពន្ធអាចទទួលបានកម្រៃក្នុងលក្ខណៈជាការបង់កម្មសិទ្ធិបញ្ញារបស់ខ្លួនជាភាគរយ ឬការបង់ផ្តាច់ ដោយចាប់ពី១០០ដុល្លាក្នុងមួយរឿង។

តាមរយៈសិក្ខាសាលា អង្គការស៊ីប៉ាបានបណ្តុះបណ្តាលអ្នកនិពន្ធចំនួន ១៣៨ នាក់អំពីបច្ចេកទេសសរសេរសៀវភៅលើប្រធានបទជាច្រើនដែលទាក់ទងនឹងការអភិវឌ្ឍសៀវភៅរបស់កុមារ។ ហើយក៏មានការបណ្តុះបណ្តាលសម្រាប់អ្នករចនារូបភាពផងដែរ។

## *អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)*

បច្ចុប្បន្ននេះអង្គការ ខេប (KAPE) ផ្តល់ជូននូវកម្មវិធីចំនួនបួនសម្រាប់ អភិវឌ្ឍន៍ ERMs រួមមានគម្រោង សៀវភៅសម្រាប់កម្ពុជា, ធនធានអប់រំ, ការអភិវឌ្ឍកម្មវិធីAPP សម្រាប់អំណាន និងការអភិវឌ្ឍន៍បណ្ណាល័យសតវត្សទី២១។

គម្រោងសៀវភៅសម្រាប់កម្ពុជា (BfC) បង្កើតឡើងដោយមូលនិធិអាស៊ី និងអនុវត្តដោយអង្គការខេប គម្រោងនេះចែកផ្សាយសៀវភៅភាសាអង់គ្លេសដែលមានគុណភាពខ្ពស់សម្រាប់កម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ ឥឡូវកម្មវិធីនេះទទួលបានការឧបត្ថម្ភមួយផ្នែកដោយក្រសួងអប់រំ យុវជន និងកីឡា ហើយរហូតមកដល់បច្ចុប្បន្ន មានសៀវភៅជាភាសាអង់គ្លេសចំនួន ៦០០០០ក្បាល (ជាអំណោយពីអ្នកបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិក) ត្រូវបានចែកចាយតាមរយៈបណ្តាញ BfC ភាគច្រើនដល់សាលាបឋមសិក្សា និងមធ្យមសិក្សា។

ធនធានអប់រំ (TTO) គឺជាសហគ្រាសសង្គមដែល អង្គការខេប រៀបចំឡើងដើម្បីផលិតសម្ភារៈឧបទ្ទេសជាជំនួយដល់ការបង្រៀន និងការសិក្សា ជាពិសេសឧបករណ៍ប្រើប្រាស់ក្នុងការបង្រៀនអំណាន។ ក្នុងមួយឆ្នាំៗគេ លក់ហ្គេមអប់រំ និងសម្ភារៈសម្រាប់អក្ខរកម្ម និងគណិតវិទ្យាបានចន្លោះពី ១៥០.០០០ដុល្លារទៅ ២០០.០០០ ដុល្លារអាមេរិកដល់សាធារណជន។ សម្ភារៈឧបទ្ទេសទាំងនោះផលិតឡើងដោយអនុលោមទៅតាមកម្មវិធីសិក្សាជាតិ។

ជាទូទៅអង្គការខេបប្រឹងប្រែងរចនាអត្ថបទតាមកម្រិតថ្នាក់ដើម្បីបោះពុម្ពផ្សាយម្តងម្កាលតាមតម្រូវការចាំបាច់តែប៉ុណ្ណោះ។ ដោយទទួលបានមូលនិធិពីអង្គការមូលនិធិកុមារ (Child Fund) អង្គការខេប បានបង្កើតកម្មវិធីមួយដែលអាចវិភាគអត្ថបទជាខេមរភាសា និងផ្តល់ការយល់ដឹងអំពីភាពស្មុគស្មាញរបស់វាដោយប្រើរង្វាស់រង្វាល់ ដូចជាព្យាង្គ ឬពាក្យក្នុងមួយប្រយោគ។ អង្គការខេប រំពឹងថាកម្មវិធីនេះអាចយកទៅប្រើប្រាស់ដើម្បីបង្កើតអត្ថបទតាមកម្រិតនានាដោយប្រើការវិភាគជាក់ស្តែង។

អង្គការខេបបាននិងកំពុងបង្កើនការយកចិត្តទុកដាក់វិនិយោគធ្វើទំនើបកម្មបណ្ណាល័យ ដើម្បីបង្កើនលទ្ធភាពទទួលបានសៀវភៅ និងកម្មវិធីអប់រំនានា តាមរយៈកម្មវិធី*បណ្ណាល័យសតវត្សទី២១*របស់ខ្លួន។ កិច្ចអន្តរាគមន៍នេះត្រូវរួមបញ្ចូលទៅក្នុងគម្រោងជាច្រើនក្នុងធ្លុងតែមួយ រួមមានសាលាជំនាន់ថ្មី (NGS) [៥៦] ជាកម្មវិធីកំណែទម្រង់មួយដែលផ្តល់មូលនិធិដោយ MoEYS ហើយបានចាប់ផ្តើមនៅឆ្នាំ២០១៥ ដើម្បីរៀបចំសិស្សឱ្យកាន់តែប្រសើរឡើងសម្រាប់កម្លាំងពលកម្មនៅសតវត្សរ៍ទី២១។ កំណែទម្រង់នេះមានគោលបំណងអភិវឌ្ឍសមត្ថភាព និងភាពវាងវៃរបស់សិស្ស ជាពិសេសផ្តោតលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (ICT) និងជំនាញការគិតដោយវិភាគ ក៏ដូចជាសមត្ថភាពយល់ដឹងពីខ្លួនឯង និងយល់ដឹងពីអ្នកដទៃផងដែរ។ គិតត្រឹមឆ្នាំ២០១៨ កំណែទម្រង់បានដំណើរការនៅក្នុងសាលាជំនាន់ថ្មីចំនួន១០នៅទូទាំងប្រទេស ដោយផ្តល់សេវាដល់សិស្សានុសិស្សជាង៤.០០០នាក់។ MoEYS វិនិយោគលើការអភិវឌ្ឍន៍បណ្ណាល័យទាំងអនឡាញ (លើអិនធឺណិត) និងអុហ្វឡាញ (ក្រៅអិនធឺណិត) រួមមានកម្មវិធីអប់រំដែលផ្តល់លទ្ធភាពឱ្យសិស្សរកសៀវភៅអានបានរាប់រយក្បាល នោះរួមទាំងកម្មវិធី «តោះអាន» (Let's Read) របស់មូលនិធិអាស៊ីផង។

### *អង្គការ RTI ក្នុងគម្រោង All Children Reading-Cambodia*

គម្រោង All Children Reading-Cambodia គឺជាកម្មវិធីគាំទ្រភាសាខ្មែរថ្នាក់ដំបូងមួយដែលដំណើរការឡើងដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដោយទទួលបានជំនួយឧបត្ថម្ភពី USAID។ កម្មវិធីនេះអនុវត្តដោយ RTI International និងមានការចូលរួមពីបុគ្គលិក និងអ្នកប្រឹក្សាឯករាជ្យ ព្រមទាំងអង្គការដៃគូរួមមានអង្គការរូមធូរីដ, អង្គការសង្គ្រោះកុមារ (Save the Children), អង្គការយូណេស្កូ, អង្គការទស្សនៈពិភពលោក និងអង្គការអប់រំពិភពលោក (World Education)។ កម្មវិធីនេះគឺជាឧទាហរណ៍ដ៏ល្អពីកិច្ចសហការដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវការ។

---

*៥៦ អង្គការខេប "យើងធ្វើអ្វីខ្លះ៖ ភាពជោគជ័យ និងនិរន្តរភាព" https://link.springer.com/chapter/10.1007/978-981-15-2137-9_6; http://www.kapekh.org/en/what-we-do/4/*

ជាមួយនឹងគោលបំណងកែលម្អអំណានរបស់កុមារនៅថ្នាក់ទី១-៣ កម្មវិធីនេះបានណែនាំឧបករណ៍ច្នៃប្រឌិត ERM ដោយហៅវាថាសៀវភៅជំនួយសិស្ស (SSB) ដែលរៀបចំឡើងមានផ្នែកប្រកបអក្សរដើម្បីបំពេញបន្ថែមលើសៀវភៅអាន។ ដោយផ្តោតលើភាសាខ្មែរ និងគណិតវិទ្យា SSBs ប្រើប្រាស់វិធីសាស្ត្រគរុកោសល្យទំនើប និងសាមញ្ញ ដោយផ្អែកលើគំរូដដែលៗដែលពង្រឹងការអាន និងការសរសេរ។ សម្ភារៈទាំងនេះតាក់តែងឡើងឱ្យសមស្រប និងបំពេញបន្ថែមទៅនឹងសៀវភៅសិក្សាគោលរបស់សិស្ស និងកម្មវិធីសិក្សាក្នុងថ្នាក់ ដែលលោកគ្រូ-អ្នកគ្រូប្រើសម្រាប់ណែនាំមេរៀនប្រចាំថ្ងៃរបស់ពួកគេ។ កម្មវិធីនេះបានបង្កើតសៀវភៅចំនួន ៣០ក្បាល ដែលរួមមានសៀវភៅណែនាំសម្រាប់គ្រូ និង សៀវភៅជំនួយសិស្ស។ កញ្ចប់សម្ភារៈទាំងនេះត្រូវបានផ្គត់ផ្គង់ដល់ថ្នាក់ទី១នៃសាលាបឋមសិក្សាទាំងអស់ក្នុងខេត្តចំនួនប្រាំពីរ មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) ផ្គត់ផ្គង់ក្នុងខេត្តចំនួនប្រាំ និង USAID ផ្តល់ទៅខេត្តចំនួនពីរ។ ក្នុងឆ្នាំ២០២១ មានការផ្គត់ផ្គង់ដល់ថ្នាក់ទី២ ជាមួយនឹងផែនការពង្រីកនៅក្នុងស្រុក១២បន្ថែមទៀត។ បច្ចុប្បន្ន អង្គការ RTI កំពុងសាកល្បងគណិតវិទ្យានៅថ្នាក់ទី១ នៅគ្រប់ស្រុកទាំងអស់នៃខេត្តសៀមរាប ហើយអង្គការ UNESCO សាកល្បងលើសិស្សថ្នាក់ទី២ នៅក្នុងស្រុកចំនួនពីរ។

ក្នុងមួយឆ្នាំៗគេបោះពុម្ពសៀវភៅសម្រាប់ថ្នាក់ទី១ និងទី២ ហើយថ្នាក់នីមួយៗទទួលបានសៀវភៅចំនួន១៤០.០០០ក្បាល។ ការបោះពុម្ពត្រូវបានធ្វើឡើងដោយសំណើដេញថ្លៃបិទជិត ដោយប្រើឡូត៍ដាច់ដោយឡែកពីគ្នាដែលអាចផ្តល់ជាឱកាសដល់រោងពុម្ពមួយចំនួននៅក្នុងប្រទេស។ RTI ក៏បើកឱ្យមានការដេញថ្លៃសម្រាប់អង្គការផ្សេងទៀតដើម្បីបោះពុម្ពសៀវភៅក្នុងបរិមាណច្រើនក្នុងតម្លៃសមរម្យ។

ការផ្តល់មូលនិធិសម្រាប់កម្មវិធីនឹងជាបន្ទុកលើក្រសួងអប់រំ យុវជន និងកីឡា នៅពេលកម្មវិធី RTI បិទបញ្ចប់។ ក្រសួងអប់រំ យុវជន និងកីឡា មានផែនការប្រើប្រាស់ថវិកាកម្មវិធីរបស់រដ្ឋាភិបាលសម្រាប់សាលារៀនដើម្បីផ្តល់កញ្ចប់អំណានកម្រិតថ្នាក់ដំបូង (EGR) ដល់សាលារៀនជាបន្តទៀត។ ដោយសារមូលនិធិពីរដ្ឋាភិបាលមានកំណត់ ដោយសារតែជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានគម្រោងស្នើសុំមាតាបិតាសិស្សដែលមានលទ្ធភាពផ្នែកហិរញ្ញវត្ថុ ទិញសម្ភារៈសម្រាប់កូនរបស់ខ្លួន។ ជាមួយនឹងអាជ្ញាប័ណ្ណ CC ក្រសួងអនុញ្ញាតឱ្យ វិស័យឯកជន និងទីផ្សារអាចបោះពុម្ព និងលក់សម្ភារៈនៅលើទីផ្សារបាន។ យ៉ាងណាក៏ដោយ ក្រសួងអប់រំ យុវជន និងកីឡា នឹងផ្តល់សម្ភារៈដោយឥតគិតថ្លៃដល់កុមារក្រីក្រ។ គិតត្រឹមខែកក្កដា ឆ្នាំ២០២១ ACR-Cambodia កំពុងធ្វើការលើការផ្ទេរហ្វាល់ឯកសារសម្រាប់បោះពុម្ពទៅ ក្រសួងអប់រំ យុវជន និងកីឡា ។

នៅពេលសរសេររបាយការណ៍នេះ អង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលធ្វើការលើ EGR ដូចជា អង្គការអប់រំពិភពលោក, អង្គការរូមធូរីដ, អង្គការសង្គ្រោះកុមារ និង អង្គការទស្សនពិភពលោកកំពុងប្រើប្រាស់កញ្ចប់ EGR ថ្មីនៅក្នុងសាលាគោលដៅរបស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលយក និងឥស្ស៊ូមតិពេញទំហឹងដល់អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ឱ្យគាំទ្រដល់ការដាក់ឱ្យប្រើប្រាស់កញ្ចប់សម្ភារៈនេះទូទាំងប្រទេស។ ទីភ្នាក់ងារជំនួយអាមេរិក USAID កម្ពុជាបានប្តេជ្ញាចិត្តគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រីកកម្មវិធីនេះទៅកាន់ខេត្តផ្សេងៗទៀតក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

បន្ថែមលើការពង្រីកនេះ កម្មវិធីនឹងសម្រួលឱ្យមានការចូលរួមធនធានក្នុងស្រុកពី RGC និង DP និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូដទៃទៀតផង។

ដើម្បីឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ ACR-Cambodia បានកែសម្រួលកិច្ចអន្តរាគមន៍របស់ខ្លួនដូចខាងក្រោម ៖

- បានបង្កើតខ្លឹមសារសិក្សាតាមអិនធឺណិត និងសម្ភារៈអប់រំពីចម្ងាយដែលត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធបណ្ដាញសង្គម និងវេទិកាផ្សេងទៀត ដើម្បីគាំទ្រដល់លោកគ្រូ-អ្នកគ្រូ មាតាបិតា និងសិស្សនៅថ្នាក់មត្តេយ្យកម្រិតខ្ពស់រហូតដល់ថ្នាក់ទី២ ក្នុងសកម្មភាពអំណាន និងសិក្សាប្រចាំថ្ងៃ។
- បានបង្កើត និងផ្សព្វផ្សាយកញ្ចប់សម្ភារៈEGRរៀនតាមផ្ទះ ដល់កុមារប្រមាណ ១៥០.០០០ នាក់នៅក្នុងខេត្តចំនួនបី។ USAID បានឧបត្ថម្ភកញ្ចប់សិក្សាតាមផ្ទះសម្រាប់សិស្សថ្នាក់ទី ១ និងថ្នាក់ទី២ទូទាំងប្រទេស។
- បានបង្វែរការបណ្ដុះបណ្ដាលគ្រូបង្រៀនផ្ទាល់ទៅជាការបណ្ដុះបណ្ដាលនិម្មិតដោយប្រើវីដេអូ និងការផ្ញើសារសម្រាប់អ្នកគ្រូមត្តេយ្យកម្រិតខ្ពស់ លោកគ្រូ-អ្នកគ្រូថ្នាក់ទី១ និងថ្នាក់ទី២ ទាំងអស់នៅក្នុងខេត្តចំនួនបី។

ដោយមានកិច្ចសហការជាមួយអង្គការយូនីសេហ្វ USAID ក៏បានចូលរួមចំណែកផ្ដល់សម្ភារៈអនាម័យសំខាន់ៗ រួមទាំងសាប៊ូ និងទឹកលាងដៃ ឧបករណ៍វាស់កម្ដៅ និងប័ណ្ណព័ត៌មាន សម្ភារៈអប់រំ និងទំនាក់ទំនង (IEC) ដល់សាលារៀនទាំងអស់ក្នុងប្រទេសកម្ពុជា។

ACR-Cambodia បានបង្កើត និងចែកចាយកញ្ចប់អំណានកម្រិតថ្នាក់ដំបូង (EGR) សម្រាប់រៀនតាមផ្ទះដើម្បីគាំទ្រដល់សិស្សានុសិស្ស និងមាតាបិតាសិស្សក្នុងអំឡុងពេលបិទសាលា។ កញ្ចប់សិក្សាតាមផ្ទះ រួមនឹងសម្ភារៈ EGR កំពុងត្រូវបានចែកចាយដល់កុមារទាំងអស់ក្នុង២៥ រាជធានីខេត្តទូទាំងប្រទេសកម្ពុជា ក្រោមមូលនិធិភាពជាដៃគូដើម្បី អភិវឌ្ឍន៍សមត្ថភាពដំណាក់កាលទី III (CDPF ដំណាក់កាលទី III) ដែលជាយន្តការផ្ដល់មូលនិធិពីម្ចាស់ជំនួយជាច្រើន រួមទាំងសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (ស៊ីដា ស៊ុយអែត) USAID GPE និងអង្គការយូនីសេហ្វ។ ACR-Cambodiaផ្ដល់វគ្គបណ្ដុះបណ្ដាលតម្រង់ទិសខ្លីៗសម្រាប់កញ្ចប់សិក្សាតាមផ្ទះដល់លោកគ្រូ-អ្នកគ្រូថ្នាក់ទី១ និងថ្នាក់ទី២ប្រមាណ២១.០០០នាក់ និងដល់នាយក-នាយិកាសាលាបឋមសិក្សារដ្ឋទាំងអស់ចំនួន៧.៣០៣នាក់ទូទាំងប្រទេសកម្ពុជា។ ដើម្បីគាំទ្រដល់ការអនុវត្តកញ្ចប់សិក្សាតាមផ្ទះទូទាំងប្រទេស ដល់គ្រូបង្រៀន និងនាយកសាលាថ្នាក់ទី១ និងទី ២ ប្រមាណ ២១,០០០ នាក់ និងនាយកសាលានៅបឋមសិក្សាសាធារណៈចំនួន ៧,៣០៣ នាក់។

### *អង្គការរូមធូរីដ (Room to Read)*

អង្គការរូមធូរីដ (RtR) កម្ពុជាជាដៃគូមួយក្នុងចំណោមដៃគូសំខាន់ៗទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់គុណភាពអប់រំ។ អង្គការនេះសហការយ៉ាងស្អិតរមួតជាមួយដៃគូទាំងឡាយក្នុងវិស័យ ERMs សម្រាប់ថ្នាក់ទី១ដល់ថ្នាក់ទី៦ ដោយគិតអត្រាថេរដល់អ្នកនិពន្ធប្រមាណ៨០ដុល្លារទៅ ១០០ ដុល្លារក្នុងសៀវភៅមួយរឿង។ រៀងរាល់ឆ្នាំ RtRផលិតប្រហែល១៥-២០ចំណងជើង សរុបទៅគេបង្កើតបានជាង២៩០ចំណងជើងហើយ។ អង្គការនេះក៏ទិញ

សៀវភៅពីអ្នកបោះពុម្ពផ្សាយ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ដោយជ្រើសរើសសៀវភៅផ្អែកលើគុណភាព និងតម្លៃ។ ក្នុងចំណោមប្រមាណសៀវភៅជិត១០០០ចំណងជើងសម្រាប់ថ្នាក់បឋមសិក្សានៅលើទីផ្សារ RtR ជ្រើសរើសយកប្រហែល ៦០% ប៉ុណ្ណោះដែលមានខ្លឹមសារសមល្មម ក្រៅពីនោះប្រធានបទមានភាពមិនសមស្រប និងពិបាកប្រើប្រាស់នៅក្នុងសាលារៀន។

RtR ជាម្ចាស់កម្មសិទ្ធិបញ្ញានៃសម្ភារៈរបស់ខ្លួន ប៉ុន្តែក្នុងនាមជាអង្គការសប្បុរសធម៌ គឺគេមិនអាចលក់សៀវភៅទៅសាលារៀន ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតបានទេ។ អង្គការនេះរមែងផ្គត់ផ្គង់សៀវភៅដល់បណ្ណាល័យតាមសាលានានា ដោយមិនគិតថ្លៃ។ RtR នៅបន្តផ្តល់ជូនកម្មវិធីបណ្តុះបណ្តាល ដោយថ្មីៗនេះបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយរយៈពេលប្រាំថ្ងៃ និងកំពុងរៀបចំសិក្ខាសាលាមួយផ្សេងទៀតលើការបោះពុម្ពសៀវភៅឯកសារ ERMs។ RtR នៅតែជាអង្គការរួមចំណែកដ៏ខ្លាំងក្លាក្នុងការផ្តល់ថវិកាផលិត ERMs សម្រាប់សាលារៀន និងការកែលម្អវប្បធម៌អានតាមរយៈការចូលរួមរបស់លោកគ្រូ-អ្នកគ្រូ និងបណ្ណារក្ស។

## *អង្គការមូលនិធិអាស៊ី៖ គម្រោងតោះអាន*

គម្រោង តោះអាន (Let's Read) របស់មូលនិធិអាស៊ីបង្កើតឡើងនៅក្នុងឆ្នាំ២០១៧ ហើយផ្តល់វគ្គបណ្តុះបណ្តាលបីប្រភេទដើម្បីបង្កើតសម្ភារៈអំណានសម្រាប់កុមារ ៖

- Bookathons – សិក្ខាសាលារយៈពេលពីរថ្ងៃដែលសរសេរសៀវភៅដើមដោយអ្នកនិពន្ធខ្មែរ។
- សិក្ខាសាលាបកប្រែ – រយៈពេលពីមួយទៅពីរថ្ងៃ ដោយមាននិស្សិតមហាវិទ្យាល័យ និងអ្នកបកប្រែភាសាចូលរួមបកប្រែសៀវភៅពីភាសាបរទេសទៅជាភាសាខ្មែរ ហើយនឹងត្រូវកែសម្រួលដោយអ្នកជំនាញ រួចបង្ហោះនៅលើវេទិកាតោះអាន។
- Book Labs – កម្មវិធីដែលរៀនពេញក្នុងរយៈពេលប្រាំពីរខែដើម្បីកសាងសមត្ថភាពអ្នកនិពន្ធ និងអ្នករចនារូបភាពសម្រាប់សៀវភៅកុមារ និងសៀវភៅរឿង តាមរយៈការសរសេរសៀវភៅជាភាសាខ្មែរថ្មីចំនួន ១០ចំណងជើង។

អ្នកទទួលផលចូលរួមសិក្ខាសាលា ក្រោមការបណ្តុះបណ្តាលពីអ្នកជំនាញវិជ្ជាជីវៈអន្តរជាតិ។ សិក្ខាកាមរៀនពីដំណើរការបោះពុម្ពទាំងមូល តាំងពីនៅជាគំនិត (concept) រហូតដល់ការបោះពុម្ពចេញជាសៀវភៅ។ សៀវភៅដែលបានបញ្ចប់រួច ទទួលបានអាជ្ញាប័ណ្ណ Creative Commons (CC) ហើយបោះពុម្ពផ្សាយ និងផ្ទុកនៅលើវេបសាយ តោះអាន សម្រាប់ការផ្សព្វផ្សាយជាទម្រង់សៀវភៅអេឡិចត្រូនិច។ អ្នកនិពន្ធ និងអ្នករចនារូបភាពទទួលបានប្រាក់កម្រៃចំនួន ១៥០ ដុល្លារអាមេរិក និង ២០០ ដុល្លារអាមេរិកក្នុងម្នាក់ៗ ខណៈពេលដែលអ្នកត្រួតពិនិត្យនិងកែសម្រួលទទួលបានប្រាក់ចំនួន២០០ ដល់២៥០ដុល្លារអាមេរិកសម្រាប់ការកែសម្រួលសៀវភៅពីរក្បាល។ គម្រោងនេះផ្តល់សេវាដោយអ្នកនិពន្ធ និងអ្នករចនារូបភាពចំនួន២០០ នាក់ ហើយពួកគេតាក់តែងបានសៀវភៅ២០០ចំណងជើង (សៀវភៅដើម ៧០-១០០ក្បាល រួមទាំងចំណងជើងបកប្រែពីភាសាបរទេសប្រហែល ២០០ទៀត)។

## *អង្គការឃែរ* (CARE)

ជាងមួយទសវត្សរ៍កន្លងមកនេះ អង្គការឃែរ បានផលិតសៀវភៅច្រើនភាសាជាង ៩០ ចំណងជើងសម្រាប់ថ្នាក់ទី ១-៣ សម្រាប់កម្មវិធីអប់រំភាសាចម្រុះរបស់ MoEYS។ សៀវភៅទាំងនោះត្រូវបានពិនិត្យ និងអនុម័តជាផ្លូវការ។ បច្ចុប្បន្នអង្គការឃែរពុំមានអនុវត្តកម្មវិធីពាក់ព័ន្ធនឹង ឬព្យាករណ៍អំពីសៀវភៅក្នុងប្រទេសកម្ពុជាទៀតទេ។

## *វិទ្យាស្ថានបើកទូលាយ* (Open Institute)

វិទ្យាស្ថានបើកទូលាយ (OI) បានធ្វើការលើផ្នែក ICT សម្រាប់ការអប់រំរយៈពេល ១២ ឆ្នាំ ហើយបានចាត់ទុកការងាររបស់ខ្លួនជាការបំពេញបន្ថែមទៅលើកិច្ចការរបស់អង្គការដទៃទៀត។ ខណៈអង្គការនានាផ្តោតលើអំណាន ដោយឡែកវិទ្យាស្ថានបើកទូលាយផ្តោតលើការសរសេរជាមូលដ្ឋានគ្រឹះរបស់អំណាន។ វិទ្យាស្ថានបានបង្កើតកម្រងសៀវភៅចំនួនពីរសម្រាប់បង្រៀនការសរសេរភាសាខ្មែរ និងរៀនលេខ ជាមូលដ្ឋានសម្រាប់មត្តេយ្យ ក៏ដូចជាកម្មវិធីនានាក្នុងរូបភាពជាសម្ភារៈឧបទ្ទេសនិងសៀវភៅសិស្សថ្នាក់ទី១ និងថ្នាក់ទី២។ វិទ្យាស្ថានកំពុងផលិតសៀវភៅលំហាត់ចំនួន១២ ក្នុងនោះសៀវភៅរៀនភាសាខ្មែរចំនួន៦ សៀវភៅរៀនលេខសម្រាប់មត្តេយ្យសិក្សាចំនួន២ និងសៀវភៅអភិវឌ្ឍចលនាជំនាញសរសេរចំនួន៤។ សៀវភៅលំហាត់ទាំងនេះបង្កើតឡើងដោយអនុលោមតាមកម្មវិធីសិក្សារបស់មត្តេយ្យសិក្សា ហើយត្រូវភ្ជាប់ជាមួយនាយកដ្ឋានអប់រំកុមារតូច និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា។ វិទ្យាស្ថានកំពុងរង់ចាំការយល់ព្រមពី MoEYS សម្រាប់ការប្រើប្រាស់ក្នុងថ្នាក់រៀន។ បច្ចុប្បន្នពុំទាន់មានសម្ភារៈណាមួយដែលទទួលបានការយល់ព្រមពីក្រសួងសម្រាប់ក្មេងៗនៅមត្តេយ្យសិក្សាទេ ដូច្នេះកម្រងសៀវភៅ *កូនស្វាឆ្លាត* របស់វិទ្យាស្ថានបើកទូលាយ នឹងក្លាយជាសម្ភារៈដំបូងគេលើគេហទំព័ររបស់ក្រសួងអប់រំ និងនៅតាមបណ្ណាគារនានាក្នុងប្រទេស។ មាតាបិតាសិស្សអាចទាញឯកសារចេញពីវេបសាយដើម្បីបោះពុម្ពដោយខ្លួនឯង ឬទិញនៅតាមបណ្ណាគារសម្រាប់កូនៗរបស់ខ្លួនដែលរៀននៅមត្តេយ្យសាលា។

វិទ្យាស្ថានបើកទូលាយក៏កំពុងធ្វើការជាមួយនាយកដ្ឋានបឋមសិក្សា (PED) ដើម្បីបង្កើតសៀវភៅស្រដៀងនឹងសៀវភៅកូនស្វាឆ្លាត សម្រាប់ថ្នាក់ទី១។ ក្រោមគម្រោងថវិកាពីអង្គការ UNESCO ក្នុងកម្មវិធីពង្រឹងសមត្ថភាពគ្រូបង្រៀននៅកម្ពុជា (STEPCam) វិទ្យាស្ថានបើកទូលាយបានសហការជាមួយ PED ដើម្បីបង្កើតសៀវភៅលំហាត់អនុវត្ត (SSB) និងសៀវភៅគ្រូសម្រាប់គណិតវិទ្យាថ្នាក់ទី១ និងថ្នាក់ទី២ ក្នុងបំណងបន្ថែមសៀវភៅលំហាត់អនុវត្ត *កូនស្វាឆ្លាត*។

## *បណ្ណាល័យអង្គការសៀវភៅបើកទូលាយ* (Open Book)

សៀវភៅបើកទូលាយ (Open Book) ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយរបស់កម្ពុជា ដែលបើកបណ្ណាល័យសាធារណៈ និងបណ្ណាគារមួយនៅផ្លូវ ២៤០ និងមានបណ្ណាល័យជាច្រើនក្នុងរាជធានីភ្នំពេញ និងខេត្តចំនួនពីរ។ ការ

បោះពុម្ពផ្សាយរបស់ខ្លួនមានសៀវភៅកុមារជាភាសាខ្មែរ ភាសាបារាំង ភាសាអង់គ្លេស និងភាសាចិន ដោយលក់សៀវភៅតាមបណ្ណាគារខ្លួនផ្ទាល់ លក់ឱ្យអង្គការនានា និងលក់នៅក្នុងពិព័រណ៍សៀវភៅនៅកម្ពុជា និងនៅអន្តរជាតិ។

## *គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ*

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ(PDH) មាននាយកដ្ឋានតូចមួយដែលផលិតសៀវភៅកុមារ សៀវភៅលំហាត់ និង ERMs ។ គ្រឹះស្ថាននេះមិនមែនរកផលចំណេញទេ ប៉ុន្តែដោយសារជាកាតព្វកិច្ចជាប្រវត្តិសាស្ត្រដែលខ្លួនជាអ្នកបោះពុម្ពសៀវភៅកុមារតែមួយគត់ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាននេះបន្តសកម្មភាពរហូតមក។ PDH បានកាត់បន្ថយចំនួន ERMs របស់ខ្លួន ដោយផលិតដោយខ្លួនឯងខ្លះ និងការទិញសិទ្ធិពីគេខ្លះផង។

គណៈគ្រប់គ្រងគ្រឹះស្ថានគ្រោងផលិតសៀវភៅចន្លោះ១០-២០មុខក្នុងមួយឆ្នាំ ដែលទំនងជាសៀវភៅលំហាត់ជាជាង ERMs ដោយសារសៀវភៅលំហាត់នេះមានហុចផលបានច្រើនជាង។ ការផលិតសម្ភារៈដែលមិនមែនជាសៀវភៅសិក្សានោះក៏នៅតែតម្រូវឱ្យមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ហើយត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការផលិតសៀវភៅសិក្សាដែរ។ មួយមុខៗត្រូវបោះពុម្ពចំនួនប្រាំពាន់ច្បាប់ ហើយរក្សាទុកក្នុងឃ្លាំង រហូតដល់ទិញអស់។ សៀវភៅ ERM ប្រហែល៥៥០ចំណងជើងមាននៅក្នុងបញ្ជី PDH (ខ្លះបង្កើតដោយ PDH ខ្លួនឯង និងខ្លះទៀតទិញពីគ្រឹះស្ថានដទៃទៀត)។ ចំណងជើងមួយចំនួនទិញដោយសាលារៀន ប៉ុន្តែភាគធំត្រូវបោះដុំទៅឱ្យអ្នកលក់សៀវភៅនៅផ្សារអូរឫស្សីដើម្បីលក់រាយបន្ត។

## *ការរីកដុះដាល និងការដួលរលំនៃសៀវភៅតុក្កតា ឬឆាករូបភាព (Comic Books)*

សៀវភៅឆាករូបភាពសម្រាប់កុមារបានហូរចូលមកក្នុងប្រទេសកម្ពុជា ហើយក្រោយមកក៏សាបរលាបបាត់ទៅវិញ។ ការរីករាលដាលនៃបណ្តាញសង្គមបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ទីផ្សារសម្រាប់រឿងឆាករូបភាព ប៉ុន្តែអ្នកផលិត អ្នកនិពន្ធ និងអ្នករចនារូបភាពសៀវភៅទាំងនោះបានបង្វែរបង្ហោះកិច្ចការរបស់ខ្លួនលើអិនធឺណិត ជាពិសេសលើបណ្តាញហ្វេសប៊ុក។ ការប្រើប្រាស់វេទិកានេះកាត់ជួយបន្ថយចំណាយលើការបង្កើត ថែទាំ និងធ្វើបច្ចុប្បន្នភាពគេហទំព័រ ហើយផ្តល់នូវការផ្ទុករូបភាពដោយឥតបង់ប្រាក់ឡើយ។

### *ការរក្សាសិទ្ធិ ERMs*

សម្រាប់សៀវភៅដែលបានបោះពុម្ពក្នុងស្រុក ជាទូទៅអ្នកផលិតបង់ថ្លៃម្តងគត់ (ប្រមាណ ២០០ ដុល្លារសម្រាប់ប្រលោម-លោកមួយចំណងជើង) ទៅឱ្យអ្នកនិពន្ធ ហើយការរក្សាសិទ្ធិជាកម្មសិទ្ធិរបស់បណ្ណាគារឬអ្នកបោះពុម្ពពេញមួយជីវិត។[៥៧]

អង្គការស៊ីប៉ាដែលយើងបានរៀបរាប់ពីសកម្មភាពគេពីខាងដើមរួចមកហើយ ផ្តល់កម្រៃក្នុងលក្ខណៈជាការបង់កម្មសិទ្ធិបញ្ញាជាភាគរយ ឬការបង់ផ្តាច់ ដោយចាប់ពី១០០ដុល្លាក្នុងមួយរឿង សម្រាប់ការសរសេរអត្ថបទរឿងសម្រាប់កុមារបឋមសិក្សា (ថ្នាក់ទី១-៦)។

ក្រៅពីការបោះពុម្ពផ្សាយរបស់អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជនចាប់ផ្តើមអនុវត្តការទូទាត់ប្រាក់ថ្លៃកម្មសិទ្ធិបញ្ញាជាភាគរយ និងបង់រៀងរាល់ឆ្នាំ។ «ការទូទាត់ផ្តាច់» ធ្វើឱ្យការបោះពុម្ពឡើងវិញទ្រង់ទ្រាយតូចៗ និងសន្សំសំចៃក្នុងរយៈពេលវែង។

## ការរកឃើញរបស់ GBA ៖ ការអភិវឌ្ឍចំណងជើង និងចំណុចខ្លាំង

- អង្គការក្រៅរដ្ឋាភិបាលដូចជាស៊ីប៉ា និងរូមធូរីដ កំពុងអភិវឌ្ឍអក្សរសិល្ប៍កុមារដែលមានគុណភាពខ្ពស់។
- ខណៈពេលដែល MoEYS ពុំទាន់អាចដើរតួឈានមុខទាំងស្រុងក្នុងការអភិវឌ្ឍន៍វិស័យអប់រំដោយសារធនធាន និងសមត្ថភាពនៅមានកម្រិតនៅឡើយនាពេលបច្ចុប្បន្ន ប៉ុន្តែមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងវិស័យអប់រំ (ជាពិសេសសម្រាប់ថ្នាក់ដំបូងៗ) និងត្រូវបានពង្រឹងយ៉ាងខ្លាំងក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះតាមរយៈគំរូ ACR ។ កិច្ចការនេះអាចបន្តទៅមុខទៀត និងនៅទីបំផុត ប្រហែលជាកិច្ចខិតខំប្រឹងប្រែងនេះនឹងត្រូវដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡាផង។

## ការរកឃើញរបស់ GBA ៖ ការអភិវឌ្ឍចំណងជើង និងចំណុចខ្វះខាត

- ពុំមានការចូលរួមពីរដ្ឋាភិបាលដោយផ្ទាល់ក្នុងការផលិត ERMs ហើយបន្ទុកនេះធ្លាក់ទៅលើអង្គការមិនមែនរដ្ឋាភិបាល និងអ្នកបោះពុម្ពផ្សាយឯកជនមួយចំនួន។
- ពុំមានវិភាគលើទីផ្សារឱ្យបានហ្មត់ចត់ស្តីពីតម្រូវការអានរបស់សិស្សានុសិស្ស ថាតើគេចង់អានអ្វីក្នុងសៀវភៅ និងតម្លៃសៀវភៅដែលមាតាបិតាសិស្សមានលទ្ធភាពទិញ។ ការវាយតម្លៃបែបនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើតយុទ្ធសាស្ត្រដើម្បីលើកកម្ពស់វប្បធម៌អំណាន។
- ក្រៅពីគម្រោងមួយចំនួនដូចជាACR កិច្ចសហការក្នុងការចែករំលែកចំណងជើងក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាលនៅតិចតួច ដោយហេតុថា អង្គការនីមួយៗច្រើនអនុវត្តតាមរបៀបវារៈរៀងៗខ្លួន ហើយជារឿយៗគេធ្វើការតែនៅក្នុងតំបន់ភូមិសាស្ត្ររបស់គម្រោងរបស់គេតែប៉ុណ្ណោះ។ ដូចដែលលើកឡើងខាងលើ គំរូACR

---

*៥៧ ការរក្សាសិទ្ធិក្នុងប្រទេសកម្ពុជាមានអាយុកាលពេញមួយជីវិតរបស់អ្នកនិពន្ធ និងបន្ថែម៥០ឆ្នាំទៀតក្រោយពីមរណៈភាពរបស់គាត់។*

អាចត្រូវគេមើលឃើញថាជាគំរូមួយដើម្បីបន្តការសហការបែបនេះ។

- ពុំទាន់មានវិធីសាស្រ្តរួមក្នុងការកំណត់វាស់វែងអ្នកអាន ឬនិយមន័យស្តង់ដារអក្ខរកម្មនៅកម្ពុជាទេ។

## អនុសាសន៍របស់ GBA ៖ ការអភិវឌ្ឍចំណងជើង

អនុសាសន៍របស់ GBA ៖

- រៀបចំវគ្គបណ្តុះបណ្តាលដើម្បីបង្កើត ERMs ទៅឱ្យអង្គការក្រៅរដ្ឋាភិបាល និងអ្នកបោះពុម្ពផ្សាយផ្នែកឯកជន។
- ដាក់បញ្ចូលស្តង់ដារបណ្ណាល័យ និងសៀវភៅអានតាមកម្រិតថ្នាក់នីមួយៗ ក្នុងការសិក្សាថ្នាក់បឋមសិក្សាទាំងប្រាំមួយកម្រិត ហើយភាគីទាំងអស់យល់ព្រម និងអនុវត្តតាមស្តង់ដារចំណាត់ថ្នាក់នេះនៅក្នុងការអភិវឌ្ឍន៍ ERM ។
- ERMs ដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយទាំងអស់ត្រូវរក្សាសិទ្ធិក្រោមអាជ្ញាប័ណ្ណ Creative Commons (ឬអាជ្ញាប័ណ្ណប្រហាក់ប្រហែល) និងធ្វើឱ្យមានជាឯកសារអេឡិចត្រូនិកដើម្បីអាចផលិតឡើងវិញជាលក្ខណៈវិមជ្ឈការ។
- វិភាគលើទីផ្សារឱ្យបានហ្មត់ចត់ស្តីពីតម្រូវការអានរបស់សិស្សានុសិស្ស ថាតើ គេចង់អានអ្វីក្នុងសៀវភៅ និងតម្លៃសៀវភៅដែលមាតាបិតាសិស្សមានលទ្ធភាពទិញ។ ការវាយតម្លៃបែបនេះមានសារៈសំខាន់ណាស់ក្នុងការបង្កើតយុទ្ធសាស្រ្តដើម្បីលើកកម្ពស់វប្បធម៌អំណាន។
- វិភាគប្រៀបធៀបរាល់តម្លៃផលិតកម្មទាំងអស់រវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងដើម្បីជួយរកឱកាសសម្រាប់សន្សំសំចៃថ្លៃដើម។
- គាំទ្រឱ្យនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD) នៃ MoEYS កំណត់ និងបង្កើតស្តង់ដារជាតិដើម្បីចាត់ថ្នាក់អំណាន និងអក្ខរកម្ម។

# ដំណាក់កាលទីពីររបស់ SCA ៖ ការចងក្រង និងការបោះពុម្ព

ការបោះពុម្ពផ្សាយជាទូទៅរាប់តាំងការចុះកិច្ចសន្យាជាមួយអ្នកនិពន្ធ និងគ្រប់ដំណាក់កាលទាំងឡាយនៃការអភិវឌ្ឍន៍ចំណងជើងដែលបានពិពណ៌នាពីខាងលើ (ការនិពន្ធ ការកែសម្រួល គូររូបភាព ការបង្កើតក្រាហ្វិករចនាទំព័រ)។ បន្ថែមពីនោះ ក៏រាប់បញ្ចូលនូវកម្មសិទ្ធិ អាជ្ញាប័ណ្ណ និងទីផ្សារនៃកម្មសិទ្ធិបញ្ញា។ ក្នុងករណីបោះពុម្ពជាវិស័យឯកជន វាជាអាជីវកម្មសម្រាប់រកប្រាក់ចំណេញ។ ប្រសិនបើជាការបោះពុម្ពផ្សាយរបស់រដ្ឋ ទាំងកម្មវិធីសិក្សា ទាំងសៀវភៅសិក្សា គឺត្រូវតាក់តែងឡើងដោយមន្រ្តីរបស់ក្រសួងអប់រំ។ ការបោះពុម្ពសំដៅលើដំណើរការផលិតឯកសារ PDF ចុងក្រោយ រួចបោះពុម្ពទៅលើសន្លឹកក្រដាស និងកិបជាសៀវភៅ។ អ្នកបោះពុម្ពឯកជនខ្លះមានរោងពុម្ពផ្ទាល់ខ្លួន ប៉ុន្តែជាទូទៅគេចុះកិច្ចសន្យាបោះពុម្ពជាមួយរោងពុម្ពខាងក្រៅ។ ក្នុងករណីគ្រឹះស្ថានបោះពុម្ពផ្សាយជារបស់រដ្ឋ កិច្ចការបោះពុម្ពនេះត្រូវធ្វើដោយម៉ាស៊ីនក្នុងរោងពុម្ពរដ្ឋ ឬដាក់ដេញថ្លៃទៅម៉ាស៊ីនបោះពុម្ពឯកជន។

ក្នុងរបាយការណ៍នេះ យើងបានចាត់ទុកការអភិវឌ្ឍន៍ ERMs ក្នុងដំណាក់កាលទីពីរ ៖ ការអភិវឌ្ឍន៍ចំណាងជើង និងការអភិវឌ្ឍន៍សៀវភៅសិក្សា ហើយដំណាក់កាលទី៣ ៖ ការចងក្រង និងការបោះពុម្ព។

## ការបោះពុម្ពសៀវភៅសិក្សា

នៅក្នុងប្រទេសកម្ពុជា ការចាត់តាំង និងការនិពន្ធសៀវភៅសិស្សនិងសៀវភៅគ្រូ គឺត្រូវចាប់ផ្តើមពីកម្មវិធីសិក្សា ដែលរួមជាមួយស្តង់ដារ បង្ហាញលទ្ធផលបង្កើតក្របខ័ណ្ឌសម្រាប់សៀវភៅសិក្សា។ ជាមធ្យមគេចំណាយពេលប្រាំមួយខែសម្រាប់និពន្ធសៀវភៅមួយក្បាលៗ ហើយក្រុមអ្នកនិពន្ធបានមកពី PDH នៃក្រសួងអប់រំ យុវជន និងកីឡា, ពីសាលារៀន និងពីសាកលវិទ្យាល័យនានា ដែលទទួលបានប្រាក់កម្រៃថេរមួយ។

## ការអភិវឌ្ឍន៍កម្មវិធីសិក្សា និងសៀវភៅគោល

ជាទម្លាប់តាំងពីមុនមក ការអភិវឌ្ឍន៍កម្មវិធីសិក្សា និងសៀវភៅគោល ជាទំនួលខុសត្រូវរួមគ្នារវាង DCD និង PDH។ គម្រោងសៀវភៅសិក្សាអប់រំមូលដ្ឋាន (BETP; ១៩៩៦-២០០២) ទទួលមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានជួយរដ្ឋាភិបាលក្នុងការរៀបចំមុខងារបោះពុម្ពផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អការផ្តល់សៀវភៅសិក្សា និងសម្រេចបានសមាមាត្រសៀវភៅសិក្សាគោល និងសិស្ស ១:១ ។ ចាប់ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ២០០១ DCD បានបន្តទទួលខុសត្រូវក្នុងការកំណត់កម្មវិធីសិក្សា និងការសរសេរសំណៅដើមសម្រាប់សៀវភៅសិក្សាបឋមសិក្សា និងមធ្យមសិក្សាទាំងអស់។ សំណៅនេះត្រូវបានបញ្ជូនទៅ PDH សម្រាប់ការរចនា ការវាយអក្សរ ការបោះពុម្ព និងការចែកចាយ។ តាមរយៈ BETP ការនិពន្ធ ការកែសម្រួល ការរចនា និងការផលិតត្រូវដាក់ឱ្យនៅក្រោមចំណុះ PDH ហើយនៅឆ្នាំ ២០០១ ទំនួលខុសត្រូវក្នុងនិពន្ធសៀវភៅសិក្សាត្រូវបានផ្ទេរពី DCD ទៅ PDH វិញ ប៉ុន្តែ DCD នៅតែទទួលខុសត្រូវលើការបណ្តុះបណ្តាលអ្នកនិពន្ធដដែល។

PDH បានក្លាយជាពាក់កណ្តាលស្វយ័តក្នុងឆ្នាំ ២០០២ ដែលក្រោមចំណុះឱ្យក្រសួងពីរចូលគ្នា (MoEYS និង MoEF) ដូចដែលបានពណ៌នាថា ជាសហគ្រាសសាធារណៈដែលមានលក្ខណៈសម្បត្តិផ្អែកលើសេដ្ឋកិច្ច (PEEC)។ ក្នុងឆ្នាំ ២០០៨ PDH បានចាប់ផ្តើមគ្រប់គ្រងសិទ្ធិបោះពុម្ពឡើងវិញលើចំណងជើងថ្មីដែលខ្លួនបានគ្រប់គ្រង ផ្អែកលើកម្មវិធីសិក្សាដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗនេះ។ ក្នុងប្រព័ន្ធបច្ចុប្បន្ន PDH បន្តការរក្សាសិទ្ធិចំពោះសៀវភៅដែលខ្លួនបានអភិវឌ្ឍ។ ជារៀងរាល់ឆ្នាំ ក្រសួងអប់រំ យុវជន និងកីឡា ទិញសិទ្ធិសៀវភៅដែលខ្លួនត្រូវការ បន្ទាប់មកដាក់ដេញថ្លៃបោះពុម្ព និងចែកចាយដោយមានវត្តមានក្រុមហ៊ុនឯកជនចូលរួមផងដែរ។ ទោះបីជាផ្ទាល់មុខ និងសម្រាប់រកប្រាក់ចំណេញក៏ដោយក៏ PDH ស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីក្រុមប្រឹក្សាភិបាលរបស់ខ្លួន ដែលមានសមាសភាពពីមន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីស្តីការគណៈរដ្ឋមន្ត្រី។ PDH ទទួលបានការអនុញ្ញាតឱ្យរកប្រាក់ចំណេញក៏ពិតមែន ប៉ុន្តែរកឱ្យគ្រប់គ្រាន់សម្រាប់តែប្រតិបត្តិការ និងសម្រាប់បន្តសកម្មភាពរបស់ខ្លួនប៉ុណ្ណោះ

ដោយមិនអនុញ្ញាតឱ្យរកធ្វើមានធ្វើបានទេ។ តម្លៃសៀវភៅសិក្សាត្រូវឆ្លងកាត់ការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

ការអភិវឌ្ឍន៍កម្មវិធីសិក្សាត្រូវបានផ្ទេរត្រឡប់ទៅ DCD វិញក្នុងឆ្នាំ ២០១៤ ហើយកម្មវិធីសិក្សាផ្អែកលើស្តង់ដារនេះគឺធ្វើឡើងសម្រាប់គ្រប់ថ្នាក់ និងគ្រប់មុខវិជ្ជាទាំងអស់ ដោយផ្អែកលើបទដ្ឋានកុមារមជ្ឈមណ្ឌល គឺរៀនសូត្រតាមការសាកសួរ និងតាមការដោះស្រាយចំណោទដែលរៀបចំ និងអនុម័តដោយក្រសួងក្នុងឆ្នាំ ២០១៦។ កម្មវិធីសិក្សាផ្នែកសិក្សាសង្គមបានរៀបចំឡើងដោយអ្នកប្រឹក្សាជនជាតិជប៉ុន ហើយនៅឆ្នាំ ២០១៧ ផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា និង ICT ត្រូវបានបង្កើតឡើងដោយអ្នកជំនាញជនជាតិសិង្ហបុរី ដើម្បីឱ្យស្របតាមស្តង់ដារនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ កម្មវិធីសិក្សាសម្រាប់មុខវិជ្ជាទាំងអស់ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៨។ ក្នុងខែកុម្ភៈ ឆ្នាំ ២០២០កម្មវិធីសិក្សាទាំងអស់ត្រូវបានដាក់ស្នើអនុញ្ញាតចុងក្រោយសម្រាប់អនុវត្ត ក្នុងអំឡុងពេលសរសេររបាយការណ៍នេះ យើងសង្កេតឃើញថាវាស្ថិតនៅក្នុងការរង់ចាំនៅឡើយ។ តាមពិតទៅការមិនបានអនុវត្តក៏ដោយសារតែមិនមានសៀវភៅសិក្សាថ្មី ហើយក្រសួងអប់រំ យុវជន និងកីឡាពុំមានផែនការជាក់លាក់ដើម្បីអភិវឌ្ឍសៀវភៅថ្មីនោះដែរ។

DCD បានទទួលរងការលំបាកពីការខ្វះខាតទិសដៅ និងភាពច្បាស់លាស់ដោយសារភាពប្រែប្រួលឥតឈប់ឈរនៃទំនួលខុសត្រូវនេះ បណ្តាលឱ្យមានភាពស្រពេចស្រពិលលើតួនាទីរបស់ខ្លួនក្នុងការផ្គត់ផ្គង់សៀវភៅ និងដោយ OPTD ប្តូរទៅការប្រមូលទិន្នន័យអំពីចំនួនសិស្សានុសិស្សក្នុងសាលា និងអភិវឌ្ឍន៍កម្មវិធីសិក្សានៅវិញ។ បន្ទាប់ពីអូសបន្លាយគ្មានអ្នកដឹកនាំមួយរយៈមក ក្រសួងបានតែងតាំងលោក ស៊ុន ប៊ុណ្ណា ជាប្រធាននាយកដ្ឋានថ្មី នៅក្នុងខែមករាឆ្នាំ ២០២០។ លោកបានពន្យល់ដល់ក្រុមយើងអំពីបញ្ហាជាប្រព័ន្ធនៃការអនុវត្តកម្មវិធីសិក្សា ទោះបីជាគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាគឺដើម្បីដេញថ្លៃការអភិវឌ្ឍន៍សៀវភៅសិក្សាទៅដល់វិស័យឯកជនក៏ដោយ។ តាមពិតទៅគឺគ្មានគ្រឹះស្ថានបោះពុម្ពឯកជនណាមានសមត្ថភាពរ៉ាប់រ៉ងកិច្ចការនេះបានទេ ហើយម្យ៉ាងវិញទៀតក៏គេពុំមានអ្នកនិពន្ធដែលទទួលបានការបណ្តុះបណ្តាលជំនាញនេះនៅឡើយដែរ។ ថ្មីៗនេះ DCD បានទទួលការបណ្តុះបណ្តាលពីសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា លើការនិពន្ធ និងអភិវឌ្ឍន៍សៀវភៅសិក្សាសង្គម ហើយលោក ប៊ុណ្ណា ចង់ឃើញមានវគ្គបណ្តុះបណ្តាលបែបនេះបន្ថែមទៀតពីអ្នកជំនាញអន្តរជាតិ។

## ការផ្លាស់ប្តូរកម្មវិធីសិក្សា ៖ ឥទ្ធិពលលើសៀវភៅសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា កំពុងណែនាំដល់សាលាបង្រៀនឱ្យប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌល តាមរយៈការសួរឆ្លើយ និងប្រមាណវិធីដោះស្រាយចំណោទ។ ផ្ទុយទៅវិញបញ្ហាថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ហើយចំណាយក្នុងការផលិតសៀវភៅមួយក្បាលៗក៏អស់ច្រើន ដូច្នេះការកែសម្រួលភ្លាមៗវាជាការលំបាក។ ក្នុងអំឡុងពេលបច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡាបានកំហិតថា ប្រសិនបើអនុវត្តកម្មវិធីសិក្សាបាន៦០%នោះចាត់ទុកថាទទួលយកបានហើយ។

## មូលនិធិភាពជាដៃគូអភិវឌ្ឍន៍សមត្ថភាព

មូលនិធិភាពជាដៃគូអភិវឌ្ឍន៍សមត្ថភាព (CDPF) គឺជាយន្តការផ្តល់មូលនិធិ និងភាពជាដៃគូរវាង MoEYS សហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (Sida) និង USAID ដែលគ្រប់គ្រងដោយអង្គការយូនីសេហ្វកម្ពុជា។ CDPF មានកាតព្វកិច្ចកសាងសមត្ថភាពនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើផែនការមេសម្រាប់អភិវឌ្ឍន៍សមត្ថភាព (CDMP) ហើយកំពុងអនុវត្តកិច្ចការរបស់ខ្លួនក្រោមការគាំទ្រថវិកាពីសហភាពអឺរ៉ុបពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២៣។ គម្រោងថវិកាចំនួន ២៧ លានអឺរ៉ូ (ដែលក្នុងនោះ ១៤ លានអឺរ៉ូបានមកពី EU) ១ លានដុល្លារទទួលបានពី USAID និងវិភាគទានពី GPE និង Sida។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវការកិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍន៍សម្ភារៈឧបទ្ទេសអំណាន គ្រប់កម្រិតទាំងអស់ ដោយផ្អែកលើស្តង់ដារកម្មវិធីសិក្សាបច្ចុប្បន្ន ប៉ុន្តែនៅខ្វះជំនួយស្មារតីទាក់ទិននឹងសៀវភៅពី CDPF ឬពីសហភាពអឺរ៉ុប។ ប៉ុន្តែដោយមានការតែងតាំងនាយក DCD នាពេលថ្មីៗនេះ សហភាពអឺរ៉ុបបានត្រៀមលក្ខណៈសម្បត្តិដើម្បីពិចារណាលើការគាំទ្រ ល្គឹកណាគំនិតផ្តួចផ្តើមនេះចេញមកពីក្រសួងអប់រំ យុវជន និងកីឡា ដោយដាក់បញ្ចូលក្នុង CDMP បន្ទាប់ ហើយផ្តល់ភាពច្បាស់លាស់លើបញ្ហានៃការអនុវត្តកម្មវិធីសិក្សាទាំងអស់។ តម្រូវការចុងក្រោយនេះត្រូវតែបំពេញ មុនពេលការពិភាក្សាអាចចាប់ផ្តើម។

## ការផលិតសៀវភៅសម្រាប់កុមារពិការ

យោងតាមការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០១៤ បង្ហាញថាកុមារអាយុពី ៥ ទៅ ១៤ ឆ្នាំចំនួន១,៨% ជាកុមារពិការ។[៥៨] គិតត្រឹមឆ្នាំ ២០១៧ ចំនួនកុមារពិការសរុបនៅបឋមសិក្សាគឺ ៤៥.៧៥៩នាក់ និងនៅក្នុងមធ្យមសិក្សាចំនួន៦.៧៨៧នាក់ ជាទូទៅគេសង្កេតឃើញមានពិការភាពផ្នែកស្មារតីចំពោះកុមារនៅបឋមសិក្សា និងពិការភាពផ្នែកចក្ខុ និងសោតវិញ្ញាណនៅមធ្យមសិក្សា។ [៥៩]

គម្រោង ACR ទទួលបានមូលនិធិពី USAIDអនុវត្តដោយ RTI International បានអភិវឌ្ឍសម្ភារៈសិក្សា ក្នុងគោលបំណងធានាថា កុមារពិការទទួលបានកិច្ចគាំពារយ៉ាងពេញទំហឹងក្នុងការរៀនភាសាខ្មែរ និងអក្ខរកម្មអនុលោមតាមគោលនយោបាយ MoEYS ដោយប្រកាន់ខ្ជាប់ យកកម្មវិធីសិក្សាជាគោល។

នៅក្នុងប្រទេសកម្ពុជា ការអប់រំកុមារពិការដំបូងឡើយផ្តោតលើសិស្សបឋមសិក្សា លុះដល់ឆ្នាំ ២០១៦ ទើបសេវានេះ

---

*៥៨ តួលេខពីការស្រង់មតិតនេះមិនបង្ហាញតួលេខក្នុងតំបន់ទេ។ គេប៉ាន់ស្មានថាប្រហែល ៥%-៦% នៃកុមារនៅអាស៊ីអាគ្នេយ៍ដែលមានអាយុពី ០-១៤ ឆ្នាំពិការ។ https://www.who.int/publications/i/item/9789241564182*

*៥៩ Akiro, ប្រវត្តិស្ថានភាពបច្ចុប្បន្ន។*

ពង្រីកដល់ការអប់រំកុមារតូច និងមធ្យមសិក្សា។ មានអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរដែលមានឯកទេសក្នុងការអប់រំ CWD ៖

- *អង្គការកុមារពិការ* ផ្តល់កិច្ចគាំពារកុមារពិការទាំងកម្រិតស្រាលដល់កម្រិតធ្ងន់ធ្ងរ ហើយក៏ផ្តល់ការគាំទ្រដល់គ្រួសាររបស់ពួកគេផងដែរ។
- *សាលាទន្សាយ* ផ្តល់ការអប់រំដល់កុមារពិការផ្នែកបញ្ញានៅក្នុងសាលារៀនមួយ ក្នុងរាជធានីភ្នំពេញ។

មូលនិធិទាំងពីរនេះពុំទាន់ទទួលបានការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡាទេ។

ការផ្ទេរសាលាគថ្លង់របស់អង្គការគ្រួសារថ្មីមកឱ្យនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ ២០១៩ ហើយដែលឥឡូវច្រើនគេស្គាល់ថា សាលាអប់រំពិសេសថ្មី មានដំណើរការជាសាលាសាធារណៈ។ សាលានេះផ្តល់ការអប់រំដល់សិស្សានុសិស្សពិការភ្នែក និងគថ្លង់ ហើយមានចំនួនប្រាំបីក្នុង៤រាជធានី/ខេត្ត គឺនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកំពង់ចាម។ ក្រុមការងារ GBA បានធ្វើទស្សនកិច្ចនៅសាលានោះ ដើម្បីណែនាំអំពីបណ្ណាល័យឌីជីថលសកល (GDL) សំឡេង និងអក្សរស្ទាប ដល់លោកគ្រូ-អ្នកគ្រូនៅទីនោះ។ មានសិស្សគថ្លង់ជាង ១០០ នាក់កំពុងរៀននៅសាលានោះចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។ សាលាត្រូវបញ្ជាទិញសៀវភៅពីវិទ្យាស្ថានជាតិអប់រំពិសេសរបស់ MoEYS ដែលបង្កើតចំណងជើងត្រូវនឹងកម្មវិធីសិក្សាធម្មតាសម្រាប់សិស្សពិការភ្នែក និងគថ្លង់។ មានការខ្វះខាតសៀវភៅភាសាសញ្ញា គឺថាមានដល់ត្រឹមតែថ្នាក់ទី ៥ ប៉ុណ្ណោះ រីឯសៀវភៅថ្នាក់ទី ៦ ស្ថិតនៅដំណាក់កាលកំពុងអភិវឌ្ឍ ហើយលុះត្រាបញ្ចប់ការតាក់តែងរួចទើបគេរៀបចំធ្វើសៀវភៅថ្នាក់ទី៧ ជាបន្តទៀត។ ដើម្បីបំពេញបន្ថែមកង្វះខាតនេះលោកគ្រូ-អ្នកគ្រូប្រើប្រាស់សៀវភៅធម្មតា ដោយសិស្សរៀនថាតាម និងចម្លងពីសៀវភៅសិក្សា ឬក្តារខៀនចូលក្នុងសៀវភៅសរសេររបស់ខ្លួន។ ផ្ទាំងរូបភាពនៃអក្ខរសញ្ញាមានព្យួរនៅលើជញ្ជាំង។ គ្រូបង្រៀនភាគច្រើនក៏គថ្លង់ ក៏ដូចជាសិស្សានុសិស្សទាំងអស់ដែរ ហើយពួកគាត់ខ្លះក៏មានតម្រូវការសិក្សាពិសេសផ្សេងទៀត។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២០ មិនមានសៀវភៅថ្មីបញ្ជូនមកបំពេញបន្ថែមទេ ទោះបីជាឆ្នាំសិក្សាបានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ ២០១៩ ក៏ដោយ។

## ការបោះពុម្ព

មានរោងពុម្ពចំនួនពីរនៅក្នុងប្រទេសកម្ពុជា ដែលមានសមត្ថភាពបោះពុម្ពក្នុងចំនួនច្រើនដើម្បីផលិតសៀវភៅសិក្សា គឺ Sindy Printing (Golden Printing Ltd) [៦០] ដែលជាក្រុមហ៊ុនឯកជន និង PDH គ្រប់គ្រងដោយរដ្ឋ។[៦១]

---

*៦០ Golden Printing Ltd. គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Sindy Import Export Co., Ltd. ដែលមានសកម្មភាពចម្រុះ រួមមាន នាំចូលក្រដាស និងបោះពុម្ព។ ដើម្បីងាយស្រួល ក្រុមហ៊ុននេះត្រូវបានគេហៅថា Sindy Printing។*

*៦១ PDH ពាក់ព័ន្ធនឹងសកម្មភាពបោះពុម្ព បោះពុម្ពផ្សាយ និងចែកចាយនៅក្នុងដំណើរការខ្សែសង្វាក់ផ្គត់ផ្គង់។*

Sindy Printing មានឧបករណ៍ទំនើបសម្រាប់បោះពុម្ព តែបើនិយាយពីតម្លៃវិញវាហាក់ដូចជាថ្លៃខ្ពស់ជាងគេ បើប្រៀបនឹងស្តង់ដារទីផ្សារអន្តរជាតិ។ រោងពុម្ពនេះបំពាក់ដោយឧបករណ៍ស្វ័យប្រវត្តិកម្រិតខ្ពស់ហើយមានសមត្ថភាពបញ្ចប់ការផលិតសៀវភៅ (ដេរ ឬកិប រួចបិទក្រប) ពី៥០០០ ទៅ៦០០០ក្បាល ក្នុងមួយម៉ោង។

PDH មានទីតាំងនៅកណ្តាលទីក្រុងភ្នំពេញ ដែលវាមិនល្អដោយសារតែបញ្ហាចរាចរណ៍ និងបញ្ហាបរិស្ថានដោយសារតែមានការប្រើប្រាស់សារធាតុគីមី។ គ្រឹះស្ថាននេះមានគ្រឿងបរិក្ខារមិនគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងការបោះពុម្ពដែលមានបរិមាណច្រើន។ PDH អាចបំពេញតម្រូវការបានតាមរយៈកាលវិភាគការងារពេញមួយឆ្នាំដែលធានាដោយចំណែកត្រឹមតែ៥០% នៃការបញ្ជាទិញសៀវភៅសិក្សារបស់ MoEYS ។ លើសពីនេះ PDH បោះពុម្ពសៀវភៅសិក្សាបន្ថែមចំនួន ២,២ លានក្បាល សម្រាប់ដាក់លក់ក្នុងទីផ្សារក្នុងតម្លៃមួយក្បាលរវាង២-២,៥០ដុល្លារ ក៏ដូចជាការចូលរួមក្នុងគម្រោងជួយសង្គមរបស់ក្រុមហ៊ុននិងសហគ្រាសឯកជននានាផងដែរ។

PDH ធ្វើកិច្ចសន្យាបន្តដល់ Sindy Printing ឱ្យបោះពុម្ពសៀវភៅសិក្សាសម្រាប់រយៈពេលបីឆ្នាំចុងក្រោយនេះ ដោយគ្មានការដេញថ្លៃប្រកួតប្រជែងទេ។ គណៈកម្មាធិការលទ្ធកម្មពន្យល់ថាដោយសារតែ (១) ពុំមានការឆ្លើយតបពីរោងពុម្ពកម្ពុជានៅពេលដែលប្រកាសដាក់ឱ្យដេញថ្លៃត្រូវប្រកួតប្រជែងកាលពីបីឆ្នាំមុន និង (២) សមត្ថភាពបោះពុម្ពនៅកម្ពុជាក្នុងការផលិតសៀវភៅចំនួន ២,៧ លានក្បាលនៅមានកម្រិត។

មានរោងពុម្ពមានជាច្រើនផ្សេងដែរ ដែលមានបំពាក់ម៉ាស៊ីនទំនើបៗខុសៗគ្នា សម្រាប់ការបោះពុម្ពបរិមាណតិចក្នុងរាជធានីភ្នំពេញ។ រោងពុម្ពទាំងនេះប្រើប្រាស់ដោយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូបោះពុម្ពសៀវភៅសិក្សាមានចំនួនតិច។ រោងពុម្ពទាំងនេះអាចផ្តល់នូវផលិតផលដែលមានគុណភាពខ្ពស់ក្នុងតម្លៃប្រកួតប្រជែង និងមានសក្តានុពលក្នុងការពង្រីកដោយការបណ្តុះបណ្តាលបុគ្គលិក និងការវិនិយោគលើឧបករណ៍ទំនើប។ តាមរយៈការបើកលទ្ធភាពឱ្យមានការប្រកួតប្រជែង ធ្វើឱ្យចំណាយលើការផលិតសៀវភៅនឹងធ្លាក់ចុះ ហើយឧស្សាហកម្មបោះពុម្ពអាចប្រើប្រាស់ប្រាក់ចំណេញទៅពង្រីកអាជីវកម្មរបស់ខ្លួន។

ការជួសជុល និងថែទាំម៉ាស៊ីនមិនមាននៅក្នុងប្រទេសកម្ពុជាទេ។

## ដំណើរការផ្គត់ផ្គង់បោះពុម្ព

រហូតមកដល់ពេលនេះ PDH ជាអ្នកទទួលខុសត្រូវចំពោះការវិភាគលើតម្រូវការលើសៀវភៅសិក្សាតាមថ្នាក់នីមួយៗដែលប្រមូលបានពីគ្រប់កម្រិតនៃប្រព័ន្ធអប់រំ។ នៅពេលដែលថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាអនុម័តរវាងខែឧសភានិងខែមិថុនា ការបោះពុម្ពក៏ចាប់ផ្តើមដោយផ្អែកលើទិន្នន័យដែលបានព្យាករណ៍ពីឆ្នាំមុន ព្រោះគេមិនទាន់បានដឹងថាតួលេខចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សាថ្មីពិតប្រាកដប៉ុន្មានទេ។ ហានិភ័យចម្បងដែលបង្កដល់គ្រឹះស្ថានបោះពុម្ពនោះគឺមានការចំណាយបន្ថែមសម្រាប់ក្រដាស និងការទិញសម្ភារៈផ្សេងទៀត។ រឿងនេះនឹងអាចកាត់បន្ថយ

បាននៅពេលដែលប្រព័ន្ធតាមដាន និងត្រួតពិនិត្យប្រតិបត្តិដំណើរការរបស់ខ្លួនពេញលេញ។

### ពន្ធនាំចូល និងអាករលើតម្លៃបន្ថែម (VAT)

ប្រទេសកម្ពុជាមានពន្ធនាំចូល និងពន្ធចំនួនបួនប្រភេទ ដែលប៉ះពាល់ដល់ថ្លៃដើមសរុបនៃទំនិញដែលបានទិញ និងលក់សម្រាប់ដំណើរការសង្វាក់ផ្គត់ផ្គង់។ ក្នុងចំណោមពន្ធទាំងនោះ ១០%អាករលើតម្លៃបន្ថែម និង៧,៧%ពន្ធនាំចូលវត្ថុធាតុដើម (ក្រដាស) ហើយគួរតែមានការពិនិត្យដើម្បីលុបពន្ធទាំងនេះចោល។ RGC ក៏មានការលើកលែងពន្ធផងដែរ នេះជាការលើកទឹកចិត្តដល់ភ្នាក់ងារសេដ្ឋកិច្ចមួយចំនួន ហើយរដ្ឋគួរពិចារណាផ្ដល់ការអនុគ្រោះពន្ធដល់ឧស្សាហកម្មបោះពុម្ពសៀវភៅផងដែរ។ បើមិនដូច្នេះទេ វិស័យនេះនឹងមិនអាចរីកចម្រើនបានទេ ដោយហេតុថាមានការខ្វះខាតវប្បធម៌អំណាន ទីផ្សារសៀវភៅចង្អៀត ការលួចចម្លងនឹងកើនឡើង និងការអនុវត្តប្រាសចាកសីលធម៌ផ្សេងៗទៀតនៅក្នុងខ្សែសង្វាក់សៀវភៅ។[៦២]

## ការរកឃើញរបស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព / ចំណុចខ្លាំង

- មានការតែងតាំងនាយក DCD ថ្មីកាលពីខែមករា ឆ្នាំ ២០២០ បន្ទាប់ពីមុខតំណែងនេះនៅទំនេរមួយរយៈមក។
- កម្មវិធីសិក្សាថ្មីសម្រាប់គ្រប់ថ្នាក់ និងមុខវិជ្ជាដែលរួមបញ្ចូលស្តង់ដារនៃការសិក្សាដែលផ្ដោតលើកុមារមជ្ឈមណ្ឌល ដោយរៀនតាមរយៈការសួរឆ្លើយ និងការរៀនផ្អែកលើការដោះស្រាយចំណោទបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ ២០១៦។
- ថ្មីៗនេះ DCD បានទទួលការបណ្ដុះបណ្ដាលពីសាកលវិទ្យាល័យ Hiroshima លើការតែងនិពន្ធ និងការផលិតសៀវភៅសិក្សា។
- សិស្សានុសិស្សពិការទទួលបានកិច្ចគាំទ្រពីគម្រោង ACR ដែលអនុវត្តដោយ RTI International ដែលកំពុងអភិវឌ្ឍសម្ភារៈឧបទេ្ទសជាភាសាខ្មែរ និងសម្ភារៈឧបទេ្ទសសម្រាប់រៀនអានផងដែរ។
- នាយកដ្ឋានអប់រំពិសេសកំពុងអនុវត្តផែនការសកម្មភាព MLE ដែលត្រូវបានកែសម្រួល ដើម្បីកៀរគរជំនួយបច្ចេកទេសដើម្បីពិនិត្យឡើងវិញនូវរាល់សម្ភារៈឧបទេ្ទសអំណាន និងឧបទេ្ទសសម្រាប់បង្រៀននៅកម្រិតមត្តេយ្យ និងបឋមសិក្សាជាប្រាំភាសាដែលមានស្រាប់ ព្រមទាំងភាសាចារ៉ាយផងដែរ។
- ឧស្សាហកម្មបោះពុម្ពនៅទីក្រុងភ្នំពេញមានម៉ាស៊ីនបោះពុម្ពតូចក្ដី តែអាចទុកចិត្តបាន ជាមួយនឹងម៉ាស៊ីនទំនើបខុសៗគ្នា ហើយវាផ្ដល់នូវផលិតផលដែលមានគុណភាពខ្ពស់ក្នុងតម្លៃប្រកួតប្រជែង។ វាមានសក្ដានុពលក្នុងការរីកលូតលាស់តាមរយៈការបណ្ដុះបណ្ដាលបុគ្គលិក និងការវិនិយោគបន្ថែមលើទំនើបកម្មបរិក្ខានានា។
- គណៈកម្មការប្រតិភូសហភាពអឺរ៉ុបកំពុងពិចារណាលើកិច្ចគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការ

---

៦២ *ADEA/AUC/GBA, Continental Framework.*

កសាងសមត្ថភាពក្នុងការអភិវឌ្ឍន៍សៀវភៅសិក្សាតាមរយៈគម្រោង CDPF បន្ទាប់ពីមានការតែងតាំងនាយក DCD នាពេលថ្មីៗនេះ។

## ការរកឃើញរបស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព / ចំណុចខ្សោយ

- ខ្វះខាតអ្នកនិពន្ធដែលបានទទួលការបណ្តុះបណ្តាល ហើយការអភិវឌ្ឍសៀវភៅសិក្សាមិនបានរួមបញ្ចូលលោកគ្រូ-អ្នកគ្រូដែលមានបទពិសោធន៍ក្នុងថ្នាក់រៀនថ្មីៗទេ។ មិនមានគោលការណ៍ច្បាស់លាស់ណាមួយស្តីអំពីការជ្រើសរើសអ្នកនិពន្ធសៀវភៅសិក្សាថ្មី ក៏ដូចជាគោលការណ៍ផ្តល់ប្រាក់សម្រាប់និពន្ធឡើយ។
- គ្រឹះស្ថានបោះពុម្ពផ្សាយឯកជនខ្វះធនធាន និងជំនាញក្នុងការអភិវឌ្ឍន៍សៀវភៅសិក្សា។
- ទោះបីជាក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តកម្មវិធីសិក្សាឆ្នាំ ២០១៦ហើយក្តី ក៏ DCD មិនអាចអនុវត្តវាបានទេ ដោយសារក្រសួងអប់រំ យុវជន និងកីឡា ព្យាយាមអនុវត្តឱ្យស៊ីសង្វាក់ស្តង់ដារជាមួយប្រទេសអាស៊ានដទៃទៀត។ សៀវភៅសិក្សាមិនត្រូវបានធ្វើបច្ចុប្បន្នភាពទៅនឹងកម្មវិធីសិក្សាឆ្នាំ ២០១៦ទេ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា អនុញ្ញាតឱ្យប្រើប្រាស់សៀវភៅសិក្សាដែលមានស្រាប់ ដោយផ្អែកតាមកម្មវិធីសិក្សាយ៉ាងហោចណាស់ឱ្យបាន ៦០% ជាបណ្តោះអាសន្នសិន។
- ពុំមានការវិភាគលម្អិតលើតម្លៃនៃសៀវភៅសិក្សាថ្មី ទៅលើវិសាលភាពនៃការងារ និងកម្រិតនៃការប្តេជ្ញាចិត្តទៅក្នុងកម្មវិធីសិក្សានោះទេ ទោះបីជាមានសក្តានុពលទទួលបានមូលនិធិពី CDPF ក៏ដោយ។[៦៣]
- ពន្ធនាំចូលខ្ពស់ (៧,៧%) និងពន្ធផ្សេងៗទៀតលើក្រដាសធ្វើឱ្យតម្លៃសៀវភៅសិក្សាឡើងថ្លៃ។
- ការជួសជុល និងថែទាំម៉ាស៊ីនមិនអាចមាននៅក្នុងប្រទេសកម្ពុជាទេ។
- រោងពុម្ពដែលមានសមត្ថភាពបោះពុម្ពទ្រង់ទ្រាយធំ ដែលអាចកាត់បន្ថយថ្លៃដើមនៃការផលិតមានតិចតួចនៅឡើយ។

## អនុសាសន៍របស់ GBA ៖ ការបោះពុម្ពផ្សាយ និងរោងពុម្ព

អនុសាសន៍របស់ GBA ៖

- ជាផ្នែកមួយនៃអនុសាសន៍កម្រិតខ្ពស់ក្នុងការវិភាគតំរូនានានៃតួនាទីរបស់វិស័យសាធារណៈ និងឯកជន នៅក្នុងប្រព័ន្ធផ្គត់ផ្គង់សៀវភៅសិក្សា ការពិនិត្យឡើងវិញឱ្យបានទូលំទូលាយអំពីការទទួលខុសត្រូវរបស់អង្គភាពនីមួយៗពាក់ព័ន្ធនឹងដំណើរការបោះពុម្ពផ្សាយសៀវភៅសិក្សាគួរតែ ធ្វើឡើងដើម្បីជំរុញឱ្យមានការបើកចំហរក្នុងវិស័យនេះ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ជាកិច្ចបង្កើតឱ្យមានការប្រកួតប្រជែងដែលនាំទៅរក

*៦៣ CDPF មានមូលនិធិ $២០,២ លាន។*

ភាពរីកចម្រើន – រួមជាមួយនឹងទំនួលខុសត្រូវរបស់ក្រសួងក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងសិទ្ធិក្នុងការនិពន្ធសៀវភៅសិក្សាគោល។

- ជាផ្នែកមួយនៃការវិភាគនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរពិចារណាលើលទ្ធភាពបង្វែរ PDH ពីការបោះពុម្ពផ្សាយសៀវភៅសិក្សា ឱ្យផ្ដោតលើការបោះពុម្ព និងចែកផ្សាយសៀវភៅ ដោយរួមបញ្ចូលសម្ភារៈអំណានចាំបាច់ (ERMs) ផងដែរ។ DCD នឹងកំណត់កម្មវិធីសិក្សា និងស្តង់ដារ ហើយគ្រឹះស្ថានបោះពុម្ពផ្សាយឯកជននឹងប្រកួតប្រជែងក្នុងការដេញថ្លៃដើម្បីបោះពុម្ពសៀវភៅសិក្សា និងសម្ភារៈអំណានចាំបាច់។
- គ្រឹះស្ថានបោះពុម្ពផ្សាយឯកជន អ្នកនិពន្ធសៀវភៅសិក្សា និងអ្នកត្រួតពិនិត្យកែសម្រួលត្រូវបណ្ដុះបណ្ដាលជំនាញអភិវឌ្ឍន៍សៀវភៅសិក្សា និងធ្វើឱ្យស៊ីសង្វាក់គ្នាត្រឹមត្រូវរវាងកម្មវិធីសិក្សា និងសៀវភៅសិក្សា។ DCD អាចរៀបចំផ្តួចផ្តើមគោលគំនិតមួយ ដើម្បីទទួលបានមូលនិធិពីខាងក្រៅ សម្រាប់ការកសាងសមត្ថភាពនេះ។
- ជាផ្នែកមួយនៃការវិភាគនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏គួរពិចារណាលើការរកដៃគូបោះពុម្ពសៀវភៅសិក្សារបស់ខ្លួនដោយចំហ និងប្រកួតប្រជែង។ ដូចគ្នានឹងការពិនិត្យគុណភាពនៃខ្លឹមសារសៀវភៅដែរ DCD គួរតែបង់ថ្លៃការត្រួតពិនិត្យគុណភាពនៃការផលិតនៅរោងពុម្ព។
- ប្រសិនបើក្រសួងអប់រំ យុវជន និងកីឡាសម្រេចថាការបោះពុម្ពត្រូវប្រគល់ឱ្យគ្រឹះស្ថានបោះពុម្ពខាងក្រៅនោះ PDH គួររៀបចំអនុវត្តវិធានការដូចខាងក្រោមដើម្បីរក្សាឱ្យមានចីរភាព ៖
    - វិនិយោគក្នុងទំនើបកម្មសម្រាប់ឱ្យមានការប្រកួតប្រជែងតម្លៃជាមួយនឹងការដំឡើងដើមទុន ដោយ (១) ការធ្វើឯកជនភាវូបនីយកម្ម (២) លក់ភាគហ៊ុនមួយភាគលើទីផ្សារមូលបត្រកម្ពុជា; និង (៣) លក់ទីតាំងដ៏មានតម្លៃរបស់ខ្លួននៅកណ្តាលទីក្រុងភ្នំពេញ ហើយប្តូរទៅក្នុងតំបន់ឧស្សាហកម្មតាមខេត្តណាមួយវិញ។
- គួរពិចារណាលើការលុបបំបាត់អាករលើតម្លៃបន្ថែម ១០% និងពន្ធនាំចូលវត្ថុធាតុដើម (ក្រដាស) ៧,៧%។
- គួរបង្កើតក្រុមអ្នកនិពន្ធ និងបណ្តុះបណ្តាលពួកគេលើគ្រប់មុខវិជ្ជាទាំងអស់។
- ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើរបាយការណ៍វិភាគលើការចំណាយសរុបនៃគម្រោងផលិតសៀវភៅសិក្សាថ្មីដែលស្របតាមកម្មវិធីសិក្សាក្នុងមុខវិជ្ជានីមួយៗសម្រាប់ថ្នាក់ទី១-ទី៦ក្នុងបឋមសិក្សាទាំងមូល។

## ដំណាក់កាលទី៤របស់ SCA ៖ លទ្ធកម្ម និងការទិញ

*លទ្ធកម្ម* និង*ការទិញ* គឺជាការទិញសៀវភៅ និងអត្ថបទ ដើម្បីគាំទ្រដល់អំណាន។ នៅក្នុងវិស័យអប់រំ អ្នកទិញសៀវភៅធំជាងគេគឺរដ្ឋាភិបាលដែលនឹងជ្រើសរើសអ្នកលក់ដាក់លក្ខខណ្ឌក្នុងការបង់ប្រាក់ចរចាកិច្ចសន្យាថ្លៃបោះពុម្ពសៀវភៅ និងសម្ភារៈក្នុងមួយឯកតាៗ និងទូទាត់ប្រាក់ឱ្យអ្នកលក់ជាដើម។ ការទិញក៏អាចអនុវត្តបានតាមរយៈហិរញ្ញប្បទានក្រៅបទដ្ឋាន ដូចជាវិធីសាស្ត្រការផ្តល់កិច្ចសន្យាទីផ្សារជាមុន ឬការទិញជាសម្ព័ន្ធ។ លោកគ្រូ-អ្នកគ្រូ គ្រួសារ និងសិស្សានុ-

សិស្សជាអ្នកប្រើប្រាស់សៀវភៅដែរ ហើយអាចទិញសៀវភៅអាស្រ័យលើលទ្ធភាពរបស់ខ្លួន។

នៅក្នុងប្រទេសកម្ពុជា អ្នកទិញសៀវភៅធំជាងគេគឺ RGC។ ដោយសារតែការអភិវឌ្ឍន៍ខ្លឹមសារត្រូវបានគ្រប់គ្រងដោយ PDH ការដេញថ្លៃលទ្ធកម្មតែមួយគត់ដែលដាក់ចេញគឺសម្រាប់តែការបោះពុម្ព និងការចែកចាយប៉ុណ្ណោះ។

## ដំណើរការលទ្ធកម្មរបស់រដ្ឋាភិបាលសម្រាប់ការបោះពុម្ព និងចែកផ្សាយ

បន្ទាប់ពីគណនាចំនួនសម្ភារៈសរុបដែលត្រូវការរួចរាល់ហើយ អង្គភាពលទ្ធកម្មនៃក្រសួងអប់រំ ប្រើប្រាស់ឯកសារស្តង់ដារជាតិដើម្បីប្រកួតប្រជែងដេញថ្លៃ សម្រាប់កំណត់លទ្ធកម្មសម្រាប់ការបោះពុម្ព និងចែកផ្សាយ។ ដូចដែលបានរៀបរាប់ខាងលើមកហើយថា សម្រាប់រយៈពេលបីឆ្នាំចុងក្រោយនេះ PDH បានផលិតសៀវភៅសិក្សាបានចំនួន ៥០% តាមរយៈការចុះកិច្ចសន្យាបន្តតែមួយគត់គឺរោងពុម្ព Sindy។ ដំណើរការនេះហាក់ដូចជាជម្រើសផ្លូវកាត់ ខណៈពេលដែលអង្គភាពលទ្ធកម្មទទួលបានសំណើដេញថ្លៃបានតែមួយគត់នោះ ម៉្យាងទៀតមានតែរោងពុម្ពនេះមួយគត់ដែលមានម៉ាស៊ីនបោះពុម្ពដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចការនេះបាន។

លទ្ធកម្មសៀវភៅសិក្សាមានទំហំទឹកប្រាក់ចំនួន ៥លានដុល្លារនោះមិនត្រូវបានគេបែងចែកទៅជាចំណែកតូចៗ ដែលជាលទ្ធភាពសម្រាប់ផ្តល់ឱកាសឱ្យរោងពុម្ពតូចៗមានការងារធ្វើ និងនាំឱ្យមានការពង្រីកឧស្សាហកម្មក្នុងស្រុក ឬក៏មិនបើកឱ្យមានការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ ដែលអាចកាត់បន្ថយថ្លៃដើមសៀវភៅសិក្សាទេ។ ការធ្វើលទ្ធកម្មពុំមានប្រសិទ្ធភាពនេះបណ្តាលឱ្យការផ្គត់ផ្គង់សៀវភៅទៅកាន់ថ្នាក់រៀនមិនទាន់ពេលវេលា។

## ការលក់សៀវភៅសិក្សាជាលក្ខណៈឯកជន

ការលក់សៀវភៅសិក្សាទៅកាន់អ្នកទិញមិនមែនរដ្ឋាភិបាលកើនឡើងជារៀងរាល់ឆ្នាំប្រមាណ ១០% ដែលរាប់បញ្ចូលទាំង ២,២ លានក្បាលដាក់លក់ដោយ PDH ។ ការទិញអាចធ្វើឡើងដោយផ្ទាល់ (តាមរយៈបណ្តាញតេឡេក្រាម) ទៅកាន់បណ្ណាគាររបស់ PDH ដែលមានជម្រើសមិនត្រឹមតែសៀវភៅសិក្សាប៉ុណ្ណោះទេ គឺថែមទាំងមានសៀវភៅជាច្រើនពីអ្នកបោះពុម្ពផ្សាយនានាផង។

## សៀវភៅសម្រាប់សាលាឯកជន

លោកគ្រូ-អ្នកគ្រូដែលបង្រៀនតាមគ្រឹះស្ថានអប់រំឯកជនត្រូវតែបង្រៀនដោយអនុលោមតាមស្តង់ដារកម្មវិធីសិក្សាជាតិ តែពួកគេអាចប្រើប្រាស់សៀវភៅណាក៏បានតាមការជ្រើសរើសរបស់ខ្លួន។ ក្រៅពីបណ្ណាគារPDH បណ្ណាគារ និងតូបលក់សៀវភៅតាមផ្សារនានាក៏មានដាក់លក់សៀវភៅសិក្សាដែលបោះពុម្ពដោយ PDH ក៏ដូចជាច្បាប់ចម្លងផងដែរ។

## តម្លៃនៃសម្ភារៈអំណានចាំបាច់

សម្រាប់សាលារៀន តម្លៃសំខាន់ណាស់ ព្រោះថាសាលារៀនត្រូវការទិញសៀវភៅគ្រប់មុខ ហើយដោយសារតែការទិញសៀវភៅធ្វើឡើងតាមបែបរិមជ្ឈការ ខណៈពេលដែលថវិកាប្រតិបត្តិការរបស់សាលាមានកម្រិត សាលារៀននីមួយៗមិនមានលទ្ធភាពចរចាការបញ្ចុះតម្លៃជាមួយអ្នកបោះពុម្ព និងពីអ្នកលក់ដុំទេ។ ដូច្នេះគេត្រូវសម្របសម្រួលលើគុណភាពជាមួយបរិមាណដែលខ្លួនត្រូវការ។ ផ្ទុយទៅវិញអង្គការក្រៅរដ្ឋាភិបាលអាចចរចាតម្លៃសមរម្យបាន តាមបរិមាណដែលផ្គត់ផ្គង់ដល់បណ្ណាល័យក្នុងសាលារៀន។

ក្រុមការងាររបស់អង្គការសកម្មភាពសម្ព័ន្ធសៀវភៅសកល (GBAIA) បានរកឃើញថា តម្លៃនៃ ERMsលក់នៅតាមបណ្ណាគារ និងតូបលក់សៀវភៅតាមផ្សារ កាន់តែកើន បើចម្ងាយទីតាំងលក់នោះកាន់តែឆ្ងាយពីកន្លែងបោះដុំនៅក្រុងភ្នំពេញ។ ភាពស្ទាក់ស្ទើររបស់អាណាព្យាបាលក្នុងការទិញសៀវភៅទាំងនេះក៏ដូច្នេះដែរ។ មានមាតាបិតាសិស្សមួយចំនួនតូចប៉ុណ្ណោះ ដែលហ៊ានចំណាយលើ ERMs សម្រាប់កូនរបស់គេ ខណៈពេលដែលអ្នកមានជីវភាពកណ្ដាលនៅទីក្រុងភ្នំពេញសុខចិត្តចំណាយ ៥ ដុល្លារ ឬ ៧ ដុល្លារសម្រាប់ទិញសៀវភៅឱ្យកូន។ រីឯប្រជាជនមានជីវភាពក្រីក្រចាត់ទុកថាសៀវភៅគឺជារឿងមិនចាំបាច់ទេ ហើយតម្លៃនៃសៀវភៅ ត្រូវគេវិនិច្ឆ័យតាមប្រវែងនៃអត្ថបទ។

## សំណៅលួចចម្លង

គេសង្កេតឃើញថា សៀវភៅ RtR ដែលដាក់កំហិតយ៉ាងតឹងរឹងលើសៀវភៅខ្លួនដោយសរសេរថា *សម្រាប់បណ្ណាល័យនៅសាលារៀន* បែរជាមានលក់នៅតាមបណ្ណាគារតូចៗ និងយ៉ាងហោចណាស់មានតូបចំនួនពីរដែលមានលក់សៀវភៅនៅសាលារៀនក្នុងខេត្តកណ្ដាល ដែលមិនមែនជាតំបន់ប្រតិបត្តិរបស់ RtRផងទេ ។

## ការរកឃើញរបស់ GBA ៖ ការទិញ / ចំណុចខ្លាំង

- ឧស្សាហកម្មនេះបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដើម្បីសម្រួលដល់ការបង្កើនការផលិត ERMs ដូច្នេះ MoEYSគួរមានផ្តល់មូលនិធិសម្រាប់ពួកគេ។
- ក្នុងនាមជាសមាជិកអាស៊ាន កម្ពុជាអាចចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះលើវត្ថុធាតុដើមសម្រាប់ការផលិតសៀវភៅ ប្រសិនបើមិនទាន់បានធ្វើទេនោះ។

## ការរកឃើញរបស់ GBA ៖ ការទិញ / ចំណុចខ្សោយ

- កិច្ចសន្យាបោះពុម្ពសៀវភៅសិក្សាពុំទាន់មានតម្លាភាព និងផាត់ចោលការដេញថ្លៃពីរោងពុម្ពអន្តរជាតិ។
- មិនមានមូលនិធិពី MoEYS សម្រាប់អភិវឌ្ឍន៍ ERMs ដើម្បីជំរុញអក្ខរកម្មទេ។
- ការទិញ ERM ត្រូវបានធ្វើវិមជ្ឈការនៅកម្រិតសាលារៀនតាមរយៈថវិកាប្រតិបត្តិការរបស់សាលា [៦៤] ហើយជារឿយៗនាយកសាលាពុំបានផ្តល់អាទិភាពឡើយ។
- ប្រព័ន្ធបច្ចុប្បន្ននៃការរក្សាសិទ្ធិសៀវភៅសិក្សាដោយ PDH រឹតបន្តឹងការប្រកួតប្រជែង នេះទំនងជាមូលហេតុមួយធ្វើឱ្យតម្លៃសៀវភៅកើនឡើង។

## អនុសាសន៍របស់ GBA ៖ ការទិញ

អនុសាសន៍របស់ GBA ៖

- រដ្ឋាភិបាលគួរកែសម្រួលនិតិវិធីនៃការធ្វើលទ្ធកម្ម ដើម្បីធានាបាននូវប្រសិទ្ធភាពនៃតម្លៃសម្រាប់អ្នកទិញ (MoEYS) ក្នុងនោះក៏រួមបញ្ចូលទាំងការកំណត់ដាក់ដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិលើកិច្ចសន្យាទាំងឡាយណាដែលមានទឹកប្រាក់លើសពី១០០,០០០ដុល្លារដែរ។
- ឧស្សាហកម្មបោះពុម្ពគួរបញ្ចុះបញ្ចូលអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (GDEC) កម្ពុជា ឱ្យមានយន្តការលើកលែងពន្ធដារលើក្រដាសដែលយកមកប្រើប្រាស់ដើម្បីផលិតសម្ភារៈអប់រំ។
- MoEYSគួរផ្តល់ថវិកាសម្រាប់ទ្រទ្រង់បណ្ណាល័យតាមសាលាបឋមសិក្សានីមួយៗដោយផ្ទាល់ទៅក្នុងថវិកាប្រតិបត្តិរបស់សាលា ហើយថវិកានោះប្រើប្រាស់សម្រាប់តែទិញ ERMsតែប៉ុណ្ណោះ។

---

*៦៤ ការបែងចែកសរុបសម្រាប់ថវិកាប្រតិបត្តិការរបស់សាលាគឺ ៣១,២ លានដុល្លារ (ថវិកា MoEYS ២០២០)។*

# ដំណាក់កាលទី៥របស់ SCA ៖ ការគ្រប់គ្រងការចែកចាយ

ការគ្រប់គ្រងការចែកចាយរួមមានការរៀបចំ ការត្រួតពិនិត្យ និងសកម្មភាពដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនសៀវភៅពីប្រភពដើមទៅគោលដៅសម្រាប់សិស្សានុសិស្សប្រើប្រាស់ រួមទាំងការវេចខ្ចប់ ការធ្វើបញ្ជីសារពើភ័ណ្ឌ ការរក្សាទុកក្នុងឃ្លាំង និងភស្តុភារ។

ទោះបីជាបញ្ហាប្រឈមទាក់ទងនឹងការអភិវឌ្ឍន៍ចំណងជើង និងលទ្ធកម្មត្រូវបានដោះស្រាយក៏ដោយ ក៏សៀវភៅទំនងជាមិនទៅដល់ថ្នាក់រៀន និងកុមារដែលសិស្សានុសិស្សដែលកំពង់តែទន្ទឹងរង់ចាំប្រើប្រាស់នោះទេ។ នេះអាចមកពីហេតុផលជាច្រើន រួមទាំងលក្ខខណ្ឌអាកាសធាតុ និងភូមិសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមិនគ្រប់គ្រាន់ ថវិកាសម្រាប់ប្រើប្រាស់ដើម្បីចែកចាយមិនប្រាកដប្រជានិងពេលវេលាកំណត់ អំពើពុករលួយក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងកត្តាផ្សេងៗជាច្រើនទៀត។

## ការចែកចាយសៀវភៅនៅកម្ពុជា

នៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានបោះពុម្ព PDH និង រោងពុម្ព Sindy ទទួលខុសត្រូវលើការចែកចាយសៀវភៅសិក្សា។ PDH និងរោងពុម្ព Sindy ប្រគល់សៀវភៅដល់សាលារៀនតាមបណ្តាស្រុកនៅទូទាំងប្រទេសកម្ពុជា ដោយមានអ្នកម៉ៅការទទួលខុសត្រូវផ្នែកបច្ចេកទេស។ នៅពេលដែលសៀវភៅបោះពុម្ពរួច កម្មាធិការលទ្ធកម្មរបស់ RGC ត្រួតពិនិត្យដោយហ្មត់ចត់។ PDH ចំណាយពេលប្រមាណពីរខែដើម្បីចែកចាយសៀវភៅ។

ការចែកចាយសៀវភៅត្រូវបានសម្របសម្រួលបានលឿនជាងមុនច្រើនដោយសារតែមានការកែលម្អផ្លូវ និងស្ពានថ្មីៗក្រោមជំនួយថវិកាជាពិសេសពីរដ្ឋាភិបាលចិន និងរដ្ឋាភិបាលជប៉ុន។

លក្ខណ្ឌផ្លូវចេញចូលទៅកាន់ភូមិសាស្ត្រសាលារៀនមិនត្រូវបានកត់ត្រារក្សាទុកទាំងនៅក្នុងស្ថិតិអប់រំសាធារណៈ និងសូចនាករ ឬដោយ PDH ឬដោយរោងពុម្ព Sindyទេ។ នៅក្រោមប្រព័ន្ធបច្ចុប្បន្ន សៀវភៅសិក្សាទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានបញ្ជូនតាមផ្លូវទៅកាន់ការិយាល័យអប់រំស្រុក(DOE) ហើយបន្ទាប់មក នាយកសាលានីមួយៗមកប្រមូលយកចំណែករៀងៗខ្លួន។ ក្រោមលក្ខខណ្ឌអាកាសធាតុធម្មតា គេអាចធ្វើដំណើរទៅកាន់ DOE បាន។ ការដឹកជញ្ជូនទៅមកពីសាលារៀនមួយចំនួនអាចប្រឈមនឹងការអាក់ខានដោយសារការលិចលង់ក្នុងរដូវវស្សា។ ប៉ុន្តែដោយមានការពង្រឹងឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ វាអាចជួយរួមចំណែកកាត់បន្ថយបញ្ហាមួយនេះបាន។

## ទីផ្សារ និងបណ្ណាគារ

បន្ថែមពីលើការចែកចាយជាផ្លូវការដល់សាលារៀន មាតាបិតាសិស្ស និងអ្នកដទៃទៀតអាចទិញសៀវភៅនៅតាមទីផ្សារ និងបណ្ណាគារបាន។

### *ផ្សារអូរឫស្សីកន្លែងលក់សៀវភៅដុំ និងរាយ*

ផ្សារអូរឫស្សី គឺជាផ្សារបោះដុំដ៏ធំបំផុតរបស់រាជធានីភ្នំពេញ ដែលលក់ទំនិញជាច្រើនប្រភេទ។ ផ្នែកលក់សៀវភៅមានដូចជា សៀវភៅគោល សៀវភៅចម្លើយ(ថ្នាក់ទី៣-១២)ប្រលោមលោក SRMs បោះពុម្ពក្នុងស្រុកក៏ដូចជាសម្ភារៈអំណាន និងសម្ភារៈសិក្សាជាច្រើនផង។ ក្រុមការងារ GBAIA បានទៅសួរអ្នកលក់សៀវភៅពីរកន្លែងនៅផ្សារអូរឫស្សី ដែលកន្លែងទាំងពីរបានលក់នៅទីនោះអស់រយៈពេលជាង ២០ ឆ្នាំមកហើយ ហើយបានចែករំលែកចំណេះដឹងជាច្រើនស្ដីពីរបររកស៊ីផ្នែកសៀវភៅនេះ។

ទំនិញដែលលក់ដាច់ជាងគេគឺកញ្ចប់សៀវភៅសិក្សារបស់ MoEYS ។ ដូចដែលរៀបរាប់មកហើយថាសៀវភៅសិក្សាត្រូវបានផ្គត់ផ្គង់ដោយមិនគិតថ្លៃដល់សាលារដ្ឋ ប៉ុន្តែមាតាបិតាសិស្សសាលាឯកជន ឬអ្នកដែលត្រូវការសៀវភៅបន្ថែមរមែងទៅទិញពីទីផ្សារតាមមូលដ្ឋានរៀងៗខ្លួន។ កញ្ចប់សៀវភៅសិក្សារបស់ក្រសួង (មានសៀវភៅចំនួនបីក្បាល ៖ សៀវភៅគណិតវិទ្យា សៀវភៅវិទ្យាសាស្ត្រ និងសៀវភៅភាសាខ្មែរ) នឹងទទួលបានប្រាក់ចំណេញប្រហែល ០,១៤ ដុល្លារ ក្នុងមួយឈុត។ MoEYSមិនបានកំណត់តម្លៃសម្រាប់លក់រាយទេ ដូច្នេះម្ចាស់ហាងកាត់ថ្លៃ និងតថ្លៃគ្នាដោយផ្ទាល់ជាមួយអតិថិជន។ អ្នកលក់រាយនៅតាមបណ្ដាខេត្ត មកទិញពីផ្សារអូរឫស្សីដើម្បីយកទៅលក់បន្ត។

សៀវភៅរៀនភាសាអង់គ្លេស មានដូចជាសៀវភៅលំហាត់រៀនបង្កើនជំនាញភាសាអង់គ្លេសមានតម្រូវការខ្ពស់ទីពីរនៅលើទីផ្សារ។ សៀវភៅទាំងនេះច្រើនតែនាំចូលពីប្រទេសវៀតណាម។ សៀវភៅរៀនអក្ខរក្រមភាសាអង់គ្លេសក៏មានលក់ដែរក្នុងតម្លៃ០,៣៦ដុល្លារ ផ្ទុយទៅវិញបើធៀបនឹងសៀវភៅស្រដៀងគ្នាដែលផលិតដោយក្រសួង គឺគេលក់ក្នុងតម្លៃ១,២៣ ដុល្លារ ឯណោះ។

សៀវភៅដាក់លក់នៅផ្សារអូរឫស្សី ក៏មានតាំងលក់នៅតាមបណ្ណាគារនានា រួមមានសៀវភៅសិក្សា និងសៀវភៅអានច្រើនប្រភេទផ្សេងទៀត។ ទិញសៀវភៅមួយ ឬពីរក្បាល អតិថិជនទៅតូបលក់សៀវភៅរាយតូចៗ ប៉ុន្តែសម្រាប់ការទិញច្រើន ពួកគេនឹងទៅផ្សារអូឫស្សី។ អ្នកលក់សៀវភៅម្នាក់ដែលយើងបានសម្ភាសន៍រៀបរាប់ថា គេទិញសៀវភៅពីផ្សារអូរឫស្សីសម្រាប់លក់បន្ត។ តែបើសៀវភៅដែលមានតម្លៃថ្លៃ (ចាប់ពី៨ដុល្លារទៅ) គេត្រូវទៅទិញដោយផ្ទាល់ពីអ្នកនិពន្ធ ឬគ្រឹះស្ថានបោះពុម្ព ហើយយកទៅលក់បន្តឱ្យអ្នកអាន តាមបណ្ណាគារ ក៏នៅផ្សារអូឫស្សី។ អ្នកនិពន្ធទាក់ទងជាមួយអ្នកលក់សៀវភៅដើម្បីផ្សព្វផ្សាយសៀវភៅថ្មីរបស់គេ ដើម្បីសាកល្បងទីផ្សារសិន ហើយប្រសិនបើមានគេរកទិញសៀវភៅនោះច្រើន គេនឹងកុម្ម៉ង់យកមកជាច្រើនបន្ថែមទៀត។ ពេលនោះអ្នកនិពន្ធនឹងបញ្ចុះតម្លៃដោយទុកឱ្យអ្នកលក់បន្តបានចំណេញជាបន្តបន្ទាប់។

យើងក៏បានសួរអ្នកលក់សៀវភៅទាំងពីរនាក់នោះពីតម្លៃសៀវភៅអានដែលមាតាបិតាសិស្សទិញនៅតាមខេត្ត អ្នកទាំងពីរបញ្ជាក់ថាតម្លៃគឺ០,២៤ដុល្លារ សម្រាប់អ្នកទិញយកទៅប្រើផ្ទាល់ ហើយ០,១៩ដុល្លារសម្រាប់អ្នកទិញយកទៅលក់បន្ត។ ការដឹកជញ្ជូនផ្ញើអីវ៉ាន់មានតម្លៃសមរម្យ ជាធម្មតាមួយកញ្ចប់ថ្លៃ ២,៥ ដុល្លារ។

## *ការចែកចាយរបស់អង្គការស៊ីប៉ា*

អង្គការស៊ីប៉ាមានប្រព័ន្ធចែកចាយរបស់ខ្លួនផ្ទាល់ ដែលរួមមានការបញ្ជូនសៀវភៅដោយផ្ទាល់ពីរោងពុម្ពទៅកាន់ឃ្លាំងរបស់ខ្លួនដែលមានទីតាំងនៅកណ្ដាលរាជធានីភ្នំពេញ។ សៀវភៅត្រូវដឹកជញ្ជូនតាមមធ្យោបាយរបស់អង្គការផ្ទាល់ទៅកាន់ទីតាំងដូចខាងក្រោម ៖

- អង្គការមិនមែនរដ្ឋាភិបាល – ទំហំ ៧០% នៃការលក់របស់ស៊ីប៉ា។
- សាខានៃបណ្ណាគារធំៗចំនួន៤០នៅក្នុងទីក្រុង - IBC PBC ។ល។ ដែលមានទីតាំងនៅកណ្ដាលទីក្រុងភ្នំពេញ សៀមរាប និងបាត់ដំបង។ បណ្ណាគារទទួលបានការបញ្ចុះតម្លៃដល់៣០%។

មធ្យោបាយដឹកជញ្ជូនធ្វើឡើងដូចខាងក្រោម ៖

- រឺម៉ក់ម៉ូតូសណ្ដោងសម្រាប់ដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ។
- ឡានតាក់ស៊ីសម្រាប់ដឹកជញ្ជូនទៅតាមខេត្ត។
- រថយន្តក្រុងដឹកទៅកាន់បណ្ណាល័យទាំង៣០០ ដែលមានទីតាំងនៅគ្រប់ខេត្ត។
- តាមការចែកចាយជាលក្ខណៈឯកជន។

មានអ្នកចែកចាយឯករាជ្យតិចតួចនៅឡើយ។ DHL ផ្ដល់សេវាដឹកជញ្ជូនពេញផ្ទៃប្រទេស ប៉ុន្តែតម្លៃសេវា ថ្លៃណាស់សម្រាប់ការដឹកជញ្ជូនសៀវភៅនោះ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Bolloré Logistics[៦៥] នៅកម្ពុជាគឺជាក្រុមហ៊ុនលំដាប់ខ្ពស់ និងដំណើរការពេញលេញ ដែលផ្ដល់ការចែកចាយសម្រាប់គម្រោងតូចៗដែលផ្ដល់មូលនិធិដោយយូនីសេហ្វ និងអង្គការសហប្រជាជាតិ (UN)។ សេវាកម្មចែកចាយក្រៅផ្លូវការដែលគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា គឺរថយន្តតាក់ស៊ីក្នុងស្រុក និងរថយន្តតាក់ស៊ី១២កៅអី(សាំយ៉ុង)។ មធ្យោបាយទាំងនេះគេប្រើប្រាស់ជាទូទៅសម្រាប់ការដឹកជញ្ជូនទៅកាន់បណ្ដាខេត្តនានា ពោលគឺទៅកាន់បណ្ណាគារក្នុងខេត្តដែលជាអ្នកលក់ដុំបន្តក្នុងតំបន់ ឬក៏ដូចជាដឹកទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ ទាំងអ្នកដឹកជញ្ជូន និងអ្នកលក់ត្រូវរៀបចំវេចខ្ចប់ និងដឹកទៅដល់ទីប្រជុំជន ហើយបណ្ណាគារនៅទីនោះនឹងមកទទួលយកដោយខ្លួនឯង។

---

*៦៥ Bolloré Logistics (Cambodia) Ltd គឺជាការិយាល័យនៅទីក្រុងភ្នំពេញ នៃក្រុមហ៊ុនអន្តរជាតិបារាំង Bolloré ។ ត្រូវបានដកស្រង់ជាសាធារណៈនៅក្នុងទស្សនាវដ្ដី Paris Bourse ថាជាក្រុមហ៊ុនធំជាងគេមួយក្នុងចំណោមក្រុមហ៊ុនធំៗ ៥០០ នៅលើពិភពលោក។*

## តាមដាននិង ត្រួតពិនិត្យ

ដើម្បីដោះស្រាយភាពយឺតយ៉ាវ និងពុំមានប្រសិទ្ធភាពនៃប្រព័ន្ធបច្ចុប្បន្នដែលធ្វើនៅលើក្រដាស គម្រោងលើកកម្ពស់ការចែកចាយសៀវភៅនៅកម្ពុជា ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក (អនុវត្តដោយ World Education និង John Snow, Inc.) បានបង្កើតប្រព័ន្ធតាមដាន និងត្រួតពិនិត្យ ដែលជាបច្ចេកវិទ្យាសម្រាប់ដោះស្រាយក្នុងគោលបំណងកែលម្អប្រសិទ្ធភាពនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សាឱ្យកាន់តែច្បាស់លាស់។[៦៦]

ប្រព័ន្ធតាមដាន និងត្រួតពិនិត្យមានមុខងារសំខាន់ៗបី ៖

**១. ទទួលបានរបាយការណ៍ទិន្នន័យទាន់ពេលវេលា** ៖ សាលារៀនរាយការណ៍ពីទិន្នន័យបានទាន់ពេលវេលា ហើយប្រព័ន្ធតាមដាន និងត្រួតពិនិត្យ (Track and Trace) អាចជួយក្រសួងដែលជាថ្នាក់កណ្តាល ដើម្បីព្យាករណ៍បានត្រឹមត្រូវនូវតម្រូវការសៀវភៅសម្រាប់ធ្វើគម្រោងស្នើថវិកា និងធ្វើលទ្ធកម្ម។

**២. ការតាមដានពេលវេលាដំណាលគ្នា** ៖ តាមដានដំណាលគ្នានឹងការចែកចាយសៀវភៅ ដោយកំណត់នូវបញ្ហាយឺតយ៉ាវ បញ្ហាបាត់បង់ ឬបញ្ហាខូចខាត ដូច្នេះក្រសួងអាចចាត់វិធានការទាន់ពេលវេលា។

**៣. ការចូលរួមពីសហគមន៍** ៖ ទាមទារការចូលរួមពីសហគមន៍សាលារៀន ដែលត្រូវបញ្ជាក់ពីការទទួលសៀវភៅ និងចុះពិនិត្យក្នុងថ្នាក់រៀនក្រោយពីការចែកចាយដោយមិនឱ្យដំណឹងមុន ដើម្បីធានាថាសិស្សមានសៀវភៅសម្រាប់សិក្សាគ្រប់គ្រាន់មែន។ [៦៧]

តាមប្រព័ន្ធតាមដាន និងត្រួតពិនិត្យ ដំណើរការចែកចាយភាគច្រើនដំណើរការដោយស្វ័យប្រវត្តិ ដោយនាយកសាលាផ្ញើការព្យាករណ៍បរិមាណសៀវភៅតាមតេឡេក្រាមទៅប្រព័ន្ធតាមដាន និងត្រួតពិនិត្យ(TnT Telegram) [៦៨] កម្មវិធីនេះនឹងបញ្ជូនសារទៅកាន់ម៉ាស៊ីនមេកណ្តាល និងគណនាដោយស្វ័យប្រវត្តិនូវការព្យាករណ៍ដែលក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់ ដើម្បីកំណត់ថវិកា លទ្ធកម្ម និងការបញ្ចេញតាមតម្រូវការ។

---

*៦៦ ទទួលថវិកាពីធនាគារពិភពលោកតាមរយៈលទ្ធផលនៃគម្រោង All Children Reading (REACH) របស់ Trust Fund។ https://www.worldbank.org/en/programs/reach; https://worlded.org/WEIInternet/international/project/display.cfm?ctid=na&cid=na&tid=40&id=29763; https://www.jsi.com/project/results-based-financing-for-enhancing-book-distribution-in-cambodia/*

*៦៧ សម្រាប់ព័ត៌មានបន្ថែមស្តីពីការចូលរួមត្រួតពិនិត្យរបស់សហគមន៍ សូមអានដំណាក់កាលទី៦ ៖ ការប្រើប្រាស់សកម្ម។*

*៦៨ តេឡេក្រាមជាមធ្យោបាយសម្រាប់ទំនាក់ទំនងគ្នាសារអក្សរ ឬជាសារសម្លេងតាមសេវាកម្ម-IP ។ ផ្នែកទន់ដែលប្រើប្រាស់លើកម្មវិធីនេះឈ្មោះថាSalesforce។ តេឡេក្រាមអាចប្រើប្រាស់បាននៅលើប្រព័ន្ធAndroid, iOS, Windows Phone, Windows, macOS, និង Linux។*

នៅពាក់កណ្ដាលខែសីហាឆ្នាំ ២០២០ ប្រព័ន្ធតាមដាន និងត្រួតពិនិត្យ (TnT) ត្រូវបានដាក់ឱ្យដំណើរការទូទាំងប្រទេស ជាមួយនាយកសាលាដែលបានចុះឈ្មោះនៅលើកម្មវិធី និងផ្តល់ការបណ្តុះបណ្តាលតាមតម្រូវការ [៦៩]។ គិតត្រឹមខែមីនា ឆ្នាំ ២០២១ នាយកសាលាស្ទើរតែ ១០០% ប្រើប្រាស់ប្រព័ន្ធដើម្បីតាមដានសៀវភៅ។ ទាមទារឱ្យមានការបណ្តុះ-បណ្តាល និងការគាំទ្រជាបន្តបន្ទាប់សម្រាប់មន្ត្រីក្រសួង និងអ្នកតំណាង SSC ឱ្យបានទូលំទូលាយ ខណៈការអនុវត្តត្រូវបានពង្រីកតាមរយៈការបណ្តុះបណ្តាលធនធានឌីជីថល ដូចជាវីដេអូអនឡាញ សារជាអក្សរ និងវគ្គសិក្សាតាមអេឡិច-ត្រូនិក។[៧០]

PDH បានទទួលបន្ទុកក្នុងការរ៉ាប់រងលើចំណាយប្រចាំឆ្នាំនៃការធ្វើពង្រីកប្រព័ន្ធនេះឱ្យបានទូទាំងប្រទេស ដែលគេប៉ាន់ប្រមាណថាអស់ក្រោម១០,០០០ដុល្លារអាមេរិក។

ជំងឺរាតត្បាត COVID-19 រំខានដល់ដំណើរការTnTមួយចំនួន។ ការបិទទាំងស្រុងនៃ PDH ក្នុងរយៈពេលខ្លី ការប្រើប្រាស់បុគ្គលិករបស់រដ្ឋាភិបាលសម្រាប់ការចាក់វ៉ាក់សាំង ការបិទសាលារៀន ការបិទខ្ទប់ជាបណ្តើរៗ ការបន្តបិទសាលា និងការបណ្តុះបណ្តាលដោយផ្ទាល់មិនអាចធ្វើបានតាមការគ្រោងទុកក្នុងដំណាក់កាលចុងក្រោយ ទាំងនេះសុទ្ធតែជាមូលហេតុក្នុងការពន្យារពេល ហើយជាលទ្ធផលសកម្មភាពនានារបស់គម្រោងនៅជាប់គាំងស្ទួក។

## តាមដាន និងត្រួតពិនិត្យ - ការធ្វើសវនកម្មលើការចែកចាយ

នៅក្រោមប្រព័ន្ធតាមដាន និងត្រួតពិនិត្យ បញ្ជីចែកចាយសៀវភៅទៅដល់សាលារៀនត្រូវបានបង្កើតដោយស្វ័យប្រវត្តិពីប្រព័ន្ធ ដោយវាកាត់បន្ថយទាំងពេលវេលាបញ្ចូលទិន្នន័យ និងកំហុសដោយចៃដន្យក្នុងពេលបញ្ចូលទិន្នន័យនោះ។ ការដឹកជញ្ជូនត្រូវបានគ្រោងទុកទាន់ពេលវេលា។ ការដឹកជញ្ជូនត្រូវបានចុះបញ្ជីនៅពេលចាកចេញពីរោងពុម្ព ដោយអនុញ្ញាតឱ្យ PDH និងមន្ត្រីក្រសួងគ្រប់ជាន់ថ្នាក់អាចត្រួតពិនិត្យការដឹកជញ្ជូនបាន។ នៅឯសាលារៀន នៅDOEs នាយកសាលា និង/ឬនាយក SSC បញ្ជាក់ពីការទទួល និងចំនួនសៀវភៅដែលបានបញ្ជូនមក។ ការត្រួតពិនិត្យឆ្លងកាត់នៅក្នុងប្រព័ន្ធនេះនឹងជួយបង្ការកំហុសឆ្គងដែលអាចកើតមានជាយថាហេតុ និងញុំាងឱ្យ SSC មានតួនាទីសំខាន់សម្រាប់សហគមន៍។ ជាអកុសល ការបិទសាលារៀនដោយសារជំងឺរាតត្បាតនេះ មានន័យថាការបញ្ជាក់ទាំងនេះមិនទាន់អាចធ្វើទៅបានពេញលេញនៅឡើយ។

---

*៦៩ មន្ត្រី PDH បានបញ្ជូនព័ត៌មានស្តីពីការដាក់ឱ្យប្រើប្រាស់នៅក្នុងសប្តាហ៍ទីពក្នុងខែសីហា៖ «យើងទើបតែដាក់ឱ្យប្រើប្រាស់ TnT កាលពីសប្តាហ៍មុន។ ឥឡូវនេះនាយកសាលាកំពុងចុះឈ្មោះ ហើយយើងនឹងបណ្តុះបណ្តាលពួកគេបន្តិចម្តងៗ រហូតដល់ពួកគេអាចប្រើប្រាស់ TnT ឱ្យបានត្រឹមត្រូវ។»*

*៧០ ធនាគារពិភពលោក តម្លាភាព និងការលើកទឹកចិត្ត។*

## ប្រសិទ្ធភាពនៃការផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល

ប្រព័ន្ធTnT ត្រូវបានរចនាឡើងដើម្បីគាំទ្រការផ្តល់ហិរញ្ញប្បទានផ្អែកលើលទ្ធផល (RBF) ទោះបីជាគេមិនទាន់រាប់បញ្ចូលវាក្នុងដំណាក់កាលដំបូងនៃគម្រោងក៏ដោយ។ បច្ចុប្បន្ន រោងពុម្ពនិងអ្នកចែកចាយទទួលបានការបង់ប្រាក់១០០% នៃប្រាក់សរុបចែងក្នុងកិច្ចក្នុងកិច្ចសន្យារបស់ពួកគេ ប៉ុន្តែពួកគេត្រូវតំកល់ប្រាក់កក់១០%សិន។ គណៈកម្មាធិការត្រួតពិនិត្យលទ្ធកម្មរបស់ក្រសួងបញ្ចេញប្រាក់ទូទាត់នៅពេលដែលគេបំពេញលក្ខណៈវិនិច្ឆ័យទាំងអស់រួចរាល់ ពោលគឺវិក្កយប័ត្រទាំងអស់ត្រូវពិនិត្យបញ្ជាក់ដល់កន្លែងផ្ទាល់ ឬការសាកសួរតាមទូរស័ព្ទ និងការធ្វើដំណើរទៅកាន់សាលារៀនដើម្បីបញ្ជាក់ពីការទទួលសៀវភៅពិតប្រាកដឬទេ។

វាជាសក្តានុពលដ៏ប្រសើរដោយមានការដាក់បញ្ចូល RBF ទៅក្នុងប្រព័ន្ធTnT ហើយវាត្រូវបានដោះស្រាយក្នុងដំណាក់-កាលអនុវត្តសាកល្បងរួចហើយដែរ។ ដោយសារតែលក្ខខណ្ឌតម្រូវឱ្យបញ្ចូលទៅក្នុងកិច្ចសន្យាអ្នកទិញ និងអ្នកដឹកជញ្ជូន គេពុំមានពេលវេលាដើម្បីធ្វើដូច្នេះនៅឡើយទេ។ អ្នកជំនាញផ្នែកលទ្ធកម្មរបស់រដ្ឋាភិបាលគាំទ្រការបញ្ចូល RBF ដើម្បីបន្ធូរបន្ថយកាតព្វកិច្ចលទ្ធកម្ម ហើយវាក៏ជួយសម្រួលឱ្យមានការប្រកួតប្រជែងសម្រាប់អ្នកចែកចាយ។[៧១]

## ការរកឃើញរបស់ GBA ៖ ការគ្រប់គ្រងការចែកចាយ / ចំណុចខ្លាំង

- មានការរីកចម្រើនជឿនលឿនគួរឱ្យកត់សម្គាល់ក្នុងការកែលម្អ និងស្ថាបនាផ្លូវ និងស្ពានថ្មីៗនៅទូទាំងប្រទេស។
- ប្រព័ន្ធTnT សាកល្បង ដែលគេរំពឹងថាជួយកាត់បន្ថយការយឺតយ៉ាវក្នុងការរាយការណ៍ទិន្នន័យ ត្រូវបានដាក់ឱ្យដំណើរការសាកល្បងប្រកបដោយជោគជ័យ ហើយក្នុងខែសីហា ឆ្នាំ២០២០ ប្រព័ន្ធនេះត្រូវបានដាក់ឱ្យអនុវត្តទូទាំងប្រទេស។ ចំណុចសំខាន់ៗរួមមាន ៖ [៧២]
  - ប្រព័ន្ធTnTត្រូវបានគេផ្ទុកទិន្នន័យសំណើលើទម្រង់ក្រដាសដើម្បីបង្កើតបញ្ជីបែងចែកនៅថ្នាក់ជាតិ និងដើម្បីបោះពុម្ពឯកសារដឹកជញ្ជូន និងវិក្កយប័ត្រ។
  - MoEYS ទទួលបន្ទុកលើចំណាយដើម្បីដាក់ឱ្យដំណើរការនៃប្រព័ន្ធTnT ហើយកំពុងប្រើប្រាស់វាដើម្បីតាមដានសកម្មភាពលើប្រព័ន្ធនេះ។
  - បច្ចុប្បន្ន នាយកសាលាបានចុះឈ្មោះនៅលើថ្នាលប្រព័ន្ធនេះ (ចំនួន៨៥%បើគិតត្រឹមចុងឆ្នាំ២០២១) ហើយពួកគាត់បានចាប់ផ្តើមបញ្ជាក់តួលេខពីសៀវភៅក្នុងសាលារៀនខ្លួនហើយ។
- ប្រព័ន្ធTnT បង្កើតបញ្ជីចែកចាយដោយស្វ័យប្រវត្តិសម្រាប់សាលារៀន ដោយទាមទារឱ្យមានការត្រួតពិនិត្យពី

*៧១ ធនាគារពិភពលោក តម្លាភាព និងការលើកទឹកចិត្ត។*

*៧២ Day និង Hatch, តាមដាន & ត្រួតពិនិត្យសៀវភៅនៅកម្ពុជា។*

លោកគ្រូ-អ្នកគ្រូ និង SSC ដែលអាចកាត់បន្ថយកំហុសឆ្គងជាយថាហេតុ និងធ្វើឱ្យមានការចូលរួមពីសហគមន៍។

- ភាពសម្បូរបែបនៅលើទីផ្សារបង្កភាពងាយស្រួលឱ្យទទួលបានសៀវភៅ និងសម្ភារៈអំណានផ្សេងទៀតដល់សាលាឯកជន និងដល់មាតាបិតាសិស្ស។
- ប្រព័ន្ធចែកចាយដែលបានបង្កើតឡើងប្រាកដជាជួយគាំទ្រការលក់សៀវភៅសម្រាប់ទាំងទីផ្សារលក់ដុំ និងលក់រាយ។

## ការរកឃើញរបស់ GBA ៖ ការគ្រប់គ្រងការចែកចាយ / ចំណុចខ្សោយ

- ការបែងចែកការចែកចាយសៀវភៅរវាងរោងពុម្ពទទួលបានកិច្ចសន្យា និង PDH ធ្វើឱ្យមានការភ័ន្តច្រឡំ។
- ពុំមានប្រព័ន្ធសម្រាប់កែតម្រូវលើការចែកចាយជាថ្មីម្តងទៀតទៅដល់សាលារៀនដែលទទួលសម្ភារៈមិនគ្រប់នោះទេ។

## អនុសាសន៍របស់ GBA ៖ ការគ្រប់គ្រងការចែកចាយ

GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- ការចែកចាយគួរធ្វើឡើយដោយចំហរដល់ផ្នែកចែកចាយឯកជនឯករាជ្យ តាមរយៈការដាក់ដេញថ្លៃប្រកួតប្រជែងថ្នាក់ជាតិដើម្បីបានតម្លៃល្អបំផុត។
- លេខនិយាមកា GPS គួរតែភ្ជាប់ទៅតាមសាលារៀនទាំងអស់ក្នុងប្រព័ន្ធEMIS ហើយគ្រប់កញ្ចប់សម្ភារៈទាំងអស់ត្រូវមានស្លាកបារកូដដើម្បីសម្រួលក្នុងការតាមដាន។
- បើកវគ្គបណ្តុះបណ្តាលសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធតាមដាននិងត្រួតពិនិត្យគ្រប់កម្រិតទាំងអស់ ជាមួយការគាំទ្រនានាឱ្យបានគ្រប់គ្រាន់។

# ដំណាក់កាលទី៦របស់ SCA ៖ ការប្រើប្រាស់សកម្ម

*ការប្រើប្រាស់សកម្ម*សំដៅលើការប្រើប្រាស់សៀវភៅអានសម្រាប់ប្រកបដោយប្រសិទ្ធភាពពីសំណាក់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ ក៏ដូចជាអាណាព្យាបាលសិស្ស។ ផលប៉ះពាល់លើការអភិវឌ្ឍជំនាញអានរបស់កុមារពី ERMs និង SRMs ស្ថិតនៅលើការប្រើប្រាស់សៀវភៅ និងសម្ភារៈទាំងនោះប្រកបដោយប្រសិទ្ធភាពទាំងនៅក្នុងថ្នាក់រៀន និងនៅផ្ទះ។ កត្តាដែលជះឥទ្ធិពលដល់ការប្រើប្រាស់សៀវភៅ ទាំងក្នុង និងក្រៅសាលា សំខាន់ណាស់សម្រាប់ពិចារណាក្នុងការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។ ភស្តុតាងបានបង្ហាញថា គ្រូបង្រៀន និងអាណាព្យាបាលជារឿយៗខ្វះការយល់ដឹងពីសារៈសំខាន់នៃការហ្វឹកហាត់អំណាន និងរបៀបអនុវត្តអំណានឱ្យមានប្រសិទ្ធភាព។ លើសពីនេះ ការផ្គត់ផ្គង់សៀវភៅដែលមិនទៀងទាត់ និងការដាក់ទណ្ឌកម្មដល់សិស្សធ្វើខូចសៀវភៅអាចនាំឱ្យលោកគ្រូ-អ្នកគ្រូមិនចង់ឱ្យសិស្សានុសិស្សប្រើប្រាស់សៀវភៅ ហើយការផ្គត់ផ្គង់យឺតយ៉ាវមានន័យថា លោកគ្រូ-អ្នកគ្រូបង្រៀនដោយពុំបានប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀននៅក្នុងថ្នាក់រៀនឡើយ។

## ការប្រើប្រាស់សកម្មនៅក្នុងសាលារៀន

### បណ្ណាល័យរបស់សាលា និងការផ្សព្វផ្សាយសៀវភៅ

MoEYS បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូផ្សេងទៀត ដើម្បីអនុវត្តគំនិតផ្តួចផ្តើមសហគមន៍ដែលគាំទ្រដល់ការអភិវឌ្ឍន៍ជំនាញអំណាន និងលទ្ធផលការសិក្សា ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការលើកស្ទួយអក្ខរភាពដែលគេឃើញថានៅមានកម្រិតទាបនៅឡើយចំពោះសិស្សានុសិស្សតាមសាលាបឋមសិក្សាកម្ពុជា។ នៅក្នុងឆ្នាំ២០២១ ស្តង់ដារសម្រាប់បណ្ណាល័យនៅក្នុងសាលាបឋមសិក្សាត្រូវបានបង្កើតឡើងដើម្បីធានាគុណភាព និងប្រសិទ្ធភាពកាន់តែខ្លាំងនៃកន្លែងបណ្ណាល័យ ហើយផ្អែកលើការវាយតម្លៃលើ ៖

- បុគ្គលិក - បណ្ណារក្សដែលជាបុគ្គលិក និងទទួលបានការបណ្តុះបណ្តាល។
- បណ្ណាល័យ – អគារ និងធនធាន។
- កិច្ចការបច្ចេកទេសបណ្ណាល័យ – ការរៀបចំសារពើភ័ណ្ឌ និងសេវាកម្ម។[៧៣]

ដោយប្រើក្របខណ្ឌនេះ ក្រុមការងារ GBAIA បានធ្វើការសង្កេតខណៈពេលទៅធ្វើទស្សនកិច្ចសាលារៀនជាច្រើនដោយវិធីសាស្ត្រជ្រើសរើសដោយចៃដន្យ ហើយបានរកឃើញថាពួកគេអនុវត្តតាមអ្វីដែលខ្លួនបានចូលបណ្តុះបណ្តាលក្នុងវគ្គសិក្សាខ្លីៗធ្វើឡើងដោយ MoEYS និង អង្គការទស្សនៈពិភពលោកក្នុងឆ្នាំ ២០១៦ ។[៧៤]

*៧៣ អង្គការទស្សនៈពិភពលោក៖ ស្ថានភាពបច្ចុប្បន្ន និងការប្រើប្រាស់។*

*៧៤ អង្គការទស្សនៈពិភពលោក៖ ស្ថានភាពបច្ចុប្បន្ន និងការប្រើប្រាស់។*

បណ្ណាល័យខុសគ្នាពីសាលាមួយទៅសាលាមួយ ប៉ុន្តែនៅក្នុងដែលយើងទៅទស្សនកិច្ចនោះ មិនមានប្រើប្រាស់ ERMs នៅក្នុងថ្នាក់រៀនទេ។ ផ្ទុយទៅវិញ ពួកវាបានរក្សាសម្ភារៈទាំងនោះទុកក្នុងបណ្ណាល័យ ហើយសិស្សានុសិស្សមិនសូវបានប្រើប្រាស់សម្ភារៈទាំងនោះឡើយ។ តាមទ្រឹស្តី សិស្សានុសិស្សអាចខ្ចីសៀវភៅពីបណ្ណាល័យសាលាបានរយៈពេលរហូតដល់បីថ្ងៃ ប៉ុន្តែក្នុងសៀវភៅមួយក្នុងចំណោមសាលាដែលក្រុមយើងបានបានទៅទស្សនកិច្ចនោះ មិនមានទិន្នន័យទេ ព្រោះសាលាគ្មានបណ្ណារក្ស ទោះបីមានការទទូចស្នើសុំបណ្ណារក្សរៀងរាល់ឆ្នាំក៏ដោយ។ បណ្ណាល័យមានសភាពស្អាតដោយមានការដាក់តាំងសៀវភៅចម្រុះ ក្នុងនោះមានទាំងសៀវភៅអានជាភាសាអង់គ្លេស និងសំណៅសៀវភៅសិក្សាចាស់ៗ។ ជាទូទៅ បណ្ណាល័យដែលយើងទៅទស្សនកិច្ចនោះមិនបានដាក់បញ្ចូលប្រភេទនៃ ERMs ដែលត្រូវការចាំបាច់ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍អក្ខរកម្មកុមារតូចឡើយ។ សកម្មភាព និងសង្ហារិមមានកម្រិត ហើយទោះបីជាសៀវភៅអាចឱ្យខ្ចីតាមទ្រឹស្តីក៏ដោយ ក្នុងករណីសិស្សានុសិស្សណាធ្វើបាត់ ឬខូចសៀវភៅពួកគេ ប្រឈមនឹងការទិញយកមកដាក់សងវិញ។

លោកគ្រូ-អ្នកគ្រូបានបញ្ជាក់ថាឥរិយាបទរបស់មាតាបិតាសិស្សចំពោះសៀវភៅគឺជាបង្កជាឧបសគ្គដល់ការអាន។ ការសង្កេតនេះគឺស៊ីសង្វាក់គ្នានឹងទស្សនៈរបស់អ្នកបោះពុម្ពផ្សាយលើកឡើងវប្បធម៌អាន ក៏ដូចជាបញ្ហាមាតាបិតាសិស្សដូចខាងក្រោម ៖

- បារម្ភថាទិញសៀវភៅថ្លៃ (ឧ. មាតាបិតាសិស្សជឿថាសៀវភៅដែលមានអក្សរតិចក៏មិនសូវថ្លៃទេ)
- គិតថានៅក្មេងមិនទាន់ចេះអានមិនចាំបាច់មានសៀវភៅទេ។
- ចូលចិត្តអានសៀវភៅចាស់ៗ និងរឿងព្រេងទាក់ទងនឹងវប្បធម៌ជាងសៀវភៅនិពន្ធថ្មីៗ។
- ខ្វះខាតធនធានជាទូទៅ។
- ទទួលរងឥទ្ធិពលបច្ចេកវិទ្យាទូរស័ព្ទនៅក្នុងគ្រួសារ។

ថ្វីត្បិតមាតាបិតាសិស្សមានលទ្ធភាពទិញ ERMs ក៏ដោយ ក៏ភាគច្រើនគេមិនដឹងថាទិញពីកន្លែងណា ហើយមិនដឹងថាបណ្ណាគារមានលក់សម្ភារៈនោះដែរឬទេ។ សៀវភៅសិក្សាមានលក់នៅពេញផ្សារប៉ុន្តែពុំមាន ERMs ប្រកបដោយគុណភាពខ្ពស់នោះទេ។

គ្រូបង្រៀនមានក្តីសោមនស្សក្នុងការលើកកម្ពស់សៀវភៅ និងអំណាន ប៉ុន្តែបានបញ្ជាក់ថា ការអប់រំមិនមែនជាការទទួលខុសត្រូវរបស់លោកគ្រូ-អ្នកគ្រូតែម្នាក់ប៉ុណ្ណោះទេ វាទាមទារឱ្យមានការសាមគ្គីគ្នារវាងសហគមន៍ និងមាតាបិតាសិស្សផងដែរ។

## ការប្រើប្រាស់សកម្មនៅក្នុងសហគមន៍

មានការមើលឃើញជាទូទៅក្នុងចំណោមអ្នកសិក្សា និងអ្នកធ្វើការងារពាក់ព័ន្ធនឹងវិស័យអប់រំថាសង្គមខ្មែរមិនមានវប្បធម៌អំណានទេ។ គេបានផ្តល់ទឡ្ហីករណ៍មួយចំនួនជាអំណះអំណាង។ មានការអះអាងខ្លះផ្ទុយលើកឡើងថា កម្ពុជាជាសង្គមមួយពោរពេញដោយអ្នកចេះអក្សរផ្អែកតាមប្រវត្តិសាស្ត្រ ខ្មែរមានប្រពៃណីសរសេរកត់ត្រាយូរលង់ណាស់មកហើយ។ អ្វីជាបញ្ហាទាក់ទងនឹងការអានរបស់ប្រជាជាតិនេះ គឺបណ្តាលមកពីរបត់ប្រវត្តិសាស្ត្រនាពេលថ្មីៗនេះទៅវិញទេ។ អ្នកខ្លះទៀតលើកឡើងថា សង្គមខ្មែរភាគច្រើនមានទម្លាប់និយាយច្រើនជាងដូច្នេះហើយគេមិនសូវផ្តល់តម្លៃខ្លាំងលើសំណេរឡើយ។

ដូច្នេះហើយការអប់រំនៅក្នុងប្រទេសនេះត្រូវពឹងផ្អែកលើការចូលរួមយ៉ាងមោះមុតពីសំណាក់អាណាព្យាបាលសិស្ស និងសហគមន៍ – ជាមួយនឹងចំណាប់អារម្មណ៍របស់ពួកគេលើបច្ចេកវិទ្យា វេទិកាសង្គម និងកម្រិតនៃការតភ្ជាប់ – ដើម្បីពង្រឹងនិងពង្រីកការអានតាមមធ្យោបាយវប្បធម៌ និងគំនិតច្នៃប្រឌិត។

### ពិព័រណ៍សៀវភៅ

កម្ពុជារៀបចំពិព័រណ៍សៀវភៅនៅភ្នំពេញលើកដំបូងក្នុងឆ្នាំ២០១១ ដោយទាក់ទាញអ្នកចូលទស្សនាបាន១.០០០នាក់ក្នុងរយៈពេល៥ថ្ងៃ។ នៅក្នុងខែធ្នូ ឆ្នាំ២០១៩ ប្រាំបីឆ្នាំក្រោយមក ពិព័រណ៍នេះបានទាក់ទាញអ្នកចូលរួមបានចំនួន១៨០.០០០នាក់ ក្នុងនោះមានស្តង់តាំងលក់សៀវភៅចំនួន១៤០ បើគិតពីចំនួនអ្នកទស្សនានោះជាពិព័រណ៍ពាណិជ្ជកម្មដ៏ធំបំផុតនៅក្នុងប្រទេសកម្ពុជា។ មានអ្នកស្ម័គ្រចិត្តចំនួន ២០០ នាក់ និងលក់សៀវភៅដាច់អស់ ៣០០.០០០ក្បាល បើគិតជាតម្លៃប្រមាណជាង ១លានដុល្លារ។ ប្រធានសមាគមបណ្ណាល័យកម្ពុជា ជាប្រធានពិព័រណ៍សៀវភៅ។ ព្រឹត្តិការណ៍នេះបង្កើតឡើងដោយសមាគមបណ្ណាល័យកម្ពុជា ជាមួយគណៈកម្មការរៀបចំដែលមានតំណាងសុទ្ធតែបុគ្គលពាក់ព័ន្ធនឹងវិស័យសៀវភៅ [៧៥]។ សៀវភៅគ្រប់ប្រភេទត្រូវបានដាក់តាំងបង្ហាញ ចាប់ពីសៀវភៅកុមារ សៀវភៅប្រលោមលោក រហូតសៀវភៅឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេស។

ពិព័រណ៍សៀវភៅផ្សេងទៀតរួមមាន ទិវាសៀវភៅកុមារអន្តរជាតិ IBBY (ចុងខែមីនា-ដើមខែមេសា), ពិព័រណ៍សៀវភៅរៀបចំឡើងប្រចាំឆ្នាំដោយរដ្ឋាភិបាលក្នុងឱកាសទិវាជាតិអំណាន (១១ មីនា) និងមហោស្រពអក្សរសិល្ប៍ខ្មែរ (តុលា) ដែលធ្វើដំណើរចល័តតាមខេត្តនានា។ ក្រៅពីនោះក៏ធ្លាប់មានការរៀបចំពិធីជួបជុំយ៉ាងសស្រាក់សស្រាំរវាងអ្នកនិពន្ធអន្តរជាតិ និងមិត្តអ្នកអានរយៈពេលប្រាំថ្ងៃនាទឹកដីក្រុងកំពតដែរ។

---

*៧៥ គណកម្មការដឹកនាំរួមមាននាយិកាបណ្ណាល័យជាតិ, អតីតនាយិកាបណ្ណាល័យនៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ, ប្រធានបណ្ណាល័យរដ្ឋសភា, លោក ហុក សុទ្ធិ (ប្រធានសមាគមបណ្ណាល័យកម្ពុជា ប្រធានពិព័រណ៍សៀវភៅកម្ពុជា នាយកអង្គការស៊ីប៉ា) ក៏ដូចជាតំណាងមកពី Room to Read, អង្គការ Shanti Volunteer Association (SVA) និងវិទ្យាស្ថានបារាំង។*

## បណ្ណាល័យចល័ត

ដូចបានរៀបរាប់ខាងដើមហើយថា អង្គការស៊ីប៉ាដំណើរការបណ្ណាល័យចល័តរបស់ខ្លួនចំនួន១៧។ អ្នកឧបត្ថម្ភជាលក្ខណៈបុគ្គល ទ្រទ្រង់បណ្ណាល័យចល័តមួយដែលរួមបញ្ចូលការចំណាយប្រតិបត្តិការទាំងមូលដើម្បីដំណើរការកម្មវិធីនេះសម្រាប់រយៈពេលបីឆ្នាំ (សម្រាប់ឆ្នាំដំបូង ចំណាយអស់៣០.០០០ដុល្លារ និង ១៥.០០០ដុល្លារ សម្រាប់ឆ្នាំបន្តបន្ទាប់)។ ឡាននីមួយៗបើកបរចូលទៅកាន់ភូមិចំនួនប្រាំបួនរៀងរាល់សប្តាហ៍ហើយមានផ្ទុក សៀវភៅសម្រាប់កុមារអាយុពី ១ ទៅ ១៤ ឆ្នាំ។ អ្នកខ្ចីសៀវភៅភាគច្រើនបានចូលរួមសកម្មភាពបណ្ណាល័យនេះរយៈពេលមួយម៉ោងផងដែរ។

ស៊ីប៉ាក៏បើកបណ្ណាល័យនៅក្នុងពន្ធនាគារចំនួន ២៦ និងមានបណ្ណាល័យនៅក្នុងរោងចក្រកាត់ដេរ ចំនួន២៥ផងដែរ។ ម្តាយៗភាគច្រើនមិនចេះអក្សរបានខ្ចីសៀវភៅកុមារក្នុងកម្មវិធីទាំងនេះសម្រាប់ឱ្យកូនៗរបស់ពួកគេអាន។

អង្គការ Aide et Action ផ្តល់បណ្ណាល័យចល័តកម្រិតសហគមន៍ ដែលគ្រប់គ្រងដោយក្រុមប្រឹក្សានៅមូលដ្ឋាន។ ជាសរុបរៀងរាល់សប្តាហ៍ ក្រុមម៉ូតូសណ្តោងរ៉ឺម៉កបើកបរចូល៥០ភូមិ ដោយម៉ូតូរ៉ឺម៉កមួយៗចូលពី១០ទៅ ១២ភូមិ។ ការចំណាយប្រតិបត្តិការប្រចាំឆ្នាំគឺប្រមាណ១.២០០ដុល្លារ ដែលរាប់បញ្ចូលទាំងសម្ភារៈបំពាក់លើរ៉ឺម៉កម៉ូតូ និងប្រាក់ឧបត្ថម្ភបន្តិចបន្តួចដល់អ្នកស្ម័គ្រចិត្ត។ រ៉ឺម៉កម៉ូតូនីមួយៗផ្ទុកសៀវភៅប្រហែល៧០០ក្បាលដែលបានទិញពីផ្សារ – ជាធម្មតាសៀវភៅមួយមុខៗមានបីក្បាល។ រ៉ឺម៉កម៉ូតូសំចតក្នុងរយៈពេលប្រហែលពីរម៉ោងនៅទីតាំងនីមួយៗ ហើយទាក់ទាញសិស្សពី ១០ ទៅ ៣០ នាក់ក្នុងម្តងៗ។ ក្មេងៗប្រគល់សៀវភៅមកវិញមុនពេលគេចាកចេញ។ មានការបាត់បង់សៀវភៅតិចតួចដែរ តែគ្មានការពិន័យចំពោះអ្នកធ្វើឱ្យខូចខាតសៀវភៅទេ។

## ទិវាអំណាន

រាជរដ្ឋាភិបាលបានទទួលស្គាល់បញ្ហាអក្ខរកម្ម និងអំណាន ហើយបានផ្តួចផ្តើមព្រឹត្តិការណ៍សង្គម ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមរយៈទិវាអំណានជាតិ។ ទិវាអំណានជាតិលើកទីប្រាំមួយ ក្រោមប្រធានបទ «ការអានបណ្តុះបញ្ញា ការស្រាវជ្រាវ និងនិវានុវត្តន៍» ត្រូវបានប្រារព្ធឡើងនៅក្នុងខែមីនា ឆ្នាំ ២០២១ បន្ទាប់មកមានយុទ្ធនាការអានអនឡាញរយៈពេល ៦ ថ្ងៃនៅទូទាំងខេត្តដែលលើកកម្ពស់បណ្ណាល័យតាមសាលារៀន និងការអានតាមផ្ទះ។

## ការចូលរួមរបស់សហគមន៍ក្នុងការត្រួតពិនិត្យ

គណៈកម្មការទ្រទ្រង់សិស្ស (SSCs) អាចជាឧបករណ៍មួយក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ក៏ដូចជាការពិនិត្យដល់ក្នុងថ្នាក់ ដើម្បីធានាថាសៀវភៅសិក្សាបានបញ្ជូនមក ជាបន្តបន្ទាប់សម្រាប់កុមាររៀនសូត្រ។ វិធីសាស្ត្រនេះអនុវត្តទៅដោយជោគជ័យក្នុងដំណាក់កាលសាកល្បងប្រព័ន្ធTnT។ ក្នុងអំឡុងពេលនោះ ៤៤% នៃ SSCs បញ្ជាក់ពីការទទួលសៀវភៅនៅក្នុងដំណាក់កាលចែកចាយលើកទី១ ទោះបីជាមានកំហុសបច្ចេកទេសក៏ដោយ។ ប្រាំខែក្រោយមក

ចំនួននេះបានកើនឡើងដល់ ៧០% ។ SSCs បានធ្វើការត្រួតពិនិត្យដល់ទីកន្លែងក្នុងការប្រើប្រាស់សៀវភៅក្នុងថ្នាក់រៀន ដែលនេះជាលើកទីមួយហើយដែលសមាជិកសហគមន៍ឱ្យលោកគ្រូ-អ្នកគ្រូ និងនាយកសាលាទទួលខុសត្រូវចំពោះការប្រើប្រាស់សៀវភៅ [៧៦]។ ជាទូទៅគេគិតថា SSCs មានភារកិច្ចត្រួតពិនិត្យយ៉ាងសំខាន់លើការគ្រប់គ្រងសាលារៀននៅក្នុងប្រទេសកម្ពុជា ការសិក្សាបានបង្ហាញថាយន្តការត្រួតពិនិត្យគណនេយ្យភាពនៅក្នុងការចំណាយប្រតិបត្តិការសាលារៀនពុំមានប្រសិទ្ធភាពទេ ជាពិសេសនៅក្នុងសាលារៀនតូចៗ[៧៧]។ ផ្ទុយទៅវិញ ភាពជាដៃគូនាពេលថ្មីៗនេះរវាងសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ដូចជាវិទ្យាស្ថានខ្មែរសម្រាប់ការអភិវឌ្ឍន៍ជាតិ (KIND) និងបណ្តាញសម្ព័ន្ធសម្រាប់គណនេយ្យភាពសង្គម-អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានផ្តល់មធ្យោបាយគណនេយ្យភាពសង្គមថ្មី និងមានប្រសិទ្ធភាព។ កិច្ចសហការនេះបានគាំទ្រដល់ «គម្រោងតាមដានសៀវភៅសិក្សានៅកម្រិតមធ្យម ដែលរួមបញ្ចូលការបណ្តុះបណ្តាលលើឧបករណ៍ពង្រឹងសមត្ថភាពគណនេយ្យភាពសង្គមផងដែរ»។ ប្រព័ន្ធផ្សព្វផ្សាយទោះតាមរយៈការផ្សព្វផ្សាយវិទ្យុ តាមព្រឹត្តប័ត្រព័ត៌មាន តាមរយៈអនឡាញ និងតាមបណ្តាញផ្សព្វផ្សាយសង្គម មានតួនាទីសំខាន់ណាស់នៅក្នុងកិច្ចសហការប្រកបដោយជោគជ័យនេះ។ វាមិនត្រឹមតែចែករំលែកលទ្ធផលនៃការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងលើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈផងដែរ។

## ការរកឃើញរបស់ GBA ៖ ការប្រើប្រាស់សកម្ម / ចំណុចខ្លាំង

- លោកគ្រូ-អ្នកគ្រូបង្ហាញពីភាពសោមនស្សលើកកម្ពស់សៀវភៅ និងអំណាន ឱ្យបានជ្រួតជ្រាបដល់សហគមន៍ និងអាណាព្យាបាលសិស្ស។
- ទិវាជាតិអំណានលើកទីប្រាំរបស់ប្រទេសកម្ពុជាដែលបានប្រារព្ធឡើងនៅឆ្នាំ ២០២០ ដែលជាព្រឹត្តិការណ៍ប្រចាំឆ្នាំដែលឧបត្ថម្ភគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា និងព្រឹត្តិការណ៍នានាជាបន្តបន្ទាប់ដូចជាយុទ្ធនាការអំណានថ្នាក់ជាតិ សបញ្ជាក់ឱ្យឃើញថាមហាជនមានការយល់ដឹងអំពីតម្រូវការសៀវភៅសម្រាប់ការប្រើប្រាស់កាន់តែសកម្ម។

## ការរកឃើញរបស់ GBA ៖ ការប្រើប្រាស់សកម្ម / ចំណុចខ្សោយ

- នាយកសាលាមានការព្រួយបារម្ភអំពីការបាត់បង់សៀវភៅដែលបានមកពីការប្រើប្រាស់ថវិកាសាលា។
- បណ្ណាល័យតែត្រូវបិទទ្វារចោលដោយមិនប្រើប្រាស់។
- មានERMsល្អៗជាច្រើនសម្រាប់កុមារ ប៉ុន្តែសម្ភារៈទាំងនោះមិនបានដឹកជញ្ជូនដល់សាលារៀនទៀងទាត់ទេ។

---

*៧៦ ធនាគារពិភពលោក តម្លាភាព និងការលើកទឹកចិត្ត។*

*៧៧ Benveniste, Marshall, and Araujo. ការបង្រៀនក្នុងប្រទេសកម្ពុជា។*

- សៀវភៅ និងសម្ភារៈសិក្សានានាមានមិនគ្រប់គ្រាន់នៅក្នុងថ្នាក់រៀនសម្រាប់សិស្សពិការភ្នែក និងគថ្លង់។

## អនុសាសន៍របស់ GBA ៖ ការប្រើប្រាស់សកម្ម

GBA ផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- បណ្តុះបណ្តាល និងផ្សព្វផ្សាយលើបណ្តាញសង្គមដើម្បីលើកកម្ពស់ការប្រើប្រាស់ERMs នៅតាមថ្នាក់បឋមសិក្សា និងសម្រាប់សិស្សពិការ។ កិច្ចខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងស្មារតីរបស់គណកម្មការទ្រទ្រង់សាលាក្លាយជាកត្តាជំរុញសកម្មភាពអក្ខរកម្មនិងការអប់រំបរិយាបន្នដែលជាគោលដៅរបស់វិស័យអប់រំនៅកម្ពុជា។
- បង្រៀនសិស្សានុសិស្សនៅក្នុងថ្នាក់រៀនឱ្យចេះថែរក្សាទាំងក្រប និងសាច់ក្នុងសៀវភៅ។
- សាលារៀនគប្បីធានាបណ្ណាល័យទុកដាក់ និងត្រួតពិនិត្យសៀវភៅបានល្អ ហើយសៀវភៅទាំងនោះអាចឱ្យសិស្សខ្ចីយកទៅផ្ទះបាន។
- ណែនាំលោកគ្រូ-អ្នកគ្រូ និងអាណាព្យាបាលសិស្សតាមរយៈសកម្មភាពតស៊ូមតិផ្នែកអក្ខរកម្មដូចជាសារតាមវិទ្យុ និងសិក្ខាសាលាស្តីពីការប្រើប្រាស់ERMs (សម្រាប់ទាំងក្នុងថ្នាក់រៀន និងនៅតាមផ្ទះ) និងអង្គការនានាដែលធ្វើការផ្នែកបណ្ណាល័យនៅតាមមូលដ្ឋាន។

# សន្និដ្ឋាន

កម្ពុជាមានខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅដែលបានបង្កើតឡើងសម្រាប់សៀវភៅសិក្សា ប៉ុន្តែភាពខ្វះខាត ជាមូលដ្ឋាននៅតែបន្តរាំងរាការអនុវត្តឱ្យមានប្រសិទ្ធភាពលើកំណែទម្រង់ដែលមានចែងក្នុងសៀវភៅយុទ្ធសាស្ត្រចំណុច ២.៣ នៃ *ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣* របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានគោលបំណង «កែលម្អការផ្គត់ផ្គង់ និងការប្រើប្រាស់សៀវភៅគោល និងសម្ភារៈឧបទ្ទេសផ្សេងៗទៀត។» លើសពីនេះ ពុំមានមូលនិធិសមស្រប និងគ្រប់គ្រាន់សម្រាប់ ERMs ទេ។ ការទិញ ERMs ត្រូវបន្ទុកបណ្តាក់លើថវិកាប្រតិបត្តិការរបស់សាលានីមួយៗ ដូច្នេះកង្វះ ERMs នៅក្នុងថ្នាក់រៀនមានន័យថា កុមារមិនរៀនអានដូចដែលគួរទទួលបាននោះទេ។

គ្រឹះស្ថានបោះពុម្ពផ្សាយឯកជននៅប្រទេសកម្ពុជានៅមានកម្រិតតិចតួច បើទោះជាមានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ។ ដោយសារតែគម្រោងទទួលមូលនិធិពីម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់តែតំបន់ជាក់លាក់ ពួកគេមិនអាចដើរតួនាទីដើម្បីបំពេញកង្វះខាតនៃគ្រឹះស្ថានបោះពុម្ពផ្សាយផ្នែកឯកជននោះទេ។

វប្បធម៌ខ្មែរតាំងពីយូរលង់ណាស់មកហើយ គឺគេច្រើននិយាយជាជាងសរសេរ ដូច្នោះហើយវាពុំមានការតម្រង់ទិសទៅរកការកត់ត្រា ឬផលិតសម្ភារៈបោះពុម្ពច្រើននៅឡើយទេ។

នៅមានបញ្ហាប្រឈមនៃលក្ខណៈជាប្រព័ន្ធបន្ថែមទៀត ដែលអាចដោះស្រាយបានលុះត្រាតែមានការវាយតម្លៃជាមូលដ្ឋានជាមួយនឹងដំណោះស្រាយនយោបាយយ៉ាងម៉ឺងម៉ាត់ ប្រសិនបើត្រូវតែមានខ្សែសង្វាក់ផ្គត់ផ្គង់ដ៏រឹងមាំ និងមានប្រសិទ្ធភាព។ ការវាយតម្លៃដ៏ទូលំទូលាយលើផែនការអនុវត្តវិស័យសៀវភៅនឹងរួមបញ្ចូលចំណុចដូចខាងក្រោមនេះ ៖ (១) វិភាគអត្ថប្រយោជន៍នៃការចំណាយប្រៀបធៀបនៃយុទ្ធសាស្ត្រផ្សេងៗដែលពាក់ព័ន្ធនឹងការផ្តល់មូលនិធិសម្រាប់ ERMs (២) ការចូលរួមកាន់តែសស្រាក់សស្រាំពីវិស័យឯកជនក្នុងការដឹកជញ្ជូន ការបោះពុម្ព និងតែងនិពន្ធសៀវភៅ និងផ្នែកផ្សេងៗទៀត (៣) ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាថ្មី ដែលរួមបញ្ចូលកម្មវិធីសិក្សាដែលបានកែសម្រួលដោយផ្អែកលើការសួរឆ្លើយ និងការដោះស្រាយលំហាត់ដោយផ្អែកតាមវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល។

ដំណើរនេះទាមទារឱ្យមានការចូលរួមពីម្ចាស់ជំនួយជាបន្តបន្ទាប់ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងក្រោយមកនឹងត្រូវផ្ទេរឱ្យទៅ RGC និងវិស័យឯកជន។ អាទិភាពចម្បងសម្រាប់ដំណើរការនេះគឺការបង្កើតក្រុមការងារអភិវឌ្ឍន៍សៀវភៅរួម GBA (JBDWG) ជាមួយតំណាងមកពីសហគមន៍ម្ចាស់ជំនួយ ក្រសួងអប់រំ យុវជន និងកីឡា និងរោងពុម្ព និងគ្រឹះស្ថានបោះពុម្ពផ្សាយ។

បន្ទាប់មក JBDWG គួរតែពិចារណាបង្កើត BSDP ជាតិកម្ពុជា ដើម្បីដោះស្រាយបញ្ហាលំបាកៗដែលបានពណ៌នានៅក្នុងរបាយការណ៍នេះ ក៏ដូចជាអនុសាសន៍សម្រាប់ដំណាក់កាលនីមួយៗនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។ BSDP នឹង

ព្យាករណ៍ក្នុងរយៈពេល ២០ ឆ្នាំខាងមុខ ដើម្បីឱ្យវិស័យឯកជនចូលរួមជាមួយ និងកសាងសមត្ថភាពដើម្បីផ្គត់ផ្គង់សៀវភៅអានសម្រាប់ប្រកបដោយនិរន្តរភាព ហើយទីបំផុត RGC នឹងមានម្ចាស់ការក្នុងការផ្តល់មូលនិធិ និងអនុញ្ញាតឱ្យម្ចាស់ជំនួយបង្កើតយុទ្ធសាស្ត្រចាកចេញ។

BSDP គួរតែពិចារណាលើការពង្រឹងភាពជាដៃគូរវាងគ្រឹះស្ថានបោះពុម្ពផ្សាយក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលក្នុងគោលដៅមិនត្រឹមតែបង្កើតខ្លឹមសារកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រែក្លាយឧស្សាហកម្មនេះឱ្យមានស្វ័យយ័តភាព រកប្រាក់ចំណេញដោយឯករាជ្យ និងនិរន្តរភាពផងដែរ។ ផែនការនេះក៏អាចរួមបញ្ចូលថវិកាដែលបម្រុងទុកដើម្បីធានាថាមានការផ្គត់ផ្គង់ ERMs នៅក្នុងថ្នាក់រៀន និង/ឬបណ្ណាល័យ។

ការកែប្រែទៅលើប្រព័ន្ធបច្ចុប្បន្ននឹងញុំាងឱ្យមានការពុះពារបង្កើតវប្បធម៌អាន និងប្រើប្រាស់សៀវភៅឱ្យបានសមស្រប ហើយកុមារកម្ពុជាទាំងអស់មានសៀវភៅដែលមានភាសាចម្រុះសម្រាប់ពួកគេអាចអាន និងយល់បាន។

# ឧបសម្ព័ន្ធ១ ៖ គោលបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរ

គោលបំណងនៃការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ GBA គឺដើម្បីបញ្ជាក់ពីចំណុចខ្លាំង និងចំណុចខ្វះខាតក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅក្នុងប្រទេសកម្ពុជា និងផ្តល់ទាំងការវិភាគជាក់លាក់នៅក្នុងប្រទេសនេះ និងរួមចំណែកដល់ការយល់ដឹងជាសកលអំពីបញ្ហាប្រឈមនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ បញ្ហាប្រឈមទាំងនេះពិតជាខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ប៉ុន្តែតាមរយៈការស្រាវជ្រាវលើប្រទេសចំនួនប្រាំបីដែលមានលក្ខណៈទំហំ ភូមិសាស្ត្រ និងវប្បធម៌ផ្សេងៗពីគ្នា GBAIA នឹងឆ្លុះបញ្ចាំងបញ្ហាប្រឈមទូទៅដែលអាចត្រូវបានដោះស្រាយដោយភាគីពាក់ព័ន្ធ។ កម្ពុជាជាប្រទេសទីពីរដែលយើងបានជ្រើសរើសសម្រាប់ការស្រាវជ្រាវនេះ។

លទ្ធផលនៃការស្រាវជ្រាវមានពីរ ៖

១- អនុសាសន៍សម្រាប់ប្រទេសកម្ពុជាដើម្បីអនុវត្តពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួន។

២- នៅទីបញ្ចប់នៃការស្រាវជ្រាវរបស់ GBAIA មានចេញបទដ្ឋានគោលការណ៍ណែនាំដើម្បីឱ្យភាគីពាក់ព័ន្ធ (មានដូចជារដ្ឋាភិបាល ម្ចាស់ជំនួយ ដៃគូអនុវត្ត ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ល។) អាចស៊ើបអង្កេតលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅរបស់ជាតិ និងឆ្លៀតយកប្រយោជន៍ពីការស្រាវជ្រាវនេះដើម្បីធ្វើការកែលម្អ។

ការរកឃើញនៃ SCAs ទាំងអស់អាចយកទៅប្រើប្រាស់ដើម្បីបង្ហាញជាជម្រើស និងជាការសម្រេចចិត្តជាយុទ្ធសាស្ត្រដែលមានសូចនាករបញ្ជាក់ពីចំនួនលទ្ធផលដែលអាចសម្រេចបាន។

យើងគ្រោងវិធីសាស្ត្រស្រាវជ្រាវដោយប្រើប្រាស់ក្របខ័ណ្ឌគម្រោងដែលត្រូវតាក់តែងឡើងដោយក្រុម GBAIA រួមជាមួយនឹងសម្ភារៈមួយចំនួនដែលជាធាតុចូលពីគណៈកម្មាធិការដឹកនាំ GBA និង USAID។

## វិធីសាស្ត្រ

វិធីសាស្ត្រដែលប្រើប្រាស់ដើម្បីប្រមូលព័ត៌មានក្នុងប្រទេសកម្ពុជា រួមមានកិច្ចពិគ្រោះយោបល់ និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធគ្រប់ផ្នែកសរុបចំនួន ៥៧រូប[៧៨] ។ អ្នកធ្វើការងារពាក់ព័ន្ធទាំងឡាយត្រូវចាត់ជាប្រាំបួនក្រុម អនុលោមទៅ

*៧៨ សម្រាប់ព័ត៌មានលម្អិតនៃប្រភពព័ត៌មាន និងបុគ្គលដែលសម្ភាសន៍ សូមមើលឧបសម្ព័ន្ធទី ៣៖ អំណាននៅប្រទេសកម្ពុជា និងគម្រោងសម្រាប់អំណាន។*

ការចូលរួមរបស់ពួកគេនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ មុនពេលធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ក្រុមការងារ GBAIA បានរៀបចំបញ្ជីសំណួរចំនួន ២៧៦សំណួរ ដោយចែកចេញជា ៤៨ ប្រភេទ។ ប្រភេទនីមួយៗតាងឱ្យធាតុសំខាន់ៗនៃមុខងារដែលបានអនុវត្តនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។ សំណួរត្រូវធ្វើជូនទៅជាមុនដើម្បីធានាថាគេយល់សំណួរតាមប្រភេទនីមួយៗដោយហេតុថាយើងនឹងសួរទៅកាន់មនុស្សយ៉ាងហោចណាស់ម្នាក់ក្នុងចំណោមបីនាក់ នៃអ្នកពាក់ព័ន្ធទាំង៥ក្រុម។ បន្ទាប់មក ចម្លើយដែលយើងទទួលបានពីកិច្ចសម្ភាសន៍នោះនឹងត្រូវយកទៅផ្ទៀងផ្ទាត់ដើម្បីទទួលបានព័ត៌មានមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

យើងពុំមានប្រើប្រាស់កម្រងសំណួរក្នុងការស្រាវជ្រាវនេះទេ។ ក្រុមការងារបានតាក់តែងពិធីការដែលរាយសំណួរនឹងត្រូវសួរអំឡុងពេលសម្ភាសន៍សម្រាប់ក្រុមនីមួយៗក្នុងចំណោមក្រុមទាំងប្រាំបួន[៧៩] ។ កិច្ចសម្ភាសន៍ស៊ីពេលប្រមាណមួយម៉ោង ក្នុងនោះភាគច្រើនមានសមាជិកក្រុមរបស់យើងចំនួនពីររូបចូលរួម។ អ្នកទាំងពីកត់ត្រានូវអ្វីដែលខ្លួនទទួលបាន។ កំណត់ត្រាត្រូវប្រៀបធៀប និងពិភាក្សាផ្លោះប្តូរយោបល់គ្នាក្នុងក្រុមទាំងមូលនៅរៀងរាល់ពីរថ្ងៃម្តង។ ការសម្ភាសន៍មានភាពបត់បែន និងធ្វើឡើងក្នុងលក្ខណៈរៀបរាប់ឱ្យយល់រួចហើយទើបយើងជជីកសួរ។ ពិធីការស៊ើបអង្កេតត្រូវរៀបចំឡើងពីក្របខណ្ឌគម្រោង ដែលត្រូវបានប្រើប្រាស់ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅនៃខ្សែសង្វាក់ផ្គត់ផ្គង់ និងដើម្បីបង្ហាញពីចំណុចដែលអន្តរាគមន៍អាចធ្វើឱ្យប្រសើរឡើងនូវមុខងារនៃប្រព័ន្ធទាំងមូល។

*៧៩ អានឧបសម្ព័ន្ធ២៖ ឧបករណ៍ដែលយកមកប្រើប្រាស់ ៩ វិធីសាស្ត្រស្រាវជ្រាវ។*

# ឧបសម្ព័ន្ធ២ ៖ ឧបករណ៍ដែលយកមកប្រើប្រាស់ និងវិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រប្រមូលព័ត៌មានគឺតាមរយៈកិច្ចពិគ្រោះយោបល់ និងសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធជាច្រើន ដែលត្រូវរៀបចំជាប្រាំបួនក្រុមតាមផ្នែកសំខាន់ៗដែលគេបានចូលរួម។ ចំណាត់ក្រុមទាំងប្រាំបួននេះគឺ ៖

- ក្រសួងអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- គម្រោងថវិកា និងហិរញ្ញវត្ថុ
- ការិយាល័យជាតិស្ថិតិ និង EMIS
- ម្ចាស់ជំនួយ និងអ្នកអនុវត្ត
- គ្រឹះស្ថានបោះពុម្ពផ្សាយ អ្នកលក់រាយ និងអ្នកលក់ដុំ
- អ្នកធ្វើការនៅរោងបោះពុម្ព និងអ្នកដេរកិបសៀវភៅ
- អ្នកវេចខ្ចប់ និងអ្នកចែកចាយ
- ប្រធានការិយាល័យអប់រំស្រុក និងនាយកសាលា
- លោកគ្រូ-អ្នកគ្រូ មាតាបិតាសិស្ស និងក្រុមស្ត្រី

មុនពេលធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ក្រុមការងារ GBAIA បានរៀបចំបញ្ជីសំណួរចំនួន ២៧៦ ទាំងសំណួរជាក់លាក់ និងសំណួរទូទៅ ដែលគ្របដណ្តប់លើ ៤៨ ផ្នែក ៖

1. ស្ថិតិសេដ្ឋកិច្ច និងនយោបាយ
2. ហេដ្ឋារចនាសម្ព័ន្ធ
3. តំណតភ្ជាប់
4. គោលនយោបាយ និងការអនុវត្តរបស់រដ្ឋាភិបាល
5. ហិរញ្ញប្បទានសៀវភៅ
6. ភាសាសម្រាប់អាន និងសរសេរ
7. លោកគ្រូ-អ្នកគ្រូ
8. ការវាយតម្លៃលើអំណាន
9. ការប៉ាន់ប្រមាណលើតម្រូវការ
10. សៀវភៅតម្លៃ
11. ការបញ្ជូនទិញពីសាលា
12. ប្រភពចំណូលគ្រឹះស្ថានបោះពុម្ពផ្សាយ
13. ការចំណាយរបស់រដ្ឋាភិបាលលើសៀវភៅ
14. ផែនការលំហូរសាច់ប្រាក់
15. ដាក់កំហិតពេលវេលាសម្រាប់សៀវភៅមួយមុខៗ
16. សំណៅតែងនិពន្ធ និងរចនារូបភាព
17. ការស្ទង់មតិនៃសម្ភារៈអំណាន
18. ផែនទីទីផ្សារ
19. ស៊ើបអង្កេតការបោះពុម្ពឌីជីថលក្នុងស្រុក
20. ធនធានមនុស្សសម្រាប់ការបោះពុម្ព

21. ទទួលបានសៀវភៅបរទេស បកប្រែ និងកែសម្រួល
22. ការវាយតម្លៃការលួចចម្លង
23. នាំចូលសៀវភៅបរទេសដោយផ្ទាល់
24. គោលនយោបាយលទ្ធកម្មរបស់រដ្ឋាភិបាល
25. វិធីសាស្ត្រលទ្ធកម្ម
26. ការសរសេរឯកសារលទ្ធកម្ម
27. ការជ្រើសរើសសៀវភៅ
28. ប្រើកិច្ចសន្យាដូចមានចែងក្នុងឯកសារលទ្ធកម្ម
29. ការកែសម្រួល
30. ការរចនានិងការគូររូបភាព
31. រក្សាសិទ្ធិ
32. ការផ្តល់អំណះអំណាង និងការសាកល្បង
33. ការរៀបចំម៉ាស៊ីនថតឱ្យរួចរាល់ ថតចម្លងឯកសារ
34. ការបោះពុម្ព
35. ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា
36. ការធានារ៉ាប់រង
37. ការបង់ពន្ធគយ
38. ការរៀបចំទុកក្នុងឃ្លាំង
39. ភស្តុភារ
40. ការតាមដានការដឹកជញ្ជូន
41. ការដឹកជញ្ជូន
42. ទៅកាន់បណ្ណាគារ ហាងលក់សម្ភារៈសិក្សា និងតូបក្នុងផ្សារ
43. ការទទួល និងការពិនិត្យ
44. ការរៀបចំទុកដាក់ និងការថែទាំ
45. ការបំពេញស្តុក
46. ការចែកចាយសៀវភៅដល់ថ្នាក់រៀន
47. ការប្រើសៀវភៅក្នុងថ្នាក់រៀន
48. ការប្រើប្រាស់សៀវភៅនៅផ្ទះ

# ពិធីសារ

ពិធីសារចំនួនប្រាំមួយត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។ ពិធីសារទាំងនេះត្រូវបានដាក់លេខ និងដាក់ចំណងជើងដូចខាងក្រោម ៖

1. ពិធីសារសម្ភាសន៍ ២ សម្រាប់ម្ចាស់ជំនួយ និងអ្នកអនុវត្ត
2. ពិធីសារសម្ភាសន៍ ៤ សម្រាប់អ្នកបោះពុម្ពផ្សាយ
3. ពិធីសារសម្ភាសន៍ ៥ សម្រាប់អ្នកលក់រាយ និងលក់ដុំ
4. ពិធីសារសម្ភាសន៍៦ សម្រាប់បោះពុម្ព សម្រាប់អ្នកកិប សម្រាប់អ្នកវេចខ្ចប់ និងសម្រាប់អ្នកចែកចាយ
5. ពិធីសារសម្ភាសន៍ ១០ សម្រាប់ការិយាល័យជាតិស្ថិតិ និងអ្នកផ្តល់អិនធីណិត
6. ពិធីសារសម្ភាសន៍ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

យើងមានឯកសារទាំងអស់ តែដោយហេតុផលនៃទម្ងន់ឯកសារ យើងយកតែគំរូមួយប៉ុណ្ណោះគ្រាន់បង្ហាញគឺ៖ ពិធីសារសម្ភាសន៍ ១០ សម្រាប់ការិយាល័យជាតិស្ថិតិ និងការស្រាវជ្រាវតាមអិនធីណិត។

# ពិធីសារសម្ភាសន៍ ១០ សម្រាប់ការិយាល័យជាតិស្ថិតិ និងការស្រាវជ្រាវតាមអិនធឺណិត

## សេចក្តីផ្តើមទូទៅ

- ស្នើសុំការអនុញ្ញាតថត។
- សួរថាតើរបាយការណ៍អាចប្រើឈ្មោះអ្នកសម្ភាសន៍ ឬតួនាទីបានដែរឬទេ។
- ណែនាំដោយសង្ខេបអំពី GBAIA និង SCA រួមទាំងគោលបំណង និងវិធីសាស្ត្រ និងរបៀបប្រើប្រាស់ព័ត៌មាន
  - » បញ្ជាក់ពីលទ្ធផលដែលត្រូវការ។
  - » តាមទ្រឹស្តីវាយ៉ាងដូចម្តេចដែរ?
  - » តាមធាតុពិតវាយ៉ាដូចម្តេចដែរ?
  - » តើអ្វីខ្លះដំណើរការបានល្អ?
  - » តើអ្វីខ្លះជាឧបសគ្គ?
  - » តើអ្វីជាពេលវេលាសម្រាប់តំណភ្ជាប់នេះ?
- បង្ហាញ និងពន្យល់ពីភាពចាំបាច់នៃខ្សែសង្វាក់ផ្គត់ផ្គង់ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។
- បង្ហាញពីផ្នែករបស់អ្នកពាក់ព័ន្ធនៅក្នុង SC។

## សំណួរជាក់លាក់

### *ស្ថិតិសេដ្ឋកិច្ច និងនយោបាយ*

តើស្ថិតិចុងក្រោយរបស់ប្រជាជនមានប៉ុន្មាន?

តើកុមារមានអាយុពី ០ ទៅ ៩ ឆ្នាំមានប៉ុន្មានភាគរយ?

តើអត្រាកំណើនសេដ្ឋកិច្ចប៉ុន្មានភាគរយ?

តើប្រាក់ចំណូលគ្រួសារជាមធ្យមប៉ុន្មាន?

តើអ្វីជាលទ្ធភាពទិញរបស់ប្រជាជន?

### *សំណៅតែងនិពន្ធ និងរចនារូបភាព*

តើភាសាអ្វីដែលគេនិយមប្រើប្រាស់ជាងគេ និងមានកុមារប៉ុន្មានភាគរយ?

### *ហេដ្ឋារចនាសម្ព័ន្ធ*

តើមានកំពង់ផែប៉ុន្មានដែលអាចទទួលកប៉ាល់ដឹកទំនិញបាន?

តើមានអាកាសយានដ្ឋានប៉ុន្មានដែលគ្រប់គ្រងការដឹកជញ្ជូនទំនិញក្នុងស្រុក និងអន្តរជាតិ?

### *តំណភ្ជាប់*

តើមានប្រជាជនចំនួនប៉ុន្មានប្រើអិនធឺណិតបានជាប្រចាំថ្ងៃ/ប្រចាំសប្តាហ៍នៅផ្ទះ/សាលារៀន ឬមជ្ឈមណ្ឌលសហគមន៍របស់ពួកគេ?

តើមានសាលាបឋមសិក្សាប៉ុន្មានភាគរយភ្ជាប់អិនធឺណិត ហើយប្រើប្រាស់បានប្រចាំថ្ងៃ? (ការភ្ជាប់អិនធឺណិត/រាប់ទាំងបណ្តាញអិនធឺណិតខ្លាំង/មានល្បឿនលឿនដែលអាចប្រើប្រាស់សម្រាប់ចូលអានសៀវភៅ/ខ្លឹមសារឯកសារឌីជីថលសាមញ្ញៗ។)

តើមានប្រជាជនចំនួនប៉ុន្មានមានអាចប្រើប្រាស់ទូរស័ព្ទចល័តជាប្រចាំថ្ងៃ/ប្រចាំសប្តាហ៍ ហើយម៉ោងផ្សាយដូចម្តេចដែរ?

តើសេវាប្រព័ន្ធទូរស័ព្ទចល័តនោះមានកម្រិតដូចម្តេចដែរ?

### *ភស្តុភារ*

តើមានរបាយការណ៍ស្តីពីបញ្ហាប្រឈមអ្វីខ្លះជាមួយនឹងការចែកចាយនៅតាមផ្នែកនីមួយៗដែរឬទេ?

តើមានប្រព័ន្ធកូដប្រៃសណីយ៍ដែរឬទេ?

### *ភាសាសម្រាប់អាន និងសរសេរ*

តើមានផែនទីនៃការប្រើប្រាស់ភាសានៅក្នុងប្រទេសដែរឬទេ?

តើភាសាណាអ្វីខ្លះដែលគេប្រើជាប្រចាំនៅក្នុងប្រទេស? តើប្រជាជនចំនួនប៉ុន្មានប្រើប្រាស់ភាសានីមួយៗ ហើយភាសាទាំងនោះមានការបែងចែកភូមិសាស្រ្តផ្សេងៗពីគ្នាដែរឬទេ?

### *លោកគ្រូ-អ្នកគ្រូ*

តើប្រាក់បៀវត្សរបស់លោកគ្រូ-អ្នកគ្រូមានកម្រិតណាដែរ?

# ឧបសម្ព័ន្ធ៣ ៖ អំណាននៅកម្ពុជា និងគម្រោងនានាពាក់ព័ន្ធនឹងសៀវភៅ

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| OPIFER – Finland | ធនាគារអភិវឌ្ឍអាស៊ី (ADB) | កម្មវិធីសៀវភៅសិក្សាអប់រំមូលដ្ឋាន (BETP) | 1997 | |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| Aide et Action | អប់រំកុមារ | អប់រំសម្រាប់ទាំងអស់គ្នា ៖ វិធីសាស្ត្ររួមពីក្រុមអង្គការកម្ពុជាសម្រាប់កុមារក្រៅសាលារៀន (CCOSC) | កំពុងបន្ត | ក្នុងនាមជាសមាជិករបស់ CCOSC, Aide et Action ផ្តល់ប្រព័ន្ធអប់រំគ្រប់ជ្រុងជ្រោយ និងការអប់រំបរិយាបន្នដល់កុមារទាំងអស់គ្នា។ សកម្មភាពនានាមានជាអាទិ៍ ការគូសផែនទីសាលារៀន, ការកំណត់កុមារក្រៅសាលា, ការជួសជុលសាលារៀន, ការអប់រំចល័ត, MLE, ការអប់រំក្រៅប្រព័ន្ធ, និងការបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀន។<br>- បណ្ណាល័យនៅសាលារៀន<br>- កម្មវិធីបណ្ណាល័យខ្មែរ ៖<br>  » សៀវភៅជាPDFចំនួន៨៤៧ក្បាល<br>  » សៀវភៅអានជាសំឡេងចំនួន២៤៥ក្បាល<br>- ការបកប្រែសៀវភៅទៅជាភាសាជនជាតិភាគតិច<br>- បណ្ណាល័យចល័តរ៉ឺម៉កសណ្តោង<br>- សៀវភៅសម្រាប់កុមារនៅក្រៅសាលា<br>*ពាក្យគន្លឹះ ៖ បណ្ណាល័យសាលា, ជនជាតិភាគតិច, សៀវភៅពុម្ព* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| សម្រាប់គណនីយភាពសង្គម<br>(ANSA) | សភាពអឺរ៉ុប និង ក្រសួងសេដ្ឋកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ (អាល្លឺម៉ង់) | កំណើនសៀវភៅពុម្ព និង WASH – សម្រាប់បឋមសិក្សាក្នុងខេត្តរតនគីរី | 2017–2018 | កំណើនសៀវភៅពុម្ព និង WASH – សម្រាប់បឋមសិក្សាក្នុងខេត្តរតនគីរីគឺជាផ្នែកមួយនៃកម្មវិធីផ្តល់ជំនួយមានឈ្មោះថាការដោះស្រាយគម្លាតនៃការអនុវត្តក្នុងវិស័យកំណែទម្រង់អប់រំ ការប្រមូលផ្តុំសង្គមស៊ីវិល។ កម្មវិធីនេះសម្របសម្រួលដោយ NEP និង DVV អន្តរជាតិ។<br><br>កម្មវិធីនេះមានគោលបំណងដើម្បីរួមចំណែកក្នុងការកែលម្អសេវាអប់រំតាមរយៈយន្តការមតិត្រឡប់ និងការឆ្លើយតបយ៉ាងឆាប់រហ័ស។ គម្រោងនេះក៏បានឱ្យយុវជនចូលរួមដានការផ្តល់សៀវភៅសិក្សា កម្មវិធី WASH និងតស៊ូមតិឱ្យទទួលបានសេវាទាំងនេះនៅក្នុងសាលាបឋមសិក្សាចំនួន ៦០ នៅក្នុងស្រុកចំនួនបី (ស្រុកវើនសៃ ស្រុកតាវែង និងស្រុកបរកែវ) ខេត្តរតនគិរី។<br><br>*ពាក្យគន្លឹះ៖ សៀវភៅសិក្សា យុវជនស្ម័គ្រចិត្ត WASH ការត្រួតពិនិត្យការដឹកជញ្ជូនសៀវភៅសិក្សា* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| CARE – Cambodia | គ្មាន | ការអប់រំជនជាតិភាគតិច | 2019–2022 | គោលបំណងគឺដើម្បីបង្កើនអត្រាចុះឈ្មោះចូលរៀន និងរៀននៅកម្រិតបឋមសិក្សា និងបន្តដល់អនុវិទ្យាល័យ តាមរយៈការលើកកម្ពស់គុណភាពអប់រំ លក្ខខណ្ឌសាលា និងបរិយាកាសសិក្សាបរិយាបន្នកុមារមេត្រី ជាពិសេសសម្រាប់ក្មេងស្រីជនជាតិភាគតិច។ សកម្មភាពគំរូរួមមានការផ្តល់វគ្គបណ្តុះបណ្តាលកីឡា និងឧបករណ៍កីឡា ការបង្រៀនជំនាញសតវត្សន៍ទី២១ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ល។ នៅក្នុងខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។<br><br>*ពាក្យគន្លឹះ ៖ ការអប់រំ បរិយាបន្ន ការបណ្តុះបណ្តាល គរុកោសល្យ សៀវភៅនិងសម្ភារៈ សម្ភារៈឧបទ្ទេស កុមារី* |
| CARE – Cambodia | គ្មាន | ការអប់រំជនជាតិភាគតិច | 2013–2017 | គោលដៅរបស់គម្រោងគឺដើម្បីកែលម្អលទ្ធភាពទទួលបានការអប់រំក្នុងកម្រិតមធ្យមសិក្សា ដែលលើកកម្ពស់វប្បធម៌ចម្រុះ និងឈានមុខក្នុងការអប់រំកុមារី។ សកម្មភាពគំរូរួមមានការបង្កើតសម្ភារៈឧបទ្ទេសសិក្សាដែលសមស្របតាមវប្បធម៌ ដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន។<br><br>ភាគឦសាននៃប្រទេសកម្ពុជា<br><br>*ពាក្យគន្លឹះ ៖ សម្ភារៈឧបទ្ទេសសមស្របនឹងវប្បធម៌ កុមារី* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| CARE – Cambodia | អប់រំកុមារ | គម្រោងជនជាតិភាគតិចនៅកម្ពុជាសម្រាប់កុមារក្រៅសាលា (CCOSC) | 2014–2017 | គម្រោងនេះមានគោលបំណងបង្កើនលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ ដោយកែលម្អគុណភាព និងបទពិសោធន៍សាលាដែលសមស្របតាមវប្បធម៌ រួមមានសម្ភារៈ ការអនុវត្តការបង្រៀន និងការស្រាវជ្រាវ និងការតស៊ូមតិឱ្យមានការចុះឈ្មោះចូលរៀននៅសាលាឱ្យបានច្រើន។ ឧទាហរណ៍ គម្រោងបានរៀបចំសម្ភារៈ MLE សម្រាប់ចែកចាយនៅតាមសាលារៀន។<br><br>ស្រុកចំនួនប្រាំក្នុងខេត្តរតនគិរីគឺស្រុកបរកែវ ស្រុកវើនសៃ ស្រុកលំផាត់ ស្រុកកូនមុំ និងស្រុកអូរជុំ។<br><br>*ពាក្យគន្លឹះ៖ សម្ភារៈឧបទ្ទេសសមស្របនឹងវប្បធម៌, សម្ភារៈឧបទ្ទេសភាសាចម្រុះ* |
| KAPE (Kampuchea Action Primary Education) | មូលនិធិអាស៊ី | កម្មវិធីសៀវភៅសម្រាប់កម្ពុជា | 2017–2020 | គោលបំណងនៃគម្រោងនេះគឺដើម្បីលើកកម្ពស់ការអានភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ក៏ដូចជារួមចំណែកជួយដល់សាកលវិទ្យាល័យផងដែរ។ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបង្កើតវប្បធម៌នៃការអាន និងបើកលទ្ធភាពទទួលបានសៀវភៅ។ សកម្មភាពគំរូរួមមានការចែកចាយសៀវភៅ និងសម្ភារៈអប់រំផ្សេងទៀត និងការបណ្ដុះបណ្ដាលសម្រាប់អង្គការដែលធ្វើការលើសៀវភៅ។<br><br>*ពាក្យគន្លឹះ៖ ការរៀនភាសាអង់គ្លេស ការរកបានសៀវភៅ* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
| --- | --- | --- | --- | --- |
| KAPE | Phoenix Foundation | វិធីសាស្ត្រអានសម្រាប់កុមារ<br><br>(TRAC III) | 2017–2020 | គម្រោងនេះបានលើកកម្ពស់កុមារឱ្យទទួលបាននូវជំនាញអានដំបូងសំខាន់ៗតាមរយៈវិធីសាស្ត្រដ៏គ្រប់ជ្រុងជ្រោយដែលគិតគូរពីបរិយាកាសសិក្សារបស់កុមារទាំងមូល។ សកម្មភាពគំរូរួមមានការផ្តល់ប្រអប់សម្ភារៈអំណាន មិត្តបង្រៀនមិត្ត ថេប្លេតសម្រាប់M-learning បណ្ណាល័យសតវត្សទី ២១ និងការផ្សព្វផ្សាយ និងការចូលរួមពីមាតាបិតាសិស្ស។<br><br>តំបន់ជនបទ<br><br>*ពាក្យគន្លឹះ៖ ប្រអប់សម្ភារៈអំណាន, ជនបទ* |
| KAPE | USAID, World Vision, Australian AID, All Children Reading (ACR) | E-books ជាភាសាខ្មែរ<br>(E4K) | 2015–2017 | គម្រោងនេះបានសម្រេចយកវិធីសាស្ត្រផ្អែកលើបច្ចេកវិទ្យាដែលមានការណែនាំជាភាសាដើម និងសម្ភារៈអំណាន ដើម្បីឱ្យកុមារអានបានពិន្ទុល្អជាងមុន។ គម្រោងបានបង្កើត SmartBooks App ដើម្បីបង្កើនសមត្ថភាពអាន និងលើកកម្ពស់ និងបណ្តុះបណ្តាលគ្រូក្នុងការណែនាំផ្សេងៗ។<br><br>*ពាក្យគន្លឹះ៖ ភាសាខ្មែរ, កម្មវិធីអំណាន, សៀវភៅតាមកម្រិត* |
| KAPE | មូលនិធិអាស៊ី | បណ្ណាល័យឌីជីថលសម្រាប់កុមារ | កំពុងបន្ត | គោលបំណងរបស់គម្រោងគឺបង្កើនការចូលរួមរបស់កុមារឱ្យទទួលបានសម្ភារៈអំណានប្រកបដោយគុណភាព។<br><br>*ពាក្យគន្លឹះ៖ ភាសាខ្មែរ, កម្មវិធីអំណាន* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| NGO Education Partnership | | | | NEP គឺជាស្ថាប័នបង្គោលដ៏សំខាន់លើការងារអប់រំនៅកម្ពុជា។ NEPជាអង្គការសមាជិកភាពធ្វើការក្នុងវិស័យអប់រំចំនួន ១៤៤ (៩២ជាអង្គការក្នុងស្រុក និង ៥២ជាអង្គការអន្តរជាតិ ដោយផ្អែកតាមបញ្ជី NEP database ឆ្នាំ ២០១៨)។ បណ្តាញអង្គការនេះមានគោលបំណងលើកកម្ពស់កិច្ចសហការយ៉ាងសកម្មរវាងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យអប់រំ និងអ្នកតស៊ូមតិក្នុងនាមអង្គការសមាជិករបស់ខ្លួនក្នុងកិច្ចប្រជុំគោលនយោបាយ និងកិច្ចពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ |
| Room to Read | គ្មាន | ពុំមានប្រភពជាក់លាក់ទេ | | Room to Read ឬ RtR ផ្តល់ SRMs ដល់បណ្ណាល័យបឋមសិក្សារដ្ឋមួយចំនួន ដែលបានជ្រើសរើស គេបានបង្កើតSRM អំណានជាភាសាខ្មែរតាមកម្រិតចំនួន ១៥មុខក្នុងមួយឆ្នាំៗ និងលើកកម្ពស់វប្បធម៌អំណាន។. |
| See Beyond Borders – Cambodia | គ្មាន | កម្មវិធីអក្ខរកម្ម | គ្មាន | កម្មវិធីនេះមានគោលបំណងកែលម្អចំណេះដឹង វិធីសាស្រ្ត និងការអនុវត្តរបស់គ្រូបង្រៀនភាសាសម្រាប់ថ្នាក់ទី ១ ដល់ទី ៣ នៅក្នុងសាលាចំនួន ៥ ។. |
| Sipar NGO – International | គ្មាន | សាលាបឋមសិក្សា ៖ ស្ថាបនាបណ្ណាល័យ និងបើកវគ្គបណ្តុះបណ្តាល | 1993- បច្ចុប្បន្ន | អង្គការស៊ីប៉ាបានបង្កើតបណ្តាញបណ្ណាល័យចំនួន ៣០០ នៅក្នុងសាលាបឋមសិក្សា ហើយបច្ចុប្បន្នកំពុងពង្រឹងស្តង់ដារបណ្ណាល័យ និងបណ្តុះបណ្តាលបណ្ណារក្ស។<br>*ពាក្យគន្លឹះ ៖ បណ្ណាល័យ ការបណ្តុះបណ្តាលបណ្ណារក្ស* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| Sipar NGO – International | SMART Axiata | អំណានសម្រាប់ទាំងអស់គ្នា<br>កម្មវិធី ៖ បណ្ណាល័យចល័ត | គ្មាន | រថយន្តបណ្ណាល័យចល័តចំនួនប្រាំបួន និងបណ្ណាល័យម៉ូតូមួយគ្រឿង ដំណើរការក្នុង ៩០ កន្លែងក្នុងមួយសប្តាហ៍ នៅតំបន់ជាយក្រុងក្រីក្របំផុតនៃរាជធានីភ្នំពេញ និងខេត្តមួយចំនួននៅជុំវិញរាជធានី (កណ្តាល តាកែវ និងកំពង់ស្ពឺ) សៀមរាប និងរតនគិរី។<br>បណ្ណាល័យចល័តធ្វើសកម្មភាពអំណាន និងលើកកម្ពស់ការយល់ដឹងស្តីអំពី (សុខភាព អាហារូបត្ថម្ភ STEM ។ល។)។<br>*ពាក្យគន្លឹះ ៖ បណ្ណាល័យចល័ត* |
| Sipar NGO – International | UNICEF | កម្មវិធីអំណានសម្រាប់ទាំងអស់គ្នា ៖ ជ្រុងបណ្ណាល័យក្នុងមន្ទីរពេទ្យ | 2009- កំពុងបន្ត | ស៊ីប៉ាបានបង្កើតជ្រុងបណ្ណាល័យចំនួន ១៩ នៅក្នុងមន្ទីរពេទ្យកុមារសម្រាប់អ្នកជំងឺ ជាពិសេសកុមារកំពុងសម្រាកព្យាបាលជំងឺ។<br>*ពាក្យគន្លឹះ ៖ បណ្ណាល័យ* |
| Sipar NGO – International | Self-sustained Smart Axiata (digital) | កម្មវិធីបោះពុម្ពផ្សាយសៀវភៅ | 2000- បច្ចុប្បន្ន | គំរូសេវាកម្មរួមមានការលក់សៀវភៅទៅបណ្ណាគារ ដើម្បីគាំទ្រនិរន្តរភាព និងបន្តចែកចាយសៀវភៅកាន់បណ្ណាល័យដែលគាំទ្រដោយអង្គការស៊ីប៉ា ដោយគិតថ្លៃ។ ផលិតកម្មផ្តោតលើកុមារតូច (អាយុ ០-៦ ឆ្នាំ) ព្រមទាំងការផលិតសៀវភៅឌីជីថលផងដែរ។<br>*ពាក្យគន្លឹះ ៖ ការផលិតសៀវភៅ, ឌីជីថល, សៀវភៅអេឡិចត្រូនិក* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| The Asia Foundation – International | The Asia Foundation | តោះអាន (កម្ពុជា) | 2017- កំពុងបន្ត | មូលនិធិអាស៊ីបានបង្កើត បណ្ណាល័យឌីជីថលសៀវភៅកុមារជាភាសាក្នុងស្រុក រួមទាំងភាសាខ្មែរ ដែលគាំទ្រដល់ការផលិត និងការបកប្រែ SRMs។<br>កម្មវិធីមានដូចខាងក្រោម ៖<br>• កន្លែងសម្រាប់ប្រមូលផ្តុំអ្នកនិពន្ធ វិចិត្រករ និង អ្នកកែសម្រួលដើម្បីបង្កើតសៀវភៅសម្រាប់កុមារជាភាសាក្នុងស្រុកដែលមានគុណភាពខ្ពស់ (Book Labs)។<br>• សេវាបកប្រែតាមរយៈអ្នកស្ម័គ្រចិត្ត និងអ្នកជំនាញភាសាក្នុងស្រុក (សិក្ខាសាលាបកប្រែ)។<br>• ភាពជាដៃគូដើម្បីភ្ជាប់សហគមន៍ អង្គការ អ្នកអប់រំ អ្នកបោះពុម្ពផ្សាយ និងសាកលវិទ្យាល័យទៅនឹងប្រភពខ្លឹមសារ និងបង្កើតដំណោះស្រាយជាមូលដ្ឋាននិងមាននិរន្តរភាពចំពោះការ ខ្វះខាតសៀវភៅ (ឧ.Hackathons)។<br>*ពាក្យគន្លឹះ៖ សម្ភារៈអំណានបន្ថែម សៀវភៅអេឡិចត្រូនិក ភាសាខ្មែរ* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) – កម្ពុជា<br>អនុវត្តដោយ RTI International – United States | USAID, Global Partnership for Education (GPE), World Education (funder) | កុមាររៀន កុមារចេះ - កម្មវិធីជាតិសម្រាប់បណ្តុះបណ្តាលកុមារមត្តេយ្យ | 4/24/2017–4/24/2019 | កម្មវិធីជាតិសម្រាប់អំណានថ្នាក់ដំបូងជាភាសាខ្មែរ និងគណិតវិទ្យាសម្រាប់ថ្នាក់ទីមួយ និងទីពីរ។ កម្មវិធីនេះផ្តល់សម្ភារៈដែលមានគុណភាពខ្ពស់ឱ្យសាលារៀន (សៀវភៅគ្រូ សៀវភៅរឿង អក្សរចល័ត និងសៀវភៅអានបន្ថែម) និងការបណ្តុះបណ្តាលគ្រូអំពីរបៀបប្រើប្រាស់សម្ភារៈឧបទ្ទេសទាំងនេះ ក៏ដូចជាការបណ្តុះបណ្តាលគរុកោសល្យអន្តរកម្ម និងសកម្មភាពរីករាយផងដែរ។ *ពាក្យគន្លឹះ ៖ ភាសាខ្មែរ, គណិតវិទ្យា, សៀវភៅពុម្ព, សៀវភៅគ្រូ, បណ្តុះបណ្តាលគរុកោសល្យ* |
| | | All Children Reading (ACR) Cambodia | | គោលបំណងនៃគម្រោងគឺដើម្បីពង្រឹងជំនាញអំណានកម្រិតដំបូង (EGR) របស់កុមារនៅថ្នាក់ទី ១-៣ ក្នុងប្រទេសកម្ពុជា តាមរយៈលទ្ធផលបីដូចខាងក្រោម ៖<br>១-ក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព កម្មវិធី EGR ផ្អែកលើភស្តុតាងថ្នាក់ជាតិ ថ្នាក់ខេត្តថ្នាក់ស្រុក និងសាលារៀន។<br>២- ភាពជាដៃគូ និងភាពស៊ីសង្វាក់គ្នាត្រូវបានពង្រឹង ដើម្បីគាំទ្រដល់គោលដៅ EGR នៅក្នុងប្រទេសកម្ពុជា។<br>៣-ផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍន៍ EGR ដែលផ្អែកលើភស្តុតាងដែលសម្របសម្រួល និងចុះសម្រុងគ្នា ហើយកម្មវិធីសរសេរដែលអាចធ្វើទៅបាន ជាក់ស្តែង និងអាចវាស់វែងបាន ត្រូវទទួលយក និងអនុវត្តនៅសម្រាប់ថ្នាក់ទី ១-៣។<br>*ពាក្យគន្លឹះ ៖ សៀវភៅពុម្ព សម្ភារៈអានបន្ថែម ភាសាខ្មែរ កុមារពិការ* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| VSO – England and Wales | គ្មាន | គ្មាន | 2012–2016 | កម្មវិធីនេះបានផ្តល់សម្ភារៈឧបទ្ទេសជូនគ្រូបង្រៀនភាសាអង់គ្លេស និងបានផ្គត់ផ្គង់ SRMs សម្រាប់ថ្នាក់ទី ៤ ដល់ទី ៦ សៀវភៅគ្រូ សំឡេង ពាក្យគន្លឹះ និងអក្សរចល័ត ព្រមទាំងសៀវភៅសិស្សផងដែរ។<br>*ពាក្យគន្លឹះ ៖ ភាសាអង់គ្លេស, សម្ភារៈអំណានបន្ថែម* |
| VSO – England and Wales | គ្មាន | អប់រំបរិយាបន្ន | 2017- កំពុងបន្ត | ដោយចាប់ដៃគូជាមួយក្រសួងអប់រំកម្ពុជា VSO បង្កើនសមត្ថភាពគ្រូបង្រៀន និងផ្តោតលើការហ្វឹកហ្វឺន និងការបណ្តុះបណ្តាលលើវិធីសាស្ត្រកុមារមជ្ឈមណ្ឌល។<br>*ពាក្យគន្លឹះ ៖ ការបណ្តុះបណ្តាលគរុកោសល្យ* |
| World Education, Inc. – United States<br><br>John Snow, Inc. – United States | World Bank | ពង្រឹងការ ចែកចាយសៀវភៅ នៅកម្ពុជា | គ្មាន | គោលបំណងនៃគម្រោងគឺពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ដើម្បីធានាថាកុមារនៅក្នុងថ្នាក់បឋមសិក្សាមានសៀវភៅសម្រាប់រៀន។ គម្រោងនេះរៀបចំ និងសាកល្បងកម្មវិធី TnT ដែលជាដំណោះស្រាយបច្ចេកវិទ្យាដែលឱ្យគេមើលឃើញកាន់តែច្បាស់ និងប្រសិទ្ធភាពនៃខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅសិក្សា។ កម្មវិធីនេះគាំទ្រដូចខាងក្រោម ៖<br>• សាលារៀនរាយការណ៍ទិន្នន័យទាន់ពេលវេលា និងព្យាករណ៍តម្រូវការសៀវភៅបានត្រឹមត្រូវ។<br>• ក្រសួងអប់រំតាមដានការចែកចាយសៀវភៅសិក្សាតាមពេលវេលាជាក់ស្តែង និងអាចចាត់វិធានការទាន់ពេលវេលា។<br>• សហគមន៍ចូលរួមដើម្បីបញ្ជាក់ពីការទទួលសៀវភៅ និងពិនិត្យដល់ទីកន្លែងដើម្បីធានាថាសិស្សានុសិស្សមានសៀវភៅអាន។<br>*ពាក្យគន្លឹះ ៖ សៀវភៅសិស្ស, ខ្សែសង្វាក់ផ្គត់ផ្គង់, បច្ចេកវិទ្យា* |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| World Vision International – Cambodia | គ្មាន | Learning Roots | គ្មាន | កម្មវិធីនេះដោះស្រាយការវិវត្តន៍ និងតម្រូវការសិក្សារបស់កុមារចាប់ពីអាយុ ៣ ដល់ ៦ ឆ្នាំ ដោយរៀបចំពួកគេដើម្បីចូលរៀននៅកម្រិតបឋមសិក្សាដោយជោគជ័យ។ គម្រោងបានបង្កើតសម្ភារៈអំណានសម្រាប់មត្តេយ្យសិក្សាចំនួន ១០០០មុខ ។<br>*ពាក្យគន្លឹះ៖ កុមារតូច* |
| World Vision International – Cambodia | គ្មាន | Unlock literacy | គ្មាន | កម្មវិធីនេះគាំទ្រដល់កុមារនៅថ្នាក់ទី ១-៣ ដើម្បីបង្កើនជំនាញអំណានស្ទួលទាំងប្រាំ (អំណានដោយយល់)។<br>កម្មវិធីមានសកម្មភាពដូចខាងក្រោម៖<br>• ការជួសជុលសាលារៀនតាមរយៈការចូលរួមពីសហគមន៍។<br>• ការតស៊ូមតិស្វែងរកការទទួលស្គាល់ពីរដ្ឋាភិបាល និងទិញសៀវភៅ។<br>• ទិញសម្ភារៈលេង ប្រើកម្មវិធី Bloom ដើម្បីបកប្រែ។<br>*ពាក្យគន្លឹះ៖ សៀវភៅសិស្ស, សម្ភារៈអំណានបន្ថែម* |

| NGO, ទីភ្នាក់ងារ,& ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| Open Institute | | | 2008- កំពុងបន្ត | សកម្មភាពរួមមានដូចខាងក្រោម ៖<br>• បង្កើតសៀវភៅសិក្សា ICT ជាផ្លូវការនៅថ្នាក់ទី ១១ និងទី ១២។<br>• មត្តេយ្យសិក្សា ៖ បានបង្កើតសៀវភៅលំហាត់ចំនួន ១២ ក្បាល ដើម្បីបង្រៀនការសរសេរភាសាខ្មែរ និងរៀនលេខ និងសៀវភៅចំនួន ៤ លំដាប់ដើម្បីអភិវឌ្ឍជំនាញចលករឱ្យបានល្អប្រសើរ (ស្របតាមកម្មវិធីមត្តេយ្យសិក្សា)។ |
| Open Institute | UNESCO STEPCam | | | វិទ្យាស្ថានបើកទូលាយធ្វើការជាមួយនាយកដ្ឋានអប់រំបឋមសិក្សាកម្ពុជា (PED) ដើម្បីបង្កើតសៀវភៅគណិតវិទ្យាសម្រាប់គ្រូ និងសៀវភៅលំហាត់សម្រាប់ថ្នាក់ទី ១ និងទី ២ ។ |
| N/A | European Union | គាំទ្រដោយថវិការបស់សភាពអឺរ៉ុប | 2014–2020 | តាមរយៈសូចនាករជាច្រើនឆ្នាំក្នុងកម្មវិធីរបស់ខ្លួន សហភាពអឺរ៉ុបបានបែងចែកថវិកាចំនួន ១៤០ លានអឺរ៉ូ ដើម្បីជួយប្រទេសកម្ពុជាឱ្យសម្រេចបាននូវគោលបំណងសំខាន់ៗបីដូចខាងក្រោម ៖<br>១ ដើម្បីកែលម្អលទ្ធភាពទទួលបានប្រកបដោយសមធម៌សម្រាប់ទាំងអស់គ្នាក្នុងសេវាកម្មអប់រំ។<br>២ ដើម្បីបង្កើនគុណភាព និងភាពពាក់ព័ន្ធនៃការរៀន។<br>៣ ដើម្បីធានាបាននូវភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងបុគ្គលិកអប់រំគ្រប់កម្រិតប្រកបដោយប្រសិទ្ធភាព |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| UNICEF – International | Swedish International Development Agency (Sida) –Sweden | ជំនួយសម្រាប់កែលម្អសាលារៀន<br><br>(SIG) | 2014 | ស៊ីដាបានផ្តល់ជំនួយឧបត្ថម្ភសម្រាប់កែលម្អសាលារៀន (SIG) ដល់MoEYS។ គោលបំណងនៃ SIG ធានាឱ្យទទួលបានការអប់រំប្រកបដោយសមភាព និងគុណភាព។ SIG ធ្វើវិមជ្ឈការ លើកតម្កើងភាពម្ចាស់ការរបស់អង្គភាពថ្នាក់ក្រោមជាតិ ក៏ដូចជាសាលារៀន និងបង្កឱ្យមានការចូលរួមកាន់តែសស្រាក់សស្រាំពីសំណាក់អ្នកពាក់ព័ន្ធ រួមទាំងសមាជិកសហគមន៍ មាតាបិតាសិស្ស មន្ត្រីអប់រំនៅសាលា នៅDOE និងនៅមន្ទីរអប់រំខេត្ត (POE) គឺដើម្បីដោះស្រាយមូលហេតុនៃកំណើនអត្រាត្រួតថ្នាក់ បង្ការការបោះបង់ចោលការសិក្សា និងជំរុញឱ្យមានការចុះឈ្មោះឡើងវិញពីសំណាក់សិស្សបោះបង់ការសិក្សាទាំងនោះ។<br><br>កម្មវិធីនេះដំណើរការជាមួយនាយកដ្ឋានអប់រំកុមារតូច (ECE) នាយកដ្ឋានអប់រំបឋមសិក្សា នាយកដ្ឋានអប់រំមធ្យមសិក្សា និងនាយកដ្ឋានហិរញ្ញវត្ថុ POE DOE និងសាលារៀនទូទាំងប្រទេស។ |

| NGO, ទីភ្នាក់ងារ, & ដៃគូអនុវត្ត | ម្ចាស់ជំនួយ | គម្រោង ឬកម្មវិធី | កាលបរិច្ឆេទ | បរិយាយ |
|---|---|---|---|---|
| UNICEF – International | EU, Sida, GPE, UNICEF, USAID | មូលនិធិភាពជាដៃគូដើម្បីកសាងសមត្ថភាព (CDPF) | 2011–2023 | CDPF (២០,២ លានដុល្លារ) គឺជាកម្មវិធីដៃគូចម្រុះមានរយៈពេលច្រើនឆ្នាំ ក្នុងគោលបំណងពង្រឹងវិស័យអប់រំនៅកម្ពុជា ដើម្បីធានាថាកុមារកម្ពុជាកាន់តែទទួលបានការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ នៅក្នុងបរិយាកាសអំណោយផលដល់ការសិក្សា។<br>បញ្ជីស្ថាប័នអនុវត្តក្នុងរយៈកាលកន្លងមករួមមាន ៖<br>• ២០១១-២០១៦ ៖ នាយកដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នាយកដ្ឋានអប់រំបឋមសិក្សា នាយកដ្ឋាន ECE នាយកដ្ឋានមធ្យមសិក្សា នាយកដ្ឋានបណ្តុះបណ្តាលគរុកោសល្យ និងនាយកដ្ឋានកិច្ចការអាស៊ាន។<br>• ២០១១-២០១៥ ប៉ុណ្ណោះ ៖ នាយកដ្ឋាន ICT នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ។<br>• ២០១១-២០១៥ ប៉ុណ្ណោះ ៖ វិទ្យាស្ថានជាតិអប់រំ និង RUPP។<br>• ២០១១-២០១៧ ប៉ុណ្ណោះ ៖ អង្គការ CARE។<br>• សេវាស្ម័គ្រចិត្តក្រៅប្រទេស (VSO) ។<br>• វិទ្យាស្ថានគរុកោសល្យ (TEC) ។ |

# ឧបសម្ព័ន្ធ៤៖ បញ្ជីរាយនាមអ្នកសម្ភាសន៍តាមលំដាប់លំដោយ

| No | អង្គការ/ស្ថាប័ន | អ្នកផ្ដល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 1 | ការិយាល័យ USAID | **John Collins**, ប្រធានក្រុមអប់រំ និងកុមារ<br>**រស់ សិរីសត្យា**, អ្នកជំនាញគ្រប់គ្រងគម្រោងអប់រំ | 10-កុម្ភៈ |
| 2 | ពឹង លាងគ្រុយ (ផ្សារអូឬស្សី) | **ម្ចាស់តូបសៀវភៅ** | 11-កុម្ភៈ |
| 3 | តូបលេខ ៩៧-៩៨ | **ម្ចាស់តូបសៀវភៅ** | 11-កុម្ភៈ |
| 4 | MoEYS | **ឯ.ឧ ហង់ ជួនណារ៉ុន**, រដ្ឋមន្ត្រី និងមន្ត្រីក្រោមឱវាទ | 11-កុម្ភៈ |
| 5 | ប្រតិភូ EU ប្រចាំកម្ពុជា | **Michele Crimella**, ប្រធានកម្មវិធីអប់រំ | 12-កុម្ភៈ |
| 6 | Asia Foundation | **Meloney Lindberg**, តំណាងប្រចាំកម្ពុជា | 12-កុម្ភៈ |
| 7 | World Education | **គឹម តារា**, នាយក | 12-កុម្ភៈ |
| 8 | Image Printing | **ទាវ បណ្ឌួល** | 12-កុម្ភៈ |
| 9 | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (PDH) | **ឯ. ឧ. សុខ ឫទ្ធី**, ប្រធានអគ្គនាយកគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | 13-កុម្ភៈ |
| 10 | Aide et Action | **វ៉ែន សម្ផស្ស**, ប្រធានកម្មវិធីប្រចាំកម្ពុជា<br>**មករា សុគន្ធារិទ្ធ**, មន្ត្រីផ្នែកសិក្សាឌីជីថល | 13-កុម្ភៈ |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 11 | Sipar | **Béatrice Montariol**, ទីប្រឹក្សា<br>**អ៊ូច សុជានី**, អ្នកបោះពុម្ពផ្សាយ ផ្នែកក្រុមសៀវភៅរឿង<br>**ហ៊ុំ គន្ធា**, ទទួលបន្ទុកផ្នែកលក់ និងចែកចាយ | 13-កុម្ភៈ |
| 12 | Sipar | **ហុក សុទ្ធិ**, នាយក | 13-កុម្ភៈ |
| 13 | Room to Read | **ជា វណ្ណថា**, នាយក | 14-កុម្ភៈ |
| 14 | UNICEF | **Katheryn Bennett**, ប្រធានផ្នែកអប់រំ | 14-កុម្ភៈ |
| 15 | រោងពុម្ពភ្នំពេញ | **ហោ គង់សេង**, អ្នកគ្រប់គ្រង | 14-កុម្ភៈ |
| 16 | តូបលក់សៀវភៅ ទួលគោក | **សំរ៉ង** | 14-កុម្ភៈ |
| 17 | Save the Children | **ខូយ រ៉ានី**, ទីប្រឹក្សាផ្នែកអប់រំ | 14-កុម្ភៈ |
| 18 | បណ្ណាគារ តាព្រហ្ម (ផ្សារអូរឫស្សី) | **ស្រី នាង**, ម្ចាស់តូប | 15-កុម្ភៈ |
| 19 | Book World (ផ្សារអូរឫស្សី) | **ដាលីន**, ម្ចាស់តូបសៀវភៅ | 15-កុម្ភៈ |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 20 | បណ្ណាគារបន្ទាយស្រី (ផ្សារអូឫស្សី)<br>Beeads ឪសាញ និងផ្សព្វផ្សាយពាណិជ្ជកម្ម | **ស្រី ប៊ុនលី**, អ្នកគ្រប់គ្រងទូទៅ | 15-កុម្ភៈ |
| 21 | The Phnom Penh Post | Vikram Keo, ផ្នែកផ្សព្វផ្សាយពាណិជ្ជកម្ម | 15-កុម្ភៈ |
| 22 | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (PDH) | **ឯ. ឧ. សុខ ឫទ្ធី**<br>ប្រធានអគ្គនាយកគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | 17-កុម្ភៈ |
| 23 | តូបលេខ ៣-៤ (ផ្សារចាស់) | **ស្រី អូន**, ម្ចាស់តូប | 17-កុម្ភៈ |
| 24 | តូបលេខ ៧-៨ (ផ្សារចាស់) | **ឈឹម ចន្ធី**, ម្ចាស់តូប | 17-កុម្ភៈ |
| 25 | MoEYS (នាយកដ្ឋានផែនការ) | **ឡុង ឌឹម**, ប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានផែនការ | 17-កុម្ភៈ |
| 26 | World Vision Cambodia | **ព្រំ វុទ្ធី** | 17-កុម្ភៈ |
| 27 | វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី | **គ្រូបង្រៀន** | |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 28 | MoEYS (នាយកដ្ឋានអប់រំទូទៅ) | **ឯ. ឧ. ចាន់ សុភា,** ប្រធាននាយកដ្ឋានអប់រំបឋម<br>**កាន់ ពុទ្ធី,** អនុប្រធាននាយកដ្ឋានអប់រំបឋម | 18-កុម្ភៈ |
| 29 | MoEYS (នាយកដ្ឋាន ព័ត៌មានវិទ្យា) | **អ៊ំ ចាន់តារា,** អនុប្រធាន IT | 18-កុម្ភៈ |
| 30 | GIM Publishing | **ភឹម សុថាន,** នាយកគ្រប់គ្រង | 18-កុម្ភៈ |
| 31 | MoEYS (នាយកដ្ឋានគ្រប់គ្រង អប់រំព័ត៌មានវិទ្យា) | **ពង្ស ពិធិន,** ប្រធាននាយកដ្ឋានគ្រប់គ្រង អប់រំព័ត៌មានវិទ្យា | 18-កុម្ភៈ |
| 32 | John Weeks | អ្នកឯកទេសបោះពុម្ពផ្សាយសៀវភៅត្លុក និងសៀវភៅរឿងរូបភាព | 18-កុម្ភៈ |
| 33 | MoEYS (នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា) | **ស៊ុន ប៊ុណ្ណា,** នាយក DCD<br>**លឹម សុត្ថារិទ្ធ,** ប្រធានការិយាល័យ ផែនការ និងចែកផ្សាយសៀវភៅ | 18-កុម្ភៈ |
| 34 | Diamond Printing | **សួន វណ្ណិ,** អ្នកគ្រប់គ្រងផ្នែកលក់ | 18-កុម្ភៈ |
| 35 | EKP Printing | **អឿ អ៊ាង,** អ្នកគ្រប់គ្រង | 19-កុម្ភៈ |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 36 | MoEYS (នាយកដ្ឋានហិរញ្ញវត្ថុ) | ឯ. ឧ. ទេព តិយោឫទ្ធិ, នាយក | 19-កុម្ភៈ |
| 37 | រោងពុម្ព អង្គរធំ | សុខ វណ្ណា, អ្នកគ្រប់គ្រង | 19-កុម្ភៈ |
| 38 | RTI | Claire Wyatt, អ្នកគ្រប់គ្រង | 19-កុម្ភៈ |
| 39 | Image Printing | ទាវ បណ្តូល, អ្នកគ្រប់គ្រងផ្នែកលក់ | 19-កុម្ភៈ |
| 40 | រោងពុម្ពសុខ ហេង | អ៊ាវ ហុក, អ្នកគ្រប់គ្រងទូទៅ | 20-កុម្ភៈ |
| 41 | Sunbright Publishing | ឈុំ សុខហឿន, អ្នកគ្រប់គ្រង | 20-កុម្ភៈ |
| 42 | Sindy Import Export (Golden Printing Ltd) | ហួត គន្ធា, អ្នកគ្រប់គ្រងធុរកិច្ច<br>សុខ ចាន់ដារីន, អ្នកគ្រប់គ្រងផ្នែកលក់ | 20-កុម្ភៈ |
| 43 | MoEYS ផែនការ | ចាន់ សុភា, អគ្គនាយករងរំ | 20-កុម្ភៈ |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 44 | MoEYS (លទ្ធកម្ម) | **រ៉េន សុភាព,** អនុប្រធាន ការិយាល័យICT | 20-កុម្ភៈ |
| 45 | Sindy Import Export Co. Ltd. | **សុខ ចាន់ដារីន,** អ្នកគ្រប់គ្រងផ្នែកលក់ | 21-កុម្ភៈ |
| 46 | Matey Pack & Co | **ជា សុភ័ក្រ,** អ្នកចាត់ការទូទៅ | 21-កុម្ភៈ |
| 47 | បណ្ណាល័យបញ្ញវ័ន្ត | **សុខ ឡាក់,** សហស្ថាបនិក | 21-កុម្ភៈ |
| 48 | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (PDH) | **ឯ. ឧ. សុខ ឫទ្ធី,** ប្រធានអគ្គនាយកគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | 21-កុម្ភៈ |
| 49 | NGO Education Partnership (NEP) | **សេង ហុង,** នាយកប្រតិបត្តិ | 21-កុម្ភៈ |
| 50 | តូបលេខ ៣០-៣១ (ផ្សារអូរឫស្សី) | **សាំង សុថារី** | 21-កុម្ភៈ |
| 51 | TNS Printing/Matey Pack Co. Ltd | **ជា សុភ័ក្រ,** អ្នកចាត់ការទូទៅ | 21-កុម្ភៈ |
| 52 | អគ្គនាយកដ្ឋានអប់រំ | **ឯ. ឧ. ពុធ សាមិត្ត,** អគ្គនាយកអប់រំ | 21-កុម្ភៈ |

| No | អង្គការ/ស្ថាប័ន | អ្នកផ្តល់សម្ភាសន៍ | កាលបរិច្ឆេទ |
|---|---|---|---|
| 53 | បណ្ណាគារសេរីភាព | | 24-កុម្ភ: |
| 54 | តូបលក់សៀវភៅក្បែរសាលារៀន | | 24-កុម្ភ: |
| 55 | Sindy Import and Export Co. Ltd | **សុខ ចាន់ដារីន**, អ្នកគ្រប់គ្រងផ្នែកលក់ | 25-កុម្ភ: |
| 56 | USAID | **John Collins**, ប្រធានក្រុមអប់រំ និងកុមារ<br>**Sereisatya Ros**, អ្នកជំនាញគ្រប់គ្រងគម្រោងអប់រំ | 27-កុម្ភ: |
| 57 | Bolloré Logistics (Cambodia) Ltd | ហ៊ាង លី, អ្នកគ្រប់គ្រងផ្នែកអាហារ័ណ នីហរ័ណ និងឃ្លាំង | 28-កុម្ភ: |

# ឧបសម្ព័ន្ធ៥ ៖ កិច្ចប្រជុំរវាង GBA, រោងពុម្ព និងគ្រឹះស្ថានបោះពុម្ពផ្សាយ

ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០២០ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ដើម្បីជួយផ្តល់នូវបរិមាណកាន់តែច្រើន ហើយមានគុណភាពខ្ពស់ ដល់សម្ភារៈអំណានដែលពាក់ព័ន្ធដល់សិស្សានុសិស្ស និងអ្នកអាននៅក្នុងប្រទេសកម្ពុជា សម្ព័ន្ធសៀវភៅសកល (GBA) បានរៀបចំកិច្ចប្រជុំអ្នកបោះពុម្ព និងគ្រឹះស្ថានបោះពុម្ពចំនួន ៣០ នៅរាជធានីភ្នំពេញ។ ព្រឹត្តិការណ៍នេះបានផ្តល់ឱកាសសម្រាប់អ្នកចូលរួមដើម្បីស្វែងយល់បន្ថែមអំពីខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ ស្តាប់ឮពីឱកាសដែលផ្តល់ដោយបណ្ណាល័យឌីជីថលសកល (GDL) និងពិភាក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយសក្តានុពលចំពោះបញ្ហាជុំវិញការផ្តល់ ERMs នៅក្នុងប្រទេសកម្ពុជា។

ក្រៅពីកិច្ចពិភាក្សាជាផ្លូវការ នេះជាព្រឹត្តិការណ៍លើកទីមួយហើយដែលអ្នកចូលរួមជាច្រើនបានជួបមុខគ្នា ដែលនាំមកនូវការសន្ទនាពីនេះពីនោះក្រៅផ្លូវការជាច្រើន។

បន្ទាប់ពីការណែនាំអំពី GBA ដោយលោក Simon James (នាយកGBAIA) លោក Roel de Haas (ទីប្រឹក្សា GBAIA) បានណែនាំ និងបង្ហាញលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ–ទិដ្ឋភាពផ្សេងៗ បញ្ហាប្រឈម និងដំណោះស្រាយប្រកបដោយសក្តានុពល។ លោកបានគូសបញ្ជាក់អំពីឱកាសពាណិជ្ជកម្មដែលមានស្រាប់ និងលេចធ្លោសម្រាប់ឧស្សាហកម្មបោះពុម្ព និងការបោះពុម្ពផ្សាយ ហើយបានសង្កត់ធ្ងន់លើតម្រូវការសម្រាប់ការសន្ទនារវាងឧស្សាហកម្ម រដ្ឋាភិបាល និងម្ចាស់ជំនួយ។

Tracy Cordner សមាជិក GBAIA បានណែនាំឱ្យស្គាល់ GDL ដោយផ្តោត និងពិភាក្សាលើខ្លឹមសារដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណដោយចំហក្រោម Creative Commons CC-BY, [៨០] ដែលអនុញ្ញាតឱ្យអ្នកបោះពុម្ពផ្សាយ និងអ្នកបោះពុម្ពប្រើប្រាស់ខ្លឹមសារសម្រាប់ការសម្របខ្លួន–រួមទាំងការបកប្រែ– និងការបោះពុម្ពក្នុងគោលបំណងធ្វើពាណិជ្ជកម្ម។ មានការចាប់អារម្មណ៍ជាពិសេសពីរោងបោះពុម្ពចំនួនពីរលើដំណើរការនៃការបកប្រែ ការផ្លាស់ប្តូរ និងការប្រើប្រាស់

*៨០ ដូចដែលកំណត់លើគេហទំព័ររបស់ Creative Commons ៖ « អាជ្ញាប័ណ្ណអនុញ្ញាតឱ្យមានការចែកចាយ កាត់ខ្លឹមសារបញ្ចូលគ្នាយកទៅផលិតឡើងវិញនូវស្នាដៃរបស់លោកអ្នក (រហូតដល់ការយកទៅធ្វើជាពាណិជ្ជកម្ម) លុះត្រាតែមានការដាក់ឈ្មោះម្ចាស់ស្នាដៃដើម។ នេះជាអ្វីដែលអាជ្ញាប័ណ្ណអនុញ្ញាតឱ្យធ្វើបាន ដើម្បីជំរុញឱ្យមានការផ្សព្វផ្សាយនិងប្រើប្រាស់សម្ភារៈមានអាជ្ញាប័ណ្ណរឹតតែទូលំទូលាយ។» https://creativecommons.org/licenses/ (ប្រើប្រាស់ដោយទទួលបានការអនុញ្ញាតពី Creative Commons Attribution 4.0 International license.)។*

សម្ភារៈនៅក្នុង GDL។ សរុបមក ការចាប់អារម្មណ៍យ៉ាងខ្លាំងត្រូវបានបង្ហាញក្នុងការបកប្រែ និងកែសម្រួលសម្ភារៈនៅលើ GDL សម្រាប់កម្ពុជា។

ទោះបីជាអ្នកចូលរួមភាគច្រើននិយាយភាសាអង់គ្លេសក៏ដោយ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងជាភាសាខ្មែរតាមដែលអាចធ្វើទៅបាន ដោយមានឯកសារជាភាសាខ្មែរ និងការបកប្រែភាសាផ្ទាល់។

បន្ទាប់ពីការធ្វើបទបង្ហាញ មានការរៀបចំកិច្ចពិភាក្សាសម្របសម្រួលផ្តោតលើផ្នែកនីមួយៗនៃខ្សែសង្វាក់ផ្គត់ផ្គង់។ ការរកឃើញទាក់ទិននឹងខ្សែសង្វាក់ផ្គត់ផ្គង់ពិពណ៌នាដូចខាងក្រោមនេះ ៖

# ការរកឃើញពីកិច្ចពិភាក្សាអំពីខ្សែសង្វាក់ផ្គត់ផ្គង់

## ការធ្វើផែនការ និងការព្យាករណ៍

រោងបោះពុម្ព និងអ្នកបោះពុម្ពបានចូលរួមចំណែកក្នុងកិច្ចពិភាក្សាអំពីការធ្វើផែនការ និងការព្យាករណ៍ ដោយត្រូវបានកំណត់ថាជាបញ្ហាប្រឈមសំខាន់ៗដូចខាងក្រោម ៖

- អ្នកបោះពុម្ពផ្សាយសម្តែងការព្រួយបារម្ភអំពី**ទីផ្សារ** និងការ**ប្រកួតប្រជែងមានសភាពតូចចង្អៀត**នៅកម្ពុជា។
- ក៏មានការព្រួយបារម្ភផងដែរដែលថាគ្រួសារ**មិនអាចមានលទ្ធភាពទិញសៀវភៅ**សម្រាប់កូនរបស់ពួកគេបាន៖ ទោះជាយ៉ាងណាក៏ដោយ ដំណោះស្រាយដែលមានតម្លៃសមរម្យត្រូវបានស្នើឡើង រួមទាំងឥណទានសម្រាប់ការទូទាត់បន្ថែមប្រចាំសប្តាហ៍ដល់អ្នកលក់សៀវភៅផងដែរ។
- រោងពុម្ព និងអ្នកបោះពុម្ពផ្សាយបានបង្ហាញពី**កង្វះចំណេះដឹងអំពីទីផ្សារសៀវភៅ** ឧទាហរណ៍ ៖
  - មានអង្គការមិនមែនរដ្ឋាភិបាលជាង១០០ធ្វើការលើផ្នែកអប់រំនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែខាងបោះពុម្ព និងអ្នកបោះពុម្ពផ្សាយមិនមានការយល់ដឹងច្បាស់អំពីរបៀបទាក់ទងជាមួយពួកគេ។ ពួកគេមិនដឹងពីអ្វីដែលដៃគូអភិវឌ្ឍន៍កំពុងធ្វើ និងតម្រូវការបោះពុម្ពនាពេលអនាគតទេ ដូច្នេះខាងរោងពុម្ព និងអ្នកបោះពុម្ពមិនអាចរៀបចំផែនការទុកជាមុន ឬព្យាករណ៍អំពីតម្រូវការបានឡើយ។
- អ្នកចូលរួមបានទទួលចំណេះដឹងថាការធ្វើលទ្ធកម្មមិនចាំបាច់ចេញមកពីរដ្ឋាភិបាលតែមួយនោះទេ វាអាចមកពីអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអនុវត្តរបស់ម្ចាស់ជំនួយអន្តរជាតិក្នុងវិស័យនានា។ អ្នកចូលរួមមួយចំនួនបាននិយាយលេងស្នើថា អ្នកសម្របសម្រួលគួរបញ្ជូនអង្គការមិនមែនរដ្ឋាភិបាលឱ្យមកទិញសៀវភៅពីពួកគេឱ្យបានច្រើន។
- ពិភាក្សាលើ**កង្វះសៀវភៅនៅក្នុងសាលារៀន** ដូចជា**កង្វះខាតបណ្ណារក្សដែលមាន ឆន្ទៈខ្ពស់**ក្នុងបណ្ណាល័យតាមសាលារៀន ជាមួយនឹងការស្ម័គ្រចិត្តពីលោកគ្រូ-អ្នកគ្រូក្នុងការគ្រប់គ្រងបណ្ណាល័យ។ សៀវភៅនៅក្នុងបណ្ណាល័យសាលាតែងតែប្រើប្រាស់តិចតួច ឬក៏មិនបានប្រើប្រាស់តែម្តង ហើយជារឿយៗសៀវភៅទាំងនោះ

មិនសមស្របសម្រាប់សិស្សានុសិស្សទេ។ អ្នកបោះពុម្ពផ្សាយបាននិយាយថា ពួកគេកំពុងធ្វើការជាមួយរដ្ឋាភិបាលដើម្បីបង្កើតបណ្ណាល័យថ្មី ប៉ុន្តែព័ត៌មានជាក់លាក់មិនត្រូវបានគេបង្ហើបឱ្យដឹងឡើយ។

## ការបោះពុម្ពផ្សាយ

បញ្ហាប្រឈមចម្បងក្នុងការបោះពុម្ពផ្សាយមានដូចខាងក្រោម ៖

- ទីផ្សារសៀវភៅមានភាពចង្អៀត ហើយការផ្គត់ផ្គង់ ឬ**សមត្ថភាពផ្គត់ផ្គង់ លើសពីតម្រូវការ**។
- មានអ្នកបោះពុម្ពផ្សាយជាច្រើនប្រភេទដែលផលិតសៀវភៅដែលមានគុណភាព និងតម្លៃខុសៗគ្នា ឧទាហរណ៍ ដូចជាអ្នកបោះពុម្ពក្នុងស្រុកស៊ីប៉ា ធ្វើសៀវភៅមានគុណភាពខ្ពស់។
- អ្នកបោះពុម្ពផ្សាយតូចៗត្រូវតែរៀបចំយុទ្ធសាស្ត្រដើម្បីឱ្យចំណេញ។ ការឆ្លើយតបរបស់អ្នកបោះពុម្ពផ្សាយម្នាក់ គឺត្រូវបញ្ចេញសៀវភៅថ្មីៗចំនួន៥មុខក្នុងមួយឆ្នាំទើបបន្តរកស៊ីទៀតបាន។
- អ្នកបោះពុម្ពផ្សាយកំពុងបង្កើតសៀវភៅថ្មីដែលមានរូបភាពច្រើន និងអត្ថបទតិច ទោះបីដឹងថាមាតាបិតាសិស្សខ្វល់ពីតម្លៃសៀវភៅក៏ដោយ។ **មាតាបិតាសិស្សភាគច្រើនយល់ថាសៀវភៅដែលមានអក្សរតិចប្រាដកជាមានតម្លៃថោក**ជាង។
- ពួកគេបានសម្តែងការព្រួយបារម្ភទន្ទឹមនឹងកង្វះវប្បធម៌អំណាន ក៏មានបច្ចេកវិទ្យាទូរស័ព្ទបង្កការរំខានដ៏សំបើមក្នុងការអានសៀវភៅដែរ។
- **អ្នកបោះពុម្ពផ្សាយពិបាកសម្របខ្លួន**ទៅនឹងឱកាស និងស្ថានភាពទីផ្សារថ្មីៗ ជាពិសេសជាមួយទីផ្សារឌីជីថល។
- **ការកំណត់តម្លៃ**ត្រូវបានលើកឡើងជាបញ្ហាប្រឈមមួយ តើពួកគេអាចដឹងដោយរបៀបណាថាតើសៀវភៅមួយក្បាលគួរគិតថ្លៃប៉ុន្មាន?
- **បញ្ហារក្សាសិទ្ធិ** ៖ កង្វះព័ត៌មានអំពីអ្នកនិពន្ធ អ្នករចនារូបភាព និងអ្នកបោះពុម្ពសៀវភៅ ព្រមទាំងក្តីកង្វល់អំពីការប្តឹងផ្តល់ត្រូវបានពិភាក្សាទាំងអស់។
- បញ្ហាមួយដែលបង្ហាញដោយអ្នកចូលរួមម្នាក់ ៖ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗមាននីតិវិធីដេញថ្លៃ និងផែនការផ្ទាល់ខ្លួន ប៉ុន្តែមិនមែនរាល់អង្គការទាំងអស់ផលិតសៀវភៅក្នុងបរិមាណច្រើននោះទេ។ នេះធ្វើឱ្យវាចាំបាច់ដើម្បីឱ្យមានប្រព័ន្ធ និងដំណើរការនីមួយៗដែលពាក់ព័ន្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលដោយឡែកៗពីគ្នា ហើយវាពិបាកក្នុងការទាក់ទងពួកគេរួមគ្នាទាំងមូល នេះមានន័យថា ការ**វិនិយោគផ្នែករដ្ឋបាលអាចលើសពីការទូទាត់នៃការ**បោះពុម្ពសម្រាប់**អង្គការ**មិនមែនរដ្ឋាភិបាល។

- សក្ខីកម្មនៃ GDL ត្រូវបានទទួលដោយសាទរពីសំណាក់រោងពុម្ព និងអ្នកបោះពុម្ពផ្សាយជាច្រើន។

## ការផលិតនៅរោងពុម្ព

រោងពុម្ពបានកំណត់បញ្ហាប្រឈមជាក់លាក់មួយចំនួន ៖

- ការស្វែងរក**បុគ្គលិកជំនាញ**ដើម្បីដំណើរការ និងជួសជុលម៉ាស៊ីនបោះពុម្ពគឺជាបញ្ហាប្រឈមមួយ។ **ពុំមានកម្មវិធីបណ្តុះបណ្តាលជំនាញ**នេះនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ដូច្នេះមានតែពឹងផ្អែកខ្លាំងលើកម្មករជំនាញបរទេសសម្រាប់ការថែទាំ និងការដំឡើងឧបករណ៍។
- ការ**ដាច់អគ្គិសនីញឹកញាប់**ក៏បង្កជាបញ្ហា។
- ខ្វះខាតអ្នកជំនាញក្រាហ្វិក និងអ្នករចនារូបភាព។
- **អាករនាំចូល** និងពន្ធលើក្រដាសខ្ពស់ (ពន្ធនាំចូល ៧,៧% លើវត្ថុធាតុដើម និងពន្ធនាំចូល ១០%) ក៏ជាឧបសគ្គក្នុងការធ្វើសៀវភៅផងដែរ។
- **ការប្រកួតប្រជែង**ខ្លាំងនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែនៅប្រទេសចិន និងប្រទេសជិតខាងផ្សេងទៀត គេអាចដំណើរការបានកាន់តែថោក ដោយសារគេយកពន្ធទាប។
- **កង្វះខាតវត្ថុធាតុដើម** រួមទាំងក្រដាស និងទឹកថ្នាំ មានន័យថាវាប៉ះពាល់ដល់ពេលក្នុងសង្វាក់ផលិតកម្ម។

## ការចែកចាយ

- **សៀវភៅមានតម្លៃថ្លៃសម្រាប់ជនបទ** លទ្ធភាពទិញសៀវភៅធ្លាក់ចុះបើធៀបអ្នកទីក្រុងនិងអ្នកជនបទ។ នេះក៏ដោយសារតែលទ្ធភាពរបស់មាតាបិតាសិស្សនៅតំបន់ជនបទមានតិចតួចតែប៉ុណ្ណោះ ហើយសៀវភៅក៏មានតម្លៃខ្ពស់ទៅដល់ទីនោះសម្រាប់កូនពួកគេ។
- សៀវភៅភាគច្រើនត្រូវបាន**ផលិតនៅក្នុងទីក្រុងភ្នំពេញ** ជាកន្លែងដែលគេអាចរកប្រាក់ចំណេញបានច្រើន។
- អ្នកលក់សៀវភៅមួយចំនួនបានព្យាយាមលក់សៀវភៅតាមអនឡាញ ដោយទទួលការបញ្ជាទិញ ហើយបន្ទាប់មកគេក៏រៀបចំផ្ញើបញ្ជូនទៅកាន់អតិថិជនខ្លួន។
- អ្នកលក់រាយអាចយកចំណេញបានរវាង២៥%–១៥០%។

## ការប្រើប្រាស់សៀវភៅ និងឥរិយាបថរបស់មាតាបិតា

- អ្នកបោះពុម្ពផ្សាយបានបង្ហាញពីបញ្ហាជាមួយនឹងឥរិយាបថរបស់មាតាបិតាដែលថាសៀវភៅរបស់កុមារដែលមានរូបភាពច្រើនគឺ "ខាតលុយ" ហើយគួរតែមានអក្សរឱ្យបានច្រើន។ **ពាក្យច្រើនទៀតនៅលើទំព័រទើបសមជាមួយនឹងតម្លៃ** ហើយ**អក្សរច្រើនទើបក្មេងរៀនចេះ**បើតាមការគិតរបស់ឪពុកម្តាយសិស្ស។
- ឪពុកម្តាយភាគច្រើនមានទម្លាប់មួយ គឺថាមិនគួរឱ្យសៀវភៅទៅកូនតូចៗទេ ព្រោះពួកគេមិនទាន់ចេះអាននៅឡើយ។ គេមិនដឹងថាការអានដល់កុមារឱ្យកុមារស្តាប់ពិតជាជួយអភិវឌ្ឍសមត្ថភាពអំណានរបស់កូនៗរបស់គេទេ។ ដោយគេរំពឹងថាកុមារនឹងអានដោយខ្លួនឯង។
- ឪពុកម្តាយចូលចិត្តសៀវភៅចាស់ៗ ពាក់ព័ន្ធនឹងរឿងព្រេង ទំនៀមទម្លាប់ ជាងសៀវភៅថ្មីៗ ឬសៀវភៅដែលកើតចេញពីការច្នៃប្រឌិតថ្មីៗ។

## កិច្ចសហការគ្នារវាងរោងពុម្ព និងអ្នកបោះពុម្ពផ្សាយ

បញ្ហាទូទៅមួយនៅក្នុងឧស្សាហកម្មនេះគឺកង្វះកិច្ចសហការគ្នា។ កិច្ចប្រជុំនេះអាចជាជំហានដំបូងក្នុងការកែលម្អនូវកិច្ចសហការ និងការរៀបចំទូទាំងប្រទេស ៖

- នេះជាលើកទីមួយហើយដែលអ្នកឯកទេសទាំងនេះជាច្រើនបានជួបគ្នា ហើយបង្ហាញ**ចំណាប់អារម្មណ៍ជាទូទៅក្នុងការកែលម្អ**នូវកិច្ចសហការ។
- មានការពិភាក្សាដែលថាពុំទាន់មានបណ្តាញណាមួយធ្វើការសម្របសម្រួល ទាំងនៅក្នុងឧស្សាហកម្មបោះពុម្ព និងជាមួយម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីសហការគ្នាក្នុងការបោះពុម្ពសៀវភៅឡើយ។ **ពុំមានស្ថាប័នណាមួយដើរតួសំខាន់និងសកម្មក្នុងការធ្វើអន្តរាគមន៍** និងបង្កើតទំនាក់ទំនង ឬដោះស្រាយបញ្ហាដូចជាពន្ធលើក្រដាសជាដើមនៅឡើយទេ។
- លោក សុខ ឫទ្ធី មកពីគ្រឹះស្ថានបោះពុម្ព និងចែកចាយ (PDH) នៃក្រសួងអប់រំ និងដែលជា**ប្រធានសមាគមអ្នកបោះពុម្ពសៀវភៅកម្ពុជា បានអំពាវនាវដល់អ្នកផ្សេងទៀតឱ្យចូលជាសមាជិកនៃសមាគម**នេះ។ នៅចុងបញ្ចប់កិច្ចពិភាក្សានេះ លោកបានប្រាប់ថាយ៉ាងហោចណាស់មានសមាជិកថ្មីចំនួនបួនដែលចាប់អារម្មណ៍ពីការចូលជាសមាជិក។ យើងមើលទៅឃើញថាសមាគមនេះយល់ឃើញដូចគ្នានូវតម្រូវការទូទៅ។ លោក ឫទ្ធី បញ្ជាក់ថា កិច្ចប្រជុំរបស់សមាគមអាចនឹងត្រូវប្រព្រឹត្តទៅនៅខែមីនា ឬខែមេសា ឆ្នាំ២០២០។

# ជំហានបន្ទាប់

## ការបោះពុម្ព និងរោងពុម្ពនៅកម្ពុជា

- អ្នកចូលរួមបានសម្តែងការពេញចិត្តចំពោះកិច្ចប្រជុំ និងសម្រាប់ឱកាសក្នុងការបង្កើតបណ្តាញ និងសហការ។
- ការភ្ជាប់ទំនាក់ទំនងទៅកាន់សមាគមអ្នកបោះពុម្ពសៀវភៅកម្ពុជាអាចអនុញ្ញាតឱ្យបុគ្គល និងក្រុមហ៊ុនផ្សេងទៀតចូលរួមសមាគម និងធ្វើការរួមគ្នាដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលពួកគេប្រឈមមុខទាក់ទងនឹងតម្លៃ ការនាំចូលក្រដាស និងការផ្លាស់ប្តូរទីផ្សារឆ្ពោះទៅរកវេទិកាឌីជីថល និងអនឡាញ។
- ខាងរោងពុម្ពបង្ហាញចំណាប់អារម្មណ៍លើទិន្នន័យ និងស្ថិតិ ដើម្បីជួយពួកគេឱ្យយល់ថាតើពេលណា និងចំនួនសៀវភៅប៉ុន្មានអាចត្រូវបោះពុម្ព។
- ត្បិតតែប្រធានបទស្តីពីការបញ្ជូនសៀវភៅចេញទៅកាន់ខេត្ត និងតំបន់ដាច់ស្រយាលដែលជារឿងចាំបាច់សម្រាប់ទាំងសិស្សានុសិស្សនិងអ្នកអាន មិនត្រូវបានលើកឡើងដោយផ្ទាល់នៅក្នុងកិច្ចប្រជុំក្តី តែប្រធានបទនេះសំខាន់ណាស់ ហើយវាក៏ជាឱកាសសម្រាប់ឱ្យរោងពុម្ព និងគ្រឹះស្ថានបោះពុម្ពជ្រួតជ្រាបជាព័ត៌មានដែរ។
- នាពេលបច្ចុប្បន្ននេះ រោងពុម្ពឆ្លើយតបតែទៅនឹងតម្រូវការរបស់អតិថិជនតែប៉ុណ្ណោះ ហើយមិនបានឈ្នុសឈ្នុលស្វែងរកឱកាសពង្រីកបន្ថែមធុរកិច្ចខ្លួននៅឡើយទេ។ ពួកគេប្រឹងប្រែងតែទៅរកអតិថិជនសក្តានុពលប៉ុណ្ណោះ (ឧ. អង្គការក្រៅរដ្ឋាភិបាល និងដៃគូអនុវត្ត) ដើម្បីពិភាក្សាអំពីតម្រូវការ និងទាក់ទាញអាជីវកម្មរបស់ខ្លួន។
- ទោះជាយ៉ាងណា ពួកគេត្រូវការបណ្តុះបណ្តាលសម្រាប់ពង្រីកពាណិជ្ជកម្ម គឺដើម្បីអាចសរសេរ និងឆ្លើយតបបានត្រឹមត្រូវទៅនឹងសំណើសុំតម្លៃ (RFQs) ប្រសិនបើពួកគេចង់បានអតិថិជនកាន់តែច្រើននោះ។
- ម្យ៉ាងវិញទៀត មានតម្រូវការខ្ពស់ក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេសរោងពុម្ពផងដែរ។ ជារឿងការល្អមួយដែលគេអាចអញ្ជើញអ្នកជំនាញមកពីប្រទេសក្រៅមកធ្វើការបណ្តុះបណ្តាលរយៈពេលមួយសប្តាហ៍លើប្រតិបត្តិការ និងជួសជុលម៉ាស៊ីនបោះពុម្ព។
- មានការយល់មិនច្បាស់អំពីអាជ្ញាប័ណ្ណបោះពុម្ពដែរ ហើយទាំងអ្នកនៅរោងពុម្ព និងអ្នកបោះពុម្ព នឹងទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាលស្តីពីអាជ្ញាប័ណ្ណ Creative Commons (ឬការផ្តល់អាជ្ញាប័ណ្ណបើកចំហណាមួយ) ព្រមទាំងឱកាសដែលអាជ្ញាប័ណ្ណនេះនឹងផ្តល់ឱ្យពួកគេ។

## ជំនួបប្រជុំរវាងរោងពុម្ពនិងអ្នកបោះពុម្ពផ្សាយសម្រាប់ GBAIA នាពេលអនាគត

ដំណើរការនៃការរៀបចំ និងដឹកនាំកិច្ចប្រជុំនេះបានផ្តល់ព័ត៌មានដែលមានប្រយោជន៍សម្រាប់ GBAIA ក្នុងការរៀបចំកិច្ចប្រជុំបែបនេះ នៅប្រទេសដទៃនាពេលអនាគត។ ជាបែបបទរដ្ឋបាល គេរកឃើញថាកម្មវិធីផ្ញើសារ Telegram ត្រូវបានគេពេញនិយមជាងអ៊ីមែលសម្រាប់ការឆ្លើយឆ្លងគ្នា ហើយអ្នកចូលរួមទំនងជាចូលរួមកិច្ចប្រជុំ ប្រសិនបើពួកគេបានជួបក្រុមការងារ GBAIA ជាមុន តាមរយៈការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់កាលពីដើមខែនេះ។

ការបកប្រែប្រដេញរវាងភាសាអង់គ្លេស និងខ្មែរបានញុំាងឱ្យការប្រាស្រ័យទាក់ទងគ្នាកាន់តែប្រសើរឡើង និងអនុញ្ញាតឱ្យអ្នកចូលរួមនិយាយ និងចែករំលែកកាន់តែងាយស្រួលជាងគេនិយាយជាភាសាអង់គ្លេសដោយខ្លួនឯង។ ទោះជាយ៉ាងនេះក្តី ត្រូវតែមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការឆ្លើយសំណួរ។ ឧទាហរណ៍ ពេលសួរថា "What is your market?" អ្នកចូលរួមយល់ថា «តើទីផ្សារគឺជាអ្វី?» តាមពិតទៅសំណួរសំដៅ «តើនរណាជាអតិថិជនរបស់អ្នក?» ទោះបីជាមានការបកប្រែប្រដេញក៏ដោយ ក៏អ្នកចូលរួមមួយចំនួនមិនបានបញ្ចេញមតិរបស់ខ្លួនឡើយ ដូច្នេះសម្រាប់កិច្ចប្រជុំនាពេលខាងមុខ គប្បីមានការលើកទឹកចិត្តឱ្យអ្នកចូលរួមសរសេរចម្លើយរបស់ខ្លួនគ្រប់ៗគ្នា (ឧទាហរណ៍ «តើអ្វីជាបញ្ហាធំបំផុតដែលអ្នកប្រឈមមុខក្នុងអាជីពរបស់អ្នក?») នឹងនាំមកនូវការយល់ដឹងបន្ថែមទៀតដល់ការពិភាក្សា។ យើងក៏ត្រូវពិចារណាលើជម្រើសយកការពិភាក្សាជាក្រុមតូចៗរវាងផ្នែករោងពុម្ព និងអ្នកបោះពុម្ពផ្សាយ ព្រោះធ្វើដូច្នេះពួកគេនឹងកាន់តែមានទំនាក់ទំនងជិតស្និទ្ធ។ តាមការឆ្លុះបញ្ចាំង អ្នកសម្របសម្រួលកិច្ចប្រជុំគិតថា វានឹងប្រសើរជាងនេះក្នុងការជំរុញឱ្យបង្កើតជាបណ្តាញទំនាក់ទំនង ជាអាទិ៍ ដោយសុំឱ្យមនុស្សអង្គុយ ឬនិយាយជាមួយមនុស្សដែលពួកគេមិនធ្លាប់ស្គាល់គ្នាពីមុន។

# សេចក្តីសន្និដ្ឋាន

ជាធម្មតាកិច្ចប្រជុំបែបនេះគឺជាការចង់បាន និងទទួលកោតសរសើរយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ អ្នករោងពុម្ព និងអ្នកបោះពុម្ពផ្សាយបានស្វែងយល់បន្ថែមពីអតិថិជនរបស់ពួកគេ ឃើញឱកាសដើម្បីបំពេញកិច្ចការជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអនុវត្ត ព្រមទាំងទទួលបានធនធានដោយទូលាយដូចជា GDL ជាដើម។ សមាគមអ្នកបោះពុម្ពសៀវភៅកម្ពុជាបានពង្រឹងនិងពង្រីកតាមរយៈការភ្ជាប់ទំនាក់ទំនងបណ្តាញ ហើយគេសង្ឃឹមថាសមាគមនេះនឹងបន្តធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមរោងពុម្ព និងអ្នកបោះពុម្ពផ្សាយ។ គេជឿជាក់ថាផ្នែករោងពុម្ព និងអ្នកបោះពុម្ពបានត្រៀមខ្លួនរួចជាស្រេច និងមានសុឆន្ទៈក្នុងការសហការគ្នា ហើយឧស្សាហកម្មនេះមានឱកាសដើម្បីជម្នះរាល់បញ្ហាប្រឈមដែលពួកគេទាំងអស់គ្នាជួបប្រទះ ដូចជាពន្ធនាំចូលខ្ពស់ កង្វះបុគ្គលិកជំនាញ ឬកម្មវិធីបណ្តុះ

បណ្ដាលសម្រាប់រោងពុម្ព ឧបសគ្គក្នុងការស្វែងរកអតិថិជន និងបញ្ហាប្រឈមជាមួយនឹងឥរិយាថរបស់មាតាបិតាសិស្ស និងវប្បធម៌អំណាន (ឬកង្វះខាតផ្សេងទៀត) ជាដើម។

GBAIA មានបំណងរៀបចំកិច្ចប្រជុំនាពេលអនាគតនៃលក្ខណៈនេះនៅក្នុងប្រទេសផ្សេងទៀត ហើយខ្លួនសង្ឃឹមនឹងទទួលបានថាមពល កិច្ចសហការ និងការរៀនសូត្រស្រដៀងគ្នាពីកិច្ចប្រជុំដែលរៀបចំឡើងនៅកម្ពុជា។

# ឧបសម្ព័ន្ធ៦ ៖ រចនាសម្ព័ន្ធរបស់ ក្រសួងអប់រំ យុវជន និងកីឡា



# ឧបសម្ព័ន្ធ៧៖ សាវតាររបស់គម្រោង

## សម្ព័ន្ធសៀវភៅសកល

កង្វះលទ្ធភាពទទួលបានសម្ភារៈដែលមានគុណភាព និងសមស្របបង្កជាឧបសគ្គដ៏លំបាកក្នុងការទទួលបានចំណេះដឹង ជាលទ្ធផលមានកុមារ និងយុវជនជាង ៦០០ លាននាក់ មិនបានរៀនមូលដ្ឋានគ្រឹះនៃអំណាន និងរៀនលេខ។ មួយផ្នែក គឺដោយសារតែ ៤០% នៃកុមារទាំងនេះមិនអាចទទួលបានការអប់រំតាមរយៈភាសាដែលពួកគេយល់ ទាំងដោយសារមិនមានសម្ភារៈឧបទ្ទេសនៅក្នុងសាលារៀន ឬសហគមន៍របស់ ឬមិនមានសៀវភៅជាភាសាកំណើតរបស់ពួកគេ។

ដើម្បីឆ្លើយតបនឹងបញ្ហាជុំវិញការខ្វះខាតសម្ភារៈនេះ សម្ព័ន្ធសៀវភៅសកល (GBA) [៨១] ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៨ ដើម្បីសិក្សាស្រាវជ្រាវ គាំទ្រ និងកបណ្ដុះបណ្ដាលដល់ភាគីពាក់ព័ន្ធនានា។ ភាពជាដៃគូនៃទីភ្នាក់ងារផ្ដល់ជំនួយ ស្ថាប័នពហុភាគី និងអង្គការសង្គមស៊ីវិល GBA មានគោលបំណងនាំយកដៃគូអប់រំពិភពលោករួមគ្នាដើម្បីបញ្ចប់អនក្ខរភាពតាមរយៈកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលដើម្បីដោះស្រាយបញ្ហាប្រឈមនៃគម្លាតសៀវភៅដែលកំពុងរីកធំឡើង។

ដើម្បីគាំទ្រដល់ GBA គម្រោង USAID Global Book Alliance in Action (GBAIA) ត្រូវបានបង្កើតឡើង។ គំនិតផ្ដួចផ្ដើមរយៈពេលពីរឆ្នាំនេះ (២០១៩-២០២១) ធ្វើការជាមួយសមាជិកនៃ GBA ក៏ដូចជា ក្រសួងអប់រំ ដៃគូអប់រំ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីកែលម្អខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅជាតិតាមរយៈការកំណត់ ផ្សព្វផ្សាយ និងគាំទ្រការច្នៃប្រឌិត ការអនុវត្តល្អបំផុត និងគោលនយោបាយដែលនឹងផ្លាស់ប្ដូររបៀបធ្វើ របៀបទិញ និងរបៀបផ្គត់ផ្គង់សៀវភៅ។

ការវិភាគខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ (SCAs) ជាផ្នែកមួយនៃការស្រាវជ្រាវក្រោមការចង្អុលបង្ហាញរបស់ GBAIA កំពុងត្រូវបានធ្វើឡើងនៅក្នុងប្រទេសចំនួនប្រាំបីដើម្បីកំណត់ភាពខ្លាំង និងបញ្ហាប្រឈមជាក់លាក់របស់ប្រទេសទាំងនោះទាក់ទិននឹងការផ្ដល់សៀវភៅ និងដើម្បីទទួលបានមូលដ្ឋានចំណេះដឹងសាកលជុំវិញការអនុវត្តដោយជោគជ័យទៅលើខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅ។

SCA ធ្វើឡើងដោយក្រុមអ្នកជំនាញជាតិ និងអន្តរជាតិ ដែលជួបជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមទាំងមន្ត្រីក្រសួងអប់រំ និងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត អ្នកផ្គត់ផ្គង់សៀវភៅមត្តេយ្យ និងបឋមសិក្សា អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គក្នុងវិស័យឯកជនផ្សេងទៀត ដូចជា ក្រុមហ៊ុនដឹកជញ្ជូន។ ការស្រាវជ្រាវ SCA រួមមានការប្រមូលទិន្នន័យសាវតារ

*៨១ https://globalbookalliance.org/*

និងការស្រាវជ្រាវលើឯកសារដែលមានស្រាប់ និងដោយមានកិច្ចជួបប្រជុំនៅក្នុងប្រទេសប្រមាណ ២ ទៅ ៣សប្តាហ៍ និងការតាមដានជាបន្តបន្ទាប់ជាមួយនឹងអនុសាសន៍ និងការសរសេររបាយការណ៍។ បន្ទាប់មកការស្រាវជ្រាវត្រូវបានបន្តដោយសកម្មភាពដែលកសាងសមត្ថភាពភាគីពាក់ព័ន្ធក្នុងការអនុវត្តជំហានដើម្បីកែលម្អមុខងារខ្សែសង្វាក់ផ្គត់ផ្គង់សៀវភៅនៅក្នុងប្រទេសរៀងៗខ្លួន។

SCA ទីមួយត្រូវបានអនុវត្តក្នុងប្រទេសម៉ាឡាវី និងបានបញ្ចប់នៅខែធ្នូ ២០១៩។ SCA ទីពីរត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ ២០២០ ដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍នេះ។

# ឧបសម្ព័ន្ធ៨៖ ឯកសារពិគ្រោះ


Aide et Action. *South East Asia and China. 2014 Regional Annual Report. Delivering Changes That Last*, 2014. Bangkok: Author. https://seac.aide-et-action.org/wp-content/uploads/2015/06/AN2014_Web.pdf

*South East Asia and China. 2015 Regional Annual Report*, 2014. Bangkok: Author. https://seac.aide-et-action.org/wp-content/uploads/2016/06/AeA_SEAI_Web_2015.pdf

*South East Asia and China Review 2017*, 2017. Bangkok: Author. https://seac.aide-et-action.org/wp-content/uploads/2018/08/region-annual-report-2017.pdf

Akihiro, Nishio. "History and Current Situation of Education for Children with Disabilities in Cambodia: A Gray Literature Review." *Creative Education*, 10, no. 08 (2019) 1753–1763. https://www.scirp.org/Html/1-6304387_94159.htm#:~:text=Currently%2C%20there%20are%20only%20four,and%206787%20in%20secondary%20schools

Asian Development Bank. *Cambodia and Asian Development Bank: Partnership for Inclusive Growth*, 2019. Metro Manila: Author.

*Cambodia Transport Sector Assessment, Strategy, and Road Map*, September 2019. Metro Manila: Author. http://dx.doi.org/10.22617/TCS190449-2

*Country Partnership Strategy. Cambodia 2014–2018*, 2014. Metro Manila: Author. https://www.adb.org/documents/cambodia-country-partnership-strategy-2014-2018

*Greater Mekong Sub-region. Twenty-Five Years of Partnership*, 2018. Metro Manila: Author. http://dx.doi.org/10.22617/ARM189253-2

Associated Press. "Cambodian Schools Shorten Hours to Cope with Heat Wave," 2019. New York: Author. https://apnews.com/article/ef48c21e15d849de81b4a05416768159

Association for the Development of Education in Africa, African Union, Global Book Alliance, and U.S. Agency for International Development. *Continental Framework on Book and Reading Policy Formulation in Africa*. Nairobi, June 2019. Abidjan 01 Côte d'Ivoire: Association of Education in Africa. https://www.adeanet.org/sites/default/files/continental_book_and_reading_policy_framework.pdf

Ball, Jessica and Mariam Smith. Evaluation of the Multilingual Education National Action Plan in "Cambodia." New York: UNICEF, 2019. https://www.unicef.org/cambodia/reports/evaluation-multilingual-education-national-action-plan-cambodia

Barron, Laignee and Mom Kunthear. "Start of the school year delayed." *The Phnom Penh Post*, October 24, 2014. https://www.phnompenhpost.com/national/start-school-year-delayed.

Benveniste, Luis, Jeffery Marshall, and M. Caridad Araujo. *Teaching in Cambodia*, June 2008. Washington, D.C., and Phnom Penh: The World Bank and the Ministry of Education, Youth, and Sport. http://documents1.worldbank.org/curated/en/161351468020945260/pdf/448500WP0Box3210KH0Teachers11Final1.pdf.

BlueTree Group. *Guidelines for Management of Teaching and Learning Materials*, 2015. Utrecht: Author.

Cambodia National Education Profile. GlobalEconomy.com, 2018.

Chey, S. and S. Gill. *The Textbook Monitoring Report in the Districts of Veun Saim, Bor Keo and Ta Veng 2017-2018*. Phnom Penh: The Affiliated Network for Social Accountability (ANSA) Cambodia, 2019.

Day, E. and B. Hatch. *Track & Trace Books Cambodia*, September 20, 2020. East Lansing, MI: Michigan State University.

Department of Education Management Information System. Public Education Statistics & Indicators. Phnom Penh: Author.

DeStefano, Joseph, Jennifer Pressley, and Simon King. *All Children Reading – Cambodia, Student Performance in Early Literacy: Baseline Report 2018*. Washington, D.C.: U. S. Agency for International Development, October 1, 2018.

*International Journal of Education and Research* 4, no. 5. (May 2016). https://www.ijern.com/May-2016.php.

Education in Crisis and Conflict Network. *Rapid Education and Risk Analysis Toolkit*. n.d. Washington, D.C.: U.S. Agency for International Development. https://www.eccnetwork.net/sites/default/files/media/file/RERAToolKit_508_12.04.19%20-A%20v2.pdf

EMIS Publications summarizing Public Education Statistics & Indicators up to and including 2019.

Estes, B. *Global Book Alliance Book Chain Analysis Framework & Tool*. Washington D.C.: Global Book Alliance, Bureau for Economic Growth, Education & Environment, USAID, 2019.

EU Delegation to Cambodia. *EU Development Aid in Cambodia*, 2013. https://eeas.europa.eu/archives/delegations/cambodia/documents/publications/2015/2013_eu_dev_aid_cambodia_en.pdf

European Union. *Annex 1- Performance Indicators Used for Disbursements*, n.d.

*Multiannual Indicative Program 2014–2020*, n.d. Brussels: European Union External Action Service. https://eeas.europa.eu/archives/delegations/cambodia/documents/eu_cambodia/2014_2020_mip_final_en.pdf

Fehrler et al., 2009

FHI 360. *Cambodia National Education Profile Update 2018 in Education Policy and Data Center,* n.d.

Global Book Alliance. https://globalbookalliance.org/

*Global Digital Library*, n.d. https://www.globalbookalliance.org/global-digital-library.

Google. Public Data: World Development Indicators, n.d. https://www.google.com/publicdata/explore?ds=d5bncppjof8f9_&met_y=sp_pop_grow&idim=country:KHM:LAO:HKG&hl=en&dl=en.

International Monetary Fund (October 2019) World Economic Outlook Database. https://www.imf.org/external/pubs/ft/weo/2019/02/weodata/weorept.aspx?sy=2015&ey=2020&scsm=1&ssd=1&sort=country&ds=.&br=1&pr1.x=32&pr1.y=8&c=522&s=GGR%2CGGR_NGDP%2CGGX%2CGGX_NGDP%2CGGXCNL%2CGGXCNL_NGDP%2CGGXONLB%2CGGXONLB_NGDP%2CGGXWDG&grp=0&a=

International Telecommunications Unit – ITU (2018) Measuring the Information Society Report. Vol1 and Vol 2. https://www.itu.int/en/ITU-D/Statistics/Documents/publications/ misr2018/MISR-2018-Vol-2-E.pdf

Jarvis, H., C. Lalonde, P. N. Arfanis, and N. Lakhena. *Publishing in Cambodia*. Phnom Penh: Center for Khmer Studies, 2002.

Jon Snow, Inc. and World Education, Inc. Tracking and Tracing Books in Malawi: All Children Reading Grand Challenge, n.d.

Juillard, H. *Minimum Standards for Market Analysis (MISMA)*, 2018. https://spherestandards.org/resources/minimum-standard-for-market-analysis-misma/

Kunthear, Mom. "Flood instructions issued for schools to bolster safety." *The Phnom Penh Post*, October 2020. https://www.phnompenhpost.com/national/flood-instructions-issued-schools-bolster-safety.

Let's Read. About Us. https://reader.letsreadasia.org/about.

Ministry of Education, Youth, and Sport. "Chapter V: ESP Financing Plan 2019–2023," in E*ducation Strategic Plan 2019–2023*. https://www.globalpartnership.org/sites/default/files/document/file/2019-10-education_sector_plan-cambodia.pdf

*Education in Cambodia: Findings from Cambodia's experience in PISA for Development*. Phnom Penh: Author, 2018. https://www.oecd.org/pisa/pisa-for-development/PISA-D%20national%20report%20for%20Cambodia.pdf

*Education Strategic Plan 2014–2018*. Phnom Penh: Author, 2014.

*Education Strategic Plan 2019–2023*. Phnom Penh: Author, June 2019. https://www.globalpartnership.org/sites/default/files/document/file/2019-10-education_sector_plan-cambodia.pdf.

*The National Early Grade Learning Program of the MoEYS*. Phnom Penh: Author, n.d.

*Ministry of Education, Youth, and Sport 2020 Budget*. Phnom Penh: Author.

Ministry of Education, Youth, and Sport and Department of Education Management Information System. *Public Education Statistics and Indicators 2018–2019*. Phnom Penh: Author, 2019. https://data.laos.opendevelopmentmekong.net/library_record/public-education-statistics-and-indicators-2018-2019/resource/c6cd0699-4a73-4166-bd5d-ca694e64b961

National Institute of Statistics, Directorate General for Health, and The DHS Program. *Cambodia: Demographic and Health Survey 2014*. https://dhsprogram.com/pubs/pdf/FR312/FR312.pdf

National Institute of Statistics, Ministry of Planning. *Cambodia Socio-Economic Survey 2017*, November 2018. https://www.nis.gov.kh/nis/CSES/Final%20Report%20CSES%202017.pdf.

Overton, Leonard. "Cambodia." Chicago: Britannica, n.d. https://www.britannica.com/place/Cambodia.

"Climate of Cambodia." Chicago: Britannica, n.d. https://www.britannica.com/place/Cambodia/Climate.

"Transportation and Telecommunications." Chicago: Britannica, n.d. https://www.britannica.com/place/Cambodia/Transportation-and-telecommunications.

Phong, Kimchhoy, Lihol Srou, Chhorvin Noy, Pinan Phang, and Javier Sola. *An Assessment of Children with Disabilities in Accessing Primary Education in Cambodia: Understanding Challenges, Opportunities, and Ways Forward*. Phnom Penh: NGO Education Partnership, 2018.

Pratham Story Books (n.d.) https://prathambooks.org

Results for Development Institute and International Education Partners. *Global Book Fund Feasibility Study Final Report*, 2016. https://www.r4d.org/wp-content/uploads/R4D-IEP_GBF_Full-Report_-web.pdf.

Royal Government of Cambodia. *National Strategic Development Plan (NSDP) 2019–2023*. Phnom Penh: Open Development Cambodia, 2019. https://data.opendevelopmentmekong.net/dataset/087e8a03-f09d-4eb2-94f2-00d8d237b342/resource/bb62a621-8616-4728-842f-33ce7e199ef3/download/nsdp-2019-2023_en.pdf

*Royal Government of Cambodia National Budget*, 2019.

"Public School Operating Fund Management Guideline [in Khmer], Sub-decree 309" in *The Administration and Management of Teaching Services in Public Primary Education Institutions*, 2014.

*Rectangular Strategy for Growth, Employment, Equity and Efficiency: Building the Foundation Toward Realizing the Cambodia Vision 2050*, September 2018. http://cnv.org.kh/wp-content/uploads/2012/10/Rectangular-Strategy-Phase-IV-of-the-Royal-Government-of-Cambodia-of-the-Sixth-Legislature-of-the-National-Assembly-2018-2023.pdf.

RTI International. *All Children Reading – Grade 1–3 Khmer Language Curriculum Review Report:*

*Summary Report of Available Assessment Data, Teacher Survey and Curriculum Materials Review*, 2017. https://pdf.usaid.gov/pdf_docs/PA00D5SJ.pdf

*All Children Reading – Cambodia. Quarterly Progress Report. April–June 2018*, August 2018. Washington, D.C.: U.S. Agency for International Development. https://pdf.usaid.gov/pdf_docs/PA00T87T.pdf

*All Children Reading – Cambodia. Quarterly Progress Report. January–March 2018*, May 2018. Washington, D.C.: U.S. Agency for International Development. https://pdf.usaid.gov/pdf_docs/PA00T2KT.pdf

*All Children Reading – Cambodia. Quarterly Progress Report. October–December 2017, February 2018*. Washington, D.C.: U.S. Agency for International Development. https://pdf.usaid.gov/pdf_docs/PA00SSCK.pdf

Sargren, Maria, George Edgar, Nick Beresford, and Julian Chevillard. "Cambodia's Schools are the New Frontline in the Battle Against Climate Change." World Economic Forum, June 6, 2019. https://www.weforum.org/agenda/2019/06/cambodia-schools-climate-change-education/

School to School International. *E-books 4 Khmer: End-of-Project Report*, November 2017. http://kapekh.org/files/report_file/94-en.pdf

Smart, Andy and Shanti Jagannathan. *Textbook Policies in Asia. Development, Publishing, Printing, Distribution and Future Implications*. Metro Manilla: Asian Development Bank, December 2018. https://www.adb.org/publications/textbook-policies-asia

TheGlobalEconomy.com. "Cambodia: Student Teacher Ratio, Primary School," n.d. https://www.theglobaleconomy.com/Cambodia/student_teacher_ratio_primary_school/.

The International Competition Bidding Document on Publishing and transport the main textbooks of year 2018, budget for 2018 of education sector, chapter 60, account 6002, sub-account 60023, first program, sub-program number 8, cluster of activity number 2 of budget institution of department of curriculum development

UNESCO. "Every Child Should Have A Textbook." *Global Education Monitoring Report, Policy Paper 23* (January 2016). https://unesdoc.unesco.org/ark:/48223/pf0000243321.

UNICEF. "Cambodia: Key Demographic Indicators." https://data.unicef.org/country/khm/

U.S. Agency for International Development. *2019 Education Reporting Guidance*, 2019.

*Office of Education Brief: USAID Reading MATTERS Conceptual Framework*. Washington, D.C.: Author, November 2019. https://www.edu-links.org/sites/default/files/media/file/Reading%20MATTERS%20Conceptual%20Framework_Nov19.pdf#:~:text=USAID%E2%80%99s%20Reading%20MATTERS%20Framework%20is%20adaptable%20to%20the,children%20receive%20the%20high-quality%20reading%20instruction%20they%20deserve.

*Public Financial Management Risk Assessment Framework (PFMRAF) Manual: A Mandatory Reference for ADS Chapter 220*. Washington, D.C.: USAID, July 28, 2014. https://www.usaid.gov/sites/default/files/documents/1868/220mae.pdf.

Vannak, Chea. "Internet Users Near 16m. *Khmer Times*, July 26, 2019. https://www.khmertimeskh.com/627470/internet-users-near-16m/

World Bank. "Population Total – Cambodia." https://data.worldbank.org/indicator/SP.POP.TOTL?locations=KH.

"The World Bank in Cambodia: Overview." https://www.worldbank.org/en/country/cambodia/overview.

*Track and Trace in Cambodia* [video], May 16, 2019. https://www.worldbank.org/en/news/video/2019/05/16/track-and-trace-world-education-cambodia.

World Bank Group. *Book Chain: Incentivizing Actors in the Book Chain to Increase the Availability of Quality Books for Children*, n.d. https://static1.squarespace.com/static/5cb1f6beaadd34703fcc968c/t/604775c33038d30d3f28601c/1615295942518/Book-Chain-Incentivizing-Actors-in-the-Book-Chain-to-Increase-Availability-of-Quality-Books-for

*Cambodia: Can Transparency and Incentives for Community Participation Increase the Supply of Textbooks to Schools?*, May 2020. https://openknowledge.worldbank.org/bitstream/handle/10986/33916/Cambodia-Can-Transparency-and-Incentives-for-Community-Participation-Increase-the-Supply-of-Textbooks-to-Schools.pdf?sequence=1&isAllowed=y

World Education. *Descriptive Note: Results-Based Financing (RBF) for Enhancing Book Distribution in Cambodia*, n.d. https://documents1.worldbank.org/curated/en/662741583142642717/pdf/Results-Based-Financing-RBF-for-Enhancing-Book-Distribution-in-Cambodia-Descriptive-Note.pdf

World Vision. *Current Situation & Use of Primary School Libraries: A Snapshot across 5 Provinces in Cambodia*, March 2016. https://www.wvi.org/sites/default/files/Current-Situation-and-Use-of-Primary-School-Libraries_WorldVision_10-March-2016.pdf.

*Total Reading Approach for Children: Strengthening Early Grade Reading in Cambodia through mlearning*. Federal Way, WA: World Vision, n.d. https://www.wvi.org/sites/default/files/TRAC%20Quick%20Guide_0.pdf

Xinhua. "Asia&Pacific: Cambodia Earns 6 bln UDS in Taxes Last Year." Xinhuanet, January 2, 2020.

Global Book Alliance Secretariat
c/o Center for Education
U.S. Agency for International Development
Ronald Reagan Building
1300 Pennsylvania Ave. N.W.
Washington, D.C. 20523

secretariat@globalbookalliance.org